# សំណួរពិបាកៗ សម្រាប់គ្រីស្ទបរិស័ទ

៥០ចម្លើយសម្រាប់ក្រុមជំនុំ និងគ្រូគង្វាល

50 Answers for Pastors and Churches

និពន្ធដោយ៖ ចន ផាយភ័រ

50 QnA John Piper Final 1.5.indd 5 25/01/2024 09:22:24 AM

រក្សាសិទ្ធិគ្រប់បែបយ៉ាង ដោយអ្នកនិពន្ធដើម៖ John Piper
All rights reserved.
Used by permission

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org
បកប្រែដោយ៖ លោក ឈាង ប៉ូវ៉ា, លោក ខែម ប៊ុនឡុង និងលោក ទេព វ៉ូ
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព វ៉ូ, លោកស្រី ឡូញ ស្រីវដ្ឋ, លោក ឈាង ប៉ូវ៉ា, លោក ឯក សត្យា, លោក ហុង សម្ភស, លោក សឹម រក្សា, កញ្ញា យ៉ុន សាឯម, លោក ប៊ុន ដេត, លោកស្រី ពុល រដ្ឋា, កញ្ញា សួន សុជាតា, លោកស្រី កែវ សិរីវុឌ្ឍី, លោកស្រី ថាវ ប៊ុននី, លោក សួន ចាន់រួម, កញ្ញា អឿង ដាលីន, លោកគ្រូ លូកា ស្មិត, អ្នកគ្រូ សេង សុខា, លោក ជួប ប៊ុនហាក់, លោក ង៉ែត វិទូរ និងលោក ដេហ្វ ឡៃ

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាតឲ្យសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញ, ថតទុកក្នុងប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រ, ឬចែកចាយបន្តរួមបញ្ចូលទាំង ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក, បច្ចេកទេសថតចម្លង, ការថតទុកជាឯកសារសំឡេង។ល។ ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើម។

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ ព្រះគម្ពីរកែសម្រួល រក្សាសិទ្ធិ©ឆ្នាំ២០១៤, ២០១៦ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ©ឆ្នាំ២០០៥ (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ©ឆ្នាំ២០១៤ (គគខ) ក៏ដូចជា អសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ែល ណាថាន និងលោក សឹម រក្សា
For ordering information please visit: plovpitshop.com
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ plovpitshop.com
បោះពុម្ពលើកទី១ ចំនួន២០០០ក្បាល គ.ស. ២០២៤ ព្រះរាជាណាចក្រកម្ពុជា
ISBN: 9789924566106

# មាតិកា

## ផ្នែកទី១៖ ទេវវិទ្យា

**សំណួរទី១៖**

ទេវវិទ្យានៃការអធិស្ឋាន៣នាទី. . . . . . . . . . . . . . . . . . . . . . . . . . . .១៧

**សំណួរទី២៖**

តើគ្រប់សាសនានាំមនុស្សទៅកាន់ព្រះមែនឬ? . . . . . . . . . . . . .២១

**សំណួរទី៣៖**

តើយើងមានឆន្ទៈសេរីក្នុងការជ្រើសរើសយកព្រះគ្រីស្ទ
ដែរឬទេ? . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .២៧

**សំណួរទី៤៖**

តើការដែលព្រះគ្រោងទុកឲ្យមនុស្សមួយចំនួនធ្លាក់នរក
បានថ្វាយសិរីល្អដល់ទ្រង់បានដោយរបៀបណា? . . . . . . . . . . ៣៣

**សំណួរទី៥៖**

តើវាជាអំពើបាបទេ ក្នុងការមិនចូលចិត្ត
គោលជំនឿនៃការជ្រើសតាំង? . . . . . . . . . . . . . . . . . . . . . . . . . ៣៧

**សំណួរទី៦៖**

តើខ្ញុំគួរអធិស្ឋានទៅកាន់ព្រះវរបិតាព្រះយេស៊ូវ
ឬក៏ព្រះវិញ្ញាណបរិសុទ្ធ? . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .៤១

**សំណួរទី៧៖**

តើលោកគ្រូមានយោបល់អ្វីទាក់ទងនឹងថ្ងៃបុណ្យហាឡូវីន? . . .៤៧

**សំណួរទី៨៖**
តើអ្វីទៅធ្វើឲ្យថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ
ពិសេសម្ល៉េះ? ....................................៤៩
**សំណួរទី៩៖**
តើការរក្សាថ្ងៃសប្ប័ទឲ្យបានបរិសុទ្ធមានន័យយ៉ាងដូចម្ដេច? ..៥៥
**សំណួរទី១០៖**
ទេវវិទ្យាទន់ខ្សោយបង្កើតឲ្យមានស្ត្រីទន់ខ្សោយ .............៦១

## ផ្នែកទី២៖ ការសង្គ្រោះ

**សំណួរទី១១៖**
តើគ្រីស្ទបរិស័ទដែលកើតជាថ្មីអាចបាត់បង់សេចក្ដីសង្គ្រោះ
បានដែរឬទេ?....................................៦៥
**សំណួរទី១២៖**
តើការសុគតរបស់ព្រះយេស៊ូវសម្រេចអ្វី សម្រាប់អ្នកដែលទ្រង់
មិនបានជ្រើសតាំង? ................................ ៧៣
**សំណួរទី១៣៖**
តើខ្ញុំដឹងថាខ្ញុំបានទទួលសេចក្ដីសង្គ្រោះ
បានដោយរបៀបណា? ............................... ៧៧
**សំណួរទី១៤៖**
តើខ្ញុំដឹងថាព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងខ្ញុំ
ដោយរបៀបណា?....................................៨៣

**សំណួរទី១៥៖**
ព្រះកិត្តិយសរបស់ព្រះជាម្ចាស់ និងបេសកកម្មពិភពលោក....៩១
**សំណួរទី១៦៖**
ការសម្លាប់ខ្លួន និងសេចក្ដីសង្គ្រោះ........................៩៥
**សំណួរទី១៧៖**
ចំពោះលោកអ្នក តើព្រះយេស៊ូវជានរណា? .............. ១០១
**សំណួរទី១៨៖**
មូលហេតុដែលលោក អ័ដាម សំខាន់សម្រាប់បេសកកម្ម
ពិភពលោក ........................................ ១០៧
**សំណួរទី១៩៖**
តើព្រះគម្ពីរបង្រៀនថាគ្រីស្ទបរិស័ទពិត
មិនចេះប្រព្រឹត្តអំពើបាបឬ?.......................... ១១១

## ផ្នែកទី៣៖ ទំនាក់ទំនង

**សំណួរទី២០៖**
របៀបដែលភាពនៅលីវល្អ............................ ១១៩
**សំណួរទី២១៖**
តើឲ្យខ្ញុំប្រាថ្នាទៅស្ថានសួគ៌បានដោយរបៀបណា ខណៈពេលដែល
ខ្ញុំដឹងថា ខ្ញុំនឹងមិនរៀបការជាមួយនឹងប្ដីរបស់ខ្ញុំ
នៅទីនោះ? ........................................១២៣

**សំណួរទី២២៖**
របៀបជួយមិត្តភក្តិគេចចេញពីដំណើងល្អដែលសន្យាភាពចម្រុងចម្រើន ................................... ១២៧
**សំណួរទី២៣៖**
តើវាជាអំពើបាបឬទេ ដែលខ្ញុំមានស្នេហាជាមួយនឹងអ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ? ............................ ១៣៥
**សំណួរទី២៤៖**
ប្រសិនបើលោកគ្រូមានពេលពីរនាទីនិយាយជាមួយនឹងសម្តេចប៉ាប តើលោកគ្រូនឹងនិយាយអ្វីទៅកាន់គាត់? ................ ១៤១
**សំណួរទី២៥៖**
តើទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះជាម្ចាស់ល្អដែរឬទេ? .. ១៤៣
**សំណួរទី២៦៖**
មិត្តស្រីរបស់ខ្ញុំមានផ្ទៃពោះ តើខ្ញុំគួរធ្វើអ្វីបន្ទាប់?........... ១៥៣
**សំណួរទី២៧៖**
តើជីវិតអាពាហ៍ពិពាហ៍នឹងព្យាបាលភាពត្រេកត្រអាលរបស់ខ្ញុំបានដែរឬទេ?..................................... ១៦១
**សំណួរទី២៨៖**
តើអ្នកនឹងទៅចូលរួមពិធីរៀបការភេទដូចគ្នាដែរឬទេ? ...... ១៦៩

50 QnA John Piper Final 1.5.indd 10 25/01/2024 09:22:25 AM

# ផ្នែកទី៤៖ ការរស់នៅ

**សំណួរទី២៩៖**

គ្រីស្ទបរិស័ទ និងកញ្ឆា. . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៧៥

**សំណួរទី៣០៖**

របៀបជម្នះភាពខ្ជិលច្រអូស. . . . . . . . . . . . . . . . . . . . . . . . . . . ១៧៩

**សំណួរទី៣១៖**

តើខ្ញុំដឹងថាព្រះជាម្ចាស់បានត្រាស់ហៅឲ្យខ្ញុំធ្វើជាគ្រូគង្វាល
ដោយរបៀបណា? . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៨៣

**សំណួរទី៣២៖**

តើខ្ញុំរង់ចាំព្រះជាម្ចាស់បានដោយរបៀបណា? . . . . . . . . . . . . ១៨៧

**សំណួរទី៣៣៖**

ខ្ញុំនឹងមិនបោះបង់ព្រះយេស៊ូវនោះទេ—ប៉ុន្តែខ្ញុំក៏ឆ្អែតឆ្អន់
នឹងក្រុមជំនុំហើយ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៩៧

**សំណួរទី៣៤៖**

ខ្ញុំអស់កម្លាំង ហើយរវល់—តើខ្ញុំរកពេលអានព្រះគម្ពីរ
បានដោយរបៀបណា? . . . . . . . . . . . . . . . . . . . . . . . . . . . . . ២០១

**សំណួរទី៣៥៖**

តើជាការខុសឆ្គងឬទេដែលមនុស្សប្រុសស្ដាប់ការអធិប្បាយ
របស់មនុស្សស្រី? . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២០៧

**សំណួរទី៣៦៖**

តើការផឹកស្រាមិនអីមែនឬទេ? . . . . . . . . . . . . . . . . . . . . . . . ២១១

**សំណួរទី៣៧៖**
ប្រសិនបើមនុស្សណាម្នាក់ផឹកស្រា ឬជក់បារី តើការនោះបង្ហាញថា
គាត់មិនមែនជាគ្រីស្ទបរិស័ទឬយ៉ាងណា? . . . . . . . . . . . . . . . ២១៥
**សំណួរទី៣៨៖**
តើព្រះគម្ពីរបានបញ្ជាឲ្យគ្រីស្ទបរិស័ទថ្វាយតង្វាយដែរឬទេ? ២១៧
**សំណួរទី៣៩៖**
តើខ្ញុំអាចបែងចែកប្រាក់តង្វាយរបស់ខ្ញុំរវាងក្រុមជំនុំ
និងព័ន្ធកិច្ចមួយផ្សេងទៀតបានដែរឬទេ? . . . . . . . . . . . . . . . .២២៣
**សំណួរទី៤០៖**
ជីវិតពិបាកណាស់ តែ «ព្រះអង្គល្អ». . . . . . . . . . . . . . . . . . . . . ២២៩
**សំណួរទី៤១៖**
ជំហានបីយ៉ាងក្នុងការឈប់ចំណាយជីវិត
ដោយឥតប្រយោជន៍ . . . . . . . . . . . . . . . . . . . . . . . . . . . . . . .២៣៥
**សំណួរទី៤២៖**
ហេតុអ្វីបានជាគ្រីស្ទបរិស័ទថ្វាយបង្គំនៅថ្ងៃអាទិត្យ? . . . . . . .២៣៩
**សំណួរទី៤៣៖**
របៀប៦យ៉ាងសម្រាប់ឪពុកម្ដាយ
ដើម្បីចិញ្ចឹមកូនរឹងចចេស . . . . . . . . . . . . . . . . . . . . . . . . . . . ២៤១
**សំណួរទី៤៤៖**
លោកអ្នកមិនត្រូវការកាន់តែស្រឡាញ់ខ្លួនឯងនោះទេ . . . . . . ២៤៩

## ផ្នែកទី៥៖ អំពើបាប

**សំណួរទី៤៥៖**
តើអំពើបាបខាងឯផ្លូវភេទរបស់ខ្ញុំធ្វើឲ្យខ្ញុំមិនអាចទទួលបាន
សេចក្តីសង្គ្រោះមែនឬ? ............................... ២៦១
**សំណួរទី៤៦៖**
តើខ្ញុំតយុទ្ធជាមួយនឹងការស្រេទ្បាញ់ភេទដូចគ្នា
បានដោយរបៀបណា? ............................... ២៦៩
**សំណួរទី៤៧៖**
តើខ្ញុំយកគំនិតខ្ញុំឲ្យចុះចូលនឹងព្រះដោយរបៀបណា? ...... ២៧៥
**សំណួរទី៤៨៖**
ប្រសិនបើខ្ញុំបានស្លាប់ចំពោះអំពើបាបហើយហេតុអ្វីបានជាខ្ញុំ
ត្រូវសម្លាប់វាជារៀងរាល់ថ្ងៃ? ............................ ២៨១
**សំណួរទី៤៩៖**
ការបង្រៀនកូនពេលមានវិបត្តិក្នុងគ្រួសារ ................ ២៨៩
**សំណួរទី៥០៖**
សេចក្តីប្រាថ្នាដំបូងគេបង្អស់ក្នុងការប្រព្រឹត្តអំពើបាបរបស់សាតាំង
មកពីណា? ........................................ ២៩៣
**កំណត់យោង** ........................................ ៣០០

50 QnA John Piper Final 1.5.indd 14 25/01/2024 09:22:25 AM

# ផ្នែកទី១៖ ទេវវិទ្យា



50 QnA John Piper Final 1.5.indd 15 25/01/2024 09:22:25 AM

## លោកអ្នកអាចស្តាប់សៀវភៅនេះជាសំឡេងបាន
## ដោយគ្រាន់តែ

## ស្កេននៅទីនេះ

50 QnA John Piper Final 1.5.indd 16 25/01/2024 09:22:25 AM

## សំណួរទី១៖
# ទេវវិទ្យានៃការអធិស្ឋាន៣នាទី

*ខ្ញុំចង់លើកទឹកចិត្តដល់គ្រូគង្វាលដែលបាក់ទឹកចិត្តពីការបាត់បង់សេចក្ដីសង្ឃឹម ពីការបាត់បង់ទំនុកចិត្តក្នុងការអធិស្ឋាន ទំនងមកពីគាត់ឃើញព្រះជាម្ចាស់ធ្វើតិចជាងអ្វីដែលគាត់បានសង្ឃឹមទុក។ ជាចម្បង អ្វីដែលព្រះយេស៊ូវបានត្រាស់ហៅឲ្យយើងអធិស្ឋានសម្រាប់គឺ ឲ្យព្រះនាមរបស់ទ្រង់ទទួលបានសិរីល្អ ព្រះរាជ្យនគររបស់ទ្រង់បានមកដល់ និងឲ្យព្រះហឫទ័យរបស់ទ្រង់បានសម្រេច ហើយបន្ទាប់មកជាការគាំទ្រ និងជារបៀបឲ្យការទាំងអស់នោះអាចដំណើរការបាន គឺឲ្យយើងទទួលបានអាហារជាប្រចាំថ្ងៃ ហើយឲ្យយើងទទួលបានការការពារពីអារក្ស ហើយឲ្យយើងទទួលបានការដឹកនាំក្នុងផ្លូវនៃសេចក្ដីសុចរិត។ល។*

ដូច្នេះ ចំណុចស្នូលនៃជីវិតនៃការអធិស្ឋានរបស់យើងគឺច្បាស់លាស់ណាស់៖ «ឱ! ព្រះវរបិតាអើយ! សូមធ្វើឲ្យពិភពលោកនេះមានការកោតខ្លាច ស្រឡាញ់ សរសើរ ថ្វាយព្រះកិត្តិយសដល់ព្រះនាមរបស់ទ្រង់ ហើយសូមសម្រេចការនោះនៅក្នុងដួងចិត្តរបស់ទូលបង្គំនៅវេលាព្រឹកនេះចុះ។ ឱ! ព្រះជាម្ចាស់អើយ! ហើយបន្ទាប់មក សូមពង្រីកព្រះរាជ្យនគររបស់ទ្រង់ ហើយនាំឲ្យព្រះហឫទ័យរបស់ទ្រង់បានសម្រេចដូចដែលពួកទេវតានៅឯស្ថានសួគ៌កំពុងតែធ្វើដែរ។ និយាយម្យ៉ាងវិញទៀតទៅគឺថា៖ សូមសម្រេច ហើយនាំព្រះរាជ្យនគររបស់ទ្រង់ ហើយធ្វើនូវអ្វីៗដែលព្រះអង្គចាំបាច់ធ្វើ ដើម្បីនាំយើងឲ្យឈានទៅដល់គោលដៅនោះចុះ»។

### ក្លិនក្រអូបនៃការអធិស្ឋាន

«ពេលកូនចៀមបានទទួលក្រាំងរួចហើយ សត្វមានជីវិតទាំងបួន និង



50 QnA John Piper Final 1.5.indd 17 25/01/2024 09:22:25 AM

ពួកចាស់ទុំទាំងម្ភៃបួននាក់បានក្រាបចុះនៅមុខកូនចៀម ម្នាក់ៗកាន់ស៊ុង និងពានមាស ពេញដោយគ្រឿងក្រអូប ដែលជាសេចក្តីអធិស្ឋានរបស់ពួកបរិសុទ្ធ» (វិវរណៈ ៥:៨)។

ក្នុងកណ្ឌគម្ពីរ វិវរណៈ ៥:៨ ការអធិស្ឋានកំពុងតែទទួលការប្រមូលផ្តុំចូលក្នុងចានគោមមួយ ហើយចានគោមមានតួនាទីពីរយ៉ាង។ ទី១៖ វាគឺជាគ្រឿងក្រអូប ហើយការអធិស្ឋានរបស់យើងគឺប្រៀបដូចជាគ្រឿងក្រអូបក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ ហើយគ្រឿងក្រអូបនោះក៏ពិតជាផ្គាប់ព្រះហឫទ័យដល់ទ្រង់មែនដែរ។ ព្រះជាម្ចាស់ស្រឡាញ់ក្លិននៃការអធិស្ឋានរបស់រាស្ត្រទ្រង់ ដែលនេះមានន័យថាប្រសិនបើលោកអ្នកកំពុងតែស្រែកទ្រហោយំដោយសារប្រឈមមុខក្នុងការបាត់បង់មនុស្សជាទីស្រឡាញ់របស់ខ្លួន ឬក៏ដោយសារកំពុងតែប្រឈមមុខនឹងការលំបាកក្នុងក្រុមជំនុំរបស់ខ្លួន ទង្វើនោះផ្ទាល់របស់លោកអ្នកគឺជាផ្គាប់ព្រះហឫទ័យដល់ព្រះអង្គ។ វាមិនមែនជាការឥតប្រយោជន៍នោះទេ។

ហើយព្រះជាម្ចាស់ក៏អាចឆ្លើយតបលើការអធិស្ឋាននោះឥឡូវនេះ ឬក៏នៅដប់ឆ្នាំខាងមុខ ឬក៏ឆ្លើយតបក្នុងរបៀបណាមួយដែលលោកអ្នកមិនអាចរំពឹងទុកដល់បាន។ ប៉ុន្តែ ដាច់ដោយឡែកពីរបៀបដែលព្រះអង្គនឹងឆ្លើយតបគឺត្រង់ថា ការអធិស្ឋានផ្ទាល់មានតម្លៃចំពោះព្រះជាម្ចាស់។ នេះគឺជាអត្ថន័យដំបូងនៃចានគោម និងគ្រឿងក្រអូប។

**បុព្វហេតុនៃការដែលព្រះរាជ្យនគរមកដល់**

អត្ថន័យទី២គឺនៅក្នុងកណ្ឌគម្ពីរ វិវរណៈ ៨:៣-៥។ នឹងមានថ្ងៃមកដល់ដែលចានគោមនោះនឹងពេញ។ និយាយម្យ៉ាងទៀត ការអធិស្ឋានរាប់លានដែលត្រូវបានអធិស្ឋានឡើង—“សូមឲ្យព្រះនាមព្រះអង្គបានបរិសុទ្ធ សូមឲ្យព្រះរាជ្យរបស់ព្រះអង្គបានមកដល់”—ចំណុចចុងក្រោយនឹងមានការ



50 QnA John Piper Final 1.5.indd 18 25/01/2024 09:22:25 AM

អធិស្ឋានឡើង ហើយព្រះជាម្ចាស់ក៏នឹងទតមើលពួកទេវតា ហើយមានបន្ទូលថា «ចូលចាក់លើផែនដីចុះ»។ ហើយគាត់នឹងយកចានគោមនៃសេចក្តីអធិស្ឋាន ដូចជាភ្លើង ហើយបោះទៅលើផែនដី ដែលនេះគឺជាការសម្រេចគោលបំណងចុងក្រោយរបស់ព្រះជាម្ចាស់។

ដូច្នេះ វាពិតជាគួរដ៏ភ្ញាក់ផ្អើលមែន នៅពេលដែលលោកអ្នកគិតអំពីការដែលសេចក្តីអធិស្ឋានរបស់ព្រះជាម្ចាស់ត្រូវបានអធិស្ឋានឡើងរាប់លានដង គ្រប់ពេលដែលយើងអធិស្ឋានក្នុងជំនឿ នោះព្រះជាម្ចាស់បានដាក់វាចូលក្នុងចានគោមឲ្យពេញឡើងៗ ហើយក៏នឹងមានថ្ងៃដែលមកដល់ពេលដែលទ្រង់នឹងចាក់ចានគោមនោះ ដើម្បីជាការសម្រេចពេលវេលា។ ដូច្នេះ ការអធិស្ឋានទាំងអស់នោះមិនមែនជាការឥតប្រយោជន៍នោះទេ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**

# សំណួរទី២៖
# តើគ្រប់សាសនានាំមនុស្សទៅកាន់ព្រះមែនឬ?

*មានកញ្ញាម្នាក់ឈ្មោះ ធីតា បានលើកជាសំណួរថា "តើព្រះជាម្ចាស់ជាព្រះដូចគ្នានឹងព្រះនានាក្នុងគ្រប់សាសនា ប៉ុន្តែគ្រាន់តែមានរូបរាងខុសៗគ្នាមែនឬ? នាងខ្ញុំបានឮគេនិយាយបែបដូចនោះ ប៉ុន្តែតើព្រះគម្ពីរបានចែងយ៉ាងដូចម្ដេចទាក់ទងនឹងការលើកឡើងបែបនោះ?"*

ជាដំបូង សូមអនុញ្ញាតឲ្យយើងខ្ញុំយល់នូវសំណួរដែលសួរនេះសិន។ យើងខ្ញុំយល់សំណួររបស់ធីតាដូចតទៅ៖ "ប្រសិនបើយើងពិតជាគោរពថ្វាយបង្គំព្រះណាមួយក្នុងគ្រប់សាសនាទាំងអស់ដោយអស់ពីចិត្តមែន តើយើងកំពុងតែថ្វាយបង្គំព្រះជាម្ចាស់ដ៏ពិតមែនឬ?" ឬយើងអាចសួរបែបនេះក៏បាន "តើព្រះគម្ពីរពិតជាបានបង្រៀនថា ព្រះនានានៅក្នុងសាសនាផ្សេងទៀតក្រៅពីជំនឿរបស់គ្រីស្ទបរិស័ទ គឺពិតជាព្រះដ៏ពិត ខុសប្លែកពីគ្នា ហើយផ្ទុយពីគ្នាទៅនឹងព្រះជាម្ចាស់ដ៏ពិតតែមួយគត់ ដែលជាព្រះវរបិតានៃព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើងមែនឬ?" នោះជារបៀបពីយ៉ាងដែលយើងខ្ញុំនឹងកាត់ស្រាយយល់លើសំណួររបស់កញ្ញាធីតា។

## ព្រះនានាដែលប្រជែងគ្នា

ចម្លើយរបស់យើងខ្ញុំទៅនឹងសំណួរទីពីរគឺ *បាទ!* ព្រះគម្ពីរបានបង្រៀនថា ព្រះដទៃនៅក្នុងសាសនាផ្សេងៗគឺមិនមែនគ្រាន់តែជាការរាយនាមចុះនៅក្នុងព្រះគម្ពីរប៉ុណ្ណោះនោះទេ។ ព្រះដទៃទាំងនោះមិនមែនជាព្រះបែបដូចរឿងព្រេងទេ តែតាមការពិតទៅពួកវាក៏ជាព្រះដែរ។ ពួកវាទាំងនោះចូលចិត្តឲ្យមនុស្សស្រឡាញ់ និងថ្វាយបង្គំពួកវា ហើយចង់បញ្ឆោតមនុស្សលើផែនដី ថែមទាំងចង់ទទួលការទទួលស្គាល់ពីមនុស្សលោក ដើម្បីឲ្យវាទទួលបានតំណែង



50 QnA John Piper Final 1.5.indd 21 25/01/2024 09:22:26 AM

ជំនួសកន្លែងរបស់ព្រះជាម្ចាស់ដ៏ជាព្រះពិត។ ចម្លើយសម្រាប់សំណួរទីមួយរបស់យើងខ្ញុំគឺ អត់ទេ។ ទោះបើលោកអ្នកពិតជាថ្វាយបង្គំព្រះដទៃនៅក្នុងសាសនាផ្សេងៗយ៉ាងអស់ពីចិត្តមែន ក៏នោះមិនមែនមានន័យថា លោកអ្នកកំពុងថ្វាយបង្គំព្រះដ៏ពិតតែមួយ ដែលបានបើកសម្តែងនៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទនោះឡើយ។ នោះឯងជាចម្លើយរបស់យើងខ្ញុំ។

ឥឡូវនេះ សូមអនុញ្ញាតឲ្យយើងខ្ញុំបង្ហាញនូវខគម្ពីរមួយចំនួន ដែលយើងខ្ញុំរំពឹងទៅលើចំណុចដែលទាក់ទងនឹងចម្លើយ។ សាវ័ក ប៉ុល បានមានប្រសាសន៍នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១០:១៩-២០ ដូចតទៅ “ដែលខ្ញុំនិយាយដូច្នេះ តើមានន័យថា រូបព្រះជាអ្វីឬទេ ឬតង្វាយថ្វាយដល់រូបព្រះជាអ្វីឬទេ មិនមែនជាអ្វីទេ ឯរបស់ដែលសាសន៍ដទៃបូជាថ្វាយ នោះមិនមែនថ្វាយដល់ព្រះទេ គឺថ្វាយដល់អារក្សវិញទេតើ ហើយខ្ញុំមិនចង់ឲ្យអ្នករាល់គ្នា មានសេចក្តីប្រកបនឹងអារក្សឡើយ”។ សំណួរដែលគាត់កំពុងតែឆ្លើយគឺទាក់ទងទៅនឹងម្ហូបអាហារសំណែនដល់រូបព្រះនៃសាសនាផ្សេងៗហើយផងដែរនោះ តើគ្រីស្ទបរិស័ទគួរមានចំណែកដែរឬអត់?។

នៅសតវត្សទី១ ការពន្យល់របស់សាវ័ក ប៉ុល ទាក់ទងនឹងការថ្វាយយញ្ញបូជាក្នុងសាសនាផ្សេងៗគឺមិនមែនជាការថ្វាយយញ្ញបូជាទៅកាន់ព្រះជាម្ចាស់ដ៏ពិតនោះទេ ទោះបើក្នុងសាសនាទាំងនោះបានអះអាងថា ព្រះរបស់ពួកគេគឺដូចតែគ្នាតែមួយនឹងព្រះដ៏ពិតក៏ដោយ។ ពួកគេបានថ្វាយយញ្ញបូជាទៅកាន់ព្រះ—ដែលសាវ័ក ប៉ុល បានហៅពួកវាថាអារក្ស—ដែលពួកវាប្រឆាំងនឹងព្រះជាម្ចាស់។ នោះឯងជាអ្វីដែលពួកអារក្សអសោចធ្វើ។ អ្វីដែលសាវ័ក ប៉ុល កំពុងតែប្រកាសយ៉ាងសាមញ្ញគឺថា នេះជាការបន្តនូវអ្វីដែលព្រះជាម្ចាស់បានបើកសម្តែងឲ្យឃើញរួចហើយនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ មានព្រះដ៏ពិតតែមួយទេនៅអ៊ីស្រាអែល (ព្រះយេហូវ៉ា) ដែលព្រះអង្គបានបើកសម្តែងអង្គទ្រង់ផ្ទាល់តាមរយៈព្រះបន្ទូលរបស់ទ្រង់ទៅកាន់លោក ម៉ូសេ



50 QnA John Piper Final 1.5.indd 22 25/01/2024 09:22:26 AM

ហើយនិងពួកហោរាផ្សេងៗទៀត។

សាសន៍ដទៃក៏មានព្រះនានារបស់ខ្លួនដែរ ដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់មិនគួរថ្វាយបង្គំទេ។ ឧទាហរណ៍ កណ្ឌគម្ពីរ (ចោទិយកថា ២៩:១៧) បានចែងថា “ក្រែងនៅក្នុងពួកឯងរាល់គ្នា នៅថ្ងៃនេះ មានមនុស្សប្រុស ឬស្រីណា ឬគ្រួណា ឬពូជអំបូរណាដែលមានចិត្តបែរចេញពីព្រះយេហូវ៉ា ជាព្រះនៃយើង ទៅគោរពប្រតិបត្តិដល់ព្រះរបស់សាសន៍ទាំងនោះវិញ ហើយក្រែងនៅក្នុងពួកឯងរាល់គ្នា មានឫសណាដែលបង្កើតជាតិពុលហើយនិងស្លែង”។ ឬក៏ក្នុងកណ្ឌគម្ពីរ (យ៉ូស្វេ ២៣:៧-៨)៖ “ប្រយោជន៍កុំឲ្យលាយឡំនឹងសាសន៍ទាំងនេះ ដែលសល់នៅក្នុងស្រុកឯង ហើយកុំឲ្យឯងដំណាលពីឈ្មោះព្រះរបស់គេ ឬឲ្យអ្នកណាស្បថដោយនូវឈ្មោះព្រះទាំងនោះ ហើយកុំឲ្យឯងរាល់គ្នាគោរពប្រតិបត្តិក្រាបថ្វាយបង្គំដល់ព្រះគេឡើយ គឺត្រូវឲ្យតោងជាប់នឹងព្រះយេហូវ៉ាជាព្រះនៃឯងរាល់គ្នាវិញ ដូចជាបានធ្វើដរាបដល់សព្វថ្ងៃនេះ”។

ព្រះជាម្ចាស់បានបញ្ជាក់យ៉ាងច្បាស់លាស់ ជាច្រើនដងរួចហើយ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលថា មានព្រះដទៃជាច្រើនផងដែរ។ មានសាសនាផ្សេងៗជាច្រើន ហើយប្រជារាស្ត្ររបស់ទ្រង់ក៏មិនគួរចាត់ទុកថា ព្រះទាំងអស់នោះគឺជាការបើកបង្ហាញពីភាពពិតជាក់ស្តែងរបស់ព្រះអង្គផ្ទាល់នោះឡើយ—ដូចជាសន្មតថាព្រះដូចគ្នានៅក្នុងរាល់សាសនាទេ។ ព្រះទាំងនោះខុសគ្នាពីព្រះក្នុងព្រះគម្ពីរ។ ព្រះទាំងនោះប្រជែងគ្នានឹងព្រះដ៏ពិត។ ព្រះទាំងនោះជាខ្មាំងសត្រូវរបស់ព្រះដ៏ពិត។ ព្រះទាំងនោះគឺជាអារក្សអសោច។ ពួកវាទាំងនោះមិនមែនជាព្រះជាម្ចាស់ទេ។ ពួកវាទាំងនោះគឺជាអ្នកប្រជែងដណ្តើមចង់យកតំណែងជាព្រះដ៏ពិត។ ពួកវាមានពិតប្រាកដមែន ពោលគឺជាអារក្សអសោចដ៏ពិត។



50 QnA John Piper Final 1.5.indd 23 25/01/2024 09:22:27 AM

## តើលោកអ្នកនឹងបម្រើព្រះមួយណា?

ចំណុចដ៏ចម្បងនៃជីវិតគឺថា «តើលោកអ្នកនឹងបម្រើព្រះដ៏ពិតតែមួយ ឬក៏តើលោកអ្នកនឹងបម្រើព្រះដទៃផ្សេងៗឯទៀត?» នៅលើភ្នំកើមែល ហោរាអេលីយ៉ា បានប្រៀបធៀបការនោះដូចនេះ៖ រវាងព្រះយេហូវ៉ា ហើយនិងព្រះបាល តើលោកអ្នកនឹងបម្រើព្រះមួយណា? ហោរា អេលីយ៉ា បានមានប្រសាសន៍ថា «តើអ្នករាល់គ្នានៅតែស្ទាក់ស្ទើរនាកណ្ដាលផ្លូវទាំង២នេះ ដល់កាលណាទៀត បើព្រះយេហូវ៉ាទ្រង់ជាព្រះ នោះចូរដើរតាមទ្រង់ទៅ តែបើព្រះបាលជាព្រះវិញ នោះចូរប្រតិបត្តិតាមចុះ តែពួកបណ្ដាជនមិនបានឆ្លើយសូម្បី១ម៉ាត់ឡើយ» (១ពង្សាវតារក្សត្រ ១៨:២១) ។

លោកអ្នកមិនអាចនិយាយថា អស់ដែលថ្វាយបង្គំព្រះបាលដោយស្មោះត្រង់ទាំងនោះ គឺកំពុងតែថ្វាយបង្គំព្រះដ៏ពិតបាននោះទេ។ ប្រសិនបើនោះជាការពិតមែន នោះព្រះគម្ពីរមិនគួរយកការបានឡើយ។ ព្រះទាំងអស់នោះគឺជាខ្មាំងសត្រូវដ៏ធំ ហេតុដូច្នេះហើយ បានជានៅក្នុងក្រឹត្យវិន័យដំបូងមានចែងថា «កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ» (និក្ខមនំ ២០:៣)។ នេះគឺជារឿងដ៏ចម្បងនៅសម័យកាលយើងនេះ ចាប់តាំងពីពេលដែលព្រះយេស៊ូវបានយាងមកកាន់ផែនដីនេះក្នុងនាមជាទីបញ្ចប់ និងការសម្រេចនៃការបើកសម្ដែងជាព្រះដ៏ពិតនោះមក៖ ព្រះអង្គផ្ទាល់ (ដូចដែលទ្រង់បានបើកសម្ដែងអង្គទ្រង់ផ្ទាល់នៅក្នុងប្រវត្តិសាស្ត្រ) គឺជាការល្បងលថា តើអំណះអំណាងណាដែលថាខ្លួនកំពុងថ្វាយបង្គំព្រះដ៏ពិតគឺជាការពិតឬក៏មិនពិត។

ឧទាហរណ៍៖ កណ្ឌគម្ពីរ ១យ៉ូហាន ៤:១ បានចែងថា «ពួកស្ងួនភ្ងាអើយ កុំឲ្យជឿគ្រប់ទាំងវិញ្ញាណឡើយ»—ប្រសិនបើមានវិញ្ញាណណាមួយបាននិយាយថា «នេះគឺជាសាសនាដ៏ពិតប្រាកដ ឬក៏ថា ព្រះដ៏ពិតគង់នៅទីនោះ» ចូរកុំជឿពួកវាឲ្យសោះ—«ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឲ្យបានដឹង



50 QnA John Piper Final 1.5.indd 24 25/01/2024 09:22:27 AM

ជាមកពីព្រះ ឬមិនមែន»។ តើយើងនឹងល្បងលការនោះដោយរបៀបណា? សាវ័ក យ៉ូហាន បានបន្តមានប្រសាសន៍ថា «មានហោរាក្លែងក្លាយជាច្រើន បានចូលមកក្នុងលោកីយ៍។ ដោយការនេះ លោកអ្នកនឹងដឹងថា វិញ្ញាណនេះ មកពីព្រះគឺថា៖ គឺអស់ទាំងវិញ្ញាណណាដែលថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទ បានមកក្នុងសាច់ឈាម គឺវិញ្ញាណនោះហើយ ដែលមកពីព្រះ» (១យ៉ូហាន ៤:២)។

## ការល្បងលដ៏ពិត

បើនិយាយម្យ៉ាងវិញទៀត ព្រះយេស៊ូវដែលមានបើកសម្ដែងនៅក្នុងប្រវត្តិសាស្ត្រដែលមានចែងក្នុងព្រះគម្ពីរគឺជាការល្បងលដ៏ពិតប្រាកដទាក់ទងនឹងអំណះអំណាងពីព្រះឯទៀត។ រាល់សាសនាឯទៀត ដែលមិនបានឧបក្រសោប ក្រាបថ្វាយបង្គំ និងស្ដាប់បង្គាប់ព្រះយេស៊ូវទាក់ទងនឹងលក្ខណៈរបស់ព្រះអង្គ—ដែលមានបើកសម្ដែងនៅក្នុងព្រះគម្ពីរ—គឺជាសាសនាមិនពិតហើយ។ នេះមិនមែនជាព្រះដែលយើងមិនអាចស្គាល់បាននោះឡើយ។ ព្រះយេស៊ូវបានមានបន្ទូលដូចនេះនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ៥:២៣៖ «អ្នកណាដែលមិនគោរពប្រតិបត្តិដល់ព្រះរាជបុត្រា»—ព្រះយេស៊ូវ—«នោះក៏មិនគោរពប្រតិបត្តិដល់ព្រះវរបិតា ដែលចាត់ឲ្យទ្រង់មកដែរ»។

មិនថាពួកគេកំពុងនិយាយអ្វីអំពីព្រះជាម្ចាស់ក៏ដោយ—ត្រង់នេះ ព្រះយេស៊ូវកំពុងមានបន្ទូលសំដៅទៅពួកផារិស៊ី ដែលបានអះអាងថាខ្លួនពិតជាបានទុកចិត្ត ហើយនិងទទួលជឿលើព្រះជាម្ចាស់នៃព្រះគម្ពីរសញ្ញាចាស់—ក៏ព្រះយេស៊ូវបានមានបន្ទូលឆ្លើយតបថា «អត់ទេ! ពួកឯងមិនបានទទួលជឿឡើយ ព្រោះពួកឯងមិនទទួលយកខ្ញុំ»។ ព្រះយេស៊ូវគឺជាសេចក្ដីល្បងលសម្រាប់រាល់សាសនា ដែលមានរួមបញ្ចូលទាំងសាសនាយូដាដែរ។ ជាថ្មីម្ដងទៀតកណ្ឌគម្ពីរ (យ៉ូហាន ៨:៤២) មានចែងថា «បើ



50 QnA John Piper Final 1.5.indd 25 25/01/2024 09:22:27 AM

ព្រះជាព្រះវរបិតានៃអ្នករាល់គ្នាមែន នោះអ្នកនឹងបានស្រឡាញ់ខ្ញុំ ដ្បិតខ្ញុំចេញពីព្រះមក ហើយក៏មកដល់ មិនមែនមកដោយអាងខ្លួនខ្ញុំទេ គឺព្រះអង្គបានចាត់ឲ្យខ្ញុំមកទេតើ»។ (យ៉ូហាន ៨:៤២)។ សាវ័ក យ៉ូហាន បានលើកឡើងថា «ឯអស់អ្នកដែលមិនព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏គ្មានព្រះវរបិតាដែរ តែអ្នកណាដែលព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏មានទាំងព្រះវរបិតាផង» (១យ៉ូហាន ២:២៣)។

សេចក្ដីសន្និដ្ឋានរបស់យើងខ្ញុំដែលមានចេញពីព្រះគម្ពីរគឺថា៖ ពិតជាមានព្រះឯទៀតៗជាច្រើនមែននៅខាងក្រោយសាសនាផ្សេងៗ ប៉ុន្តែពួកវាមិនមែនជាព្រះដ៏ពិតនោះឡើយ។ ពួកវាជាអ្នកប្រជែងដណ្ដើមប្រឆាំងទាស់នឹងព្រះជាម្ចាស់ទេតើ។ ពួកវាគឺជាអារក្សអសោច និងជាពួកបញ្ឆោត ហើយព្រះយេស៊ូវគ្រីស្ទគឺជាសេចក្ដីល្បងលដ៏ពិតទាក់ទងនឹងការប្រកាសពីសាសនាផ្សេងៗថាជាសាសនាពិត។ ព្រះអង្គជាទីបញ្ចប់ និងជាការសម្រេចនៃការបើកសម្ដែងនៃព្រះដ៏ពិតតែមួយគត់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 26 25/01/2024 09:22:28 AM

## សំណួរទី៣៖
# តើយើងមានឆន្ទៈសេរីក្នុងការជ្រើសរើសយកព្រះគ្រីស្ទដែរឬទេ?

*មិត្តអ្នកអានម្នាក់ឈ្មោះសកលបានផ្ញើសារមកសួរថា «តើមនុស្សមានឆន្ទៈសេរីដែរឬទេ?»*

យើងខ្ញុំចង់សម្រួលសំណួរនេះឲ្យចំៗបន្តិច ដើម្បីកុំឲ្យវាទូលំទូលាយពេក ប៉ុន្តែយើងខ្ញុំគិតថាវាក៏នឹងឆ្លើយទៅលើចំណុចស្នូលនៃសំណួរនេះដែរ៖ «តើយើងមានឆន្ទៈសេរីក្នុងការជ្រើសរើសយកព្រះគ្រីស្ទធ្វើជាព្រះអម្ចាស់ ព្រះសង្គ្រោះ និងទ្រព្យសម្បត្តិរបស់យើងដែរឬទេ?»។ យើងខ្ញុំគិតថា នេះគឺជាចំណុចស្នូលនៃការជជែកវែកញែកគ្នា។ ហើយបន្ទាប់មក យើងក៏អាចនិយាយឲ្យទូលំទូលាយជាងនោះទៀតបានដែរ៖ «តើយើងមានឆន្ទៈសេរីក្នុងការញ៉ាំផ្លែចេកដែរឬទេ?» ប៉ុន្តែ យើងខ្ញុំនឹងគ្រាន់តែឆ្លើយលើសំណួរដែលថា៖ «តើយើងមានឆន្ទៈសេរីក្នុងការជ្រើសរើសយកព្រះគ្រីស្ទធ្វើជាព្រះអម្ចាស់ ព្រះសង្គ្រោះ និងទ្រព្យសម្បត្តិរបស់យើងដែរឬទេ?» ប៉ុណ្ណោះ។ ហើយពិតណាស់! គឺវាអាស្រ័យទៅលើអត្ថន័យដែលយើងផ្ដល់លើពាក្យ «ឆន្ទៈសេរី»។

## ការប្ដេជ្ញាចិត្តដោយខ្លួនឯងចុងក្រោយ

តោះ! ចូរយើងចាប់ផ្ដើមដោយផ្ដល់នូវអត្ថន័យមួយដែលអស់អ្នកវែកញែកទាំងអស់គ្នានឹងឯកភាពជាមួយសិន។ ឧទាហរណ៍៖ យើងខ្ញុំដឹងថា ក្នុងការជជែកវែកញែករបស់យើងខ្ញុំជាមួយនឹងលោកគ្រូ ហ្គ្រេគ ប៊យ (Greg Boyd) គាត់តែងតែប្រើអត្ថន័យនេះអំពីអ្វីដែលគាត់កំពុងតែការពារ៖ «លោកអ្នកមានឆន្ទៈសេរីនៅពេលដែលលោកអ្នកមានការប្ដេជ្ញាចិត្តដោយខ្លួនឯងចុងក្រោយ»។

យោងតាមអត្ថន័យមួយនេះ លោកអ្នកមានឆន្ទៈសេរីក្នុងការជ្រើសរើសយកព្រះគ្រីស្ទ ប្រសិនបើបុព្វហេតុចុងក្រោយនៃការជ្រើសរើសរបស់លោកអ្នកគឺជាការប្ដេជ្ញាចិត្តដោយខ្លួនឯងចុងក្រោយ។ ដូច្នេះ ចំណុចគឺលើពាក្យ "*ចុងក្រោយ*"។ ទំនងជាមានចំណុចជំរុញជាច្រើនក្នុងការប្ដេជ្ញាចិត្តរបស់លោកអ្នកក្នុងការជ្រើសរើសយកព្រះគ្រីស្ទ។ ប៉ុន្តែ មានតែចំណុចជំរុញមួយប៉ុណ្ណោះដែលជាចំណុចចុងក្រោយ ឬក៏ចំណុចនៃទីបញ្ចប់។ យោងតាមអត្ថន័យមួយនេះ ឆន្ទៈសេរីតម្រូវឲ្យលោកអ្នកក្លាយជាអ្នកសម្រេចចុងក្រោយ មិនមានអ្វីផ្សេងទៀតឡើយ ដែលនេះមានរួមទាំងព្រះជាម្ចាស់។ ព្រះជាម្ចាស់មិនមែនជាចំណុចជំរុញចុងក្រោយ ឬក៏ជាចំណុចនៃទីបញ្ចប់ក្នុងការជ្រើសរើសទេ។ តែលោកអ្នកទេតើ។

យើងអាចលើកឡើងម្យ៉ាងទៀតថា៖ លោកអ្នកមានឆន្ទៈសេរីនៅពេលដែលឆន្ទៈរបស់លោកអ្នកគឺជាបុព្វហេតុនៃការសម្រេចទាក់ទងនឹងការជ្រើសរើសយកព្រះគ្រីស្ទ។ ហើយពាក្យ "*សម្រេច*" ក៏មានតួនាទីដូចគ្នាជាមួយនឹងពាក្យ "ចុងក្រោយ" ផងដែរ។ ទំនងជាមានបុព្វហេតុជាច្រើនដែលជះឥទ្ធិពលលើការជ្រើសរើសរបស់លោកអ្នកក្នុងការយកព្រះគ្រីស្ទ។ ប៉ុន្តែ ដើម្បីឲ្យលោកអ្នកមានសេរីភាព យោងតាមអត្ថន័យមួយនេះ បុព្វហេតុនៃការសម្រេចចិត្ត—ចំណុចចុងក្រោយដែលនាំឲ្យលោកអ្នកសម្រេចយកជម្រើសរបស់លោកអ្នក—ដាច់ខាតគឺត្រូវតែជាឆន្ទៈរបស់លោកអ្នក មិនមែនឆន្ទៈរបស់បុគ្គលណាម្នាក់ផ្សេងទៀត ដែលនេះក៏មានរួមទាំងព្រះជាម្ចាស់ផងដែរ។

ដូច្នេះ នោះគឺជាចំណុចនៃការវែកញែក។ នៅពេលដែលលោកអ្នកទៅដល់ស្ថានសួគ៌ ហើយប្រសិនបើព្រះជាម្ចាស់សួរលោកអ្នកថា "តើអ្វីទៅជាមូលហេតុចុងក្រោយនៃការសម្រេចរបស់ឯងក្នុងការទទួលជឿលើព្រះរាជបុត្រារបស់អញ?"។ តើលោកអ្នកនឹងឆ្លើយតបយ៉ាងដូចម្ដេច? តើលោកអ្នកនឹងលើកឡើងថា "ព្រះគុណរបស់ព្រះអង្គគឺជាមូលហេតុចុងក្រោយនៃការ



50 QnA John Piper Final 1.5.indd 28 25/01/2024 09:22:28 AM

សម្រេចចិត្តរបស់ទូលបង្គំក្នុងការជ្រើសរើស»? ឬក៏ថាលោកអ្នកនឹងឆ្លើយតបបែបនេះវិញ៖ «ជម្រើសរបស់ទូលបង្គំគឺជាមូលហេតុចុងក្រោយនៃការសម្រេចចិត្តរបស់ទូលបង្គំ»?

សូមកត់សម្គាល់ច្បាស់ថា សំណួរគឺមិនមែន «តើយើងបានធ្វើការជ្រើសរើស?» នោះទេ។ សំណួរគឺមិនមែន «តើឆន្ទៈរបស់យើងមានសកម្មភាព ហើយក៏ចាំបាច់មាន? នោះទេ។ សំណួរក៏មិនមែន «តើជម្រើសរបស់យើងពិត ឬក៏មិនពិត?» នោះទេ។ ចម្លើយលើសំណួរទាំងអស់នេះគឺ «បាទ/ចាស៎!»។ លោកអ្នកបានធ្វើការជ្រើសរើស។ ឆន្ទៈរបស់លោកអ្នកមានសកម្មភាព ហើយក៏ចាំបាច់ដែរ។ ជម្រើសរបស់លោកអ្នកក៏ពិតដែរ។ ទាំងនោះមិនមែនជាសំណួរក្នុងការរែកញែកនោះទេ។

សំណួរគឺថា នៅពេលដែលឆន្ទៈរបស់លោកអ្នកអាចជ្រើសរើស តើអ្វីទៅជាចំណុចសម្រេចក្នុងការនាំឲ្យឆន្ទៈនោះកើតមានឡើង? តើអ្វីទៅជាឥទ្ធិពល ឬក៏ជាបុព្វហេតុដែលនាំឲ្យមានការសម្រេចចិត្តបែបនោះ? ហើយព្រះគម្ពីរក៏បានឆ្លើយដូចតទៅ៖ ព្រះគុណរបស់ព្រះជាម្ចាស់។ ហើយអ្នកដទៃលើកឡើងថា៖ គឺអំណាចនៃការប្ដេជ្ញាចិត្តផ្ទាល់របស់លោកអ្នកទេតើ។ ដូច្នេះ អ្វីដែលយើងខ្ញុំកំពុងតែប្រកែកក្នុងការជ្រើសរើសយកព្រះគ្រីស្ទគឺថា យើងមិនមានឆន្ទៈសេរីបែបនេះនោះទេ—ដែលនេះមានន័យថា អំណាចនៃការប្ដេជ្ញាចិត្តផ្ទាល់។ ខាងក្រោមនេះគឺជាខគម្ពីរបីប្រភេទដែលយើងខ្ញុំចង់លើកទឹកចិត្តឲ្យយើងគិតលើ៖

### ១. ខ្វាក់ និងពុករលួយ

*ទី១* យើងមានភាពពុករលួយយ៉ាងធ្ងន់ធ្ងរខាងឯសីលធម៌ដល់ថ្នាក់ថា យើងមិនមានសមត្ថភាពក្នុងការធ្វើអ្វីដែលល្អបានឡើយ។ យើងមិនអាចទទួលជឿបានទេ។ «ដ្បិតគំនិតខាងសាច់ឈាម នោះជាសេចក្ដីស្លាប់ទទេ



50 QnA John Piper Final 1.5.indd 29 25/01/2024 09:22:28 AM

ឯគំនិតនៃព្រះវិញ្ញាណ នោះទើបជាជីវិត នឹងសេចក្តីសុខសាន្តវិញ ព្រោះគំនិតខាងសាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ ដ្បិតមិនចុះចូលនឹងក្រិត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង» (រ៉ូម ៨:៦-៧)។

«គំនិតខាងសាច់ឈាម» ដែលនៅក្រៅពីព្រះយេស៊ូវគ្រីស្ទ មិនអាចចុះចូលចំពោះព្រះជាម្ចាស់បានឡើយ។ យើងស្រឡាញ់ការលើកតម្កើងខ្លួនឯង ហើយក៏មិនអាចចុះចូលបានដែរ។ ឬក៏សូមពិចារណាលើកណ្ឌគម្ពីរ (១កូរិនថូស ២:១៤)៖ «ប៉ុន្តែ មនុស្សខាងសាច់ឈាម គេមិនទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតត្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ»—គាត់រកស្គាល់មិនបាន!—ក្នុងការយល់សេចក្តីទាំងនោះ ពីព្រោះពួកគាត់មិនមានការដឹងខុសត្រូវខាងឯព្រលឹងវិញ្ញាណ។ ដូច្នេះ ខគម្ពីរទាំងនេះនៅក្នុងព្រះគម្ពីរបានលើកឡើងថា យើងមិនអាចយល់ និងចុះចូលចំពោះព្រះជាម្ចាស់បាន ពីព្រោះយើងមានភាពពុករលួយ។

## ២. អំណោយទាននៃជំនឿរបស់ព្រះជាម្ចាស់

*ទី២* យើងមិនអាចជ្រើសរើសយកព្រះគ្រីស្ទបានទេ។ ជាចុងក្រោយ វាគឺជាអំណោយទានរបស់ព្រះជាម្ចាស់៖ «ក៏មិនគួរឲ្យបាវបម្រើនៃព្រះអម្ចាស់ឈ្លោះប្រកែកគ្នាឡើយ គួរឲ្យបានចិត្តសុភាពរាបសាដល់មនុស្សទាំងអស់វិញ ត្រូវប្រសប់ក្នុងការបង្រៀន ទាំងមានចិត្តអត់ធ្មត់ផង ត្រូវប្រដៅដំរង់មនុស្សដែលទទឹងទទែង ដោយមានចិត្តសុភាព ក្រែងព្រះទ្រង់នឹងបណ្តាលឲ្យគេប្រែចិត្តឲ្យបានស្គាល់សេចក្តីពិតវិញ» (២ធីម៉ូថេ ២:២៤-២៥)។ ដូច្នេះ វាទាមទារឲ្យមានការកែប្រែចិត្ត ហើយយើងក៏មិនអាចធ្វើការនេះបានដោយខ្លួនឯងដែរ។ បុព្វហេតុនៃការសម្រេចចិត្តគឺថា ព្រះជាម្ចាស់ទំនងជាអាចនឹងប្រទានការកែប្រែចិត្តដល់យើង។



50 QnA John Piper Final 1.5.indd 30 25/01/2024 09:22:29 AM

ឬក៏សូមអានកណ្ឌគម្ពីរ ភីលីព ១:២៩៖ «ដ្បិតមានឱកាសបើកឲ្យអ្នករាល់គ្នាហើយ មិនមែនឲ្យគ្រាន់តែជឿដល់ព្រះគ្រីស្ទតែប៉ុណ្ណោះទេ គឺឲ្យរងទុក្ខដោយព្រោះទ្រង់ដែរ»។ ការជឿព្រះគ្រីស្ទគឺជាអំណោយទាន។ ព្រះអង្គបានប្រទានមកកាន់លោកអ្នក ពីព្រោះលោកអ្នកមិនអាចបង្កើតវានៅក្នុងខ្លួនឯងបាន។ ដូច្នេះហើយបានជាសាវ័ក ប៉ុល លើកឡើងថា «ដូច្នេះ មិនសម្រេចនឹងអ្នកណាដែលចង់បាន ឬនឹងអ្នកណាដែលខំរត់តាមនោះទេ គឺស្រេចនឹងព្រះ ដែលមានសេចក្តីមេត្តាករុណាវិញ» (រ៉ូម ៩:១៦)។

## ៣. ព័ន្ធកិច្ចនៃការសម្រេចរបស់ព្រះជាម្ចាស់

*ទី៣* តើបទពិសោធន៍នេះមានលក្ខណៈដូចម្តេច នៅពេលដែលយើងជ្រើសរើសតាមរយៈអំណាចរបស់បុគ្គលណាម្នាក់ផ្សេងទៀត? ក្នុងកណ្ឌគម្ពីរ (១កូរិនថូស ១៥:១០) សាវ័ក ប៉ុល បានលើកឡើងថា «ប៉ុន្តែ ដែលខ្ញុំបានជាយ៉ាងណា នោះគឺបានដោយព្រះគុណនៃព្រះទេ ហើយព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំ នោះមិនមែនជាអសារឥតការឡើយ ដ្បិតខ្ញុំបានខំធ្វើការលើសជាងអ្នកទាំងនោះសន្ធឹកណាស់ ប៉ុន្តែ មិនមែនជាខ្ញុំ គឺជាព្រះគុណនៃព្រះ ដែលសណ្ឋិតនៅនឹងខ្ញុំវិញ»។ ដូច្នេះ យើងឃើញអំពីទិដ្ឋភាព៖ ខ្ញុំក៏ពិតជាជ្រើសរើស។ ខ្ញុំក៏ពិតជាមានសកម្មភាព។ ខ្ញុំកំពុងតែធ្វើការ។ ប៉ុន្តែទេ! គឺព្រះជាម្ចាស់ទេតើដែលកំពុងតែធ្វើព័ន្ធកិច្ចនៅក្នុងខ្ញុំ។ ព្រះអង្គគឺជាអង្គដែលសម្រេច ជាបុព្វហេតុនៅពីក្រោយដែលនាំឲ្យវាកើតឡើង។ ដូចគ្នាក្នុងកណ្ឌគម្ពីរ ភីលីព ២:១២-១៣៖ «ចូរបង្ហើយសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយកោតខ្លាច ហើយញាប់ញ័រចុះ...ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា ឲ្យមានទាំងចំណង់ចង់ធ្វើ ហើយឲ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ»។



50 QnA John Piper Final 1.5.indd 31 25/01/2024 09:22:29 AM

នេះគឺជាសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ៖ ប្រសិនបើព្រះអង្គទុកយើងចោលក្នុងឆន្ទៈសេរីរបស់យើង—ដែលនេះគឺអំណាចនៃការប្តេជ្ញាចិត្តចុងក្រោយរបស់យើងផ្ទាល់ នោះយើងទាំងអស់គ្នានឹងប្រើប្រាស់វា ដើម្បីបដិសេធព្រះគ្រីស្ទជាមិនខាន។ យើងស្លាប់ខាងឯវិញ្ញាណ ល្ងីល្ងើ ខ្វាក់ និងទាស់ប្រឆាំងនឹងព្រះគ្រីស្ទ—យើងស្រឡាញ់សេចក្តីងងឹតខ្លាំងណាស់—ដល់ថ្នាក់ថា យើងមិនទាំងមានសមត្ថភាពខាងឯសីលធម៌ក្នុងការយើញ ការឲ្យតម្លៃ និងការជ្រើសរើសយកព្រះគ្រីស្ទជាជាងយកលោកីយ៍នេះ។

ព្រះគុណនៃអធិបតេយ្យភាពរបស់ព្រះជាម្ចាស់បានយាងចូលមកក្នុងជីវិតរបស់យើង យកឈ្នះលើការបះបោររបស់យើង យកឈ្នះលើភាពខ្វាក់របស់យើង និងលើការស្លាប់របស់យើង ហើយធ្វើឲ្យយើងមានសមត្ថភាពក្នុងការឃើញព្រះគ្រីស្ទក្នុងលក្ខណៈជំរុញ និងស្អាតដែលនាំឲ្យយើងមានការជ្រើសរើសយកព្រះគ្រីស្ទដោយសេរី។ ពិតណាស់ យើងខ្ញុំដឹងថា យើងមិនទាន់បានឆ្លើយសំណួរ «បើអញ្ចឹងមែន តើយើងមានការទទួលខុសត្រូវ និងទំនួលខុសត្រូវយ៉ាងដូចម្តេចទៅ?» ប៉ុន្តែ អ្វីដែលយើងខ្ញុំចង់ឆ្លើយក្នុងឯកសារនេះគឺថា «ទេ! យើងមិនមានឆន្ទៈសេរីក្នុងការជ្រើសរើសយកព្រះគ្រីស្ទនោះទេ ប្រសិនបើយើងផ្តល់អត្ថន័យលើឆន្ទៈសេរីថា ជាការប្តេជ្ញាចិត្តចុងក្រោយរបស់យើងផ្ទាល់។»

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 32 25/01/2024 09:22:29 AM

# សំណួរទី៩៖
# តើការដែលព្រះគ្រោងទុកឲ្យមនុស្សមួយចំនួនធ្លាក់នរក បានថ្វាយសិរីល្អដល់ទ្រង់បានដោយរបៀបណា?

*មិត្តអ្នកអានម្នាក់បានសួរមកកាន់ខាងយើងថា «តើតាមរយៈការដែលព្រះជាម្ចាស់គ្រោងទុកឲ្យមនុស្សមួយចំនួនធ្លាក់ចូលក្នុងស្ថាននរកយ៉ាងអស់កល្បជានិច្ចនាំឲ្យទ្រង់ទទួលបានសិរីល្អដោយរបៀបណា?»*

មុនយើងឱបក្រសោបឃ្លាថា «គ្រោងទុកឲ្យធ្លាក់នរក» គឺយើងត្រូវតែមានលក្ខខណ្ឌមួយចំនួនជាមុនសិន ពីព្រោះឃ្លានោះផ្ទាល់កម្រមានណាស់ សូម្បីតែក្នុងព្រះគម្ពីរក៏ឃ្លានេះមិនមានប្រើប្រាស់ដែរ។ យើងខ្ញុំអាចនឹកឃើញដល់បានតែពីរបីខប៉ុណ្ណោះដែលយើងអាចសម្រួលវាជិតដល់របៀបនោះបាន ដូច្នេះយើងខ្ញុំមិនចង់ផ្តោតខ្លាំងពេកលើសំណួរនេះនោះទេ។ ប៉ុន្តែ មានលក្ខខណ្ឌដែលយើងខ្ញុំចង់លើកឡើងទាក់ទងនឹងឃ្លានេះមុនយើងខ្ញុំផ្តល់ជូននូវចម្លើយ។

## លក្ខខណ្ឌផ្នែកខាងមុខ និងខាងក្រោយ

*ទី១* នៅឯស្ថាននរកនឹងមិនមានអ្នកណាដែលមិនស័ក្តិសមនឹងទៅទីនោះនោះទេ។ បុគ្គលណាដែលអាចផ្តល់ជូននូវមូលហេតុដ៏ល្អ (ហេតុផលជាផ្លូវការ) នឹងមិនមានវត្តមាននៅទីនោះទេ អំពីមូលហេតុដែលពួកគាត់មិនគួរនៅទីនោះ។ ពិភពលោកទាំងមូលនឹងដឹងអំពីចំណុចនេះ ហើយក៏នឹងបង្ហាញថាព្រះជាម្ចាស់ត្រឹមត្រូវដែរ។ នឹងមិនមានមន្ទិលសង្ស័យលើភាពយុត្តិធម៌របស់ព្រះជាម្ចាស់នៅគ្រាចុងក្រោយឡើយ។ យោងតាមព្រះគម្ពីរ នេះគឺជាចំណុចដំបូងដែលយើងត្រូវតែលើកឡើង ត្រង់ថា នៅឯស្ថាននរកនឹងមិនមានអ្នកណាដែលមិនស័ក្តិសមនឹងទៅទីនោះនោះទេ។

*ទី២* នៅឯស្ថាននរកនឹងមិនមានអ្នកណាដែលមិនស្ថិតក្នុងការបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់ដែរ។ ប្រសិនបើយើងមានអារម្មណ៍ថា មានមនុស្សមួយចំនួនត្រូវបានបោះចូលក្នុងស្ថាននរកដែលមិនស្ថិតក្នុងស្ថានភាពនៃការបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ដែលតាមពិតទៅគឺជាអ្នកស្រឡាញ់ព្រះជាម្ចាស់ ឬក៏ជាអ្នកដែលបានកែប្រែចិត្តទៅកាន់ព្រះជាម្ចាស់ ហើយក៏ថាពួកគាត់កំពុងតែឧបក្រសោបព្រះជាម្ចាស់ ឬក៏ថាក្នុងរបៀបណាមួយពួកគាត់មិនបានទាស់ប្រឆាំងនឹងព្រះជាម្ចាស់នោះទេ នោះវាគ្រាន់តែជាគំនិតចម្លែកប៉ុណ្ណោះដែលមិនមានក្នុងព្រះគម្ពីរ។ មនុស្សដែលនឹងរងទុក្ខគឺជាមនុស្សដែលបានទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ហើយក្នុងពេលដែលពួកគាត់កំពុងតែនៅស្ថាននរកក៏ពួកគាត់កំពុងតែទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ដោយបដិសេធទ្រង់ផងដែរ។

ចំណុចទី៣ដែលយើងត្រូវតែលើកឡើងអំពីលក្ខខណ្ឌទាក់ទងនឹងឃ្លា "គ្រោងទុកឲ្យធ្លាក់នរក" ត្រង់ថា ព្រះគម្ពីរបានបង្ហាញថាការជ្រើសតាំង និងការគ្រោងទុករបស់ព្រះជាម្ចាស់ក្នុងការជ្រើសរើសដែលទ្រង់បានប្រព្រឹត្តឡើងដោយមានពេញទៅដោយព្រះគុណ ដើម្បីសង្គ្រោះមនុស្សមានបាបមួយចំនួន មិនមែនជ្រើសរើសធ្វើឲ្យមនុស្សល្អមួយចំនួនក្លាយជាមនុស្សអាក្រក់វិញនោះទេ។ ព្រះគម្ពីរតែងតែបង្ហាញថា ព្រះអង្គបានសង្គ្រោះ*មនុស្សមានបាប*តាំងពីមុនដើមកំណើតនៃពិភពលោកមកម្ល៉េះ។ ព្រះគ្រីស្ទត្រូវបានគេធ្វើគុតតាំងពីមុនកំណើតពិភពលោកមកម្ល៉េះ (វិវរណៈ ១៣:៨)។

## ការបង្ហាញពេញទីនៃភាពល្អឥតខ្ចោះរបស់ព្រះជាម្ចាស់

ដោយមានលក្ខខណ្ឌទាំងបីនោះ សំណួរនេះគឺពិតជាល្អមែន។ នោះគឺជារបៀបដែលព្រះជាម្ចាស់ទទួលបានសិរីល្អ តាមរយៈការគ្រប់គ្រងលើផែនដី ឬក៏ការបង្កើតផែនដីដែលមានមនុស្សលោក—តាមរយៈការអនុញ្ញាត ឬក៏ការ



50 QnA John Piper Final 1.5.indd 34 25/01/2024 09:22:30 AM

រចនារបស់ទ្រង់ មិនថាលោកអ្នកចង់ពណ៌នាអំពីវាយ៉ាងម៉េចក៏ដោយ—នឹងធ្លាក់នរកដោយយុត្តិធម៌? កណ្ឌគម្ពីរ (រ៉ូម ៩:២២-២៣ ) គឺជាខគម្ពីរដ៏ច្បាស់លាស់បំផុតដែលផ្ដល់នូវចម្លើយចេញពីព្រះគម្ពីរដែលយើងខ្ញុំស្គាល់ «ចុះបើសិនជាព្រះទ្រង់ចង់សម្តែងសេចក្តីក្រោធ ព្រមទាំងបើកឲ្យស្គាល់ព្រះចេស្ដាដល់គ្រឿងប្រដាប់គួរនឹងក្រោធ ដែលរៀបចំឡើងសម្រាប់តែត្រូវបំផ្លាញដូច្នេះ ដែលទ្រង់ទ្រាំទ្រដោយអំណត់ជាយូរមកហើយ ហើយបើទ្រង់ចង់បើកឲ្យពួកគ្រឿងប្រដាប់ ដែលគួរនឹងសេចក្តីមេត្តាករុណា ដែលទ្រង់បានរៀបចំជាមុនបានស្គាល់សេចក្តីវិសេសនៃសិរីល្អដ៏បរិបូររបស់ទ្រង់វិញ»។

នៅក្នុងខគម្ពីរនោះសាវ័ក ប៉ុល បានមានប្រសាសន៍ថា ព្រះជាម្ចាស់មានគោលដៅក្នុងការបង្ហាញសេចក្តីក្រោធ  និងអំណាចរបស់ទ្រង់។ គោលបំណងរបស់ព្រះអង្គគឺថា ឲ្យមនុស្សលោកស្គាល់អំពីចំណុចដ៏ល្អឥតខ្ចោះរបស់ទ្រង់យ៉ាងពេញទី។ យើងខ្ញុំគិតថា ការបង្ហាញអំពីចំណុចដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់គឺជាគោលដៅដ៏ខ្ពស់បំផុតនៃចក្រវាឡនេះ។ ព្រះជាម្ចាស់បានបង្កើតចក្រវាឡនេះមក ដើម្បីបង្ហាញអំពីភាពល្អឥតខ្ចោះរបស់ទ្រង់យ៉ាងពេញទីដែលមានរួមទាំងសេចក្តីក្រោធ អំណាចព្រះចេស្តា ការថ្កោលទោស និងភាពយុត្តិធម៌។ ហើយក្នុងការធ្វើបែបនោះគឺត្រូវមានប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃកាប្រោសលោះនៅពីក្រោយដែលយើងហៅថាការធ្លាក់ក្នុងអំពើបាប និងអំពើបាប។

ទង្វើនៃព្រះគុណ និងទង្វើនៃសេចក្តីមេត្តាករុណា និងបទពិសោធន៍នៃសេចក្តីសង្គ្រោះបំភ្លឺយ៉ាងចែងចាំងនឹងមូលហេតុនៅពីក្រោយការធ្លាក់ក្នុងអំពើបាប និងអំពើបាបដែលបាននាំឲ្យមានលទ្ធផលនៃការជះឥទ្ធិពលពីរយ៉ាងក្នុងសិរីល្អរបស់ព្រះជាម្ចាស់។ *ទី១* ព្រះគុណរបស់ទ្រង់—ដែលយើងខ្ញុំគិតថាគឺជាចំណុចកំពូលនៃសិរីល្អរបស់ទ្រង់—ចាំងពន្លឺកាន់តែខ្លាំងឡើងៗពីព្រោះផ្នែកខាងក្រោយរបស់វាគឺការថ្កោលទោស និងអំពើបាប។



50 QnA John Piper Final 1.5.indd 35 25/01/2024 09:22:30 AM

*ទី២* អ្នកទទួលប្រយោជន៍ដែលមិនស័ក្តិសមនឹងទទួលនូវការជ្រើសតាំងនេះ និងការប្រោសលោះនឹងទទួលបានអំណរដ៏ខ្លាំងក្លា និងការដឹងគុណសម្រាប់ការសង្គ្រោះរបស់យើង។ នេះគឺដោយសារយើងឃើញមនុស្សទាំងអស់ ដែលបានបាត់បង់ គឺមិនមែនអាក្រក់ជាងយើង ហើយយើងក៏មិនបានល្អប្រសើរជាងពួកគាត់ដែរ—យើងក៏គួរធ្លាក់នរកដែរ។ ដូច្នេះ ការដឹងគុណរបស់យើងក៏នឹងកាន់តែខ្លាំងជាងមុន។

យ៉ាងហោចណាស់ នៅក្នុងករណីពីរនេះ យើងខ្ញុំនឹងលើកឡើងថា ជាចម្លើយលើសំណួរមួយនេះ។ តើព្រះជាម្ចាស់ទទួលបានសិរីល្អយ៉ាងដូចម្ដេច? ព្រះអង្គទទួលបានសិរីល្អ ពីព្រោះព្រះគុណ និងសេចក្តីមេត្តាករុណារបស់ព្រះទ្រង់ចាំងបំភ្លឺយ៉ាងភ្លឺថ្លានៅលើផ្ទៃខាងក្រោយនៃអំពើបាប ការថ្កោលទោស សេចក្តីក្រោធ និងការថ្វាយបង្គំរបស់យើង និងបទពិសោធន៍របស់យើងក្នុងព្រះគុណនោះក៏កាន់តែខ្លាំងឡើងៗជាមុន និងមានភាពស៊ីជម្រៅ ពីព្រោះយើងឃើញថា យើងមិនស័ក្តិសមនៅក្នុងស្ថានភាពដែលយើងកំពុងតែនៅក្នុងនោះទេ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 36 25/01/2024 09:22:30 AM

# សំណួរទី៥៖
# តើវាជាអំពើបាបទេ ក្នុងការមិនចូលចិត្ត គោលជំនឿនៃការជ្រើសតាំង?

*«ខ្ញុំជឿលើគោលជំនឿនៃការជ្រើសតាំង តែខ្ញុំមិនចូលចិត្តវា។ សម្រាប់ខ្ញុំ តើវាជាអំពើបាបទេ ក្នុងការមិនចូលចិត្តគោលជំនឿនៃការជ្រើសតាំង?»*

ខាងក្រោមនេះគឺជាចម្លើយ៖

វាគឺជាអំពើបាបក្នុងការមិនចូលចិត្តគោលជំនឿដ៏ពិតនៃការជ្រើសតាំង។ វាគឺជាអំពើបាបក្នុងការមិនចូលចិត្តនូវអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។

## ការស្រឡាញ់សេចក្ដីពិតដែលមានក្នុងព្រះគម្ពីរ

ខ្ញុំនឹងនិយាយបែបនេះដោយសារមានមនុស្សជាច្រើនមានគំនិតខុសៗ អំពីគោលជំនឿ—គោលជំនឿគ្រប់ប្រភេទ—ដែលមិនត្រឹមត្រូវ ហេតុដូច្នេះហើយបានជាចិត្តដ៏ល្អរបស់ពួកគាត់មិនចូលចិត្តវា។ ដូច្នេះ លោកអ្នកអាចលើកឡើងថា «ខ្ញុំមិនចូលចិត្តការជ្រើសតាំង» ហើយនៅអាចធ្វើជាមនុស្សល្អបាន ពីព្រោះលោកអ្នកមិនយល់ច្បាស់អំពីការជ្រើសតាំង។ ហើយអ្វីដែលលោកអ្នកកំពុងតែមិនចូលចិត្ត នោះលោកអ្នកគួរតែមិនចូលចិត្តវាវិញ។ ឬក៏ថា លោកអ្នកទំនងជាបុគ្គលដែលកំពុងតែចាប់ផ្ដើមយល់យ៉ាងច្បាស់លាស់ ហើយមនុស្សចាស់របស់លោកអ្នក ដែលអាក្រក់ កំពុងតែងើបឡើង ហើយក៏កំពុងតែមិនចូលចិត្តនូវអ្វីដែលគួរតែទទួលបានការចូលចិត្ត។ យើងខ្ញុំមិនដឹងថា តើបុគ្គលនេះគួរទទួលការណែនាំឬក៏អត់ទេ។ ដូច្នេះ នេះគឺជាគោលការណ៍៖ ដល់កម្រិតដែលលោកអ្នកយល់ឃើញយ៉ាងច្បាស់លាស់ថាសេចក្ដីពិតនោះមានចេញពីព្រះគម្ពីរ នោះលោកអ្នកគួរតែចូលចិត្តវា។

ឧទាហរណ៍៖ ស្ថាននរកគឺជាសេចក្ដីពិតដែលមានចែងក្នុងព្រះគម្ពីរ។

ដូច្នេះ នៅពេលដែលយើងខ្ញុំលើកឡើងថា លោកអ្នកគួរតែចូលចិត្តស្ថាននរក អ្វីដែលយើងខ្ញុំចង់មានន័យគឺដូចនេះ៖ លោកអ្នកគួរចូលចិត្តស្ថាននរកក្នុងរបៀបដែលព្រះជាម្ចាស់ពេញព្រះទ័យដែរ។ ព្រះអង្គមានព្រះបន្ទូលថា ទ្រង់មិនសព្វព្រះហឫទ័យឲ្យអ្នកណាមួយវិនាសឡើយ (២ពេត្រុស ៣:៩)។ ព្រះអង្គក៏មិនសព្វព្រះហឫទ័យឲ្យមនុស្សទុច្ចរិតស្លាប់ដែរ (អេសេគាល ១៨:២៣)។ ទ្រង់ធ្វើទុក្ខយើង ប៉ុន្តែមិនដោយស្ម័គ្រពីព្រះហឫទ័យទេ (បរិទេវ ៣:៣៣)។

**កញ្ចក់ពីរ**

ដូច្នេះ ក្នុងព្រះជាម្ចាស់ផ្ទាល់ ទ្រង់មានព្រះហឫទ័យឲ្យមានស្ថាននរក ហើយក៏សព្វព្រះហឫទ័យក្នុងការឲ្យមានវាក្នុងបែបជារូបភាពធំ ប៉ុន្តែស្របពេលតែមួយទ្រង់ក៏ព្រួយព្រះទ័យក្នុងការទម្លាក់នរណាម្នាក់ចូលវាដែរ។ ហើយពាក្យថាសព្វព្រះទ័យនៅត្រង់នេះពិបាកបន្តិចដែរ ពីព្រោះលោកអ្នកត្រូវតែមានទស្សនៈពីរយ៉ាង។

ប្រសិនបើព្រះជាម្ចាស់បានរៀបផែនការឲ្យស្តេច នេប៊ូក្នេសា បំផ្លាញទីក្រុងយេរូសាឡឹម តើយើងគួរចូលចិត្តការនោះដែរឬទេ? ចម្លើយរបស់យើងខ្ញុំគឺថា៖ យើងគួរ ហើយក៏មិនគួរផងដែរ។ យើងមិនគួរចូលចិត្តនៅពេលដែលស្ត្រីស្ងោរកូនរបស់ខ្លួន ប៉ុន្តែយើងគួរទទួលយកនូវពេលដែលព្រះជាម្ចាស់បានសម្រេចឲ្យការនោះកើតឡើង។ ហេតុដូច្នេះ យើងត្រូវមានទស្សនៈពីរយ៉ាង ត្រង់ថាទាក់ទងនឹងអ្វីដែលយើងឃើញក្នុងកញ្ចក់តូចយើងមិនគួរចូលចិត្តវានោះទេ តែក្នុងកញ្ចក់ធំយើងគួរចូលចិត្តវា ពីព្រោះនោះឯងគឺជារបៀបដែលព្រះជាម្ចាស់បណ្តាលឲ្យកើតឡើងលើផែនដីនេះ។



50 QnA John Piper Final 1.5.indd 38 25/01/2024 09:22:31 AM

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 39 25/01/2024 09:22:31 AM

# សំណួរទី៦៖
# តើខ្ញុំគួរអធិស្ឋានទៅកាន់ព្រះវរបិតា ព្រះយេស៊ូវ ឬក៏ព្រះវិញ្ញាណបរិសុទ្ធ?

*ថ្ងៃនេះយើងនឹងឆ្លើយនូវសំណួរដ៏ពិបាកមួយដែលមនុស្សជាច្រើនធ្លាប់បានសួរ៖ តើខ្ញុំគួរអធិស្ឋានទៅកាន់ព្រះយេស៊ូវ ព្រះវិញ្ញាណបរិសុទ្ធ ឬក៏ព្រះវរបិតា?*

យើងខ្ញុំពិតជាភ្ញាក់ផ្អើលមែនដែលជាច្រើនឆ្នាំកន្លងមកនេះមានមនុស្សជាច្រើនបានសួរនូវសំណួរនេះមកកាន់យើងខ្ញុំ។ នេះគឺជាសំណួរដ៏សាមញ្ញបំផុតមួយ ហើយក៏ជាសំណួរដ៏ល្អផងដែរ។ ហើយយើងខ្ញុំគិតថា យើងខ្ញុំយល់អំពីមូលហេតុដែលគេតែងតែសួរនូវសំណួរនេះជារឿយៗដែរ។ ពេលដែលយើងកំពុងតែធំធាត់ឡើង យើងក៏មានប្រពៃណីជាច្រើនដែរ ហើយពេលខ្លះយើងនឹងឆ្ងល់ថា តើប្រពៃណីនេះគឺជាប្រពៃណីដ៏ពិតតែមួយគត់មែនឬ?

ឧទាហរណ៍៖ មានមនុស្សជាច្រើនក្នុងក្រុមជំនុំគ្រីស្ទបរិស័ទទំនងជាបានចម្រើនពេញវ័យឡើងដោយចាប់ផ្តើមការអធិស្ឋានជាមួយនឹងពាក្យពេចន៍ «ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌...» ឬក៏ «ឱព្រះវរបិតានៃទូលបង្គំ...» ហើយបញ្ចប់ការអធិស្ឋានរបស់យើងជាមួយនឹងពាក្យពេចន៍ «ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន!» នេះគឺជាលំនាំដែលយើងបានរៀន។ ចាប់ផ្តើមអធិស្ឋានទៅកាន់ព្រះវរបិតា ហើយបញ្ចប់ការអធិស្ឋានក្នុងព្រះនាមរបស់ព្រះយេស៊ូវ។ អាម៉ែន។ យើងខ្ញុំនឹងពន្យល់អំពីមូលហេតុដែលថានេះគឺជាប្រពៃណីដ៏ល្អ។ យើងខ្ញុំជឿជាក់ថា កូនៗគួរចម្រើនពេញវ័យឡើងដោយយកលំនាំនេះជាលំនាំចម្បងក្នុងការអធិស្ឋាន។ ចាប់ផ្តើមដោយអធិស្ឋានទៅកាន់ព្រះវរបិតា ក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ក្នុងព្រះនាម និងអំណាចរបស់ព្រះរាជបុត្រា។ នេះគឺជាលំនាំដ៏សាមញ្ញនៃការអធិស្ឋានដែលមានមូលដ្ឋាន



50 QnA John Piper Final 1.5.indd 41 25/01/2024 09:22:31 AM

លើព្រះត្រៃឯក ដែលយើងឃើញមាននៅក្នុងព្រះគម្ពីរ។

## សូមផ្តោតលើព្រះវរបិតា

លំនាំមួយនេះមានឫសគល់យ៉ាងជ្រៅក្នុងព្រះបន្ទូល៖

“ដូច្នេះ ដែលមានសម្តេចសង្ឃយ៉ាងធំ១អង្គ ដែលទ្រង់បានយាងកាត់អស់ទាំងជាន់ស្ថានសួគ៌ គឺព្រះ យេស៊ូវជាព្រះរាជបុត្រានៃព្រះ នោះត្រូវតែឲ្យយើងមានចិត្តដាច់ស្រេចនឹងជឿតាមចុះ ដ្បិតសម្តេច សង្ឃនៃយើង ទ្រង់មិនមែនមិនអាចនឹងអាណិតអាសូរ ដល់សេចក្តីកម្សោយរបស់យើងរាល់គ្នានោះទេ ព្រោះទ្រង់បានត្រូវសេចក្តីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបាបឡើយ ដូច្នេះ ត្រូវឲ្យ យើងរាល់គ្នា មកដល់បល្ល័ង្កនៃព្រះគុណ ដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបាន ព្រះគុណសម្រាប់នឹងជួយដល់ពេលត្រូវការចុះ” (ហេព្រើរ ៤:១៤-១៦)។

យើងអាចចូលទៅកាន់ព្រះជាម្ចាស់ក្នុងការអធិស្ឋានតាមតែរយៈការទទូចសូមព្រះគុណប៉ុណ្ណោះ។ នេះដោយសារយើងមានព្រះយេស៊ូវជាសម្តេចសង្ឃ។ ហើយនេះជាមូលហេតុដែលយើងអធិស្ឋានក្នុងព្រះនាមរបស់ព្រះយេស៊ូវ។ យើងខ្ញុំព្យាយាមបង្រៀនកូនៗរបស់យើងខ្ញុំថា កុំឲ្យប្រើប្រាស់ឃ្លា “ក្នុងព្រះនាមព្រះយេស៊ូវ អាម៉ែន” ក្នុងលក្ខណៈជាការបញ្ចប់សេចក្តីអធិស្ឋានជាមួយនឹងពាក្យមិនមានតម្លៃ។ យើងខ្ញុំព្យាយាមបង្រៀនកូនៗកុំឲ្យនិយាយរអ៊ូរទាំៗនូវពាក្យពេចន៍ទាំងនោះ ហើយកុំឲ្យឆាប់បញ្ចប់ដោយពាក្យពេចន៍ទាំងនោះដែរ។ ពាក្យពេចន៍ទាំងនេះលើកឡើងនូវអ្វីដែលអស្ចារ្យហើយសំខាន់។ យើងមិនអាចចូលទៅកាន់ព្រះជាម្ចាស់បានដោយគ្មានព្រះយេស៊ូវគ្រីស្ទ និងព្រះនាមរបស់ទ្រង់បានឡើយ។ នៅពេលដែលយើងអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវ គឺយើងកំពុងតែទូលទៅកាន់ព្រះវរបិតាថា “ទូលបង្គំមិនមែនកំពុងចូលទៅកាន់ព្រះអង្គក្នុងឈ្មោះរបស់ខ្លួនឯងឡើយ។



50 QnA John Piper Final 1.5.indd 42 25/01/2024 09:22:32 AM

ទូលបង្គំមិនមែនកំពុងចូលទៅកាន់ព្រះអង្គដោយពឹងលើទង្វើរបស់ខ្លួនទេ។ ទូលបង្គំមិនមែនកំពុងចូលទៅកាន់ព្រះអង្គដោយពឹងលើភាពស័ក្តិសមរបស់ខ្លួនដែរ។ ទូលបង្គំតែកំពុងចូលទៅកាន់ព្រះអង្គដោយសារព្រះគ្រីស្ទស្រឡាញ់ទូលបង្គំវិញ។ ព្រះគ្រីស្ទបានសុគតសម្រាប់ទូលបង្គំទៀតផង។ ព្រះគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញសម្រាប់ទូលបង្គំ។ ព្រះគ្រីស្ទកំពុងទូលអង្វរសម្រាប់ទូលបង្គំ»។ នេះគឺជាអត្ថន័យនៃពាក្យពេចន៍ដ៏តូចតាចទាំងនេះ។ វាគឺជាការដ៏សំខាន់ណាស់។

សាវ័ក ប៉ុល ក៏បានលើកឡើងអំពីព្រះវិញ្ញាណបរិសុទ្ធក្នុងកណ្ឌគម្ពីរ (អេភេសូរ ៦:១៨) ថា៖ «អធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា»។ ឬក៏នៅក្នុងកណ្ឌគម្ពីរ (យូដាស ១:២០) «ប៉ុន្តែ ឯអ្នករាល់គ្នា ជាពួកស្ងួនភ្ងាអើយ ចូររក្សាខ្លួនក្នុងសេចក្ដីស្រឡាញ់របស់ព្រះចុះ ព្រមទាំងរង់ចាំសេចក្ដីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ឲ្យបានជីវិតអស់កល្បជានិច្ចវិញ»។ ដួងចិត្តរបស់យើងខ្ញុំនឹងមិនដែលមានសេចក្ដីប្រាថ្នាអធិស្ឋានទៅកាន់ព្រះជាម្ចាស់សម្រាប់ព្រះពរដ៏ពិតដោយគ្មានការបន្ទាបខ្លួន ការបំផ្លាស់បំប្រែ ព័ន្ធកិច្ចនៃការទទួលបានជំនឿពីព្រះវិញ្ញាណបរិសុទ្ធឡើយ។ ដូច្នេះ យើងខ្ញុំសូមលន់តួអំពីចំណុចនេះ។ យើងខ្ញុំលើកឡើងចំណុចនេះទៅកាន់ព្រះអម្ចាស់ និងមកកាន់ខ្លួនឯង។ យើងខ្ញុំពឹងលើព្រះវិញ្ញាណបរិសុទ្ធនៅពេលដែលយើងខ្ញុំអធិស្ឋានទៅកាន់ព្រះវរបិតាក្នុងព្រះនាមព្រះរាជបុត្រា។ ហើយពិតណាស់ ព្រះយេស៊ូវបានលើកឡើងយ៉ាងច្បាស់លាស់នៅក្នុងកណ្ឌគម្ពីរ (យ៉ូហាន ១៥:១៦) ថា «ដើម្បីឲ្យព្រះវរបិតាបានប្រោសប្រទានឲ្យអ្នករាល់គ្នាបានអ្វីៗ ដែលនឹងសូមពីទ្រង់ ដោយនូវឈ្មោះខ្ញុំ»។



50 QnA John Piper Final 1.5.indd 43 25/01/2024 09:22:32 AM

## កុំភ្លេចព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ

នេះគឺជាប្រពៃណីដ៏ល្អ និងត្រឹមត្រូវ។ អាម៉ែន។ ប៉ុន្តែ វាក៏ជាការល្អ និងត្រឹមត្រូវក្នុងការអធិស្ឋានទៅកាន់ព្រះយេស៊ូវក្នុងនាមជាមិត្តភក្តិរបស់លោកអ្នក ជាព្រះអង្គសង្គ្រោះ ជាព្រះអម្ចាស់ និងជាអ្នកណែនាំលោកអ្នកដែរ។ ហើយ វាក៏ជាការល្អ និងត្រឹមត្រូវក្នុងការអធិស្ឋានទៅកាន់ព្រះវិញ្ញាណបរិសុទ្ធដែរ។ ក្នុងកណ្ឌគម្ពីរ (យ៉ូហាន ១៤:១៤) ព្រះយេស៊ូវបានមានបន្ទូលថា៖ «បើអ្នករាល់គ្នានឹងសូមអ្វី ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំនឹងសម្រេចឲ្យ»។ ហើយនៅក្នុងកណ្ឌគម្ពីរ (វិវរណៈ ២២:២០)៖ ហើយយើងកំពុងតែអធិស្ឋានទៅកាន់ព្រះយេស៊ូវនៅពេលដែលយើងលើកឡើងថា «ព្រះអង្គ ដែលធ្វើបន្ទាល់ពីសេចក្តីទាំងនេះ ទ្រង់មានព្រះបន្ទូលថា អើ អញមកជាឆាប់»។ ហើយយើងឆ្លើយតបវិញថា «អាម៉ែន ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក»។ ដូចគ្នាផងដែរនៅក្នុងកណ្ឌគម្ពីរ (១កូរិនថូស ១៦:២២) «បើអ្នកណាមិនស្រឡាញ់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ឲ្យអ្នកនោះត្រូវបណ្តាសាចុះ»។ ហើយបន្ទាប់មក យើងឆ្លើយតបទៅកាន់ព្រះអម្ចាស់ថា «ព្រះអម្ចាស់ទ្រង់យាងមក»។

ដូចគ្នាផងដែរ យើងខ្ញុំជឿជាក់ថា នៅពេលដែលយើងខ្ញុំធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធព្រួយព្រះទ័យ នោះយើងខ្ញុំគួរសុំទោសព្រះវិញ្ញាណបរិសុទ្ធ (អេភេសូរ ៤:៣០)។ ប្រសិនបើព្រះវិញ្ញាណបរិសុទ្ធគឺជាអង្គបុគ្គលដែលយើងខ្ញុំបានធ្វើឲ្យព្រួយព្រះទ័យ នោះតើយើងខ្ញុំគ្រាន់តែមិនអើពើដោយអធិស្ឋានទៅកាន់ព្រះអង្គ ហើយអធិស្ឋានទៅកាន់ព្រះវរបិតាវិញមែនឬ? តើយើងខ្ញុំគួរអធិស្ឋានទៅកាន់ព្រះវរបិតាថា៖ ទូលបង្គំសុំទោសដែលទូលបង្គំបានធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ព្រួយព្រះទ័យ? យើងខ្ញុំគិតថា យើងអាចអនុញ្ញាតចំណុចនេះបាន ប៉ុន្តែមានចំណុចដ៏ជ្រាលជ្រៅក្នុងសេចក្តីពិតនៃព្រះត្រៃឯក និងបុគ្គលភាពនៃព្រះរាជបុត្រា និងព្រះវិញ្ញាណ។ ដូច្នេះ យើងគួរចាត់ទុកអង្គបុគ្គលនីមួយៗថាជាបុគ្គល។



50 QnA John Piper Final 1.5.indd 44 25/01/2024 09:22:32 AM

សេចក្ដីសន្និដ្ឋានរបស់យើងខ្ញុំគឺដូចនេះ៖ សូមឲ្យការអធិស្ឋានជាប្រចាំ និងសាមញ្ញរបស់លោកអ្នកជាការអធិស្ឋានទៅកាន់ព្រះវរបិតាតាមរយៈ ព្រះវិញ្ញាណក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ប៉ុន្តែ ក៏សូមចងចាំថា ដែល ព្រះយេស៊ូវ និងព្រះវិញ្ញាណបរិសុទ្ធគឺជាបុគ្គល។ ក្នុងនាមជាមនុស្សមាន បាប វាជារឿងធម្មតាទេក្នុងការអធិស្ឋានទៅកាន់បុគ្គលទាំងបីអង្គ។

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 45 25/01/2024 09:22:32 AM

## សំណួរទី៧៖
# តើលោកគ្រូមានយោបល់អ្វីទាក់ទងនឹងថ្ងៃបុណ្យហាឡូវីន?

*សំណួរមួយនេះប្រៀបដូចជាសំណួរដែលផ្ដោតទៅលើសំណួរដែលថា៖ “តើលោកអ្នកឃើញព្រះគ្រីស្ទជំទាស់នឹងប្រពៃណី ឃើញព្រះគ្រីស្ទក្នុងប្រពៃណី ឬក៏ឃើញព្រះគ្រីស្ទនៅលើប្រពៃណីដែរឬទេ?”*

យើងខ្ញុំគិតថា ក្នុងក្រុមជំនុំនៅប្រទេសយើងមានមនុស្សជាច្រើននាក់ដែលមានយោបល់ខុសៗគ្នាលើសំណួរនេះ។

មានមនុស្សមួយចំនួនបានលើកឡើងថា “យើងមិនចង់មានអ្វីពាក់ព័ន្ធជាមួយនឹងថ្ងៃបុណ្យអារក្សដូចនេះទេ! ហេតុអ្វីបានជាលោកអ្នកចង់ទៅពាក់ព័ន្ធជាមួយនឹងការនេះ?”។ ហើយក៏នឹងនៅមានមនុស្សមួយចំនួនទៀតដែលនឹងស្លៀកពាក់ខោអាវឲ្យកូនៗរបស់ខ្លួនដូចជាមានរូបមេអំបៅ ហើយទៅដើរគោះទ្វារអ្នកជិតខាងសុំស្ករគ្រាប់! ហើយក៏មានមនុស្សមានជំហរនៅកណ្ដាលដែលបង្កើតព្រឹត្តិការណ៍ទាស់ប្រឆាំង ដោយពួកគាត់ស្លៀកជាតួឯកក្នុងព្រះគម្ពីរ ហើយក៏មានពេលវេលាយ៉ាងសប្បាយដែរ។

យើងខ្ញុំមិនមានបញ្ហាជាមួយនឹងទស្សនៈកណ្ដាល និងទស្សនៈដំបូងទេ។ ហើយក៏មិនសូវមានបញ្ហាជាមួយទស្សនៈទីពីរដែរ។ យើងខ្ញុំក៏ធ្លាប់ដើរសុំស្ករគ្រាប់អ្នកជិតខាងយើងខ្ញុំកាលនៅក្មេងនៅថ្ងៃបុណ្យនេះដែរ។

តំបន់ដែលយើងខ្ញុំរស់នៅក៏មិនសូវជាហ៊ឹកហ៊ាក់ប៉ុន្មានដែរ ពីព្រោះគ្រួសាររបស់យើងខ្ញុំរស់នៅឯជនបទ ដូច្នេះវាមិនសូវជាធំដុំប៉ុន្មានក្នុងការទៅគោះទ្វារអ្នកជិតខាងសុំស្ករគ្រាប់នោះទេ។ ដោយសារមូលហេតុនេះ នោះយើងក៏មិនសូវជាទទួលបានស្ករគ្រាប់ឆ្ងាញ់នោះដែរ។ ប្រសិនបើយើងចង់បាន



50 QnA John Piper Final 1.5.indd 47 25/01/2024 09:22:33 AM

ទទួលបានស្កុរគ្រាប់ឆ្ងាញ់ នោះយើងត្រូវចូលទៅទីក្រុង។

ដូច្នេះ អ្វីដែលយើងខ្ញុំសង្ឃឹមគឺថាឲ្យគ្រីស្ទបរិស័ទគ្រប់រូបគិតដោយមានការប្រុងប្រយ័ត្ន និងដោយសម្អាងលើព្រះគម្ពីរទាក់ទងទៅនឹងថ្ងៃបុណ្យ ព្រឹត្តិការណ៍ និងអំពីរបៀបដែលថា ខ្លួនអាចធ្វើជាអំបិល និងពន្លឺក្នុងពេលវេលានោះបានយ៉ាងដូចម្ដេច។ ហើយប្រសិនបើពួកគេគិតថា ព្រឹត្តិការណ៍មួយនេះអាចជាមេរៀនដ៏មានតម្លៃមួយសម្រាប់កូនៗក្នុងរបៀបណាមួយ ដើម្បីនឹងបង្រៀនពួកគេ—ប្រសិនបើវាអាចជារបៀបដែលគ្មានកំហុសក្នុងការមានអំណរក្នុងព្រះគុណរបស់ព្រះជាម្ចាស់ និងការបង្រៀនពួកគេ—ចូរប្រារព្ធចុះ។

យើងខ្ញុំហ៊ានប្រារព្ធពិធីមួយចំនួនក្នុងលោកីយ៍នេះ ដើម្បីមានភាពស្មោះត្រង់ជាមួយនឹងព្រះគម្ពីរក្នុងការធ្វើជាស្មរបន្ទាល់។ គំនិតបែបនេះក៏គួរមានដូចគ្នាចំពោះថ្ងៃបុណ្យណូអែល ខួបកំណើត នៅថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ និងថ្ងៃថ្វាយបង្គំនៅថ្ងៃអាទិត្យ។ ទាំងនេះសុទ្ធតែមានការពាក់ព័ន្ធជាមួយនឹងសាសនាខុសឆ្គង។

យើងខ្ញុំចង់មានភាពធូររលុង និងទូលំទូលាយ ហើយផ្ដល់សេរីភាពទៅកាន់អ្នកជឿក្នុងការរស់នៅក្នុងរបៀបឲ្យកាន់តែមានប្រសិទ្ធភាព។ ដូច្នេះ យើងខ្ញុំក៏គោរពអ្នកដែលបោះបង់ចោលដោយមិនចង់មានការពាក់ព័ន្ធជាមួយនឹងអំពើអាក្រក់ ហើយយើងខ្ញុំក៏គោរពអស់អ្នកដែលនិយាយថា «ទេ! ចូរយើងសង្គ្រោះវា ប្រជ្រៀតចូលវា ហើយប្រើប្រាស់វាចុះ» ដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 48 25/01/2024 09:22:33 AM

## សំណួរទី៨៖
# តើអ្វីទៅធ្វើឲ្យថ្ងៃដែលព្រះអង្គមាន ព្រះជន្មរស់ឡើងវិញពិសេសម្ល៉េះ?

*លោកគ្រូ តើអ្វីទៅជាអត្ថន័យសំខាន់ៗទាក់ទងនឹងថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ?*

ព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ដែលបានយាងមកផែនដីនេះពីព្រះវរបិតា បានប្រសូតពីនាងក្រមុំព្រហ្មចារី បានមានព្រះជន្មរស់នៅដោយគ្មានអំពើបាប និងបានធ្វើការអស្ចារ្យជាច្រើន ព្រមទាំងបានស្រឡាញ់មនុស្សទាំងអស់ គឺជាព្រះដែលគេបានឆ្កាងទ្រង់ជំនួសអំពើបាបរបស់យើង ហើយនៅថ្ងៃទី៣—គឺថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ ជាការប្រារព្ធអបអរសាទរនៅថ្ងៃអាទិត្យនោះ—ព្រះវរបិតាក៏បានប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយមិនឲ្យសុគតជាថ្មីម្តងទៀតទេ។

ហើយដូចដែលលោក លូកា បានប្រាប់យើង បន្ទាប់ពីគាត់បានធ្វើការស្រាវជ្រាវខាងផ្នែកប្រវត្តិសាស្ត្ររួចស្រេចអស់ហើយថា អស់រយៈពេល៤០ថ្ងៃ ព្រះយេស៊ូវបានប្រទាននូវភស្តុតាងជាច្រើន ហើយសាវ័ក ប៉ុល ផ្ទាល់ (ដែលបានក្លាយជាសាវ័កក្រោយគេបង្អស់) ក៏បានលើកឡើងផងដែរថា មានមនុស្ស៥០០នាក់ជាងបានឃើញព្រះយេស៊ូវបន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយក៏នៅមានអ្នកខ្លះនៅរស់ដែរ ប្រសិនបើមានអ្នកចង់ទៅនិយាយសួរនាំ (១កូរិនថូស ១៥:៦)។ នេះគឺជាភស្តុតាងប្រវត្តិសាស្ត្រដែលពួកគាត់មាន។

ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញខាងឯសាច់ឈាមផ្ទាល់។ ពួកគាត់បានស្គាល់ទ្រង់។ ពួកគាត់អាចយកដៃខ្លួនទៅប៉ះរបួសរបស់ទ្រង់បាន។



50 QnA John Piper Final 1.5.indd 49 25/01/2024 09:22:33 AM

ព្រះអង្គបានសោយសាច់ត្រីនៅពីមុខពួកគាត់ ដើម្បីបង្ហាញថាវិញ្ញាណ ឬក៏ខ្មោចមិនមានសាច់ឈាមដូចដែលពួកគាត់បានឃើញថាទ្រង់មាននោះទេ (លូកា ២៤:៣៩)។ ហើយទោះជាយ៉ាងណាក៏ដោយ ក៏វាលើសពីសាច់ឈាមផងដែរ ពីព្រោះព្រះអង្គបានទៅហើយនិងមក តាមតែព្រះហឫទ័យរបស់ទ្រង់ សូម្បីតែទ្វារជាប់សោក៏មិនអាចឃាំងទ្រង់បានដែរ។ ហើយក៏មានទិដ្ឋភាពថ្មីចម្លែកអំពីព្រះកាយរបស់ទ្រង់ដែរ។

ព្រះអង្គបានយាងទៅកាន់ខាងស្ដាំព្រះហស្តរបស់ព្រះវរបិតា។ ព្រះអង្គគង់នៅឯបល្ល័ង្កជាមួយនឹងព្រះជាម្ចាស់។ ព្រះអង្គទទូចអង្វរជំនួសយើងនៅទីនោះ ដោយអធិស្ឋានជំនួសរាស្ត្ររបស់ទ្រង់ជារៀងរាល់ថ្ងៃ។ ព្រះអង្គកំពុងតែសោយរាជ្យរហូតទាល់តែទ្រង់បានដាក់ខ្មាំងសត្រូវរបស់ទ្រង់ក្រោមព្រះបាទារបស់ទ្រង់។ កណ្ឌគម្ពីរម៉ាថាយបានលើកឡើងថា ព្រះអង្គមានគ្រប់អំណាចនៅលើផែនដី និងស្ថានសួគ៌ (ម៉ាថាយ ២៨:១៨)។ ព្រះអង្គនឹងមិនដែលសុគតជាម្ដងទៀតឡើយ។ ព្រះអង្គក៏មានកូនសោនៃសេចក្ដីស្លាប់ និងស្ថាននរកនៅក្នុងព្រះហស្តរបស់ទ្រង់។

**ហេតុអ្វីបានជាថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញសំខាន់ម្ល៉េះ?**

ជាការចាប់ផ្ដើម ពីព្រោះនោះជាព្រឹត្តិការណ៍ដែលបានកើតឡើងមែន។ ដូច្នេះ សំណួរសួរថា៖ តើអ្វីទៅជាការអនុវត្តសម្រាប់យើង ទាក់ទងនឹងអំណះអំណាងដ៏ភ្ញាក់ផ្អើលនេះ និងចំណុចពិតនៃថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ?

ការដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញមានន័យថា អំពើបាបរបស់ខ្ញុំបានទទួលការអត់ទោស។ សាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ (១កូរិនថូស ១៥:១៧) ថាប្រសិនបើព្រះគ្រីស្ទមិនបានមានព្រះជន្មរស់ឡើងវិញទេ នោះមានន័យថា យើងនៅជាប់ក្នុងអំពើបាបរបស់យើងនៅ



50 QnA John Piper Final 1.5.indd 50 25/01/2024 09:22:33 AM

ឡើយ។ ដែលនេះបង្ហាញថា ប្រសិនបើព្រះអង្គ*ពិតជាបាន*មានព្រះជន្មរស់ឡើងវិញមែន នោះបញ្ហានៃអំពើបាបរបស់យើងបានឈានដល់ទីបញ្ចប់ហើយ។ ហើយវាដូច្នោះមែន ពីព្រោះការមានព្រះជន្មរស់ឡើងវិញបង្ហាញថាគ្មានទោស ទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅថ្ងៃសុក្រដ៏ល្អ ដែលសំដៅទៅលើការសុគតរបស់ទ្រង់។ ការសុគតរបស់ទ្រង់ពិតជាបានគ្របបាំងអំពើបាបរបស់រាស្ត្រទ្រង់មែន។ ការនោះពិតជាបានប្រទាននូវសេចក្ដីសុចរិតដ៏ល្អឥតខ្ចោះសម្រាប់យើងមែន។

ដូចដែលបានលើកឡើងក្នុងកណ្ឌគម្ពីរ រ៉ូម ៤:២៥ «ទ្រង់ត្រូវគេបញ្ជូនទៅ»—ដែលនេះសំដៅទៅលើឈើឆ្កាង—«ឲ្យមានទោស ដោយព្រោះអំពើរំលងរបស់យើងរាល់គ្នា  ហើយបានប្រោសឲ្យមានព្រះជន្មរស់ឡើងវិញប្រយោជន៍ឲ្យយើងរាល់គ្នាបានរាប់ជាសុចរិត» ដែលនេះមានន័យថា ដូចដែលអំពើបាបរបស់យើងបាននាំទ្រង់ទៅកាន់ឈើឆ្កាង នោះកិច្ចការដែលទ្រង់បានសម្រេច ដើម្បីដោះស្រាយអំពើបាបរបស់យើង បាននាំឲ្យទ្រង់ចេញពីផ្នូរវិញ។ ហាក់បីដូចជាថាព្រះអង្គបានទតមើល ហើយមានបន្ទូលថា «កិច្ចការនៃបុត្រារបស់អញគឺល្អឥតខ្ចោះ។ បុត្រារបស់អញនឹងមិនបន្តនៅក្នុងផ្នូរទៀតទេ»។ ហើយព្រះអង្គក៏បានប្រោសឲ្យទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញ ដើម្បីបង្ហាញថាលែងមានទោសទៀត ទាក់ទងនឹងអ្វីដែលទ្រង់បានសម្រេចទាំងអស់សម្រាប់យើង។

ដូច្នេះ ជាការអនុវត្ត ចំណុចមួយដែលលោកអ្នកអាចលើកឡើងអំពីថ្ងៃដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញគឺថារៀងរាល់ថ្ងៃ៖ សេចក្ដីសន្យារបស់ព្រះជាម្ចាស់មកកាន់ខ្ញុំ គឺដើម្បីជួយខ្ញុំក្នុងរាល់គ្រប់នាទីនៃជីវិតរបស់ខ្ញុំ មានការធានាតាមរយៈការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ដោយសារការមានព្រះជន្មរស់ឡើងវិញបង្ហាញថាឈើឆ្កាងគ្មានទោសទៀតទេ នៅពេលដែលព្រះអង្គបានទិញសេចក្ដីសន្យានោះសម្រាប់ខ្ញុំ។



50 QnA John Piper Final 1.5.indd   51    25/01/2024   09:22:34 AM

ដោយសារព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ កណ្ឌគម្ពីរ (ភីលីព ៣:២០-២១) បានលើកឡើងដោយថា ព្រះយេស៊ូវនឹងប្រទានមកកាន់ខ្ញុំនូវរូបកាយដូចជាព្រះកាយដែលព្រះអង្គបានមាន បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញ។ នៅពេលដែលខ្ញុំស្លាប់ ហើយព្រះអង្គបានប្រោសឲ្យខ្ញុំរស់ពីស្លាប់ឡើងវិញ នៅពេលដែលទ្រង់យាងមកជាលើកទី២ នោះព្រះគ្រីស្ទនឹងប្រទានមកកាន់ខ្ញុំនូវរូបកាយដូចជាព្រះកាយដ៏អស្ចារ្យរបស់ទ្រង់ដែរ។ ដូច្នេះ ព្រះកាយដែលព្រះយេស៊ូវមាន បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញគឺជារូបកាយដំបូង ជាផលផ្លែដំបូង និងជាប្រភេទនៃរូបកាយដែលរាស្ត្ររបស់ទ្រង់ទាំងអស់នឹងទទួលបាន។

ហើយបន្ទាប់មកទៀត ហាក់បីដូចជាថាចំណុចនោះមិនអស្ចារ្យល្អល្មមគ្រប់គ្រាន់ នោះកណ្ឌគម្ពីរ (រ៉ូម ៨:២១) ក៏បានបន្តថែងទៀតថា នៅពេលដែល «សេរីភាពនៃសិរីល្អរបស់ពួកកូនព្រះ» ឈានមកដល់ ហើយពួកគាត់ទទួលបានការប្រោសឲ្យរស់ឡើងវិញពីស្លាប់ ហើយទទួលបានរូបកាយដែលពេញដោយសិរីល្អ នោះក៏នឹងមានការបង្កើតផ្ទៃមេឃ និងផែនដីថ្មីដែលសមរម្យសម្រាប់ជាកន្លែងលេងមួយសម្រាប់យើង ដែលទទួលបានរូបកាយថ្មីដែលនឹងមិនប្រព្រឹត្តអំពើបាបទៀត ដែលនឹងមិនចេះឈឺទៀត ហើយគ្រប់ទឹកភ្នែកក៏នឹងត្រូវបានជូតចេញដែរ។

ចំណុចអនុវត្តទាក់ទងនឹងថ្ងៃដែលព្រះអង្គបានមានព្រះជន្មរស់ឡើងវិញគឺពិតជាអស្ចារ្យមែន។ ចំណុចអនុវត្តនោះមានតម្លៃ*ផ្ទាល់* ទាក់ទងនឹងជីវិតរស់នៅជាប្រចាំថ្ងៃ នៅពេលដែលយើងមានការលំបាក ហើយក៏មានតម្លៃសម្រាប់ពិភពលោកទាំងមូលផងដែរ សូម្បីតែសម្រាប់*ចក្រវាល*ទាំងមូលក៏មានតម្លៃ ពីព្រោះការដែលព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញធានាថា អ្វីៗទាំងអស់នឹងត្រូវបានបង្កើតឡើងជាថ្មី។

**ការមានព្រះជន្មរស់ឡើងវិញគឺជាចំណុចពឹងផ្អែកលើទាំងស្រុង**

*ដូច្នេះ គ្រប់អ្វីៗទាំងអស់គឺសុទ្ធតែពឹងផ្អែកលើចំណុចពិតនៃការដែលព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ។*

នេះហើយជាមូលហេតុនៃកណ្ឌគម្ពីរ (១កូរិនថូស ១៥:១៧) និងអ្វីដែលមានជាបន្តបន្ទាប់។ ប្រសិនបើព្រះជាម្ចាស់មិនបានប្រោសព្រះគ្រីស្ទឲ្យបានមានព្រះជន្មរស់ឡើងវិញ នោះដំណឹងល្អរបស់យើងគឺជាការឥតអំពើ ជំនឿរបស់យើងគឺជាការឥតអំពើ ដែលនេះមានន័យថា យើងកំពុងតែប្រកាសដំណឹងក្លែងក្លាយ។ បើដូច្នោះមែន នោះយើងគួរតែស៊ីផឹក ហើយអរសប្បាយចុះ ដ្បិតថ្ងៃស្អែកយើងនឹងស្លាប់។ សាវ័ក ប៉ុល ដាក់ការទុកចិត្តទាំងស្រុងរបស់គាត់លើចំណុចនោះ។ ប្រសិនបើព្រឹត្តិការណ៍នោះមិនបានកើតឡើងខាងឯសាច់ឈាមជាអចិន្ត្រៃយ៍មែន នោះជំនឿគ្រីស្ទបរិស័ទគឺជាការបំផ្លើស។ ហើយអ្វីដែលយើងនៅអាចធ្វើបាននោះគឺ ឈប់ធ្វើការ ហើយស៊ីផឹករហូតដល់ថ្ងៃស្លាប់ចុះ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 53 25/01/2024 09:22:34 AM

50 QnA John Piper Final 1.5.indd 54 25/01/2024 09:22:34 AM

# សំណួរទី៩៖
# តើការរក្សាថ្ងៃសប្ប័ទឲ្យបានបរិសុទ្ធ មានន័យយ៉ាងដូចម្ដេច?

យើងខ្ញុំគិតថា ចំណុចនេះពាក់ព័ន្ធទៅនឹងសតិសម្បជញ្ញៈផ្ទាល់ខ្លួន។ ហើយវាគួរតែបែបនោះ។ ប៉ុន្តែ នេះមិនមែនមានន័យថា វាមិនមានអត្ថន័យ ឬក៏ការណែនាំក្នុងព្រះគម្ពីរនោះទេ។

សំណួរដ៏ធំទាក់ទងទៅនឹងថ្ងៃសប្ប័ទគឺថា តើព្រះគម្ពីរសញ្ញាថ្មីបាន ឬក៏មិនបានបញ្ជាឲ្យយើងរក្សាថ្ងៃសប្ប័ទឲ្យបានបរិសុទ្ធក្នុងរបៀបដូចដែលព្រះគម្ពីរសញ្ញាចាស់បានបញ្ជា។

វាគឺជាបទល្មើសមូលធនក្នុងព្រះគម្ពីរសញ្ញាចាស់។ ដោយគ្រាន់តែលី ឬក៏កាន់មែកឈើនៅថ្ងៃសប្ប័ទ លោកអ្នកអាចទទួលការប្រហារជីវិតចោល។

យើងខ្ញុំនឹងមិនអើពើលើបញ្ហានៃថ្ងៃអាទិត្យ នឹងថ្ងៃសៅរ៍នោះទេ ដោយគ្រាន់តែសន្មតថាវាមិនមែនជាសំណួរតែម្ដង។ ថ្ងៃអាទិត្យគឺជាថ្ងៃសប្ប័ទសម្រាប់គ្រីស្ទបរិស័ទ ជាថ្ងៃនៃព្រះអម្ចាស់ ថ្ងៃដែលព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ។ ហើយយើងខ្ញុំក៏ឯកភាពជាមួយនឹងប្រយោគនេះដែរ។ យើងខ្ញុំគិតថា អស់អ្នកដែលថ្វាយបង្គំនៅថ្ងៃសៅរ៍គឺកំពុងតែមានការយល់ដឹងខុស ហើយលើថ្ងៃនៃព្រះអម្ចាស់ ថ្ងៃដែលព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងពីសុគតវិញ គឺជាថ្ងៃដែលក្រុមជំនុំដំបូងបានកត់សម្គាល់ថាជាថ្ងៃបរិសុទ្ធនៃដើមអាទិត្យ។

ដូច្នេះ សំណួរសួរថា តើព្រះអម្ចាស់មានព្រះទ័យយ៉ាងដូចម្ដេចសម្រាប់ថ្ងៃដែលព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ សម្រាប់ថ្ងៃអាទិត្យ ដូចដែលមានបើកសម្ដែងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី?



50 QnA John Piper Final 1.5.indd 55 25/01/2024 09:22:34 AM

ចំពោះយើងខ្ញុំកណ្ឌគម្ពីរ (រ៉ូមជំពូក១៤) គឺសំខាន់ណាស់ដោយសារក្នុងជំពូកនេះ យើងឃើញថាហាក់ដូចជាមិនមានការឯកភាពគ្នាក្នុងក្រុមជំនុំ។ បុគ្គលម្នាក់ប្រារព្ធថ្ងៃមួយ ហើយបុគ្គលម្នាក់ទៀតរាប់ថ្ងៃទាំងអស់ថាដូចគ្នា។ សូមកត់សម្គាល់ត្រង់ថា ជំពូកនោះមិនបានលើកឡើងយ៉ាងចំៗអំពីបញ្ហាលើថ្ងៃសប្ប័ទទេ។ វាអាចជាថ្ងៃឈប់សម្រាកណាផ្សេងទៀតក៏ថាបាន។ ប៉ុន្តែបានលើកឡើងថា «ម្នាក់រាប់ថា ថ្ងៃ១ល្អជាងថ្ងៃ១ ម្នាក់ទៀតរាប់ថា ថ្ងៃណាក៏ដូចជាថ្ងៃណា» ដែរ (រ៉ូម ១៤:៥)។

យើងខ្ញុំចងចាំអំពីការសន្ទនាមួយនេះជាមួយនឹងសាស្ត្រាចារ្យព្រះគម្ពីរសញ្ញាចាស់ម្នាក់ ហើយគាត់បានលើកឡើងថា ខនេះមិនបានលើកឡើងថាបុគ្គលម្នាក់បានរាប់ «ថ្ងៃទាំងអស់ទាក់ទិននឹងសាសនាទេ» ប៉ុន្តែទំនងថា «ថ្ងៃទាំងអស់គឺបរិសុទ្ធ»។ ហើយយើងខ្ញុំក៏បានតបថា «ពិតណាស់! នេះជាអ្វីដែលខ្ញុំបានសន្មត់អំពីអត្ថន័យ។» និយាយម្យ៉ាងវិញទៀតទៅ រាល់ថ្ងៃនៃសប្តាហ៍ទាំងអស់គឺបរិសុទ្ធចំពោះព្រះអម្ចាស់សម្រាប់មនុស្សមួយចំនួនក្នុងកណ្ឌគម្ពីររ៉ូម ហើយអ្នកផ្សេងក៏បានតបវិញថា «ពិតណាស់! ប៉ុន្តែ ថ្ងៃមួយនេះគឺបរិសុទ្ធជាង។»

មើលទៅហាក់បីដូចជាថាមិនមានការឯកភាពគ្នា។ ហើយរបៀបដំណោះស្រាយរបស់សាវ័ក ប៉ុល ទាក់ទងទៅនឹងការមិនឯកភាពគ្នាគឺថា គាត់មិនកាន់ជើងអ្នកណានោះទេ។ នោះគឺជាអ្វីដែលធ្វើឲ្យវាសំខាន់៖ គឺគាត់បានលើកឡើងថា «អ្នកណាដែលប្រកាន់ថ្ងៃណា នោះក៏ប្រកាន់ដោយគោរពដល់ព្រះអម្ចាស់ ហើយអ្នកណាដែលមិនប្រកាន់ថ្ងៃណា នោះក៏មិនប្រកាន់ដោយគោរពដល់ព្រះអម្ចាស់ដែរ»។

នោះគឺជាចំណុចដ៏សំខាន់ណាស់ ពីព្រោះយើងខ្ញុំគិតថា មនុស្សដែលមិនគិតអំពីថ្ងៃនៃព្រះអម្ចាស់ ឬក៏ធ្វើអ្វីមួយដើម្បីធ្វើឲ្យថ្ងៃនោះពិសេសក៏ទំនងមិនធ្វើការសម្រេចចិត្តចំពោះព្រះជាម្ចាស់ដែរ។



50 QnA John Piper Final 1.5.indd 56 25/01/2024 09:22:35 AM

មើលទៅហាក់បីដូចជាពួកគាត់មិនយកចិត្តទុកដាក់ទេ ដោយមិនគិតអំពីអ្វីដែលពួកគាត់កំពុងតែធ្វើ។ ហើយពួកគាត់បែរជាជ្រើសរើសមើលគេលេងកីឡាអាជីពលើទូរទស្សន៍ ឬក៏មើលរឿងភាគទៅវិញ។ ហើយនៅពេលដែលលោកអ្នកឃើញទង្វើ នោះលោកអ្នកក៏នឹងលើកឡើងថា «តើថ្ងៃនេះខុសពីថ្ងៃសៅរ៍មែនឬ? តើវាមានអ្វីសំខាន់ពីថ្ងៃនេះមែនឬ?» ហើយមានគ្រីស្ទបរិស័ទជាច្រើននឹងតបថា «ទេ មិនមានអ្វីពិសេសអំពីថ្ងៃនេះនោះទេ»។

ហើយយើងខ្ញុំគិតថា គោលការណ៍នៅក្នុងព្រះគម្ពីរសញ្ញាថ្មីគឺថា ព្រះជាម្ចាស់បានគ្រោងទុកឲ្យមានថ្ងៃមួយក្នុងថ្ងៃទាំងប្រាំពីរក្លាយជាថ្ងៃសម្រាក។ យើងខ្ញុំគិតថា នេះគឺជាការគ្រោងទុកពេលព្រះអង្គបង្កើតរបស់សព្វសារពើសម្រាប់ជាប្រយោជន៍ដល់យើង និងសម្រាប់ជាសុខភាពដល់យើង។

ដូច្នេះ នៅថ្ងៃព្រះអម្ចាស់ ចំណុចមួយដែលយើងគួរធ្វើក្នុងចំណុចនានាគឺធ្វើនូវអ្វីដែលនាំឲ្យមានការលម្ហែដល់យើងសម្រាប់ព័ន្ធកិច្ចរបស់ព្រះអង្គ មិនថាខាងឯខួរក្បាល រាងកាយ ឬក៏វិញ្ញាណក៏ដោយ។ ដូច្នេះ ប្រសិនបើលោកអ្នកធ្វើការដោយអង្គុយនៅតុមួយកន្លែងពេញអាទិត្យ នោះអ្វីដែលលោកអ្នកគួរធ្វើគឺទៅដើរ ឬក៏ជិះកង់លេងនៅថ្ងៃអាទិត្យ។ ហើយប្រសិនបើលោកអ្នកធ្វើការនៅឯចម្ការ ហើយឈឺខ្នងពេញមួយអាទិត្យ (ដ្បិតនោះគឺជាអ្វីដែលពួកគេធ្វើនៅក្នុងព្រះគម្ពីរសញ្ញាចាស់) នោះអ្វីដែលលោកអ្នកគួរធ្វើគឺអង្គុយ ហើយសម្រាកដោយគេងលេងនៅថ្ងៃអាទិត្យ។

យើងខ្ញុំគិតថា ចំណុចដែលឲ្យយើងសម្រាកគឺពាក់ព័ន្ធទៅនឹងចិត្តសាស្ត្រ ហើយចេញពីទស្សនៈនៃការបង្កើតតាមលំដាប់លំដោយ វាក៏ជាការដ៏មានប្រាជ្ញាដែរ។ យើងខ្ញុំប្រើពាក្យ «ប្រាជ្ញា» ជាជាងតម្រូវឲ្យធ្វើអ្វីមួយក្នុងរបៀបណាមួយ។ សូមញែកថ្ងៃណាមួយក្នុងចំណោមថ្ងៃទាំងប្រាំពីរចេញ ហើយយកវាទុកជាថ្ងៃដែលលោកអ្នកនឹងសម្រាកឲ្យមានកម្លាំងឡើងវិញខាងឯសាច់ឈាមចុះ។



50 QnA John Piper Final 1.5.indd 57 25/01/2024 09:22:35 AM

នៅពេលដែលយើងមានថ្ងៃឈប់សម្រាកនៅចុងអាទិត្យ នោះយើងតែង តែគិតថា «តើវាទាក់ទងអ្វីជាមួយនឹងថ្ងៃសៅរ៍?»។ ខណៈពេលដែលព្រះគម្ពីរ មានចែងថា «ក្នុងរវាង៦ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែឯ ថ្ងៃទី៧ នោះគឺជាថ្ងៃឈប់សម្រាក» (និក្ខមនំ ២០:៩-១០)។ ដូច្នេះ ព្រះគម្ពីរ មិនមានថ្ងៃធ្វើការតែប្រាំថ្ងៃនោះទេ ប៉ុន្តែមានប្រាំមួយថ្ងៃ។

នោះគឺជារបៀបដែលយើងខ្ញុំគិតជាមួយនឹងខ្លួនឯង។ យើងខ្ញុំធ្វើការប្រាំ មួយថ្ងៃក្នុងមួយអាទិត្យ ហើយនៅថ្ងៃចន្ទ—ជាថ្ងៃដែលយើងខ្ញុំឈប់សម្រាក— យើងខ្ញុំនឹងសម្រួលឥរិយាបថដោយសម្រាក ហើយមិនគិតអំពីការងារ។ ប៉ុន្តែ ផ្ទុយទៅវិញ យើងខ្ញុំអធិស្ឋាននៅដើមថ្ងៃថា «ឱព្រះអម្ចាស់អើយ! អ្វីដែល នឹងកើតឡើងនៅថ្ងៃនេះ សូមប្រើប្រាស់វា ដើម្បីឲ្យទូលបង្គំមានកម្លាំងនៅ ថ្ងៃអង្គារ។ សូមឲ្យទូលបង្គំមានកម្លាំងសម្រាប់ថ្ងៃនានានៅក្នុងសប្ដាហ៍នេះ ដែលនឹងមកដល់។ សូមប្រទានកម្លាំងដល់ទូលបង្គំ សូមប្រទានថាមពល ដល់ទូលបង្គំ។»

ចំណុចបរិសុទ្ធគឺជាចំណុចដែលកំពុងតែផ្ដោតលើសំណួរមួយនេះ។ យើង ខ្ញុំគិតថា ចំណុចបរិសុទ្ធគឺទាក់ទងជាមួយនឹងការថ្វាយបង្គំ។ មិនថានៅយប់ ថ្ងៃសៅរ៍មុននោះ ឬក៏ព្រឹកថ្ងៃអាទិត្យ សូមញែកមួយថ្ងៃជាការផ្ដោតដ៏សំខាន់ ក្នុងការជួបជុំគ្នាថ្វាយបង្គំ។ យើងខ្ញុំគិតថា ចំណុចនេះគឺច្បាស់លាស់ណាស់ ក្នុងរបៀបដែលព្រះគម្ពីរសញ្ញាថ្មីបានលើកឡើងអំពីការជួបជុំគ្នានៃរាស្ត្ររបស់ ព្រះជាម្ចាស់។ ដូច្នេះ ថ្ងៃនោះបរិសុទ្ធក្នុងអត្ថន័យថា វាគឺជាថ្ងៃដែលបានញែក ទុកសម្រាប់ជួបជុំគ្នា ដើម្បីថ្វាយបង្គំព្រះជាម្ចាស់។

ជាបន្ទាប់ យើងខ្ញុំគិតថា លោកអ្នកគួរព្យាយាមគេចខ្លួនចេញពីការចូលរួម ជាមួយនឹងលោកីយ៍ ដើម្បីឲ្យលោកអ្នកអាចលើកឡើងអំពីចំណុចពិសេស នៅថ្ងៃនេះបាន។ វាខុសគ្នាពីថ្ងៃនានា ពីព្រោះព្រះគ្រីស្ទគឺជាព្រះអម្ចាស់ ហើយ ព្រះអង្គក៏បានមានព្រះជន្មរស់ឡើងវិញក្នុងរបៀបដែលយើងខ្ញុំចង់និយាយ



50 QnA John Piper Final 1.5.indd 58 25/01/2024 09:22:35 AM

អំពីចំណុចចម្លែករបស់វានៅថ្ងៃនេះ។ ប៉ុន្តែ យើងខ្ញុំមិនចង់លើកយកក្រឹត្យវិន័យថា វាគួរមានលក្ខណៈយ៉ាងដូចម្តេចនោះទេ? យើងខ្ញុំនឹងគ្រាន់តែចែកចាយនូវការអនុវត្តមួយចំនួនដែលគ្រួសាររបស់យើងខ្ញុំបានបង្កើតឡើង។

គ្រួសារយើងខ្ញុំមិនមើលការប្រកួតកីឡាអាជីពនៅថ្ងៃអាទិត្យនោះទេ។ កូនប្រុសៗរបស់យើងក៏មិនទៅប្រកួតបាល់នៅថ្ងៃអាទិត្យដែរ។ ហើយយើងខ្ញុំក៏មិនបានហាមប្រាមថា ពួកគាត់មិនអាចទៅផ្ទះមិត្តភក្តិ ហើយមើលទូរទស្សន៍ដែរ។ មនុស្សមួយចំនួននឹងទំនងជាលើកឡើងថា «មើលទៅហាក់បីដូចជាចម្លែកណាស់។ នោះគឺជាការហាមប្រាមដែលគួរឲ្យអស់សំណើចមែន?»។ ប៉ុន្តែ យើងខ្ញុំមានមូលហេតុរបស់ខ្លួន។ ហើយយើងខ្ញុំក៏បានប្រាប់អំពីមូលហេតុនោះទៅកាន់កូនប្រុសៗរបស់យើងខ្ញុំដែរ  អំពីការមានចំណែកក្នុងសកម្មភាពដែលមិនពាក់ព័ន្ធជាមួយនឹងព្រះជាម្ចាស់នៅឯពហុកីឡាដ្ឋាន។

គ្រួសារយើងខ្ញុំក៏មិនទៅមើលកុននៅថ្ងៃអាទិត្យដែរ។ ៩៩% នៃរឿងមិនបង្ហាញពីការកោតខ្លាចព្រះជាម្ចាស់នោះទេ ហើយក៏លើកតម្កើងការសប្បាយបែបលោកីយ៍ផងដែរ ទោះបើថាវាមិនមែនជាអំពើ «អាក្រក់» ក៏ដោយ។ រឿងទាំងអស់នោះមិនពាក់ព័ន្ធជាមួយនឹងព្រះជាម្ចាស់ទាល់តែសោះ។ ហើយយើងខ្ញុំផ្ទាល់ក៏មិនដែលទៅមើលកុននៅថ្ងៃអាទិត្យ ហើយក៏មិនមានផែនការទៅមើលនៅអនាគតដែរ។ នេះគឺជាចរិតរបស់យើងខ្ញុំ។

ប៉ុន្តែ យើងខ្ញុំក៏មិនស៊ើបសួរនាំនៅឯព្រះវិហារ ឬក៏កន្លែងធ្វើការរបស់យើងខ្ញុំថា តើបុគ្គលិកបាន ឬក៏នឹងធ្វើអ្វីខ្លះដែរ? អ្វីដែលយើងខ្ញុំចង់លើកឡើងគឺថា លោកអ្នកត្រូវតែញែកថ្ងៃណាមួយនៃសប្តាហ៍ ដើម្បីសម្រាក ហើយលោកអ្នកត្រូវរករបៀបនិយាយទៅកាន់ព្រះជាម្ចាស់ថា «ទូលបង្គំស្រឡាញ់ទ្រង់។ ទូលបង្គំគោរពកោតខ្លាចព្រះអង្គ។ ហើយទូលបង្គំក៏នឹងថ្វាយព្រះកិត្តិយសដល់ព្រះអង្គក្នុងរបៀបដ៏ពិសេសនៅថ្ងៃនេះផងដែរ»។



50 QnA John Piper Final 1.5.indd 59 25/01/2024 09:22:35 AM

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 60 25/01/2024 09:22:36 AM

# សំណួរទី១០៖
# ទេវវិទ្យាទន់ខ្សោយបង្កើតឲ្យមានស្ត្រីទន់ខ្សោយ

*សួស្តី លោកគ្រូ! តើលោកគ្រូកំណត់ភាពជាស្ត្រីដែលមានលក្ខណៈខ្លាំងដោយរបៀបណា? តើទេវវិទ្យាអាចជួយបណ្ដុះបណ្ដាលស្ត្រីឲ្យមានលក្ខណៈពូកែៗតាមព្រះគម្ពីរដោយរបៀបណាបាន?*

ខ្ញុំធ្លាប់បានអធិប្បាយលើប្រធានបទនេះម្ដងរួចហើយ។ ប្រធានបទរបស់ខ្ញុំគឺ «ទេវវិទ្យាទន់ខ្សោយបង្កើតឲ្យមានស្ត្រីទន់ខ្សោយ»។ ខ្ញុំបានអធិប្បាយនៅព្រះវិហារ អស់រយៈពេល៣២ឆ្នាំហើយ។ ចំពោះខ្ញុំ ចំណុចមួយដែលធ្វើឲ្យស្កប់ចិត្តមែនទែនគឺថា យើងមានពួកចាស់ទុំប្រុសៗនៅក្នុងក្រុមជំនុំដែលពេញវ័យខាងឯព្រលឹងវិញ្ញាណ ទទួលបានការរៀនសូត្រស្របតាមបទគម្ពីរ មានការបន្ទាបខ្លួន និងមានភាពចាស់ទុំដូចជាព្រះគ្រីស្ទ ហើយយើងក៏មានស្ត្រីដែលពូកែៗធ្វើការជាមួយពួកគាត់ដែរ ដោយភាពឆ្លាតវៃ ប៉ិនប្រសប់ខាងពាក្យសម្ដី មានភាពចាស់ទុំ ស្គាល់ព្រះគម្ពីរច្បាស់ យកព្រះជាចំណុចកណ្ដាល និងលើកតម្កើងព្រះគ្រីស្ទ។ ពួកគាត់គឺជាដៃគូសហការជាមួយប្រុសៗនៅក្នុងក្រុមជំនុំ។ ពួកគាត់សហការជាមួយគ្នាក្នុងការធ្វើព័ន្ធកិច្ចសម្រាប់ក្រុមគ្រួសារ និងសង្គមរបស់យើង។

## ទាំងបុរស និងស្ត្រីក៏ត្រូវការទេវវិទ្យា

ការនេះកើតឡើងដោយសារតែទាំងមនុស្សប្រុស និងមនុស្សស្រីគួរតែរៀនឲ្យបានជ្រៅជ្រះ មានភាពរឹងមាំ និងឲ្យទេវវិទ្យាផ្លាស់ប្ដូរជីវិតរបស់ពួកគាត់។ មិនមែនគ្រាន់តែបុរសប៉ុណ្ណោះទេ។ មិនមែនទេ។ ទាំងបុរស និងស្ត្រីគួរតែសញ្ជឹងគិត ត្រិះរិះឲ្យបានល្អិតល្អន់ អានព្រះបន្ទូល និងលូតលាស់។ ពួកគេទាំងពីរមានសតិក្នុងការគិតពិចារណាបាន។



50 QnA John Piper Final 1.5.indd 61 25/01/2024 09:22:36 AM

## សម្រាប់ជាសិរីល្អដល់ព្រះជាម្ចាស់

ចំពោះបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ខួរក្បាលរបស់មនុស្សស្រីមានភាពមុតស្រួចជាងខួរក្បាលរបស់មនុស្សប្រុសទៅទៀត។ ពេញមួយជីវិតរបស់ខ្ញុំ ខ្ញុំជឿថា ម្ដាយរបស់ខ្ញុំឆ្លាតជាងឪពុករបស់ខ្ញុំ។ ហើយស្រីៗទាំងអស់នៅក្នុងវិទ្យាល័យដែលខ្ញុំបានរៀនក៏ឆ្លាតៗជាងខ្ញុំ។ ហើយបន្ទាប់មក នៅសាកលវិទ្យាល័យ សិស្សស្រីៗក៏តែងតែជាអ្នកដែលរៀនបានល្អប្រសើរជាងសិស្សប្រុសៗដែរ។

ដូច្នេះ មនុស្សស្រីមានសមត្ថភាពក្នុងការយល់ដឹងអំពីទេវវិទ្យាបាន។ យើងគួរតែស្វែងរកមនុស្សស្រី នៅក្នុងព្រះវិហាររបស់យើង ដើម្បីឲ្យពួកគាត់ទទួលបានការបង្រៀនឲ្យបានពេញលេញ និងបណ្ដុះបណ្ដាលភាពប៉ិនប្រសប់ដល់ពួកគាត់នៅក្នុងការយល់ដឹងអំពីសិរីល្អនៃព្រះជាម្ចាស់ដូចមនុស្សប្រុសដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 62 25/01/2024 09:22:36 AM

# ផ្នែកទី២៖ ការសង្គ្រោះ



50 QnA John Piper Final 1.5.indd 63 25/01/2024 09:22:36 AM

លោកអ្នកអាចស្ដាប់សៀវភៅនេះជាសំឡេងបាន
ដោយគ្រាន់តែ

ស្កេននៅទីនេះ

50 QnA John Piper Final 1.5.indd 64 25/01/2024 09:22:36 AM

# សំណួរទី១១៖
# តើគ្រីស្ទបរិស័ទដែលកើតជាថ្មីអាចបាត់បង់សេចក្តីសង្គ្រោះបានដែរឬទេ?

ចម្លើយដែលចេញពីព្រះគម្ពីរលើសំណួរនេះគឺច្បាស់ណាស់ ហើយមានពេញទៅដោយអំណរ « ទេ! »។ បុគ្គលណាដែលបានកើតជាថ្មីហើយមិនអាចស្លាប់វិញបានឡើយ ពោលគឺមិនអាចមិនកើតម្តងទៀតបាននោះទេ។ ខ្ញុំនឹងលើកឡើងនូវផ្នត់គំនិតមួយចំនួន ដែលមានចេញពីព្រះគម្ពីរ ដោយផ្តោតទៅលើខគម្ពីរ តាមដែលខ្ញុំអាចធ្វើទៅបាន ដោយមិនគ្រាន់តែផ្តោតលើទេវវិទ្យាប៉ុណ្ណោះឡើយ។

## គ្មានការបោះបង់ចោល

ជីវិតដែលយើងទទួលបាននៅពេលកើតជាថ្មីគឺជាជីវិតដ៏នៅអស់កល្បជានិច្ច។ «ឯទីបន្ទាល់នោះគឺថា ព្រះបានប្រទានជីវិតអស់កល្បជានិច្ចមកយើង បានប្រទានជីវិតអស់កល្បជានិច្ច ហើយជីវិតនេះ គឺនៅក្នុងព្រះរាជបុត្រារបស់ព្រះអង្គ» (១យ៉ូហាន ៥:១១)។ ព្រះអង្គមិនបានប្រទានជីវិតបណ្តោះអាសន្នដល់យើងទេ។ ព្រះអង្គបានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់យើង។ ឥឡូវនេះ យើងកំពុងតែមានចំណែកក្នុងជីវិតនៃសម័យកាលដែលនឹងកើតឡើង។

នេះគឺជាប្រយោគដ៏សំខាន់មួយទៀត៖ «ព្រះអង្គបាន*តម្រូវទុកជាមុន*»។ ប្រយោគនោះមានក្នុងកណ្ឌគម្ពីរ (រ៉ូម ៨:៣០)៖ «ឯអស់អ្នកដែលព្រះអង្គបានតម្រូវទុកជាមុន ទ្រង់ក៏បានត្រាស់ហៅ ហើយអស់អ្នកដែលព្រះអង្គបានត្រាស់ហៅ ទ្រង់ក៏រាប់ជាសុចរិត ហើយអស់អ្នកដែលព្រះអង្គបានរាប់ជាសុចរិត ទ្រង់ក៏លើកតម្កើង»។ ការលើកតម្កើង [ឬក៏ការទទួលបានសិរីល្អ] គឺ



50 QnA John Piper Final 1.5.indd 65 25/01/2024 09:22:37 AM

ជាសណ្ឋានចុងក្រោយនៃសេចក្តីសង្គ្រោះដ៏អចិន្ត្រៃយ៍។ ខគម្ពីរនេះបានលើកឡើងថា «បានត្រាស់ហៅ»—ដោយគ្មានការបោះបង់អ្នកណាម្នាក់ចោលទេ—ក៏ទទួលបានការរាប់ជាសុចរិត ហើយគ្រប់គ្នាគឺទទួលបានការរាប់ជាសុចរិត—ដោយគ្មានការបោះបង់អ្នកណាម្នាក់ចោលទេ—ក៏ទទួលបានការលើកតម្កើងដែរ។

ចម្លើយគឺថា៖ ប្រសិនបើព្រះជាម្ចាស់បានត្រាស់ហៅលោកអ្នក នោះលោកអ្នកនឹងមិនអាចបាត់បង់សេចក្តីសង្គ្រោះនេះបានឡើយ។ ហើយខ្ញុំនឹងរែកញែកថា ការទទួលបានកាត្រាស់ហៅ និងការកើតជាថ្មីគឺជាចំណុចដូចគ្នា។ យើងនឹងទទួលបានការរាប់ជាសុចរិត ហើយយើងក៏នឹងទទួលបានការលើកតម្កើង ពីព្រោះយើងបានទទួលការត្រាស់ហៅ—ដែលនេះមានន័យថា យើងបានកើតជាថ្មី។

**ការហៅឲ្យមានជីវិត**

ប្រភេទនៃការត្រាស់ហៅដែលសាវ័ក ប៉ុល កំពុងតែមានប្រសាសន៍ក្នុងកណ្ឌគម្ពីរ (រ៉ូម ៨:៣០) គឺជាការត្រាស់ហៅលោក ឡាសារ តាមរយៈព្រះយេស៊ូវ ឲ្យចេញពីផ្នូរ «ឡាសារ! ខ្ញុំដឹងថាឯងស្លាប់ហើយ ប៉ុន្តែចូរចេញមក» (សូមមើលកណ្ឌគម្ពីរ យ៉ូហាន ១១:៤៣)។ ការត្រាស់ហៅបង្កើតឲ្យមានជីវិត ហើយនោះឯងគឺជាអ្វីដែលបានកើតឡើងចំពោះអ្នកដែលជាគ្រីស្ទបរិស័ទ៖ ការត្រាស់ហៅដែលមានពេញទៅដោយអធិបតេយ្យភាពរបស់ព្រះជាម្ចាស់បង្កើតឲ្យមានជីវិត។ នេះមានន័យថា មានសេចក្តីសន្យាជាមួយនឹងការត្រាស់ហៅនេះដែរ។

**ខាងក្រោមនេះគឺជាខគម្ពីរមួយចំនួនដែលបង្ហាញអំពីការតភ្ជាប់នេះ៖**

កណ្ឌគម្ពីរ (១ថែស្សាឡូនីច ៥:២៣-២៤) «សូមព្រះនៃសេចក្តីសុខសាន្តញែកអ្នករាល់គ្នាជាបរិសុទ្ធទាំងស្រុង...រហូតដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះ



50 QnA John Piper Final 1.5.indd 66 25/01/2024 09:22:37 AM

អម្ចាស់នៃយើងយាងមក។ ព្រះដែលបានត្រាស់ហៅអ្នករាល់គ្នា ទ្រង់ស្មោះត្រង់ ហើយព្រះអង្គនឹងសម្រេចការនេះ»។ នៅក្នុងខនេះមានផ្នត់គំនិតដូចគ្នាៈ ប្រសិនបើព្រះជាម្ចាស់បានត្រាស់ហៅលោកអ្នក នោះព្រះអង្គក៏នឹងនៅជាព្រះដ៏ស្មោះត្រង់ដែរ។ ព្រះអង្គនឹងរក្សាលោកអ្នកឲ្យនៅរហូតដល់ថ្ងៃចុងក្រោយ។

ឬក៏ជាថ្មីម្តងទៀតៈ នៅក្នុងកណ្ឌគម្ពីរ (១កូរិនថូស ១:៨-៩)៖ ព្រះគ្រីស្ទ «នឹងតាំងអ្នករាល់គ្នាឲ្យខ្ជាប់ខ្ជួន រហូតដល់ចុងបញ្ចប់ ដើម្បីឲ្យអ្នករាល់គ្នាឥតកន្លែងបន្ទោសបាន នៅថ្ងៃរបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង។ ព្រះទ្រង់មានព្រះហឫទ័យ*ស្មោះត្រង់* ព្រះអង្គបានត្រាស់ហៅអ្នករាល់គ្នាមកឲ្យមានសេចក្ដីប្រកបជាមួយព្រះរាជបុត្រាព្រះអង្គ គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់យើង»។ ដូច្នេះ ឥឡូវលោកអ្នកអាចត្រឡប់បកក្រោយវិញ ហើយមើលអំពីមូលហេតុ នៅក្នុង (រ៉ូម ៨:៣០) ដែលថាហេតុអ្វីអស់អ្នកដែលទទួលបានការត្រាស់ហៅក៏នឹងទទួលបានការរាប់ជាសុចរិត ហើយអស់អ្នកដែលទទួលបានការរាប់ជាសុចរិតក៏នឹងទទួលការលើកតម្កើង—ពីព្រោះព្រះជាម្ចាស់ជាព្រះដ៏ស្មោះត្រង់។ គ្មានអ្វីដើរដោយស្វ័យប្រវត្តិនោះទេ។

## ការរក្សាទុកអស់អ្នកដែលព្រះអង្គបានគ្រោងទុក

មានមនុស្សជាច្រើនបានគិតថា សុវត្ថិភាពដ៏នៅអស់កល្បជានិច្ចប្រៀបដូចជាថ្នាំវ៉ាក់សាំងមួយ។ ពួកគេគិតថា «កាលខ្ញុំមានអាយុ៦ឆ្នាំ ខ្ញុំបានអធិស្ឋាន ហើយព្រះជាម្ចាស់ក៏បានចាក់ថ្នាំវ៉ាក់សាំងលើដៃរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំនឹងមិនអាចមានជំងឺនៃការត្រូវបណ្តាសាបានឡើយ!»។ វាមិនមែនជារបៀបនោះនោះទេ។ ផ្ទុយទៅវិញ វាប្រៀបដូចជាការចូលទទួលពិធីព្យាបាលដោយចិត្តវិទ្យាអស់មួយជីវិតជាមួយនឹងគ្រូពេទ្យដែលនិយាយថា «អ្នកគឺជាអ្នកជំងឺរបស់ខ្ញុំ។ អ្នកនឹងធ្វើនូវអ្វីដែលខ្ញុំប្រាប់ ហើយខ្ញុំនឹងនាំអ្នកឲ្យដល់ទីបញ្ចប់ ល្អទាំងស្រុង នៅថ្ងៃចុងក្រោយ!»។



50 QnA John Piper Final 1.5.indd 67 25/01/2024 09:22:37 AM

កណ្ឌគម្ពីរ (យេរេមា ៣២:៤០) គឺជាខគម្ពីរដែលខ្ញុំចូលចិត្តយ៉ាងខ្លាំងទាក់ទងនឹងប្រធានបទនៃការរក្សាទុកៈ «យើងនឹងតាំងសេចក្ដីសញ្ញានឹងគេ ជាសេចក្ដីសញ្ញាដ៏ស្ថិតស្ថេរនៅអស់កល្បជានិច្ចថា យើងនឹងមិនបែរចេញពីគេឡើយ គឺនឹងឲ្យគេបានសេចក្ដីល្អវិញ យើងនឹងដាក់សេចក្ដីកោតខ្លាចដល់យើងក្នុងចិត្តគេ ប្រយោជន៍កុំឲ្យគេឃ្លាតចេញពីយើង»។ ដូច្នេះ ការតាំងសេចក្ដីសញ្ញាដែលព្រះគ្រីស្ទបានទិញជាមួយនឹងព្រះលោហិតរបស់ទ្រង់គឺជាសេចក្ដីសញ្ញានៃ*ការរក្សាទុក*។ វាមិនមែនគ្រាន់តែជាសុវត្ថិភាពក្នុងរបៀបបែបម៉ាស៊ីនណានោះទេ។ ប៉ុន្តែ គឺជាការរក្សាទុកដោយមានសកម្មភាព។ ព្រះជាម្ចាស់មានសកម្មភាពក្នុងជីវិតរបស់ខ្ញុំ។

ពេលខ្ញុំសួរអ្នកដទៃថាៈ «តើអ្នកគិតថាអ្នកនឹងក្លាយជាគ្រីស្ទបរិស័ទនៅពេលដែលអ្នកភ្ញាក់ពីដំណេកនៅពេលព្រឹកដោយរបៀបណា?» មានមនុស្សជាច្រើនមានការភ្ញាក់ផ្អើលទាក់ទងនឹងសំណួរប្រភេទដូចនេះ។ ពួកគេឆ្លើយតបថាៈ «អ៊ូ! ពីព្រោះ...ដូចអ្នកដឹងហើយ...វាដូចជាការធ្វើជាមនុស្សអញ្ចឹង!»។ ទេ! វាមិនមែនដូចជាការធ្វើជាមនុស្សទេ។ លោកអ្នកនឹងភ្ញាក់ពីដំណេកនៅថ្ងៃស្អែកជាគ្រីស្ទបរិស័ទ ពីព្រោះព្រះជាម្ចាស់ទ្រង់ស្មោះត្រង់។ ព្រះជាម្ចាស់នឹងដាស់លោកអ្នកពីដំណេក ហើយនឹងដាក់នូវជំនឿរបស់ព្រះអង្គក្នុងលោកអ្នក។

## ព្រះអង្គរក្សាទុកដោយស្មោះត្រង់

នេះគឺជាខគម្ពីរមួយចំនួនទៀតដែលលើកឡើងអំពីភាពស្មោះត្រង់របស់ព្រះជាម្ចាស់ៈ «ខ្ញុំជឿជាក់ថា ព្រះអង្គដែលបានចាប់ផ្ដើមធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឲ្យការល្អនោះកាន់តែពេញខ្នាតឡើង រហូតដល់ថ្ងៃរបស់ព្រះយេស៊ូវគ្រីស្ទ» (ភីលីព ១:៦)។ មូលហេតុដែលសាវ័ក ប៉ុល មានប្រសាសន៍បែបនោះគឺដោយសារភាពស្មោះត្រង់របស់ព្រះជាម្ចាស់មានការទាក់ទងគ្នាជា

មួយនឹងការត្រាស់ហៅរបស់គាត់ និងការកើតជាថ្មីរបស់គាត់។

ឬក៏កណ្ឌគម្ពីរ (យូដាស ១:២៤) "រីឯព្រះអង្គដែលអាចរក្សាអ្នករាល់គ្នាមិនឲ្យជំពប់ដួល..."។ ខ្ញុំពិតជាមានអារម្មណ៍រំភើបយ៉ាងខ្លាំងណាស់ដែលព្រះជាម្ចាស់បានរក្សាខ្ញុំទុក។

*ព្រះអង្គបានរក្សាខ្ញុំ។* ព្រះអង្គមិនបានអនុញ្ញាតឲ្យខ្ញុំជំពប់ដួល ដែលការនោះនឹងនាំឲ្យមានការខូចព្រះនាមរបស់ទ្រង់ ហើយបំផ្លាញក្រុមជំនុំ។ ខ្ញុំមិនបានក្រឡេកមើលក្រោយវិញ ហើយបន្ទាប់មកវាយស្មាសរសើរខ្លួនឯងថា "ឯងពិតជាមនុស្សល្អមែន" ទេ។ ប៉ុន្តែ ខ្ញុំលើកឡើងវិញថា "អស្ចារ្យណាស់! អស្ចារ្យណាស់! គឺព្រះអង្គហើយដែលបានរក្សាខ្ញុំទុក..."

## យុទ្ធានៃការធានារបស់យើង

មកដល់ចំណុចនេះ ខ្ញុំគិតថា នៅសល់តែសំណួរគន្លឹះមួយទៀតទេ ដែលមនុស្សជាច្រើនតែងតែសួរ៖ "ចុះចំណែកឯអស់អ្នកដែលនៅក្នុងក្រុមជំនុំវិញ? ពួកគេធ្លាប់ធ្វើជាអ្នកជំនួយការ ឬក៏ជាអ្នកចាស់ទុំ ហើយមើលទៅហាក់បីដូចជាថាពួកគាត់បានទទួលសេចក្ដីសង្គ្រោះកាលកំពុងរៀននៅមហាវិទ្យាល័យ។ មកដល់ពេលនេះ ពួកគាត់បានបម្រើអស់រយៈពេលបួនដប់ឆ្នាំហើយ ហើយឥឡូវពួកគាត់ក៏បានបោះបង់ទាំងអស់ចោលដែរ។ មានអ្នកខ្លះក៏បានស្លាប់ក្នុងស្ថានភាពហ្នឹងនោះដែរ។ ចុះចំណែកឯពួកគេវិញ?"។

ខ្ញុំគិតថា យ៉ាងហោចណាស់មានខគម្ពីរគន្លឹះពីរទៀតដែលពួកគេគួរចំណាយពេលគិតឲ្យបានយូរ។ ខគម្ពីរដំបូងគឺ (១យ៉ូហាន ២:១៩)៖ "គេបានចេញពីពួកយើងទៅ តែមិនមែនជាពួកយើងទេ ដ្បិតបើគេជាគ្នាយើងមែន នោះនឹងបាននៅជាប់ជាមួយយើងហើយ។ ប៉ុន្តែ ដែលគេបានចេញទៅ នោះបង្ហាញឲ្យឃើញថា ពួកគេមិនមែនសុទ្ធតែជាគ្នាយើងទាំងអស់គ្នាទេ"។ ពាក្យ "ពីពួកយើង" ក្នុងខគម្ពីរនេះពិតជាមានន័យថា "កើតជាថ្មីជាមួយយើង ការ



50 QnA John Piper Final 1.5.indd 69 25/01/2024 09:22:38 AM

ផ្សាំក្នុងព្រះគ្រីស្ទជាមួយយើង»—ប៉ុន្តែ ពួកគេមិនដូច្នោះទេ។ មើលទៅពួកគេហាក់បីដូចជាមានលក្ខណៈដូចគ្នា។ ពួកគេថែមទាំងនិយាយនូវចំណុចមួយចំនួនត្រឹមត្រូវផងដែរ។ ពួកគេ «បានភ្លក់...ព្រះចេស្តាទាំងឡាយនៃបរលោក» (ហេព្រើរ ៦:៥)។ ប៉ុន្តែ ពួកគេមិនបានកើតពីព្រះជាម្ចាស់ទេ។

លើសពីនេះទៅទៀត កណ្ឌគម្ពីរ (ហេព្រើរ ជំពូក៦) ក៏ជាកន្លែងជំពប់ដ៏ធំមួយសម្រាប់អស់អ្នកដែលធ្លាប់ទទួលបទពិសោធន៍ខាងឯវិញ្ញាណ ប៉ុន្តែនៅបាត់បង់ទៀយ។ ប៉ុន្តែ ខ្ញុំគិតថា កណ្ឌគម្ពីរ (ហេព្រើរ ៣:១៤) គឺជាខគម្ពីរគន្លឹះក្នុងកណ្ឌគម្ពីរនេះ៖ «ប្រសិនបើយើងកាន់ខ្ជាប់តាមចិត្តជឿជាក់ដែលយើងមានតាំងពីដំបូង រហូតដល់ចុងបំផុតមែន នោះយើងពិតជាមានចំណែកជាមួយព្រះគ្រីស្ទហើយ»។

អ្នកនិពន្ធមិនបានលើកឡើងថា «ប្រសិនបើលោកអ្នកកាន់ឲ្យបានខ្ជាប់ខ្ជួននូវទំនុកចិត្តរបស់លោកអ្នករហូតដល់ទីបញ្ចប់ នោះលោកអ្នកនឹងមានចំណែកជាមួយនឹងព្រះគ្រីស្ទ» នោះទេ។ គាត់បានលើកឡើងថា «យើងដឹងហើយថា យើងធ្លាប់មាន—ចាប់តាំងពីដើមដំបូងនៃជីវិតរបស់យើងជាមួយនឹងព្រះគ្រីស្ទ—ការមានចំណែកក្នុងព្រះគ្រីស្ទ ដោយសារយើងស៊ូទ្រាំដល់ទីបញ្ចប់!»។ នេះមានន័យថាការស៊ូទ្រាំក្នុងជំនឿគឺជាភស្តុតាងដែលថាយើងមានចំណែកក្នុងព្រះគ្រីស្ទមែន។

ហើយពេលយើងមិនមានការស៊ូទ្រាំដូចនោះ នោះមានន័យថា យើងក៏មិនដែលមានការធានាអះអាងដែរ។ នេះគឺជាគន្លឹះ៖ ដូច្នេះ ការធានាគឺមិនមែនជាដំណើរការស្វ័យប្រវត្តិឡើយ។ វាគឺជាការធានាដែលមានឫសក្នុងទំនុកចិត្តរបស់យើងក្នុងអធិបតេយ្យភាពដ៏ធំធេងក្នុងព្រះដែលរក្សាការតាំងសេចក្តីសញ្ញានោះ ដែលបានចាត់ព្រះរាជបុត្រារបស់ទ្រង់ជំនួសមនុស្សមានបាប ហើយខណៈពេលដែលយើងសម្លឹងមើលព្រះអង្គ នោះព្រះវិញ្ញាណនឹងធ្វើជាស្មរបន្ទាល់ថាយើងគឺជាកូនរបស់ព្រះមែន (រ៉ូម ៨:១៦)។



50 QnA John Piper Final 1.5.indd 70 25/01/2024 09:22:38 AM

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 71 25/01/2024 09:22:38 AM

50 QnA John Piper Final 1.5.indd 72 25/01/2024 09:22:38 AM

## សំណួរទី១២៖
# តើការសុគតរបស់ព្រះយេស៊ូវសម្រេចអ្វី សម្រាប់អ្នកដែលទ្រង់មិនបានជ្រើសតាំង?

សុខាបានសួរថា «តើការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងសម្រេចបានអ្វីខ្លះសម្រាប់អ្នកដែលព្រះអង្គមិនបានជ្រើសតាំង? តើសម្រេចបានអ្វីមួយដែរឬទេ?»

វាពិតជារឿងដ៏គួរឲ្យភ្ញាក់ផ្អើលមែនដែលសំណួរនេះតែងតែលេចឡើងម្តងហើយម្តងទៀតជាពិសេសថ្មីៗនេះមានគេធ្លាប់សួរយើងខ្ញុំថា «តើព្រះយេស៊ូវបានទិញព្រះគុណទូទៅ (ព្រះគុណសម្រាប់មនុស្សទាំងអស់) មែនឬ?»។ ដូច្នេះ យើងខ្ញុំចង់យកឱកាសនេះ ដើម្បីនឹងឆ្លើយសំណួរនេះ។

យើងខ្ញុំនឹងលើកឡើងអំពីការឆ្លុះបញ្ចាំងត្រួសៗតែប៉ុណ្ណោះ។ បើនិយាយឲ្យស្មោះទៅ យើងខ្ញុំមិនដឹងថាគួរឆ្លើយដោយរបៀបណាទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក៏យើងខ្ញុំគិតថា ក្នុងការដែលយើងខ្ញុំគ្រាន់តែប្រាប់អំពីមូលហេតុទៅកាន់លោកអ្នក នោះទំនងជាលោកអ្នកនឹងមិនអាចយល់បានយ៉ាងជ្រាលជ្រៅនោះទេ។

ក្នុងអត្ថន័យមួយ ខណៈពេលដែលយើងប្រព្រឹត្តអំពើបាប នោះយើងគួរទទួលបានការដាក់ទារុណកម្មដ៏នៅអស់កល្បជានិច្ច។ យើងមិនសមនឹងទទួលបានការដកដង្ហើមម្តងទៀតឡើយ។ មិនគួរមានការលើកលែងទោសទេ។ យើងក៏មិនសមនឹងទទួលបានពេលវេលាទៀតដែរ។ ដូច្នេះ យ៉ាងច្បាស់ក្នុងអត្ថន័យមួយចំនួន ពេលវេលាដែលព្រះអង្គនៅប្រទានដល់យើងគឺដោយសារព្រះគុណ។ ហើយព្រះគុណសម្រាប់មនុស្សមានបាបទាមទារឲ្យមានការបង់ថ្លៃ ឬក៏ការទិញយក ឬក៏ការធានាពីព្រះដ៏បរិសុទ្ធផ្ទាល់។ គឺព្រះគ្រីស្ទ



50 QnA John Piper Final 1.5.indd 73 25/01/2024 09:22:38 AM

ហើយដែលជាអង្គដែលប្រទានការនេះ។

ដូច្នេះ យើងខ្ញុំមានទំនោរក្នុងការនិយាយថា «ប្រាកដណាស់! ចំណុចពិតដែលថា អ្នកដែលមិនទទួលបានការជ្រើសតាំង អ្នកមិនជឿនៅពាសពេញផែនដីនេះកំពុងតែនៅបន្តទទួលខ្យល់ដង្ហើមជីវិត ហើយនៅមានឱកាសក្នុងការជឿគឺជាអំណោយមកពីព្រះ។ ដូចដែលថា ការដែលនៅមានឱកាសទទួលយកដំណឹងល្អក៏ជាអំណោយទានដែរ។ ហើយគឺឈើឆ្កាងហើយដែលផ្តត់ផ្គង់ឱកាសនេះ។»

នេះគឺជាចំណុចដែលយើងគួរចងចាំ៖ កណ្ឌគម្ពីរ (រ៉ូម ២:៤-៥) បានចែងថា «តើអ្នកមិនដឹងថា សេចក្តីសប្បុរសរបស់ព្រះ នាំអ្នកឲ្យប្រែចិត្តទេឬ? ប៉ុន្តែដោយអ្នកមានចិត្តរឹងរូស ហើយមិនព្រមប្រែចិត្ត នោះអ្នកកំពុងតែប្រមូលសេចក្តីក្រោធ ទុកសម្រាប់ខ្លួននៅថ្ងៃនៃសេចក្តីក្រោធវិញ ជាថ្ងៃដែលព្រះនឹងសម្តែងការជំនុំជម្រះដ៏សុចរិត»។

ដូច្នេះ ប្រសិនបើអ្នកដែលមិនទទួលបានការជ្រើសតាំងបដិសេធ—ហើយពួកគាត់ក៏ពិតជាបដិសេធមែនដែរ—គឺពួកគាត់កំពុងតែបដិសេធព្រះគុណមួយនេះ ហើយព្រះគុណនោះផ្ទាល់ក៏បានក្លាយជាការថ្កោលទោសបន្ថែមលើពួកគាត់។ ការនេះក៏ធ្វើឲ្យយើងខ្ញុំងឿងឆ្ងល់ផងដែរថា «តើក្នុងអត្ថន័យមួយណាដែលថាវាជាព្រះគុណ?» ក្នុងអត្ថន័យមួយវាគឺជាព្រះគុណ។ វាគឺជាការផ្តល់ជូនដ៏ពិត ហើយក៏ជាឱកាសដ៏ពិតផងដែរ។ ប៉ុន្តែ ប្រសិនបើលោកអ្នកបដិសេធព្រះគុណនេះ នោះវានឹងវាយបកមករកលោកអ្នកវិញ ហើយក៏នឹងកាន់តែបង្កើនបរិមាណនៃការថ្កោលទោសលើសដើមជាមិនខាន។

វាប្រៀបដូចជាការបង្ហាញសេចក្តីសប្បុរសទៅកាន់បុគ្គលណាម្នាក់ដែលគាត់បដិសេធសេចក្តីសប្បុរសនោះ នោះវានឹងកាន់តែបង្ហាញថាគាត់អាក្រក់ប៉ុណ្ណាហើយ។ ហើយការដែលវាបង្ហាញថា គាត់អាក្រក់ខ្លាំងប៉ុណ្ណាក៏នឹងកាន់តែនាំមកនូវការថ្កោលទោសខ្លាំងលើសដើមទៀតលើគាត់ផងដែរ។



50 QnA John Piper Final 1.5.indd 74 25/01/2024 09:22:39 AM

ចម្លើយដែលយើងខ្ញុំគិតគឺថា ប្រាកដណាស់! យើងខ្ញុំគិតថា ព្រះគុណដ៏ពិត ព្រះគុណទូទៅដ៏ពិត ការផ្ដល់ជូននូវសេចក្ដីសង្គ្រោះដ៏ពិត—ឥឡូវនេះ ចំណុចដែលថាលោកអ្នកកំពុងតែអានអត្ថបទមួយនេះ—គឺជាព្រះគុណ។ ហើយប្រសិនបើលោកអ្នកមិនមែនជាគ្រីស្ទបរិស័ទ នោះព្រះអង្គកំពុងតែផ្ដល់ជូនព្រះគុណដល់លោកអ្នកនៅពេលវេលានេះតែម្ដង តាមរយៈការដាស់តឿនរបស់យើងខ្ញុំថា ប្រសិនបើលោកអ្នកបដិសេធ នោះការថ្កោលទោសក៏នឹងកាន់តែលើសដើមហើយ។

ហើយនេះឯង គឺជាអំណោយទានចំពោះលោកអ្នកឥឡូវនេះដែលព្រះជាម្ចាស់ទំនងជានឹងសព្វព្រះហឫទ័យប្រើប្រាស់នៅពេលក្រោយ ដើម្បីឲ្យលោកអ្នកទទួលស្គាល់ថា «ទេ! ខ្ញុំមិនចង់ឲ្យការថ្កោលទោសលើជីវិតរបស់យើងខ្ញុំគុណជាទ្វេលើសដើមទៀតនោះទេ។ ខ្ញុំចង់ឆ្លើយតបនឹងព្រះគុណនេះនៅពេលនេះតែម្ដង»។

នេះឯងគឺជាអ្វីដែលយើងខ្ញុំគិតថាគួរជាការឆ្លើយតបចំពោះអត្ថបទមួយនេះ៖ សូមទទួលយកព្រះគុណចុះ។ ដោយសារលោកអ្នកកំពុងតែមានជីវិតឥឡូវនេះ នោះលោកអ្នកក៏នៅមានឱកាសក្នុងការទទួលជឿ ហើយទទួលបានសេចក្ដីសង្គ្រោះដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 75 25/01/2024 09:22:39 AM

50 QnA John Piper Final 1.5.indd 76 25/01/2024 09:22:39 AM

## សំណួរទី១៣៖
# តើខ្ញុំដឹងថាខ្ញុំបានទទួលសេចក្ដីសង្គ្រោះ បានដោយរបៀបណា?

កិច្ចការ ១៦:៣១ «ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបាន សង្គ្រោះហើយ»។

យ៉ូហាន ៣:១៦ «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបាន ជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»។

រ៉ូម ៣:២៨ «ដ្បិតយើងខ្ញុំអាងថា មនុស្សបានរាប់ជាសុចរិត ដោយសារ ជំនឿ គឺមិនមែនដោយការប្រព្រឹត្តតាមក្រឹត្យវិន័យទេ»។

ហេតុផលដែលសាវ័ក យ៉ូហាន បានកត់ត្រានៅកណ្ឌគម្ពីរយ៉ូហានគឺ «ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រា នៃព្រះដ៏ពិត ហើយឲ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយ មានជំនឿ» (យ៉ូហាន ២០:៣១)។

### ចូរប្រាប់ពីអ្វីដែលលោកអ្នកឃើញ

សរុបសេចក្ដីមក យើងអាចសន្និដ្ឋានបានយ៉ាងច្បាស់ថា រាល់ឯកសារ ទាំងអស់ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីគឺ៖ យើងបានសង្គ្រោះ ដោយសារជំនឿ ជឿលើអង្គព្រះយេស៊ូវគ្រីស្ទ។ ចូរផ្ចង់ចិត្តរបស់យើងដោយយកចិត្តទុកដាក់ ទៅលើព្រះគ្រីស្ទក្នុងកណ្ឌគម្ពីរដំណឹងល្អដែលមានដូចខាងក្រោម៖យ៉ូហាន ម៉ាថាយ ម៉ាកុស លូកា ហើយនៅក្នុងព្រះគម្ពីរទាំងមូល។ ចូរសម្លឹងមើល ដោយផ្ដោតអារម្មណ៍របស់លោកអ្នកទៅកាន់ព្រះគ្រីស្ទ ហើយទទួលការថ្លែង ប្រាប់ថា«ព្រះយេស៊ូវគ្រីស្ទគឺជាអម្ចាស់» ហើយបន្ទាប់មកទៀត ចូរនិយាយ



50 QnA John Piper Final 1.5.indd 77 25/01/2024 09:22:39 AM

អំពីអារម្មណ៍របស់លោកអ្នកទៅកាន់ព្រះថា៖ «ខ្ញុំទទួលទ្រង់ ខ្ញុំស្រឡាញ់ទ្រង់ ទ្រង់គឺជាព្រះពិតរបស់ខ្ញុំ, ទ្រង់គឺជាព្រះអម្ចាស់របស់ខ្ញុំ ហើយទ្រង់ពិតជាទ្រព្យសម្បត្តិរបស់ខ្ញុំ»។ ចូរអធិស្ឋានលន់តួបែបយ៉ាងនោះចុះ។ ចូរនិយាយឲ្យខ្លួនឯងបានឮនូវអ្វីដែលលោកអ្នកកំពុងនិយាយចុះ។ ចូរប្រាប់កិច្ចការទាំងអស់នោះទៅកាន់អ្នកដទៃផង។ ចូរនិយាយប្រាប់ការនេះទៅកាន់ប្តីប្រពន្ធរបស់លោកអ្នក ចូរនិយាយការនេះទៅកាន់កូនៗរបស់លោកអ្នក ហើយចូរនិយាយប្រាប់ការនេះទៅកាន់មិត្តភក្តិរបស់លោកអ្នកថា «ព្រះយេស៊ូវគឺជាព្រះរបស់ខ្ញុំ»។

ព្រះគម្ពីរបានលើកឡើងថា គ្មាននរណាម្នាក់អាចនិយាយថា «ព្រះយេស៊ូវគឺជាព្រះអម្ចាស់» ដោយមិនមានព្រះវិញ្ញាណបរិសុទ្ធបាននោះឡើយ។ តើនេះមិនមែនជារឿងដ៏អស្ចារ្យទេឬអី? គ្មាននរណាអាចនិយាយថា «ព្រះយេស៊ូវគឺជាព្រះអម្ចាស់» ដោយខ្លួនឯងបានទេ។ ដូច្នេះ បើសិនលោកអ្នកនិយាយការនេះ ហើយវាពិតជាមានអត្ថន័យដូចដែលលោកអ្នកបានលើកឡើងមែននោះពិតជាមានន័យថា ព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងជីវិតរបស់លោកអ្នកយ៉ាងជាក់ច្បាស់ហើយ ពោលគឺលោកអ្នកមានព្រះវិញ្ញាណបរិសុទ្ធមកគង់នៅជាមួយ។

## ចូរទទួលយក ហើយទទួលជឿ

ដូច្នេះ តើអ្វីទៅជាជំនឿ និងការជឿដូចនេះ? ក្នុងកណ្ឌគម្ពីរ (យ៉ូហាន ១:១២) មានចែងថា "ប៉ុន្តែ អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ»។ ការទទួលយក និងការទទួលជឿគឺជាការបកស្រាយប្រទាក់គ្នាទៅវិញទៅមក ហើយរីឯការទទួលយកមានន័យថា ពេលដែលទ្រង់យាងមកគង់នៅក្នុងចិត្តរបស់លោកអ្នកទុកជាព្រះសង្គ្រោះ ជាព្រះអម្ចាស់ និងជា



50 QnA John Piper Final 1.5.indd 78 25/01/2024 09:22:39 AM

ទ្រព្យសម្បត្តិ ហើយជាអង្គប្រឹក្សាយោបល់ នោះលោកអ្នកនឹងមិនបដិសេធទ្រង់ឡើយ។ លោកអ្នកទទួលយកនូវរាល់អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានសម្រេចនៅក្នុងព្រះគ្រីស្ទ។ ការទទួលយកគឺជាការស្វាគមន៍ និងការចុះចូលចំពោះទ្រង់។

ព្រះយេស៊ូវបានមានបន្ទូលថា «ខ្ញុំជានំប៉័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ» (យ៉ូហាន ៦:៣៥)។ ហេតុនេះហើយបានជាការជឿគឺជាការស្វែងរកទ្រង់ដើម្បីបំពេញការស្រេកឃ្លាន។ ឬក៏ជាការព្រមទទួលយកការចាក់បង្ហូរនូវព្រះគុណដែលហូរចេញពីអ្វីដែលទ្រង់បានធ្វើនៅលើឈើឆ្កាង ហើយព្រមទទួលស្គាល់ការនោះថា ទ្រង់អាចបំពេញរាល់ការស្រេកឃ្លានទាំងអស់បាន។

កណ្ឌគម្ពីរ ២កូរិនថូស ៤:៤ មានចែងថា «ព្រះរបស់លោកីយ៍នេះ បានបង្អាប់ដល់គំនិតពួកគេដែលមិនជឿ ក្រែងរស្មីពន្លឺនៃដំណឹងល្អ ដែលសម្ដែងពីសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះ បានភ្លឺមកដល់គេ»។ ដូច្នេះហើយ អ្វីដែលយើងបានមើលឃើញពេលដែលព្រះអង្គបើកភ្នែកឲ្យយើងបានឃើញថា ព្រះគ្រីស្ទគឺពោរពេញទៅដោយសិរីល្អ។ ព្រះគ្រីស្ទគឺជា «រូបអង្គនៃព្រះដ៏មើលមិនឃើញ» (កូឡុស ១:១៥)។ ព្រះគ្រីស្ទគឺជាមនុស្សដ៏ពិសេសអស្ចារ្យដែលផែនដីនេះមិនធ្លាប់មានពីមុនមកឡើយ ហើយជាព្រះសង្គ្រោះដ៏អស្ចារ្យ ជាព្រះអម្ចាស់ដ៏ឧត្តុង្គឧត្តម ជាគ្រូបង្រៀនដ៏ឆ្នើម ជាទីប្រឹក្សាដ៏ល្អប្រសើរណាស់ ជាមិត្តសម្លាញ់ដ៏ស្និទ្ធស្នាលបំផុត។ ទាំងអស់នេះហើយ គឺជាអ្វីដែលជំនឿទទួលបានចេញពីព្រះគ្រីស្ទក្នុងការដែលទទួលជឿ។

ទំនងបុគ្គលដែលបានសួរសំណួរទាំងនេះធ្លាប់បានគិតរួចមកហើយអំពីខគម្ពីរដែលបានលើកឡើងទាក់ទងនឹងការល្បងលជំនឿនៅក្នុងជីវិតរបស់យើង។ ហើយយើងក៏អាចនិយាយអំពីការទាំងនោះបានផងដែរ (ប្រហែលនៅក្នុងពេលវេលាមួយជាក់លាក់ ឬនៅពេលក្រោយៗទៀត) ប៉ុន្តែខ្ញុំនឹង

គ្រាន់តែលើកឡើងថាកណ្ឌគម្ពីរ (យ៉ូហានទី១) គឺត្រូវបានសរសេរបង្ហាញប្រាប់ដោយផ្តល់ឲ្យជាច្រើននូវការល្បងល។ យើងអាចសរុបសេចក្តីដូចតទៅ៖ តើជីវិតលោកអ្នកបានឆ្លុះបញ្ចាំងពីតម្លៃលើព្រះគ្រីស្ទ ដែលលោកអ្នកពិតជាបានទទួលយកជាព្រះសង្គ្រោះដែរឬទេ? ផលផ្លែនិងទង្វើមិនមែនជាអ្វីដែលនាំឲ្យព្រះជាម្ចាស់រាប់លោកអ្នកជាសុចរិតនោះឡើយ។ ដើមឈើនៃជំនឿគឺជាដើមឈើដ៏ល្អ។ ផលផ្លែគឺជាអំណះអំណាងដែលបញ្ជាក់ថាដើមឈើនោះពិតជាល្អពិតមែន។

## ដើរក្នុងពន្លឺ

ពេលដែលយើងនិយាយវែកញែកនឹងបកស្រាយអំពីចំណុចល្អនៅត្រង់កន្លែងនេះ យើងមិនសំដៅលើភាពល្អឥតខ្ចោះនោះឡើយ។ យើងខ្ញុំគិតថាមានមនុស្សជាច្រើនប្រាកដជាមានការស្ទាក់ស្ទើរតប់ប្រមល់ជាមួយខ្លួនឯងត្រង់ថា តើខ្ញុំពិតជាបានសង្គ្រោះមែនឬអត់ ? ដោយព្រោះពួកគាត់មិនមានភាពច្បាស់លាស់ទាក់ទងទៅនឹងការយល់ដឹងអំពីការរីកចម្រើនលូតលាស់របស់គ្រីស្ទបរិស័ទ រួមទាំងរបៀបដែលអំពើបាបកំពុងតែដំណើរការ។ ដូច្នេះយើងខ្ញុំសូមបញ្ចប់នៅតែត្រឹមនេះ៖ «តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្តីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សម្អាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់» (១យ៉ូហាន ១:៧)។ ការដើរក្នុងពន្លឺគឺជាការដ៏ចាំបាច់ណាស់! ព្រះលោហិតរបស់ព្រះយេស៊ូវសម្អាតយើងចេញពីអំពើបាបទាំងអស់ ប្រសិនបើយើងដើរក្នុងពន្លឺ។ តើនេះមានន័យយ៉ាងដូចម្តេច៖ ការដើរក្នុងពន្លឺគឺជាការដ៏ល្អឥតខ្ចោះមែនឬ? មិនមែនទេ! ដោយព្រោះថានឹងគ្មានអំពើបាបណា ដើម្បីឲ្យសម្អាតទៀតឡើយ។ ដូច្នេះការដើរក្នុងពន្លឺមានន័យមួយផ្សេងទៀត។



50 QnA John Piper Final 1.5.indd 80 25/01/2024 09:22:40 AM

សូមបន្តអានបន្ថែមទៀត «បើសិនជាយើងនិយាយថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងយើងទេ»។ ម្យ៉ាងវិញទៀត យើងមិនបានដើរក្នុងពន្លឺ។ ការដើរក្នុងពន្លឺនឹងមិនមានការបោកបញ្ឆោតឡើយ។  ការដើរក្នុងពន្លឺនឹងនាំលោកអ្នកឲ្យមើលឃើញ។ តើលោកអ្នកឃើញអ្វី? បើលោកអ្នកឃើញនូវអំពើបាបដែលលោកអ្នកទើបតែបានប្រព្រឹត្ត ហើយចុះតើលោកអ្នកគួរនឹងធ្វើយ៉ាងដូចម្តេចជាមួយនឹងអំពើបាបទាំងនោះ? នៅក្នុងខ៩ បានលើកឡើងថា « បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិតប្រយោជន៍នឹងអត់ទោសបាបឲ្យយើង នោះទ្រង់នឹងសម្អាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង»។

ដូច្នេះ មានមនុស្សមួយចំនួនគិតថា ការដើរក្នុងពន្លឺទំនងជាមានន័យថា ខ្ញុំមិនអាចដើរក្នុងពន្លឺបានទេ។ ខ្ញុំមិនអាចឈប់ប្រព្រឹត្តអំពើបាបបានទេ។ វាមិនដូច្នោះទេ! នោះមិនមែនជាអត្ថន័យនៃការដើរក្នុងពន្លឺ។ ការដើរក្នុងពន្លឺមានន័យថា លោកអ្នកយល់ដឹងអំពីដំណឹងល្អយ៉ាងពិតប្រាកដ ហើយយល់ពីភាពបរិសុទ្ធរបស់ព្រះជាម្ចាស់យ៉ាងច្បាស់ យល់ពីការអាក្រក់នៃអំពើបាបយ៉ាងច្បាស់ ហើយពេលដែលលោកអ្នកភ្លាត់ស្នៀតក្នុងការធ្លាក់ក្នុងសេចក្តីល្បួងនៃអំពើបាប នោះលោកអ្នកនឹងប្រតិកម្មភ្លាមៗដោយនិយាយថា «ខ្ញុំស្អប់ការនេះណាស់ ឲ្យខ្ញុំសុំទោសព្រះវរបិតា សូមទ្រង់អត់ទោសបាបឲ្យកូនផង»។ លោកអ្នកនឹងលន់តួអំពើបាបនោះ ហើយលោកអ្នកនឹងទទួលបានការលើកលែងទោស ហើយបន្តរស់នៅសម្រាប់ព្រះអម្ចាស់ ដែលទ្រង់ជាទ្រព្យសម្បត្តិដ៏ធំមហិមាទាក់ទងនឹងព្រះគុណដែលទ្រង់បានផ្តល់មកដល់លោកអ្នក។

## អំណោយទានរបស់ព្រះវិញ្ញាណនៃការធានា

សរុបសេចក្ដីមក ខ្ញុំចង់លើកឡើងថា ការធានាសេចក្ដីសង្គ្រោះគឺជាអំណោយទានពីព្រះវិញ្ញាណបរិសុទ្ធ «អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបម្រើ ឲ្យត្រូវភ័យខ្លាចទៀតឡើយ គឺបានទទួលនិស្ស័យជាកូនចិញ្ចឹមវិញ ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱ! អ័ប្បា ព្រះវរបិតាអើយ! ហើយព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ» (រ៉ូម ៨:១៥)។ ពេលដែលលោកអ្នកស្រែកឡើងថា «ឱ! អ័ប្បា ព្រះវរបិតា ព្រះយេស៊ូវ ព្រះអម្ចាស់អើយ!» នោះគឺជាការដែលព្រះវិញ្ញាណបរិសុទ្ធបានអះអាងជាមួយនឹងវិញ្ញាណរបស់លោកថាជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ហើយ។ ដូច្នេះ ចូរទូលសូមនូវអំណោយទាននោះចុះ។ចូរទូលសូមឲ្យទ្រង់ផ្ដល់នូវអំណោយទាននៃការធ្វើបន្ទាល់ដោយផ្ទាល់របស់ទ្រង់ដែលថា លោកអ្នកជាកូនរបស់ព្រះអង្គ។

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ



50 QnA John Piper Final 1.5.indd 82 25/01/2024 09:22:41 AM

# សំណួរទី១៩៖
# តើខ្ញុំដឹងថាព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងខ្ញុំដោយរបៀបណា?

*មានសំណួរតែមួយចំនួនប៉ុណ្ណោះដែលសំខាន់ដូចសំណួរមួយនេះ។ យើងទាំងអស់គ្នាសុទ្ធតែធ្លាប់សួរនូវសំណួរនេះ។ ហើយនេះក៏ជាសំណួរមួយដែលសូម្បីតែគ្រូគង្វាលក៏សួរដែរ៖ «សួស្ដីលោកគ្រូ! ជម្រាបសួរក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទនៃយើង! ខ្ញុំជាគ្រូគង្វាលម្នាក់នៅជនបទ។ សូមលោកគ្រូជួយប្រាប់ខ្ញុំថា តើខ្ញុំអាចដឹងថាព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងខ្ញុំដោយរបៀបណា? ខ្ញុំបានទទួលជឿព្រះអង្គកាលខ្ញុំនៅក្មេង ហើយឥឡូវនេះខ្ញុំក៏កំពុងតែបម្រើព្រះអង្គដែរ ប៉ុន្តែខ្ញុំនៅមិនទាន់បានទទួលបទពិសោធន៍នៃអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធក្នុងជីវិតខ្ញុំនៅឡើយ—តាមដែលអាចមើលឃើញ។ សូមលោកគ្រូជួយពន្យល់ផងថា តើខ្ញុំអាចទទួលបានការបំពេញដោយព្រះវិញ្ញាណបរិសុទ្ធដោយរបៀបណាទៅ? តើការនោះមានលក្ខណៈយ៉ាងដូចម្ដេច?»។*

ខ្ញុំចង់ចាប់ផ្ដើមឆ្លើយដោយបកស្រាយឲ្យច្បាស់សិន៖ មិត្តអ្នកសួរសំណួររបស់យើងកំពុងតែសួរនូវសំណួរពីរយ៉ាងដោយដាច់ដោយឡែកពីគ្នា តែខ្ញុំមិនប្រាកដថាគាត់ដឹងថាគាត់កំពុងតែសួរនូវសំណួរពីរយ៉ាង ឬក៏អត់នោះទេ។ ដូច្នេះ ចំណុចដំបូងរបស់ខ្ញុំគឺចង់លើកឡើងឲ្យច្បាស់ថា គាត់យល់ថានេះគឺជាសំណួរពីរយ៉ាងដោយយោងតាមព្រះគម្ពីរ។

សំណួរដំបូងគឺ៖ «តើខ្ញុំអាចដឹងថាព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងខ្ញុំដោយរបៀបណា?»។ ហើយសំណួរទី២៖ «តើខ្ញុំអាចទទួលបានការបំពេញដោយព្រះវិញ្ញាណបរិសុទ្ធដោយរបៀបណាទៅ?»។ វាពិតជាអាចកើតឡើងមែន



50 QnA John Piper Final 1.5.indd 83 25/01/2024 09:22:41 AM

ត្រង់ថា ក្នុងជីវិតជាគ្រីស្ទបរិស័ទដ៏ពិតក៏មានពេលដែលយើងមិនទទួលការបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ ហើយនេះគឺជាចំណុចដែលខ្ញុំមិនដឹងជាប្រាកដថាគាត់យល់ ឬក៏អត់នោះទេ។ ប៉ុន្តែ វាមិនអាចទៅរួចបានឡើយ ដែលថា បុគ្គលម្នាក់ជាគ្រីស្ទបរិស័ទ ប៉ុន្តែគាត់មិនមានព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងគាត់។

## គ្រីស្ទបរិស័ទគ្រប់ៗរូបមានព្រះវិញ្ញាណ

ជីវិតជាគ្រីស្ទបរិស័ទគឺជាជីវិតដែលមានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទគង់ជាមួយ។ កណ្ឌគម្ពីរ រ៉ូម ៨:៩ បានចែងថា “តែបើសិនជាព្រះវិញ្ញាណនៃព្រះសណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា នោះអ្នករាល់គ្នាមិននៅខាងសាច់ឈាមទៀតទេ គឺនៅខាងវិញ្ញាណវិញ ប៉ុន្តែ បើអ្នកណាគ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ”។

ដូច្នេះ បុគ្គលណាម្នាក់មិនអាចជាគ្នាគ្រីស្ទបរិស័ទបានឡើយ ប្រសិនបើគាត់មិនមានព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងគាត់។ បន្ទាប់មកក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:១៨ សាវ័ក ប៉ុល បានមានប្រសាសន៍ទៅកាន់គ្រីស្ទបរិស័ទដែលមានព្រះវិញ្ញាណបរិសុទ្ធ។ ហើយយើងដឹងអំពីចំណុចនេះ ពីព្រោះនៅក្នុងជំពូកទី១ គាត់បានលើកឡើងថា “ឯអ្នករាល់គ្នា [អ្នកអាន] ... ទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា ព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្ត ពីដំណើរកេរអាកររបស់យើងរាល់គ្នា ទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឲ្យយើងនោះ សម្រាប់ជាសេចក្ដីសរសើរដល់សិរីល្អនៃទ្រង់” (អេភេសូរ ១:១៣–១៤)។ បន្ទាប់មក គាត់ក៏បានសរសេរក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:១៨–២០ ថា៖

“កុំឲ្យស្រវឹងស្រាដែលនាំឲ្យព្រើលចិត្តឡើយ តែ [គ្រីស្ទបរិស័ទដែលមានព្រះវិញ្ញាណ] ចូរឲ្យបានពេញជាព្រះវិញ្ញាណវិញ ហើយនិយាយគ្នាទៅវិញទៅ



50 QnA John Piper Final 1.5.indd 84 25/01/2024 09:22:41 AM

មក ដោយបទទំនុកតម្កើង ទំនុកបរិសុទ្ធ នឹងចម្រៀង ខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតាជាដរាប ក្នុងគ្រប់ការទាំងអស់ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ»។

និយាយម្យ៉ាងទៀតទៅ ការពេញទៅដោយព្រះវិញ្ញាណគឺមានកម្រិត ឬក៏មានលក្ខណៈសម្បត្តិនៃការដែលមានអំណាចពីព្រះវិញ្ញាណដែលពេលខ្លះមានច្រើន ហើយពេលខ្លះទៀតមានតិច។ ឧទាហរណ៍៖ ក្នុងកណ្ឌគម្ពីរកិច្ចការ ៤:៣១ បានលើកឡើងអំពីគ្រីស្ទបរិស័ទដែលបានជួបជុំគ្នាដើម្បីអធិស្ឋានថា «កាលបានអធិស្ឋានរួចហើយ នោះកន្លែងដែលគេប្រជុំគ្នាក៏រញ្ជួយ ហើយគេបានពេញជាព្រះវិញ្ញាណបរិសុទ្ធទាំងអស់គ្នា រួចក៏ផ្សាយព្រះបន្ទូលដោយចិត្តក្លាហាន»។

ដូច្នេះ លទ្ធផលមួយនៃបទពិសោធន៍ដ៏ពិសេស មានតម្លៃ ផ្អែមល្ហែម ពេញដោយអំណាចព្រះចេស្ដា និងប្លែកនៃការមានពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធគឺថា យើងបានត្រៀមខ្លួនជាស្រេច មានសេរីភាព និងមានភាពក្លាហានក្នុងការធ្វើបន្ទាល់អំពីព្រះគ្រីស្ទ។ ឬក៏ថា យោងតាមកណ្ឌគម្ពីរអេភេសូរជំពូកទី៥ យើងបានត្រៀមខ្លួនជាស្រេច មានសេរីភាព និងមានចិត្តប្រាថ្នាហូរហៀរដោយបទទំនុកតម្កើង ទំនុកបរិសុទ្ធ នឹងចម្រៀងខាងឯវិញ្ញាណ និងកាអរព្រះគុណព្រះជាម្ចាស់ខ្លាំងជាងមុន។

ការមានព្រះវិញ្ញាណបរិសុទ្ធគឺជាចំណុចសម្គាល់ដ៏សំខាន់មួយដែលថាបុគ្គលណាម្នាក់ជាគ្រីស្ទបរិស័ទ។ លោកអ្នកមិនអាចធ្វើជាគ្រីស្ទបរិស័ទបាននោះទេ ប្រសិនបើលោកអ្នកមិនមានព្រះវិញ្ញាណ។ គ្មានគ្រីស្ទបរិស័ទណាដែលមិនមានព្រះវិញ្ញាណបរិសុទ្ធនោះទេ ។ ការមាន*ពេញទៅដោយ*ព្រះវិញ្ញាណបរិសុទ្ធគឺជាអ្វីដែលអ្នកជឿគ្រប់ៗរូបគួរតែស្វែងរកក្នុងបទពិសោធន៍សម្រាប់ជាប្រយោជន៍ដ៏អស្ចារ្យ សេរីភាពដែលលើកតម្កើងព្រះគ្រីស្ទ ភាព

ក្លាហាន និងអំណាចដែលការនោះនាំឲ្យកើតឡើង។

គាត់បានសួរ "ដូច្នេះ តើខ្ញុំអាចដឹងថាព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងខ្ញុំដោយរបៀបណា?"។ ចម្លើយរបស់ខ្ញុំគឺថា៖ "តាមពិតទៅ ប្រសិនបើលោកអ្នកគឺជាគ្រីស្ទបរិស័ទមែន នោះលោកអ្នកអាចដឹងថាខ្លួនមានព្រះវិញ្ញាណបាន —ប្រសិនបើលោកអ្នកពិតជាបានកើតជាថ្មីមែន"។

## សណ្ឋានរបស់យើងចំពោះព្រះគ្រីស្ទ

ដើម្បីឲ្យយើងអាចឆ្លើយសំណួរនេះបាន ដោយយោងតាមព្រះគម្ពីរ វាជាការដ៏សំខាន់ណាស់ដែលលោកអ្នកស្គាល់អំពីសណ្ឋានរបស់ខ្លួនមុនលោកអ្នកទទួលជឿសិន។ លុះត្រាតែលោកអ្នកស្គាល់ពីព្រះគម្ពីរ មិនមែនពីបទពិសោធន៍ជាចម្បងៗ—ហើយខ្ញុំក៏មិនបារម្ភអំពីមនុស្សនានាដូចខ្ញុំជាដើមដែលមិននឹកចាំអំពីពេលដែលខ្ញុំទទួលជឿ ដូច្នេះសូមអនុញ្ញាតឲ្យខ្ញុំពន្យល់អំពីការនេះឲ្យបានច្បាស់លាស់សិន៖ ខ្ញុំកំពុងតែលើកឡើងថា ដាច់ខាតយើងត្រូវតែរៀនពីព្រះគម្ពីរអំពីសណ្ឋានដែលយើងនៅក្នុងនោះមុនពេលយើងទទួលជឿជាមុនសិន។ មិនមែនពីការចងចាំរបស់អ្នកម្ដាយយើង ឬក៏ការចងចាំរបស់យើង ឬក៏ពីទីបន្ទាល់របស់អ្នកណាម្នាក់ផ្សេងទៀតអំពីសណ្ឋានដ៏អាក្រក់ៗរបស់យើងនោះទេ *ប៉ុន្តែពីព្រះគម្ពីរផ្ទាល់*។

យើងរៀនអំពីសណ្ឋានរបស់យើងពីព្រះគម្ពីរ។ មានមនុស្សច្រើននាក់ (រាប់ពាន់នាក់) បានទទួលការបង្រៀនដ៏អាក្រក់អំពីសណ្ឋានដែលពួកគេបានស្ថិតនៅក្នុងនោះមុនពេលដែលគេទទួលជឿ។ ហើយចម្លើយដែលចេញពីព្រះគម្ពីរគឺដូចនេះ៖

យើងស្លាប់ខាងឯព្រលឹងវិញ្ញាណ (អេភេសូរ ២:១, ៤)។

យើងមិនមានសមត្ថភាពក្នុងការទទួលនូវអ្វីៗពីព្រះវិញ្ញាណទេ (១កូរិនថូស ២:១៤)។



50 QnA John Piper Final 1.5.indd 86 25/01/2024 09:22:41 AM

សាវ័ក ប៉ុល បានលើកឡើងថា យើងស្ថិតក្នុងផ្នត់គំនិតនៃសាច់ឈាម ដែលមិនមានសមត្ថភាពក្នុងការចុះចូលចំពោះព្រះជាម្ចាស់ ឬក៏ការផ្គាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់បាន (រ៉ូម ៨:៧–៨)។

យើងមិនមានអំណាចក្នុងការបំផ្លាស់បំប្រែឆន្ទៈ ដួងចិត្ត ចិត្តគំនិត ឬក៏ការស្រឡាញ់របស់យើងបាននោះទេ។ យើងបានបែរចេញពីព្រះជាម្ចាស់ទាំងស្រុង។ បើអញ្ចឹងមែន តើយើងបានទទួលព្រះវិញ្ញាណបរិសុទ្ធដោយរបៀបណាទៅ? វាគឺជារឿងអស្ចារ្យ។ គឺដោយព្រះគុណដែលមានពេញទៅដោយអធិបតេយ្យភាព គឺព្រះគុណដ៏មានអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានដាក់លើយើងកាលយើងមិនអាចជួយខ្លួនឯងបាន។

**ការប្រោសពីស្លាប់**

“ឯខ្យល់ ចង់បក់ទៅឯណា ក៏ចេះតែបាន” ព្រះយេស៊ូវបានមានបន្ទូល “ហើយអ្នកឮសូរសព្ទ តែមិនដឹងជាមកពីណា ឬទៅឯណាទេ អស់អ្នកណាដែលកើតមកពីព្រះវិញ្ញាណ នោះក៏ដូច្នោះដែរ” (យ៉ូហាន ៣:៨)។ ការអស្ចារ្យបានកើតឡើង។ ព្រះវិញ្ញាណបានបើកភ្នែករបស់លោកអ្នក (កិច្ចការ ១៦:១៤)។ ព្រះជាម្ចាស់បានចែងចាំងក្នុងដួងចិត្តរបស់លោកអ្នកដោយមានពេញទៅដោយសព្វានុភាព ដើម្បីបណ្ដាលឲ្យលោកអ្នកអាចឃើញពន្លឺនៃដំណឹងល្អនៃភាពស្រស់ស្អាត និងសិរីល្អរបស់ព្រះគ្រីស្ទ (២កូរិនថូស ៤:៦)។ ព្រះអង្គបានប្រទានឲ្យលោកអ្នកមានជីវិត ដើម្បីកុំឲ្យលោកអ្នកនៅបន្តស្លាប់ខ្វាក់ ឬក៏ទាស់ប្រឆាំងនឹងព្រះជាម្ចាស់ មិនអាចមានសមត្ថភាពក្នុងការមិនអាចផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បាន មិនបន្តបះបោរ និងមិនបន្តមើលឈើឆ្កាងថាជាសេចក្ដីល្ងីល្ងើ។

ផ្ទុយទៅវិញ លោកអ្នកបានឃើញសិរីល្អរបស់ព្រះគ្រីស្ទក្នុងដំណឹងល្អ។ លោកអ្នកបានឃើញថា វាស្រស់ស្អាតជាង និងគួរឲ្យប្រាថ្នាចង់បានខ្លាំង



50 QnA John Piper Final 1.5.indd 87 25/01/2024 09:22:42 AM

ជាងអ្វីៗលើផែនដីនេះទៅទៀត។ ព្រះវិញ្ញាណរបស់ព្រះបានធ្វើឲ្យលោកអ្នកមានជីវិត។ ព្រះអង្គពិត មានតម្លៃ ហើយស្រស់ស្អាត។ លោកអ្នកលែងនៅជាខ្វាក់ទៀត។ លោកអ្នកបានឃើញឈើឆ្កាង ព្រះគ្រីស្ទ ផ្លូវរបស់ព្រះអង្គ និងព្រះបន្ទូលរបស់ទ្រង់ថាគួរឲ្យចាប់អារម្មណ៍ខ្លាំងជាងសេចក្ដីសន្យានានានៃអំពើបាប។ ជាជាងទាស់ប្រឆាំងនឹងព្រះជាម្ចាស់ លោកអ្នកបានស្រឡាញ់ព្រះអង្គ ហើយចង់ផ្គាប់ព្រះហឫទ័យដល់ទ្រង់។ ជាជាងមានមន្ទិលសង្ស័យ និងចិត្តរឹងរូស នោះលោកអ្នកបានឃើញសេចក្ដីសន្យារបស់ព្រះអង្គថាពិត ហើយក៏បានទុកចិត្តលើសេចក្ដីសន្យាទាំងនោះ ដោយបានដាក់ទំនុកចិត្តលើសេចក្ដីសន្យានោះ។ ព្រះគ្រីស្ទបានក្លាយជាទ្រព្យសម្បត្តិរបស់លោកអ្នក។

នោះឯងគឺជារបៀបដែលលោកអ្នកអាចដឹងថា ខ្លួនកំពុងតែមានជីវិត។ នោះឯងគឺជារបៀបដែលលោកអ្នកអាចដឹងថា ខ្លួនបានទទួលជឿ។ នោះឯងគឺជារបៀបដែលលោកអ្នកអាចដឹងថា ខ្លួនមានជំនឿ។ នោះឯងគឺជារបៀបដែលលោកអ្នកអាចដឹងថា ខ្លួនមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយ។ ចំណុចទាំងអស់នោះនឹងមិនអាចកើតឡើងបានឡើយ ប្រសិនបើការអស្ចារ្យនៃព្រះវិញ្ញាណរបស់ព្រះមិនបានធ្វើការនៅក្នុងលោកអ្នក។ ប៉ុន្តែលោកអ្នកក៏នឹងមិនអាចដឹងអំពីចំណុចនោះបានដែរ លុះត្រាតែលោកអ្នកបានទទួលការបង្រៀនចេញពីព្រះគម្ពីរត្រង់ថា លោកអ្នកបានស្លាប់ដល់កម្រិតណា និងអំពីរបៀបដែលមិនអាចទៅរួចបានទាល់តែសោះទាក់ទងនឹងការបំផ្លាស់បំប្រែដ៏ស្រស់ស្អាតមួយនេះ លុះត្រាតែតាមរយៈព័ន្ធកិច្ចនៃអធិបតេយ្យភាពរបស់ព្រះវិញ្ញាណ (លូកា ១៨:២៧)។

## តើលោកអ្នកមានការភ្ញាក់ផ្អើលទេ?

ប្រសិនបើលោកអ្នកធ្លាប់ទទួលការបង្រៀនថាគឺលោកអ្នកហើយដែលជាអ្នកសម្រេចចិត្ត—សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងចំណុចនេះជាថ្មីម្ដងទៀត



50 QnA John Piper Final 1.5.indd 88 25/01/2024 09:22:42 AM

ពីព្រោះនេះគឺជាការបង្រៀនដែលនាំមកនូវការបំផ្លាញចោល ហើយក៏មានការផ្សព្វផ្សាយច្រើនផងដែរ។ ប្រសិនបើលោកអ្នកធ្លាប់ទទួលការបង្រៀនថាគឺលោកអ្នកហើយដែលជាអ្នកសម្រេចចិត្តលើចំណុចទាំងអស់នេះ នោះលោកអ្នកនឹងមិនអាចមានការភ្ញាក់ផ្អើលក្នុងការបំផ្លាស់បំប្រែរបស់ខ្លួនបានឡើយ។ នោះលោកអ្នកនឹងឃើញថា នោះគឺជាការសម្រេចចិត្តនៃទង្វើរបស់ខ្លួន ដែលនោះនឹងបង្ហាញថា គ្មានភស្តុតាងដ៏ពិតណាដែលបញ្ជាក់ថាលោកអ្នកបានកើតជាថ្មីឡើយ ឬក៏ថាព្រះវិញ្ញាណក៏កំពុងតែគង់ក្នុងនៅលោកអ្នកដែរ។ នេះគឺជារឿងដែលគួរឲ្យខ្លាចផ្សាខ្លាំងមែនទែនមួយសម្រាប់អស់អ្នកដែលបដិសេធអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ក្នុងសេចក្តីសង្គ្រោះ។

សូមសួរខ្លួនឯងថា៖ តើខ្លួនឯងមានការភ្ញាក់ផ្អើលលើអធិបតេយ្យភាពនៃព្រះគុណរបស់ព្រះជាម្ចាស់ដែរឬទេត្រង់ថាជារៀងរាល់ព្រឹកលោកអ្នកភ្ញាក់ឡើងក្នុងនាមជាអ្នកជឿព្រះគ្រីស្ទ? តើលោកអ្នកមានការភ្ញាក់ផ្អើលដែរឬទេ? ជំនឿដ៏ពិតដែលសង្គ្រោះគឺជាភស្តុតាងលេខមួយដែលបង្ហាញថា លោកអ្នកបានកើតជាថ្មីមែន។ កណ្ឌគម្ពីរ ១យ៉ូហាន ៥:១ បានចែងថា «អស់អ្នកណាដែលជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ អ្នកនោះបានកើតមកពីព្រះ»។ នេះមានន័យថា កើតពី*ព្រះវិញ្ញាណ* ហើយមាន*ព្រះវិញ្ញាណ*ជាកម្មសិទ្ធិ។

ដូច្នេះ ខ្ញុំត្រូវតែបញ្ឈប់ត្រង់នេះ។ ខ្ញុំដឹងថាមិត្តអ្នកអានបានសួរថា៖ «តើខ្ញុំអាចទទួលបានការបំពេញដោយរបៀបណាទៅ?» ហើយខ្ញុំក៏មិនទាន់បានឆ្លើយអ្វីដែរ ប៉ុន្តែខ្ញុំគិតថាយើងត្រូវតែឈប់ត្រង់នេះ ពីព្រោះសំណួរមួយទៀតរបស់គាត់ «តើខ្ញុំអាចទទួលបានការបំពេញដោយព្រះវិញ្ញាណបរិសុទ្ធដោយរបៀបណាទៅ?» គឺជាសំណួរធំពេកក្នុងការឆ្លើយនៅពេលនេះ។ ហើយខ្ញុំគិតថា អ្វីដែលយើងបានឆ្លើយគឺគ្រាន់តែជាផ្នែកលើៗប៉ុណ្ណោះ៖ តើអ្វីទៅជាព័ន្ធកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធក្នុងជីវិតរបស់យើងដែលយើងអាចមើលឃើញបាន? ហើយថា តើអ្វីទៅជាចម្លើយស្នូលក្នុងព្រះគម្ពីរ? ចម្លើយគឺថា



50 QnA John Piper Final 1.5.indd 89 25/01/2024 09:22:42 AM

ព្រះអង្គបានប្រោសឲ្យយើងរស់ពីស្លាប់ឡើងវិញ ហើយបានធ្វើឲ្យយើងយក
ព្រះគ្រីស្ទធ្វើជាសម្បត្តិដ៏ធំឧត្តមបំផុតរបស់យើង។

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 90 25/01/2024 09:22:43 AM

# សំណួរទី១៥៖
# ព្រះកិត្តិយសរបស់ព្រះជាម្ចាស់ និងបេសកកម្មពិភពលោក

«ដើម្បីឲ្យគ្រប់ទាំងសាសន៍នៅផែនដីបានដឹងថា ព្រះហស្តនៃព្រះយេហូវ៉ា មានព្រះចេស្តា ប្រយោជន៍ឲ្យឯងរាល់គ្នាបានកោតខ្លាចដល់ព្រះយេហូវ៉ា ជាព្រះនៃឯង ជាដរាបតទៅ» (យ៉ូស្វេ ៤:២៤)។

*តើខគម្ពីរនេះទាក់ទងនឹងបេសកកម្មពិភពលោកដោយរបៀបណា?*

មកដល់ពេលនេះ យើងឃើញការដែលព្រះអង្គបានញែកទន្លេ យ័រដាន់ និងសមុទ្រក្រហម ក្នុងរបៀបដ៏អស្ចារ្យធំមួយ ទាក់ទងនឹងការដែលព្រះអង្គកំពុងតែធ្វើការជាមួយនឹងរាស្ត្ររបស់ទ្រង់ ដែលទ្រង់បានធ្វើ ដើម្បីឲ្យពួកគាត់អាចដើរឆ្លងកាត់បាន។ នេះគឺជាអត្ថន័យមាត្រា៖ ហេតុអ្វីបានជាព្រះជាម្ចាស់ញែកសមុទ្រក្រហម? ហេតុអ្វីបានជាព្រះជាម្ចាស់ញែកទន្លេ យ័រដាន់ ក្នុងរបៀបដែលគួរឲ្យចាប់អារម្មណ៍ និងអស្ចារ្យ? ព្រះអង្គបានធ្វើការនោះ ដើម្បីឲ្យមនុស្សជាតិទាំងអស់លើផែនដីអាចឃើញព្រះហត្ថដ៏ពេញដោយព្រះចេស្តារបស់ទ្រង់បាន។ និងដើម្បីឲ្យពួកគេអាចកោតខ្លាចដល់ព្រះអង្គដ៏ជាព្រះរបស់ខ្លួន អស់កល្បជានិច្ច។

## ព្រះកិត្តិយសរបស់ព្រះជាម្ចាស់នៅគ្រប់ទីកន្លែង

អ្វីដែលខគម្ពីរនោះកំពុងតែលើកឡើងគឺជាគោលបំណងមួយរបស់ព្រះជាម្ចាស់ ក្នុងការដែលសាសន៍អ៊ីស្រាអែលចាកចេញពីស្រុកអេស៊ីព្ទ ហើយចូលទៅក្នុងទឹកដីសន្យា ដោយសារព្រះអង្គបានប្រើព្រះហស្តដែលពេញដោយព្រះចេស្តារបស់ទ្រង់ ក្នុងការញែកសមុទ្រ និងទន្លេ៖ គឺដើម្បីឲ្យមនុស្សគ្រប់ជាតិសាសន៍ដឹងអំពីការនោះ។ ព្រះយេហូវ៉ា ដែលជាព្រះរបស់សាសន៍អ៊ីស្រាអែល គឺជាព្រះដែលមានពេញទៅដោយព្រះចេស្តា។ នេះគឺជាអ្វីដែល



50 QnA John Piper Final 1.5.indd 91 25/01/2024 09:22:43 AM

ខ្ញុំចង់មានន័យ ទាក់ទងទៅនឹងបេសកកម្ម។ កណ្ឌគម្ពីរ ទំនុកតម្កើង ៩៦:៣ បានចែងថា «ចូរថ្លែងប្រាប់ពីសិរីល្អទ្រង់ នៅកណ្ដាលអស់ទាំងសាសន៍» ហើយខគម្ពីរនេះក៏ជាប្រធានបទជាច្រើនក្នុងសន្និបាត។ ប្រធានបទគឺ៖ ព្រះអង្គកំពុងតែប្រកាសសិរីល្អរបស់ទ្រង់នៅកណ្ដាលអស់ទាំងសាសន៍។ ព្រះជាម្ចាស់គឺជាព្រះដែលធ្វើបេសកកម្ម។

តាំងពីដើមមក បន្ទាប់ពីមនុស្សបានធ្លាក់ក្នុងអំពើបាប គឺព្រះជាម្ចាស់បានដំណើរការនៃការប្រោសលោះចាប់ផ្ដើម ព្រះអង្គបានគិតអំពីជាតិសាសន៍នានា។ ទោះបីជាទ្រង់បានជ្រើសរើសផ្ដោតលើសាសន៍អ៊ីស្រាអែល អស់រយៈពេល ២០០០ ឆ្នាំក៏ដោយ ក៏ព្រះអង្គនៅបានគិតដល់សាសន៍ដទៃផងដែរ។ ពីព្រោះព្រះអង្គបានមានព្រះបន្ទូលទៅកាន់លោក អ័ប្រាហាំ ថា «អញនឹងបង្កើតនគរ១យ៉ាងធំពីឯង អញនឹងឲ្យពរដល់ឯង ទាំងលើកឈ្មោះឯងជាធំផង ឯងនឹងបានធ្វើជាទីបញ្ចេញពរដល់មនុស្សទាំងឡាយ» (លោកុប្បត្តិ ១២:២)។ នៅពេលដែលព្រះអង្គជ្រើសរើសសាសន៍អ៊ីស្រាអែល ហើយចាប់ផ្ដើមធ្វើការអស្ចារ្យក្នុង និងសម្រាប់សាសន៍អ៊ីស្រាអែល គឺព្រះអង្គតែងតែបានធ្វើការទាំងនោះលើឆាកពិភពលោក ដោយមានព្រះហឫទ័យចង់ឲ្យសាសន៍ដទៃឃើញសិរីល្អរបស់ទ្រង់ដែរ។

ប្រសិនបើលោកអ្នកត្រឡប់ទៅមើលក្នុងកណ្ឌគម្ពីរ និក្ខមនំ ១៤ នៅពេលដែលពួកគាត់កំពុងតែចាកចេញពីស្រុកអេស៊ីព្ទ នោះលោកអ្នកនឹងឃើញថាព្រះអង្គបានលើកឡើងនៅក្នុង ១៤:៤ ដូចតទៅ៖ «នោះអញនឹងបណ្ដាលឲ្យផារ៉ោនមានចិត្តរឹងទទឹងឡើង ហើយទ្រង់នឹងដេញតាម តែអញនឹងបានកិត្តិសព្ទ ដោយសារផារ៉ោននឹងពួកទ័ពទ្រង់ទាំងប៉ុន្មាន ហើយពួកសាសន៍អេស៊ីព្ទនឹងដឹងថា អញជាព្រះយេហូវ៉ាពិត គេក៏ធ្វើសម្រេចដូច្នោះ»។

សំណួរសួរថា៖ នៅពេលដែលព្រះអង្គបានធ្វើការនោះ នៅពេលដែលព្រះអង្គបានបង្ហាញសិរីល្អរបស់ទ្រង់ឲ្យអ្នកស្រុកអេស៊ីព្ទឃើញ តើនោះគ្រាន់តែ



50 QnA John Piper Final 1.5.indd 92 25/01/2024 09:22:43 AM

ជាអ្វីដែលទ្រង់មានក្នុងព្រះចិន្តារបស់ទ្រង់មែនឬ ឬក៏ថាទ្រង់ក៏បានគិតថា ដំណឹងនេះក៏នឹងសាយភាយគ្រប់ទីកន្លែង ហើយមនុស្សទាំងអស់ក៏នឹងដឹងថា ព្រះយេហូវ៉ាគឺជាព្រះដ៏ពិតដែរឬទេ? ហើយអ្នកខ្លះ តាមរយៈព្រះគុណ និងបែរទៅរកព្រះពិត ហើយទទួលបានសេចក្តីសង្គ្រោះ ហើយនោះគឺជាគោលបំណងនៃបេសកកម្ម។

អ្វីដែលខ្ញុំបានគិតដល់នោះគឺនាង រ៉ាហាប។ កណ្ឌគម្ពីរ ហេព្រើរ ១១:៣១ បានលើកឡើងថា «ដោយសារជំនឿ នោះនាងរ៉ាហាប ជាស្រីសំផឹង» នាង រ៉ាហាប កំពុងតែរស់នៅក្នុងទីក្រុងយេរីខូរ ដែលហៀបនឹងត្រូវបំផ្លាញចោល ខណៈពេលដែលសាសន៍អ៊ីស្រាអែលកំពុងតែឆ្លងទន្លេយ័រដាន់ «ដោយសារជំនឿ នោះនាងរ៉ាហាប...មិនបានវិនាសទៅ ជាមួយនឹងពួកអ្នករឹងចចេសឡើយ ពីព្រោះនាងបានទទួលពួកឈ្លបលប ដោយមេត្រីចិត្ត»។

ទាក់ទងនឹងកណ្ឌគម្ពីរ ហេព្រើរ ១១:៣១ សំណួររបស់ខ្ញុំគឺសួរថា៖ ហេតុអ្វីបានជានាងធ្វើដូច្នោះ? ហេតុអ្វី?

## ការដែលនាង រ៉ាហាប កោតខ្លាចព្រះយេហូវ៉ា

ហើយនេះជាចម្លើយ៖ ក្នុងកណ្ឌគម្ពីរ យ៉ូស្វេ ២:៩ នាង រ៉ាហាប បាននិយាយទៅកាន់ពួកឈ្លបលបថា «ខ្ញុំដឹងថាព្រះយេហូវ៉ាបានប្រទានស្រុកនេះ ដល់អ្នករាល់គ្នាហើយ មួយទៀតសេចក្តីស្ញែងខ្លាចរបស់អ្នករាល់គ្នាបានធ្លាក់មកលើយើងដែរ ឯអ្នកស្រុកទាំងប៉ុន្មាន គេនឹងរលាយបាត់ចេញពីមុខអ្នករាល់គ្នាទៅ»។ តើគាត់ដឹងអំពីការនោះដោយរបៀបណា? ខ១០ បានប្រាប់យើងដូចតទៅ៖ «ដ្បិតយើងបានឮពីការ ដែលព្រះយេហូវ៉ាទ្រង់ធ្វើឲ្យទឹកសមុទ្រក្រហមរីងទៅ នៅមុខអ្នករាល់គ្នា ក្នុងកាលដែលចេញពីស្រុកអេស៊ីព្ទមក ហើយពីការដែលអ្នករាល់គ្នាបានធ្វើ ដល់ស្តេចសាសន៍អាម៉ូរីទាំង២អង្គ នៅខាងនាយទន្លេយ័រដាន់នោះដែរ គឺដល់ស៊ីហុនហើយ



50 QnA John Piper Final 1.5.indd 93 25/01/2024 09:22:43 AM

នឹងអុក ដែលអ្នករាល់គ្នាបានបំផ្លាញអស់រលីងទៅ»។

ព្រះជាម្ចាស់បានគិតអំពីសេចក្ដីសង្គ្រោះរបស់នាង រ៉ាហាប នៅពេលដែលព្រះអង្គញែកសមុទ្រក្រហម។ នេះគឺជាអ្វីដែលខ្ញុំចង់មានន័យ។ នៅពេលដែលខ្ញុំលើកឡើងថា ការសរសើរព្រះជាម្ចាស់ទាក់ទងទៅនឹងសិរីល្អរបស់ទ្រង់ផ្ទាល់ ក្នុងការសង្គ្រោះរាស្ត្ររបស់ទ្រង់ គឺជាសកម្មភាពនៃការធ្វើបេសកកម្ម កេរ្តិ៍ឈ្មោះដែលទ្រង់នឹងទទួលបានចេញពីទង្វើនោះ គឺដើម្បីនាំឲ្យមនុស្សដូចជានាង រ៉ាហាប ឲ្យបន្ទាបខ្លួននៅចំពោះព្រះយេហូវ៉ា ដោយឈប់បន្តបះបោរទាស់ប្រឆាំងនឹងព្រះដ៏ពិត ហើយឲ្យឱបក្រសោបទ្រង់ និងទទួលបានសេចក្ដីសង្គ្រោះ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 94 25/01/2024 09:22:43 AM

# សំណួរទី១៦៖
# ការសម្លាប់ខ្លួន និងសេចក្ដីសង្គ្រោះ

*ឥឡូវនេះ យើងទទួលបានសារជិត១០០សំណួរដែលអ្នកស្ដាប់របស់យើងបានផ្ញើរសារសួរទាក់ទងជាមួយនឹងសំណួរដ៏សំខាន់មួយរបស់គ្រីស្ទបរិស័ទ អំពី ការសម្លាប់ខ្លួន និងសេចក្ដីសង្គ្រោះ។ សារសំណួរថ្មីៗទាំងនេះជាច្រើនគឺទាក់ទងជាមួយការសម្លាប់ខ្លួនរបស់គ្រូគង្វាល។ លោក ភក្ដី ដែលជាអ្នកស្ដាប់ដ៏ទៀងទាត់របស់យើងបានសួរថា "សួស្ដីលោកគ្រូ! ថ្មីៗនេះ គ្រួសាររបស់គ្រូគង្វាលនៅក្នុងក្រុមជំនុំក្នុងតំបន់មួយបានសម្លាប់ខ្លួន។ ដូច្នេះ តើមានរឿងអ្វីកើតឡើងចំពោះអ្នកជឿដែលបានអះអាងថាខ្លួនបានកើតហើយជាថ្មី ដែលបានសម្លាប់ខ្លួន? តើនេះជាអំពើបាបដែលមិនអាចអត់ទោសឲ្យបានឬ? តើការនេះបង្ហាញថា បុគ្គលម្នាក់មិនមែនជាអ្នកជឿដោយសារគាត់មិនមានការតស៊ូ? ឬក៏វាអាចទៅរួចបានទេ សម្រាប់បុគ្គលណាម្នាក់ដែលបានសម្លាប់ខ្លួនហើយនៅតែអាចទៅស្ថានសួគ៌បាន? ដូច្នេះ លោកគ្រូ ទាំងនេះជាសំណួរពិបាក ប៉ុន្តែសំណួរទាំងនេះមិនថ្មីសម្រាប់លោកគ្រូនោះទេ។*

ខ្ញុំបានចូលរួមជួយគេជាច្រើននៅពេលមាននរណាម្នាក់សម្លាប់ខ្លួន។ ខ្ញុំបានសម្អាតនៅជាន់ក្រោមដី បន្ទាប់ពីប៉ូលិសបានយកសាកសពរបស់បុរសម្នាក់ដែលបានបាញ់ក្បាលសម្លាប់ខ្លួនឯង ហើយខ្ញុំក៏ធ្លាប់បោសសម្អាតឈាម (និងរបស់ផ្សេងៗទៀត) ចូលក្នុងប្រដាប់ចូកសំរាម ហើយចាក់វាចូលទៅក្នុងឡាបូ ដើម្បីកុំឲ្យប្រពន្ធរបស់គាត់ឃើញនូវអ្វីដែលយើងបានរកឃើញ។ ហើយប្រាំថ្ងៃក្រោយមកខ្ញុំបានធ្វើពិធីបុណ្យសពរបស់គាត់។ គាត់គឺជាអ្នកដែលអះអាងថា ខ្លួនជាអ្នកជឿម្នាក់ដែរ។ ខ្ញុំធ្លាប់បានធ្វើបុណ្យសពឲ្យស្ត្រីវ័យក្មេងម្នាក់ដែលបានលោតតាមបង្អួចចេញពីបន្ទប់ដែលបានចាក់



50 QnA John Piper Final 1.5.indd 95 25/01/2024 09:22:44 AM

សោនៅមន្ទីរពេទ្យតាមផ្លូវនៅផ្ទះខ្ញុំ ដែលនាងត្រូវបានគេរក្សាទុកយ៉ាងមានសុវត្ថិភាពដោយសារជំងឺផ្លូវចិត្តរបស់គាត់។ ហើយគាត់ក៏បានស្លាប់ដោយសារលោតតាមបង្អួចនោះ។

## ការមិនទុកចិត្តព្រះជាម្ចាស់

ដូច្នេះ សូមឲ្យបានដឹងច្បាស់ឥឡូវនេះចុះ។ ការសម្លាប់ខ្លួនគឺជារឿងធ្ងន់ធ្ងរណាស់។ នៅទីនេះ យើងកំពុងតែលេងជាមួយភ្លើងហើយ។ ការសម្លាប់ខ្លួនគឺជារឿងដ៏ធ្ងន់ធ្ងរទាំងផ្នែកព្រលឹងវិញ្ញាណ និងអស់កល្បជានិច្ច។ វាមិនមែនជារឿងតូចតាចនោះទេ។ ហើយចំពោះអស់អ្នកដែលកំពុងអានអត្ថបទមួយនេះ ហើយកំពុងតែបម្រុងគិតចង់សម្លាប់ខ្លួនគួរតែយកចិត្តទុកដាក់ពិចារណាអំពីអ្វីដែលខ្ញុំកំពុងលើកឡើង៖ សូមកុំប្រព្រឹត្តឡើយ! មានជម្រើសប្រសើរជាងនេះទៀត។ ខ្ញុំសន្យានឹងបងប្អូនថា នៅក្នុងព្រះនាមព្រះយេស៊ូវនឹងមានជម្រើសប្រសើរជាងនេះមែន។ ប្រហែលឥឡូវនេះ លោកអ្នកមិនមានអារម្មណ៍ដូចនេះ ប៉ុន្តែអារម្មណ៍របស់លោកអ្នកមិនពិតប្រាកដនោះទេ។ វាកំពុងតែបោកប្រាស់លោកអ្នក។ វាជាការពិតណាស់ដែលថា ព្រះជាម្ចាស់មានផ្លូវផ្សេងសម្រាប់លោកអ្នក។ ព្រះអង្គតែងតែមានផ្លូវមួយផ្សេងទៀត។ សូមរង់ចាំទ្រង់ ហើយស្វែងរកជំនួយដែលលោកអ្នកត្រូវការ ពីព្រោះព្រះគម្ពីរពិតជាមានភាពតឹងរ៉ឹងខ្លាំងមែនទែនទាក់ទងអំពីការសម្លាប់ខ្លួននេះ។

នៅក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ៣:១៥ មានចែងដូចនេះថា “អ្នកណាដែលមានចិត្តស្អប់ដល់បងប្អូន នោះឈ្មោះថាជាអ្នកសម្លាប់គេ ហើយអ្នករាល់គ្នាដឹងហើយ ថាគ្មានអ្នកសម្លាប់គេណាមួយ ដែលមានជីវិតដ៏រស់អស់កល្បជានិច្ចនៅក្នុងខ្លួនឡើយ”។ ឥឡូវនេះ ការនោះគួរតែបំភ័យមនុស្សណាដែលគិតបម្រុងចង់បញ្ចប់ជីវិតខ្លួនដោយចង់សម្លាប់ខ្លួនឯងហើយ។ ដូច្នេះ តើការនោះមានន័យយ៉ាងដូចម្ដេច? ជីវិតអស់កល្បជានិច្ច និងការសម្លាប់ខ្លួនមិន



50 QnA John Piper Final 1.5.indd 96 25/01/2024 09:22:44 AM

អាចមានក្នុងព្រលឹងតែមួយបាននោះទេ។ ប៉ុន្តែឥឡូវនេះ សូមប្រុងប្រយ័ត្ន។ សូមកុំយកការនេះទៅឆ្ងាយជាងការដឹកនាំរបស់វាឡើយ។ តើគាត់កំពុងមានន័យថា គ្រប់គ្នាដែលធ្លាប់ស្អប់ គឺជាម្នាក់ដែលពេញដោយភាពសម្អប់មែនឬ? ប្រហែលជាមិនដូច្នេះទេ។ តើគាត់កំពុងមានន័យថា គ្រប់គ្នាដែលធ្លាប់ចង់សម្លាប់នរណាម្នាក់ គឺជាឃាតករមែនឬ? នោះគឺជាសំណួរដ៏សំខាន់មួយ។ ខ្ញុំគិតថាទេ។

ជាការពិតណាស់ ព្រះគម្ពីរមានចែងថា យើងត្រូវតែស៊ូទ្រាំរហូតដល់ទីបញ្ចប់ ដើម្បីទទួលបានសេចក្ដីសង្គ្រោះ ម៉ាកុស ១៣:១៣ និងហេព្រើរ ៣:១៤។ «ដ្បិតបើយើងរាល់គ្នាកាន់ខ្ជាប់ តាមសេចក្ដីជំនឿដើម ដរាបដល់ចុងបំផុតមែន នោះពិតជាយើងបានត្រឡប់ជាអ្នកមានចំណែកជាមួយនឹងព្រះគ្រីស្ទហើយ»។ នេះគឺជាការព្រមានដ៏ធ្ងន់ធ្ងរមួយ។ ប៉ុន្តែ វាមិនមែនមានន័យថា បទពិសោធន៍នៃទំនុកចិត្តរបស់យើងនៅក្នុងព្រះជាម្ចាស់រហូតដល់ទីបញ្ចប់គឺល្អឥតខ្ចោះ ដើម្បីឲ្យកុំយើងប្រព្រឹត្តិរំលងចំពោះអំពើបាបដែលបោកបញ្ឆោតថា យើងមិនបានទុកចិត្តលើព្រះគ្រីស្ទយ៉ាងពេញទីនោះទេ។ គ្រប់អំពើបាបទាំងអស់ រាល់គ្រប់អំពើបាបរបស់ខ្ញុំ—អំពើបាបដែលខ្ញុំបានធ្វើនៅរសៀលនេះ ថ្ងៃស្អែក ម្សិលមិញ—គឺគ្រប់ទាំងអស់មានឫសគល់នៅក្នុងកម្រិតណាមួយនៃការមិនទុកចិត្តក្នុងសេចក្ដីល្អដ៏ខ្ពង់ខ្ពស់របស់ព្រះជាម្ចាស់។ នៅពេលដែលខ្ញុំប្រព្រឹត្តអំពើបាប នោះមិនមែនមានន័យថា ម្ដងខ្ញុំជាគ្រីស្ទបរិស័ទ ហើយម្ដងខ្ញុំមិនមែនជាគ្រីស្ទបរិស័ទនោះទេ ហើយក៏មិនមែនមានន័យថា រង្វាស់នៃការមិនទុកចិត្តក្លាយជាការបង្ហាញនៅក្នុងការធ្វើបាបនោះទេ។ ខ្ញុំនៅ តែជាគ្រីស្ទបរិស័ទ។

ដូច្នេះ ការលើកឡើងថា យើងត្រូវតែស៊ូទ្រាំរហូតដល់ពេលចុងក្រោយដោយទំនុកចិត្តមិនមែនមានន័យថា លោកអ្នកត្រូវតែស៊ូទ្រាំរហូតដល់ទីបញ្ចប់ដោយមិនប្រព្រឹត្តអំពើបាប ឬក៏ការទុកចិត្តលើព្រះគ្រីស្ទបានដ៏ល្អឥត



50 QnA John Piper Final 1.5.indd 97 25/01/2024 09:22:44 AM

ខ្ចោះនោះទេ។ នៅក្នុងការមានទំនុកចិត្តរបស់យើង យើងមិនមានភាពល្អឥតខ្ចោះនោះទេ។

## ទង្វើចុងក្រោយរបស់យើង

ឥឡូវនេះ សំណួរគឺថា តើបុគ្គលដែលសម្លាប់ខ្លួនហើយអាចចូលស្ថានសួគ៌បានដែរឬទេ? យើងអាចសង្ខេបសំណួរនេះថា ប្រសិនបើបុគ្គលម្នាក់ដែលបានទុកចិត្តលើព្រះយេស៊ូវថាជាព្រះសង្គ្រោះរបស់គាត់ ជាព្រះអម្ចាស់ និងជាកំណប់ទ្រព្យរបស់គាត់ តើទង្វើចុងក្រោយរបស់គាត់នៅក្នុងជីវិតបង្ហាញពីជំហរដ៏ពិតរបស់គាត់ក្នុងនាមជាកូនរបស់ព្រះជាម្ចាស់ដែរឬទេ? មានសំណួរគន្លឹះមួយ។ តើទង្វើចុងក្រោយ—នៅក្នុងករណីរបស់គាត់គឺជាការសម្លាប់ខ្លួន—រាប់ជាការសម្រេចមួយនៅថ្ងៃជំនុំជម្រះដោយបង្ហាញថា យើងនៅក្នុងព្រះគ្រីស្ទឬក៏អត់? តើទង្វើចុងក្រោយមួយនោះកំណត់ថាជំនឿរបស់យើងពិតឬ? ឬក៏ថា តើទង្វើផ្សេងៗទៀតនៅក្នុងជីវិតនេះរាប់ថាជាភស្តុតាងបានដែរឬទេ?

សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវឧទាហរណ៍មួយ។ ការនេះបានជួយមនុស្សជាច្រើននៅពេលដែលខ្ញុំបានចែកចាយ។ ខ្ញុំសង្ឃឹមថាវាក៏ជួយលោកអ្នកបានដូចគ្នាដែរ។ ឥឡូវនេះខ្ញុំមានអាយុ៦៨ឆ្នាំ ឧបមាថានៅយប់មួយ វាអាចនៅចំណុចណាមួយក៏បាន—ខ្ញុំបានខឹងប្រពន្ធរបស់ខ្ញុំយ៉ាងខ្លាំង រហូតដល់ខ្ញុំស្ទុះចេញពីផ្ទះ។ ខ្ញុំបានបិទទ្វារមួយទំហឹង។ ហើយរត់តម្រង់ទៅឡានហើយបើកចេញទៅ ហើយខ្ញុំមិនអាចគ្រប់គ្រងលើខ្លួនឯងបាន ហើយខឹងយ៉ាងខ្លាំងផង បានធ្វើបាបខ្លាំងមែនទែន—សូមឲ្យខ្ញុំបានបន្ថែមបន្តិចទៀត—ខ្ញុំមានកំហឹងដែលពោរពេញដោយអំពើបាបរហូតដល់ខ្ញុំស្មានខុសផ្លូវបត់តូចមួយនៅត្រង់នេះ ដែលជាកន្លែងមានបង្គោលភ្លើងប្រហែលជិត១ម៉ែត្រពីផ្លូវ ហើយខ្ញុំបានបើកបុកបង្គោលនោះដោយល្បឿនប្រហែល១០០គីឡូម៉ែត្រ

ក្នុងមួយម៉ោង ហើយជាលទ្ធផលខ្ញុំក៏បានស្លាប់។ ឥឡូវនេះទង្វើចុងក្រោយរបស់ខ្ញុំគឺជាអំពើបាប ហើយខ្ញុំបានសម្លាប់ខ្លួនឯងដោយសារអំពើបាបរបស់ខ្ញុំដែរ។ ខ្ញុំមិនមានបំណងក្នុងការសម្លាប់ខ្លួននោះទេ ប៉ុន្តែវាបានកើតឡើងហើយ។ ហើយវាជាអំពើបាបដែលបានធ្វើឲ្យរឿងនេះបានកើតឡើង។ ដូច្នេះទង្វើចុងក្រោយដែលខ្ញុំបានធ្វើគឺជាអំពើបាប។ តើអំពើបាបចុងក្រោយនេះជាការសម្រេចក្នុងការកំណត់ថា តើខ្ញុំបានកើតជាថ្មីដែរឬទេ?

ហើយចម្លើយរបស់ខ្ញុំគឺៈ មិនចាំបាច់ដូច្នោះទេ។ យើងអាចនិយាយម៉្យាងទៀតថា ព្រះជាម្ចាស់នឹងមើលពីជីវិតរបស់ខ្ញុំ។ ព្រះអង្គនឹងមើលពីជីវិតរបស់ខ្ញុំទាំងមូល និងភស្តុតាងដែលថា តើខ្ញុំជាកម្មសិទ្ធិរបស់ទ្រង់ឬក៏អត់ នឹងត្រូវបានវាយតម្លៃមិនមែនដោយសារការបរាជ័យមួយនោះតែឯងជាងការបរាជ័យផ្សេងទៀតតែឯងនោះទេ។ ហេតុអ្វីបានជាទង្វើចុងក្រោយត្រូវសម្រេចនៅពេលដែលទង្វើផ្សេងៗទៀតក៏មានភាពធ្ងន់ធ្ងរដូចគ្នាដែរ?

## ពេលវេលានៃភាពអស់សង្ឃឹម

ដូច្នេះ សំណួរចុងក្រោយគឺថាៈ តើគ្រីស្ទបរិស័ទអាចមានការព្រួយបារម្ភយ៉ាងខ្លាំង ហើយមានភាពខ្វាក់ជាបណ្ដោះអាសន្នចំពោះសេចក្ដីសង្ឃឹមនៃដំណឹងល្អ រហូតដល់គាត់ហ៊ានយកជីវិតរបស់គាត់នៅអំឡុងពេលវេលានៃភាពអស់សង្ឃឹមដែរឬទេ? ហើយខ្ញុំគិតថា ចម្លើយចំពោះសំណួរនោះគឺបាទគឺអាច។

នោះគឺជាការជំនុំជម្រះមួយផ្នែករបស់ខ្ញុំក្នុងការលើកឡើងថា មានពេលវេលានៃភាពអស់សង្ឃឹមចូលមក ហើយក៏ចេញទៅវិញនៅក្នុងជីវិតជាគ្រីស្ទបរិស័ទ។ វាពិតជាគ្រោះថ្នាក់ណាស់ក្នុងការលើកឡើងបែបនេះដោយសារយើងទាំងអស់គ្នាងាយចាញ់បោកក្នុងការទទួលសេចក្ដីបញ្ឆោត ហើយយើងគួរតែមានការភ័យខ្លាចក្នុងការព្យាយាមជួបព្រះយេស៊ូវតាមរយៈ



50 QnA John Piper Final 1.5.indd 99 25/01/2024 09:22:45 AM

ការសម្លាប់ខ្លួនបែបនេះ។ នេះគឺជាជម្រើសដ៏អាក្រក់បំផុត។ ប៉ុន្តែ រវាងភាពភ័យខ្លាចដែលយើងមានអារម្មណ៍ចំពោះជម្រើសនោះ និងភាពអស់សង្ឃឹមសម្រាប់ជនរងគ្រោះរបស់អ្នកសម្លាប់ខ្លួន រវាងអ្នកទាំងពីរនោះខ្ញុំកំពុងតែគ្រវីទង់នៃសេចក្តីសង្ឃឹមមួយដែលថា ជំនឿដ៏ពិតប្រាកដអាចមានរដូវកាលនៃភាពអស់សង្ឃឹមនោះ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 100 25/01/2024 09:22:45 AM

## សំណួរទី១៧៖
# ចំពោះលោកអ្នក តើព្រះយេស៊ូវជានរណា?

*តើព្រះយេស៊ូវជានរណា? នេះគឺជាសំណួរដែលគេសួរឡើងវិញម្តងហើយម្តងទៀត។ ហើយក៏មានចម្លើយខុសៗគ្នាជាច្រើនលើសំណួរនេះដូចជាធ្លាប់មានមនុស្សជាច្រើននាក់បានដើរលើផែនដីនេះផងដែរ។ សូម្បីតែក្នុងអំឡុងពេលនៃព្រះជន្មរបស់ព្រះយេស៊ូវនៅលើផែនដីនេះ ព្រះវត្តមានរបស់ព្រះគ្រីស្ទគឺជាចំណុចវែកញែកដែលគួរឲ្យកត់សម្គាល់មួយដែរ។ អ្នកខ្លះបានលើកឡើងថាព្រះយេស៊ូវគឺជាព្រះ។ អ្នកខ្លះទៀតបានលើកឡើងថា ព្រះយេស៊ូវត្រូវបានអារក្សចូល។ អ្នកខ្លះថា ព្រះយេស៊ូវគឺជាគ្រូបង្រៀនដ៏ល្អម្នាក់។ ហើយខ្លះទៀតបានហៅព្រះអង្គថា ជាមនុស្សកុហក។ ខ្លះថាព្រះអង្គឆ្លាតវាងវៃ ហើយខ្លះទៀតថាព្រះអង្គជាមនុស្សឆ្កួត។ ខ្លះបានរាប់ព្រះអង្គថាជាហោរាម្នាក់។ ហើយខ្លះទៀតថា ព្រះអង្គជាអ្នកជេរប្រមាថដែលមិនដឹងខ្យល់។ ដូច្នេះ តើព្រះយេស៊ូវជានរណា? កណ្ឌគម្ពីរ ហេព្រើរ ១:៣ បានប្រាប់យើងថា ព្រះយេស៊ូវជា «រស្មីភ្លឺមកពីសិរីល្អនៃព្រះ ហើយជារូបភាពនៃអង្គទ្រង់»។ ក្នុងសេចក្តីអត្ថាធិប្បាយនៅឆ្នាំ១៩៩៦ លោកគ្រូ ចន ផាយភ័រ បានឆ្លើយសំណួរដ៏ចាស់បុរាណនេះ៖ តើព្រះយេស៊ូវជានរណា?*

តើអ្នកណាជាអ្នកគង់នៅខាងស្តាំព្រះហស្ត? តើអ្នកណាបានយាងទៅឯឈើឆ្កាង? តើអ្នកណាត្រូវបានគេបញ្ចុះក្នុងផ្នូរ ហើយបានមានព្រះជន្មរស់ឡើងវិញ? តើអ្នកណាទ្រទ្រង់គ្រប់អ្វីទាំងអស់តាមរយៈព្រះបន្ទូលនៃអំណាចរបស់ទ្រង់? តើព្រះយេស៊ូវគ្រីស្ទជានរណា? ព្រះអង្គជាអ្នកតំណាងផ្ទាល់នៃរូបភាពនៃលក្ខណៈរបស់ព្រះ ឬក៏លក្ខណសម្បត្តិរបស់ព្រះជាម្ចាស់។ តើឃ្លានេះមានន័យយ៉ាងដូចម្តេច? ព្រះយេស៊ូវបានមានបន្ទូលថា «អ្នកណាដែល



50 QnA John Piper Final 1.5.indd 101 25/01/2024 09:22:45 AM

ឃើញខ្ញុំ នោះក៏បានឃើញព្រះវរបិតាដែរ» (យ៉ូហាន ១៤:៩)។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «ដែលទ្រង់ជារូបអង្គនៃព្រះដ៏មើលមិនឃើញ» (កូឡូស ១:១៥)។

## រស្មីនៃសិរីល្អ

ប៉ុន្តែ តើលោកអ្នកដឹងទេថា លោកអ្នកអាចលើកប្រយោគ—ព្រះអង្គជាអ្នកតំណាងផ្ទាល់នៃរូបភាពនៃលក្ខណៈរបស់ព្រះ—ហើយនៅមានការខុសទាំងស្រុង ក្នុងរបៀបដែលលោកអ្នកគិតអំពីប្រយោគនោះដែរឬទេ? ឧទាហរណ៍៖

- លោកអ្នកអាចលើកឡើងថា ព្រះយេស៊ូវគឺជាអង្គតំណាងឲ្យព្រះវរបិតា ក្នុងរបៀបដែលគំនូរតំណាងឲ្យបុគ្គលណាម្នាក់បាន។ ប៉ុន្តែ លោកអ្នកខុសទាំងស្រុង។
- លោកអ្នកអាចលើកឡើងថា ព្រះយេស៊ូវគឺជាអង្គតំណាងឲ្យលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ ក្នុងរបៀបដែលសំបុត្រតំណាងឲ្យស្តេចមួយអង្គណាបាន។ ប៉ុន្តែ លោកអ្នកខុសទាំងស្រុង។
- ឬក៏លោកអ្នកអាចលើកឡើងថា ព្រះយេស៊ូវគ្រីស្ទដ៏ជាព្រះរាជបុត្រានៃព្រះជាអ្នកតំណាងផ្ទាល់នៃរូបភាពនៃលក្ខណៈរបស់ព្រះវរបិតា ដូចដែលទានមានស្នាមផិត ហើយស្នាមនោះបានតំណាងឲ្យចិញ្ចៀនយ៉ាងល្អឥតខ្ចោះ។ ប៉ុន្តែ លោកអ្នកខុសទាំងស្រុង។

ហើយមូលហេតុដែលយើងដឹងថា ការលើកឡើងទាំងនេះមិនត្រឹមត្រូវទាល់តែសោះ ពីព្រោះឃ្លាដំបូងបានប្រាប់យើងអំពីរបៀបដែលព្រះអង្គជាអ្នកតំណាង ហើយវាមិនពាក់ព័ន្ធទៅនឹងឧទាហរណ៍ដែលយើងបានលើកឡើងនោះទេ។ ព្រះអង្គជាអ្នកតំណាងផ្ទាល់នៃរូបភាពនៃលក្ខណៈរបស់ព្រះវរបិតាត្រង់ថា «ទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ» (ហេព្រើរ ១:៣)។ ព្រះអង្គតំណាង



50 QnA John Piper Final 1.5.indd 102 25/01/2024 09:22:46 AM

ឲ្យសិរីល្អព្រះដូចដែលរស្មីតំណាងឲ្យសិរីល្អដែរ។

ចំណុចនេះខុសគ្នាទាំងស្រុងពីរបៀបដែលគំនូរតំណាងឲ្យបុគ្គល សំបុត្រ ស្ដេច ទៀន និងចិញ្ចៀន។ រស្មីដែលចែងចាំងចេញពីពន្លឺ ចាំងចេញពីព្រះអាទិត្យ គឺមិនមែនជាអ្វីមួយផ្សេងទៀតនោះទេ។ វាមិនមែនមានចំណុចខុសគ្នាពីអ្វីមួយនោះផ្ទាល់នៅឡើយ។ រស្មីនៃសិរីល្អគឺជា*សិរីល្អ*ដែលកំពុងតែចាំង។ នេះគឺជាចំណុចដ៏ជ្រាលជ្រៅក្នុងការចូលត្រង់នេះ៖ ព្រះគ្រីស្ទមិនមែនជាអ្វីក្រៅពីព្រះដែលតំណាងឲ្យព្រះនោះទេ។ ព្រះអង្គគឺជាព្រះដែលតំណាងឲ្យព្រះ។ ព្រះអង្គគឺជាព្រះវរបិតាដែលកំពុងតែបញ្ចេញសិរីល្អ ឈរតំណាងឲ្យបុគ្គលមួយអង្គទៀត ដែលមានលក្ខណសម្បត្តិដូចគ្នាទាំងស្រុង។

នៅត្រង់នេះ ខ្ញុំយល់ថា យើងកំពុងតែនិយាយអំពីរឿងអាថ៌កំបាំង។ ហើយយើងក៏នឹងមិនចាប់ផ្ដើមពន្យល់ឲ្យអស់អត្ថន័យ ហើយបញ្ចប់នោះទេ ប៉ុន្តែយើងអាចចាប់ផ្ដើមឃើញបន្តិចបាន។ យើងអាចបើកបង្អួចល្មមបាន ដើម្បីឲ្យយើងអាចថ្វាយបង្គំបានយ៉ាងត្រឹមត្រូវ ហើយមិនបង្រៀនសេចក្ដីខុសឆ្គងអំពីព្រះរាជបុត្រាថាជារបស់សព្វសារពើ ឬក៏គ្រាន់តែជាហោរាម្នាក់។

## របៀប៤យ៉ាងដែលព្រះរាជបុត្រាបញ្ចាំងរស្មីនៃសិរីល្អរបស់ព្រះវរបិតា

ក្នុងការបញ្ចប់ សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវរបៀប៤យ៉ាងដែលព្រះរាជបុត្រាបញ្ចេញ ឬក៏បញ្ចាំងរស្មីនៃសិរីល្អរបស់ព្រះវរបិតា។

### *១. ព្រះវរបិតា និងព្រះរាជបុត្រាមានព្រះជន្មតាំងពីអស់កល្បជានិច្ច*

ជាដំបូង ចូរយើងប្រៀបធៀបព្រះអង្គទៅនឹងព្រះអាទិត្យ ព្រះអាទិត្យបញ្ចេញពន្លឺរស្មីរបស់វា។ មិនមានពេលវេលាដែលមានព្រះអាទិត្យដែលពន្លឺរស្មីរបស់វាមិនមានទេ។ ទាំងពីរមានលក្ខណៈដូចគ្នា ដែលថានៅពេលដែលមានព្រះអាទិត្យ នោះភាពត្រចះត្រចង់នៃព្រះអាទិត្យក៏មានដែរ។ នៅពេលដែលព្រះវរបិតាមានព្រះវត្តមាន នោះព្រះរាជបុត្រាក៏មានព្រះវត្តមាន

ដែរ។ ព្រះអង្គទាំងពីរអង្គមានព្រះជន្មតាំងពីអស់កល្បជានិច្ចមកម្ល៉េះ។ ព្រះវរបិតាមិនបានមានព្រះជន្ម ហើយបន្ទាប់មកទើបមានព្រះបន្ទូលថា «អញគិតថានឹងបង្កើតឲ្យមានបុត្រាមួយ» នោះទេ។ នោះមិនមែនជារបៀបដែលបានកើតឡើងទ្បើយ។ ព្រះរាជបុត្រាបានមានព្រះជន្មតាំងពីអស់កល្បជានិច្ចមកហើយ ដោយបញ្ចេញរស្មីនៃសិរីល្អរបស់ព្រះជាម្ចាស់តាំងពីដើមមកម្ល៉េះ។ ទីណាដែលមានពន្លឺ ទីនោះក៏មានរស្មីចែងចាំងផងដែរ។ ទីណាដែលមានព្រះវរបិតា ទីនោះក៏មានព្រះរាជបុត្រានៃព្រះវរបិតាដែរ។ ភាពត្រចះត្រចង់គឺជាសិរីល្អនៃការបញ្ចេញរស្មី។ ទាំងពីរមិនមានមូលដ្ឋានខុសគ្នានោះទេ។ ព្រះរាជបុត្រានៃព្រះជាម្ចាស់ក៏ជាព្រះដែរ។ តាមលក្ខណៈ ព្រះអង្គមិនមែនជាអង្គមួយណាផ្សេងទៀតនោះទេ។

## *២. ព្រះជាម្ចាស់មិនបានបង្កើតព្រះរាជបុត្រាទេ*

សូមប្រៀបធៀបចំណុចនេះជាមួយនឹងកាស្យូដែលប្រើពន្លឺព្រះអាទិត្យ។ ខ្ញុំគិតអំពីការនេះ ពីព្រោះប៉ុន្មានថ្ងៃមុនខ្ញុំបានប្រើមួយ ដើម្បីគណនាការបង់ពន្ធ។ ហើយខ្ញុំក៏បានសួរកូនប្រុសខ្ញុំថា «តើយើងបិទកាស្យូនេះនៅឯណាកូន?»។ កូនប្រុសខ្ញុំក៏បានឆ្លើយថា «វាជាកាស្យូដែលប្រើពន្លឺព្រះអាទិត្យ។ ប៉ាគ្រាន់តែដាក់វាចូលថតតុវិញចុះ។ វានឹងបិទខ្លួនឯង»។ អត្ថន័យគឺថា នៅពេលដែលព្រះអាទិត្យ ឬក៏ពន្លឺពីអំពូលនៅក្នុងផ្ទះបាយរបស់ខ្ញុំចាំងលើផ្ទាំងសូឡាតូចនោះ នោះតួលេខខ្មៅនឹងចេញ។ វាជារឿងត្រឹមត្រូវក្នុងការលើកឡើងថា ពន្លឺបានបង្កើតតួលេខនោះក្នុងរបៀបណាមួយ។ ហើយតួលេខនោះមិនមែនជាពន្លឺទេ។

ដូច្នេះ ចូរកុំគិតថាព្រះរាជបុត្រានៃព្រះក៏ដូចគ្នាទៅនឹងតួលេខនៅលើកាស្យូដែលប្រើពន្លឺព្រះអាទិត្យឡើយ—ដោយគិតថាព្រះជាម្ចាស់បានបង្កើតព្រះរាជបុត្រា ដោយនាំឲ្យព្រះអង្គមានព្រះជន្មដូចពន្លឺព្រះអាទិត្យ ឬក៏ពន្លឺអំពូល



50 QnA John Piper Final 1.5.indd 104 25/01/2024 09:22:46 AM

នាំឲ្យមានតួលេខនៅក្នុងកាស្បូទ្បើយ។ ព្រះរាជបុត្រាគឺជាពន្លឺបញ្ចាំងលើផែនដី ហើយជាអង្គដែលបានបង្កើតផែនដីដែរ។ ដូចដែលគោលជំនឿដើមបានលើកឡើង ព្រះអង្គមានព្រះជន្មតាំងពីអស់កល្បជានិច្ច មិនមែនត្រូវបានបង្កើតឡើងនោះទេ។ ចំណុចគឺដូចថា៖ មនុស្សបង្កើតមនុស្ស ឆ្កែបង្កើតឆ្កែ ឆ្មាបង្កើតឆ្មា និងព្រះបង្កើតព្រះទេ។

### *៣. ព្រះរាជបុត្រាគឺជាបុគ្គលកណ្ដាលរបស់ព្រះវរបិតា*

តាមរយៈរស្មីនៃពន្លឺនោះយើងឃើញពន្លឺ។ ប្រសិនបើលោកអ្នកព្យាយាមមើលពន្លឺព្រះអាទិត្យ នៅពេលដែលវាកំពុងតែបញ្ចាំងពន្លឺ នោះវានឹងធ្វើឲ្យលោកអ្នកខ្វាក់ភ្នែកជាមិនខាន។ កុំព្យាយាមមើលពន្លឺព្រះអាទិត្យឡើយ។ ហើយនោះគឺគ្រាន់តែជាការឆ្លុះបញ្ចាំងដ៏តិចតួចរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ក៏នឹងធ្វើឲ្យលោកអ្នកខ្វាក់ដែរ។ លោកអ្នកត្រូវតែមានមធ្យោបាយណាមួយ ដើម្បីមើលព្រះជាម្ចាស់។ លោកអ្នកត្រូវការមានមនុស្សកណ្ដាល។ ព្រះរាជបុត្រានៃព្រះគឺជាមនុស្សកណ្ដាល ហើយព្រះរាជបុត្រានៃព្រះក៏ជាភាពត្រចះត្រចង់នៃសិរីល្អរបស់ព្រះជាម្ចាស់ដែរ។

ពន្លឺចាំងលើមុខរបស់លោកអ្នកឥឡូវនេះបានមកដល់ទីនេះ៨នាទីមុន បន្ទាប់ពីវាបានរះចេញពីព្រះអាទិត្យ។ ប្រមាណជា៨នាទីមុន ខណៈពេលដែលលោកអ្នកកំពុងតែអានអត្ថបទនេះ ពន្លឺនោះបានរះចេញពីព្រះអាទិត្យ។ រស្មីពន្លឺទាំងនេះបានធ្វើដំណើរមក ហើយឥឡូវនេះក៏បានចាំងលើផ្ទៃមុខរបស់យើង។ ប្រសិនបើលោកអ្នកមើលរស្មីពន្លឺទាំងនេះ នោះលោកអ្នកអាចឃើញ—ប្រសិនបើលោកអ្នកពាក់វ៉ែនតាត្រឹមត្រូវ—កូនបាល់មួយ ឬក៏ថានៅពេលដែលព្រះអាទិត្យរះ ឬក៏ព្រះអាទិត្យលិច ដែលពេលនោះគឺជាពេលវេលាដែលមានសុវត្ថិភាព នោះលោកអ្នកអាចឃើញកូនបាល់មួយដែរ។ តើលោកអ្នកកំពុងតែមើលឃើញព្រះអាទិត្យមែនឬ? ពិតណាស់ លោកអ្នកកំពុងតែ

មើលឃើញព្រះអាទិត្យមែន ប៉ុន្តែតាមពិតទៅអ្វីដែលលោកអ្នកកំពុងតែមើលឃើញ គឺពន្លឺពីប្រាំបីនាទីមុន ដែលជាលទ្ធផលនៃរស្មីពន្លឺរបស់ព្រះអាទិត្យបានអនុញ្ញាតឲ្យលោកអ្នកឃើញទេ។ អ្វីដែលយើងកំពុងតែឃើញគឺជាកូនបាល់មួយដែលមានអាយុកាលប្រាំបីនាទី ដែលកំពុងតែសម្របសម្រួលឲ្យយើងឃើញតាមរយៈពន្លឺ ដែលកំពុងតែចែងចាំងពីចម្ងាយ ១៤.៨០៥.៩៦៥ គីឡូម៉ែត្រពីព្រះអាទិត្យ។ ប៉ុន្តែ បងប្អូន! យើងក៏កំពុងតែឃើញព្រះអាទិត្យមែនដែរ។ នោះគឺជាព្រះអាទិត្យ។ ហើយនៅពេលដែលលោកអ្នកសម្លឹងមើលទៅឯព្រះយេស៊ូវគ្រីស្ទ នោះលោកអ្នកក៏កំពុងតែមើលឃើញព្រះវរបិតាដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 106 25/01/2024 09:22:47 AM

## សំណួរទី១៨៖
# មូលហេតុដែលលោក អ័ដាម សំខាន់សម្រាប់បេសកកម្មពិភពលោក

*សូមលោកគ្រូជួយបញ្ជាក់ទំនាក់ទំនងរបស់លោក អ័ដាម ជាមួយនឹងបេសកកម្មពិភពលោក។ ហេតុអ្វីបានជាលោក អ័ដាម សំខាន់ម្ល៉េះទាក់ទងទៅនឹងជីវិតបេសកជន?*

ជាង១០ឆ្នាំមុន ខ្ញុំបានចំណាយពេលអធិប្បាយលើកណ្ឌគម្ពីររ៉ូម ហើយខ្ញុំបានអធិប្បាយដល់ជំពូក៥ មុននោះក៏ខ្ញុំមិនដែលធ្លាប់គិតអំពីចំណុចអស្ចារ្យនៃកណ្ឌគម្ពីរ រ៉ូម ៥:១២-២១ ទាក់ទងនឹងការធ្វើបេសកកម្មទេ។ ខនោះបានចាប់ផ្ដើមដូចតទៅ «ដូច្នេះ ដែលបាបបានចូលមកក្នុងលោកីយ៍ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ» (ខ១២)។ ហើយបន្ទាប់មកសាវ័ក ប៉ុល បានបន្តដោយប្រៀបធៀបលោក អ័ដាម និងព្រះគ្រីស្ទថាជាអ្នកដឹកនាំមនុស្សជាតិពីរនាក់ខុសគ្នា។ យើងទាំងអស់គ្នាសុទ្ធតែនៅក្នុងលោក អ័ដាម ពីព្រោះគាត់គឺជាឪពុករបស់យើង។ ហើយចំពោះយើងដែលបានទទួលយកព្រះគុណដែលមាននៅក្នុងព្រះគ្រីស្ទយេស៊ូវ គឺយើងនៅក្នុងព្រះគ្រីស្ទយេស៊ូវ ដែលនេះមានន័យថាព្រះអង្គគឺជាបិតាថ្មីរបស់យើង ដោយព្រោះទ្រង់បានបង្កើតមនុស្សជាតិថ្មី។

ដែលនេះចំពោះខ្ញុំមានន័យថា គ្រប់កុលសម្ព័ន្ធ គ្រប់ក្រុមមនុស្សលើផែនដី—ដែលមានរាប់ពាន់នាក់—ប្រសិនបើលោកអ្នកចូលទៅក្រុមណាមួយ ហើយរៀនភាសា និងវប្បធម៌របស់ពួកគាត់ ហើយរករបៀបណាមួយ



50 QnA John Piper Final 1.5.indd 107 25/01/2024 09:22:47 AM

ក្នុងការទំនាក់ទំនងជាមួយនឹងពួកគាត់ នោះលោកអ្នកមិនចាំបាច់ភ័យខ្លាចថា សារដែលលោកអ្នកនាំទៅកាន់ពួកគាត់មិនមានការពាក់ព័ន្ធជាមួយនឹងពួកគាត់ក្នុងរបៀបណាមួយ ក្នុងវប្បធម៌របស់ពួកគាត់ឡើយ។ ពីព្រោះលោកអ្នកអាចប្រកាសសារនេះទៅកាន់ពួកគាត់៖ មានមនុស្សម្នាក់ពីដំបូងគេបង្អស់ដែលយើងទាំងអស់គ្នាកើតចេញពីគាត់។ នោះគឺជារបៀបដែលសាវ័ក ប៉ុល បានអធិប្បាយនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ជំពូក១៧។ ហើយបញ្ហារបស់លោកអ្នកក៏ដូចនឹងបញ្ហារបស់ខ្ញុំដែរ ពីព្រោះជីដូនជីតាពីបុរាណរបស់យើងបានបោះបង់ទាស់ប្រឆាំងនឹងព្រះអាទិករ ហើយគាត់បានធ្លាក់ក្នុងអំពើបាប ហើយក៏តែងតែទាស់ប្រឆាំងនឹងព្រះអាទិករមួយអង្គនោះ ចាប់តាំងតែពីពេលនោះមក។ ហើយព្រះជាម្ចាស់ក៏បានចាត់ព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ឲ្យមកផែនដីនេះ ដើម្បីឲ្យការមិនស្តាប់បង្គាប់នេះអាចទទួលបានការជានាគ្នាវិញ តាមរយៈការស្តាប់បង្គាប់ដ៏ល្អឥតខ្ចោះរបស់ទ្រង់ និងតាមរយៈការសុគត ដែលគ្របបាំងរាល់អំពើបាប។

## ស្ពានសម្រាប់បេសកកម្មក្នុងឪពុក/បិតាដូចគ្នា

ក្នុងរបៀបនៃការគិតដូចនេះ—ទទួលការថ្កោលទោសតាមរយៈលោកអ័ដាម និងទទួលបានការរាប់ជាសុចរិតតាមរយៈព្រះគ្រីស្ទ—មិនមែនជាអ្វីដែលវប្បធម៌មានលក្ខន្តិកៈលើនោះទេ។ លោកអ្នកទំនងជាត្រូវព្យាយាមរៀបពាក្យពេចន៍ ប៉ុន្តែចំណុចនោះផ្ទាល់គឺជាផ្នត់គំនិតសកល។ នេះគឺជាមូលហេតុដែលសេចក្តីបង្រៀននេះពិតជាអស្ចារ្យមែន ទាក់ទងទៅនឹងបេសកកម្ម ពីព្រោះបេសកកម្មកំពុងតែឆ្លើយសំណួរនេះ “តើយើងអាចប្រាប់ដំណឹងល្អទៅកាន់អស់អ្នកដែលមិនដឹងអ្វីសោះបានដោយរបៀបណា?”។ ពួកគាត់មិនដឹងអ្វីសោះអំពីដំណើររឿងនៃជំនឿគ្រីស្ទបរិស័ទ ប៉ុន្តែយើងអាចភ្ជាប់ដំណើររឿងនោះបានតាមរយៈឪពុកពីបុរាណរបស់យើង និងតាមរយៈព្រះរាជបុត្រា



50 QnA John Piper Final 1.5.indd 108 25/01/2024 09:22:47 AM

របស់ព្រះជាម្ចាស់ដែលបានយាងមកផែនដី ហើយទទួលទោសដែលឪពុករបស់យើងទាំងអស់គ្នាមាន។ ដូច្នេះ ចំណុចនេះអាចឆ្លងវប្បធម៌បានក្នុងរបៀបដែលគួរឲ្យកត់សម្គាល់។

ទាំងអស់នេះមានន័យថា នៅពេលដែលបេសកជនត្រៀមខ្លួនក្នុងការទៅកន្លែងណាដែលពួកគាត់កំពុងតែរៀបចំទៅ នោះការផ្ដោតរបស់គាត់គឺមិនគួរគ្រាន់តែលើការរៀនភាសា ការសិក្សាពីមនុស្សជាតិ និងវប្បធម៌ទេ។ សព្វថ្ងៃនេះ មានការផ្ដោតយ៉ាងខ្លាំងលើចំណុចដែលថា ជោគជ័យរបស់យើងអាស្រ័យលើថាយើងចេះដឹងច្រើនក្នុងចំណុចទាំងនោះទាក់ទងទៅនឹងការធ្វើបេសកកម្ម។ ទាំងនោះក៏សំខាន់ដែរ។ ខ្ញុំមិនចង់ថា វាគ្មានតម្លៃនោះទេ ប៉ុន្តែទេវវិទ្យា និងការយល់ដឹងលើព្រះបន្ទូល—ជាពិសេសលើកណ្ឌគម្ពីរ រ៉ូម ជំពូក៥—គឺពិតជាសំខាន់ណាស់។

ដូច្នេះ បេសកជនគួរតែជាមនុស្សដែលពិតជាយកចិត្តទុកដាក់លើទេវវិទ្យាបែបព្រះគម្ពីរដូចនេះ។ នៅពេលដែលពួកគាត់ចាប់ផ្ដើមយល់នូវអ្វីដែលព្រះគម្ពីរពិតជាបានលើកឡើងមែន នោះពួកគាត់នឹងឃើញថាខ្លួនពិតជាអាចយល់វប្បធម៌នៃមនុស្សជាតិដែលពួកគាត់កំពុងតែលើកឡើង ពីព្រោះព្រះគម្ពីរមានឫសគល់ដែលគួរឲ្យចាប់អារម្មណ៍លើអ្វីដែលពិត។ ហើយចំណុចនេះក៏មិនមែនគ្រាន់តែសម្រាប់បញ្ហារបស់លោក អ័ដាម និងការរាប់ជាសុចរិតនោះទេ ប៉ុន្តែលើបញ្ហាជាច្រើនផ្សេងៗទៀត។ វានឹងមិនដែលលែងជាប្រយោជន៍ចំពោះលោកអ្នក ក្នុងការព្យាយាមសិក្សាព្រះបន្ទូល ក៏ដូចជាផ្នែកផ្សេងៗនៃវប្បធម៌ នៅពេលដែលលោកអ្នកត្រៀមខ្លួននោះទេ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 109 25/01/2024 09:22:48 AM

## សំណួរទី១៩៖
# តើព្រះគម្ពីរបង្រៀនថា គ្រីស្ទបរិស័ទពិត មិនចេះប្រព្រឹត្តអំពើបាបឬ?

*លោកគ្រូ តើកណ្ឌគម្ពីរ (១យ៉ូហាន ៥:១៨) មានន័យយ៉ាងដូចម្ដេច?*

«យើងដឹងថា អ្នកណាដែលកើតពីព្រះមក នោះមិនចេះធ្វើបាបទេ អ្នកនោះឯងជាអ្នករក្សាខ្លួនវិញ ហើយមេកំណាចនឹងពាល់អ្នកនោះមិនបានឡើយ» (១យ៉ូហាន ៥:១៨)។

ខ្ញុំមិនប្រាកដថា អ្នកសួរកំពុងផ្ដោតលើផ្នែកណាមួយនៃខគម្ពីរនេះនោះទេ ទំនងជាគាត់កំពុងតែផ្ដោតលើទាំងបីចំណុច។

១. *«អ្នកណាដែលកើតពីព្រះមក នោះមិនចេះធ្វើបាបទេ»—តើមានន័យយ៉ាងដូចម្ដេច?*

២. *«អ្នកណាដែលកើតពីព្រះមក អ្នកនោះឯងជាអ្នករក្សាខ្លួនវិញ»—តើមានន័យយ៉ាងដូចម្ដេច?*

៣. *«មេកំណាចនឹងពាល់អ្នកនោះមិនបានឡើយ»— តើមានន័យយ៉ាងដូចម្ដេច?*

ដោយសារខ្ញុំមិនប្រាកដថា អ្នកសួរកំពុងតែផ្ដោតលើចំណុចមួយណា ដូច្នេះខ្ញុំនឹងឆ្លើយលើចំណុចទាំងបី។

### អំពើបាបជាទម្លាប់

ខ្ញុំក៏មិនសូវច្បាស់ថា អ្នកសួរកំពុងតែអានការបកប្រែព្រះគម្ពីរនៅឆ្នាំណាដែរ ដូច្នេះខ្ញុំក៏នឹងកាន់តែមានការពិបាកបន្តិចក្នុងការឆ្លើយ។ ការបកប្រែចាស់មានចែងដូចតទៅ «*អ្នកណាដែលកើតពីព្រះមក នោះមិនចេះធ្វើបាបទេ*»។ នេះគឺជាការបកប្រែនៅឆ្នាំ១៩៥៤។ ឬក៏ការបកប្រែខ្មែរបច្ចុប្បន្ន នៅ



50 QnA John Piper Final 1.5.indd 111 25/01/2024 09:22:48 AM

ឆ្នាំ២០០៥៖ «អ្នកកើតមកពីព្រះជាម្ចាស់ មិនប្រព្រឹត្តអំពើបាបឡើយ»។ ដូច្នេះ គ្រីស្ទបរិស័ទដ៏ពិតមិនចេះប្រព្រឹត្តអំពើបាបមែនឬ?

ស្ដាប់ទៅ ហាក់បីដូចជាមានបញ្ហា—«គ្រីស្ទបរិស័ទដ៏ពិតមិនចេះប្រព្រឹត្តអំពើបាប»? ខ្ញុំធ្លាប់បានជួបស្ត្រីម្នាក់ដែលជឿថា នេះគឺជាការពិត។ គាត់បានប្រើប្រាស់កណ្ឌគម្ពីរ (១យ៉ូហាន ៥:១៨) និងកណ្ឌគម្ពីរ (១យ៉ូហាន ៣:៩)។ ហើយខ្ញុំក៏បានសួរគាត់វិញថា «តើប្អូនហៅអំពើបាបដែលប្អូនប្រព្រឹត្តថាយ៉ាងដូចម្ដេច?»។ ហើយគាត់បានប្ដូរឈ្មោះសម្រាប់អំពើបាបរបស់គាត់ជាច្រើនដែលមានដូចជា៖ *កំហុស គុណវិបត្តិ ភាពខ្វះមិនដល់ ភាពមិនល្អឥតខ្ចោះ* ប៉ុន្តែគាត់នៅតែចចេសថា គាត់មិនប្រព្រឹត្តអំពើបាបទៀតឡើយ។

## ជំនួយពីវេយ្យាករណ៍

ព្រះគម្ពីរកែសម្រួលឆ្នាំ២០១៦ បានបកប្រែថា «*យើងដឹងថា អ្នកដែលកើតមកពីព្រះ*»—ហើយបានបកប្រែកិរិយាសព្ទដូចតទៅ «*មិនធ្វើបាបទៀតឡើយ*» ដែលនេះបានជួយយើងបន្តិច។ កណ្ឌគម្ពីរ (១យ៉ូហាន ៣:៩) មានបញ្ហាដូចគ្នា៖ «*អស់អ្នកណាដែលកើតពីព្រះ នោះមិនដែលប្រព្រឹត្តអំពើបាបទេ ពីព្រោះពូជព្រះនៅក្នុងអ្នកនោះឯង បានជាពុំអាចនឹងធ្វើបាបបានឡើយ ដ្បិតបានកើតពីព្រះមក*»។

កិរិយាសព្ទក្នុងភាសាក្រិកក៏អាចជួយយើងបានបន្តិចដែរ ប៉ុន្តែមិនមែនជាចំណុចគោលគំនិតទេ។ គោលគំនិតក្នុងកិរិយាសព្ទបច្ចុប្បន្នកាលរបស់ភាសាក្រិក «ហាម៉ាថានី» «*hamartanei*» នៅក្នុងកណ្ឌគម្ពីរ (១យ៉ូហាន ៥:១៨) ដែលកំពុងមានការប្រើប្រាស់ គឺត្រង់ថា អស់អ្នកដែលបានកើតជាថ្មីហើយ ដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធនៃព្រះមកគង់នៅក្នុងពួកគាត់គឺពួកគាត់មិនអាចមានសន្តិភាពជាមួយនឹងអំពើបាបបានទេ មិនអាចរស់នៅជាមួយនឹងអំពើបាប មិនអាចធ្វើជាមិត្តជាមួយនឹងអំពើបាប ហើយក៏



50 QnA John Piper Final 1.5.indd 112 25/01/2024 09:22:48 AM

មិនអាចនៅបន្តប្រព្រឹត្តអំពើបាបបានដែរ—ដោយបន្តប្រព្រឹត្តអំពើបាប ហាក់បីដូចជាមិនចាំបាច់ធ្វើសង្គ្រាមទាស់ប្រឆាំងនឹងអំពើបាបឡើយ ហើយក៏នឹងគ្មានអ្វីកើតឡើងដែរប្រសិនបើយើងមិនធ្វើសង្គ្រាម។ កិរិយាសព្ទបច្ចុប្បន្នកាលលើកឡើងដូចតទៅ៖ ទេ! យើងមិនអាចធ្វើដូច្នោះបានឡើយ។ យើងមិនអាចនៅបន្តប្រព្រឹត្តអំពើបាបដូច្នោះទៀតបានទេ។

**តម្រុយពីបរិបទ**

ប៉ុន្តែ ប្រសិនបើលោកអ្នកមិនចេះភាសាក្រិក លោកអ្នកក៏មិនចាំបាច់ត្រូវទុកចិត្តលើខ្ញុំក្នុងចំណុចនេះដែរ ដោយសារមានមូលហេតុមួយចំនួនដែលអស់អ្នកដែលមិនចេះភាសាក្រិកដឹងថា ខគម្ពីរនេះមិនមែនមានន័យថា គ្រីស្ទបរិស័ទមិនធ្វើអ្វីខុសនោះដែរ។

ពីរខមុនកណ្ឌគម្ពីរ (១យ៉ូហាន ៥:១៦) បានចែងដូចតទៅ៖ «បើអ្នកណាឃើញបងប្អូន [ជាគ្រីស្ទបរិស័ទ] កំពុងតែធ្វើបាប គឺជាបាបដែលមិនមានទោសដល់ស្លាប់ទេ»។ ដែលនេះមានន័យថា អ្នកនិពន្ធមិនអាចមានន័យថាគ្រីស្ទបរិស័ទមិនប្រព្រឹត្តអំពើបាបទៀតទេ ពីព្រោះគាត់ទើបតែផ្តល់ជូននូវការណែនាំអំពីរបៀបនៃការជួយគ្រីស្ទបរិស័ទដែលប្រព្រឹត្តអំពើបាប។

ហើយចំណុចនេះក៏ពិតដែរនៅក្នុងកណ្ឌគម្ពីរ (១យ៉ូហាន ១:៨-១០)៖ «បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងយើងទេ បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសម្អាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង បើយើងថា «យើងមិនដែលធ្វើបាបសោះ» នោះឈ្មោះថាយើងធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ហើយព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ»។

ដូច្នេះ នៅក្នុងអត្ថន័យនៃកណ្ឌគម្ពីរ (១យ៉ូហាន ៥:១៨) ខ្ញុំគិតថានៅ



50 QnA John Piper Final 1.5.indd 113 25/01/2024 09:22:49 AM

ក្នុងបរិបទនេះ ចំណុចដំបូងដែលបញ្ជាក់យ៉ាងច្បាស់លាស់អំពីអត្ថន័យគឺថា៖ អស់អ្នកដែលបានកើតមកពីព្រះនឹងមិនបន្តប្រព្រឹត្តអំពើបាបដែលនាំឲ្យស្លាប់ ដែលនេះមានន័យថា យើងមិនមានសន្តិភាពជាមួយនឹងអំពើបាប យើងនឹងមិនមានទម្លាប់នៃការប្រព្រឹត្តអំពើបាប ដែលនឹងបំផ្លាញយើងចោលនៅទីបញ្ចប់។ យោងតាមកណ្ឌគម្ពីរ (១យ៉ូហាន ១:៨-១០) គ្រីស្ទបរិស័ទដើរក្នុងពន្លឺ ហើយការដើរក្នុងពន្លឺមិនមែនមានន័យថា គ្មានអំពើបាបទេ។ វាគឺជាការដើរក្នុងរបៀប ដែលលោកអ្នកមានភ្នែកមើលឃើញក្នុងពន្លឺ នូវអំពើអាក្រក់នៃអ្វីដែលលោកអ្នកទើបតែបានប្រព្រឹត្តិ ហើយលោកអ្នកក៏មានការខកចិត្តអំពីវា។ ដូច្នេះ លោកអ្នកក៏នឹងលន់តួបាប។ លោកអ្នកសូមឲ្យព្រះជាម្ចាស់អត់ទោសភ្លាមៗ ហើយបន្តរស់នៅទៅមុខទៀត។

ដូច្នេះ ខ្ញុំគិតថាឃ្លា *"មិនចេះធ្វើបាបទេ"* មានន័យថា៖

១) មិនប្រព្រឹត្តអំពើបាបដែលមានទោសដល់ស្លាប់

២) មិនបន្តមានទម្លាប់ប្រព្រឹត្តអំពើបាប ដែលបង្ហាញជាភស្តុតាងថា លោកអ្នកមិនមានជីវិតខាងវិញ្ញាណ នៅក្នុងខ្លួនឡើយ។

## ព្រះគ្រីស្ទដែលជាអ្នកការពារថែរក្សាយើង

ចំណុចទី២៖ *"អ្នកណាដែលកើតពីព្រះមក...អ្នកនោះឯងជាអ្នករក្សាខ្លួន"* ខ្ញុំគិតថាឃ្លានេះមានន័យថា ព្រះគ្រីស្ទ—ដែលព្រះគម្ពីរបានហៅថា បានកើតពីព្រះជាម្ចាស់ ជាព្រះរាជបុត្រាទ្រង់តែមួយរបស់ព្រះ ជាវិញ្ញាណអស់កល្បជានិច្ចដែលបានកើតមកពីនាងក្រមុំព្រហ្មចារី ប៉ុន្តែបានប្រសូតមកក្នុងវិញ្ញាណនៃព្រះរាជបុត្រារបស់ព្រះ—ការពារយើងពីអារក្សសាតាំង។

ព្រះអង្គអង្វរកជំនួសយើង (ហេព្រើរ ៧:២៥) ហើយព្រះអង្គក៏គង់នៅជាមួយនឹងយើងរាល់គ្នាជារាល់ថ្ងៃ ដរាបដល់បំផុតកល្ប ដើម្បីជួយយើងដែរ (ម៉ាថាយ ២៨:២០) ហើយព្រះលោហិតរបស់ទ្រង់គ្របបាំងយើង



50 QnA John Piper Final 1.5.indd 114 25/01/2024 09:22:49 AM

(អេភេសូរ ២:១៣) ហើយការពារយើងឲ្យមានសុវត្ថិភាពពីការចោទប្រកាន់របស់សាតាំង ពីព្រោះការចោទប្រកាន់នោះមិនអាចមានប្រសិទ្ធភាពបានដោយសារព្រះគ្រីស្ទបានសុគតជំនួសយើង។

## មានសុវត្ថិភាពពីសាតាំង

ចំណុចទី៣៖ «*មេកំណាចនឹងពាល់អ្នកនោះមិនបានឡើយ*»។ ការចោទប្រកាន់ សេចក្ដីល្បួង និងការរំខានរបស់សាតាំងអាចធ្វើឲ្យយើងមានការឈឺចាប់យ៉ាងខ្លាំងបាន ប៉ុន្តែវាមិនអាចបំផ្លាញយើងចោលទាំងស្រុងបាននោះទេ។ មិនមានការប៉ះពាល់ពីវាដែលអាចនឹងនាំឲ្យយើងស្លាប់បានឡើយ។ មិនមានការខាំដែលពេញទៅដោយពិសពុលនោះទេ។ ព្រះអង្គបានដកចង្កូមវាចេញនៅឯឈើឆ្កាង ហើយព្រះអង្គក៏បានដកពិសដែលធ្វើឲ្យអ្នកជឿស្លាប់ចេញពីវាដែរ។ វាមិនអាចបំផ្លាញយើងបានទេ។

ដូច្នេះ ខ្ញុំកាត់ស្រាយឃ្លា «*នឹងពាល់អ្នកនោះមិនបានឡើយ*» ឲ្យមានន័យថា សាតាំងមិនអាចប៉ះយើងរហូតដល់ធ្វើឲ្យយើងស្លាប់បាននោះទេ។ វាអាចធ្វើឲ្យយើងមានការឈឺចាប់យ៉ាងខ្លាំងបាន។ ខ្ញុំមិនចង់និយាយបន្ទាបការពិតនៃអំណាចរបស់សាតាំងនៅលើលោកីយ៍នេះទេ។ យោងតាមកណ្ឌគម្ពីរ (វិវរណៈ ២:១០) វាអាចបោះយើងចូលក្នុងគុកបាន ហើយវាក៏អាចបណ្ដាលឲ្យអ្នកដទៃសម្លាប់យើងបានដែរ។ ប៉ុន្តែ វាមិនអាចធ្វើឲ្យយើងឈឺចាប់រហូតដល់ស្លាប់បានទេ។ វាមិនអាចប៉ះយើងក្នុងរបៀបនៃការពាល់ដែលនាំឲ្យយើងធ្លាក់នរក ឬក៏បំផ្លិចបំផ្លាញយើងចោលបានដែរ។ ព្រះអង្គបានដកការនោះចេញពីដៃវា តាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវហើយ។ យោងតាមកណ្ឌគម្ពីរ (កូឡុស ២:១៥) ព្រះយេស៊ូវបានធ្វើការនោះនៅឯឈើឆ្កាងរួចស្រេចហើយ។ ព្រះអង្គបានដកអំណាចនោះចេញពីអារក្សដែលជាអ្នកគ្រប់គ្រងលើផែនដីនេះ នៅពេលដែលព្រះអង្គសុគត ហើយខ្វាយព្រះលោហិតទ្រង់។



50 QnA John Piper Final 1.5.indd 115 25/01/2024 09:22:49 AM

ដូច្នេះ ព្រះរាជបុត្រាតែមួយគត់របស់ព្រះជាម្ចាស់គឺពិតជាព្រះដែលល្អឥត ខ្ចោះរបស់យើង ហើយក៏ជាព្រះដែលការពារយើងយ៉ាងអស់កល្បជានិច្ចដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**

# ផ្នែកទី៣៖ ទំនាក់ទំនង



50 QnA John Piper Final 1.5.indd 117 25/01/2024 09:22:49 AM

លោកអ្នកអាចស្តាប់សៀវភៅនេះជាសំឡេងបាន
ដោយគ្រាន់តែ

ស្កេននៅទីនេះ

# សំណួរទី២០៖
# របៀបដែលភាពនៅលីវល្អ

*ភាពនៅលីវរបស់ អ័ដាម មិនមែនជារឿងល្អនោះទេ ហេតុដូច្នេះហើយបានជាព្រះជាម្ចាស់បានប្រទានប្រពន្ធមួយដល់គាត់។ សំណួរមួយទៀតថាគឺ «តាមផ្ទត់គំនិត តើភាពនៅលីវគឺជាអំពើបាបដែរឬទេ? តើលោកអ្នកនឹងនិយាយយ៉ាងដូចម្ដេចទៅកាន់អ្នកនៅលីវ? ជាពិសេស តើលោកអ្នកនឹងនិយាយយ៉ាងដូចម្ដេចទៅកាន់អស់អ្នកដែលអាចនឹងនៅលីវអស់មួយជីវិត»?*

នៅពេលដែលយើងចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ ទំនងជាអ្នកនៅលីវគិតក្នុងរបៀបនេះ «អាពាហ៍ពិពាហ៍គឺជាជីវិតដ៏ល្អប្រសើរ។ ហើយខ្ញុំទទួលបានជីវិតដែលមិនសូវល្អជាងនេះសោះ»។ យើងខ្ញុំចង់ឲ្យអស់អ្នកនៅលីវដឹងថាជីវិតអាពាហ៍ពិពាហ៍ និងភាពនៅលីវមានអំណោរក្នុងរបៀបខុសៗគ្នា។ មានអំណោរមួយចំនួនបានបង្ហាញនៅក្នុងជីវិតអាពាហ៍ពិពាហ៍ ហើយក៏មិនបានបង្ហាញនៅក្នុងជីវិតនៅលីវនោះទេ។ ប៉ុន្តែ ក៏មានអំណោរមួយចំនួនបានបង្ហាញនៅក្នុងជីវិតនៅលីវ ដែលមិនបានបង្ហាញនៅក្នុងជីវិតអាពាហ៍ពិពាហ៍ដែរ។

## ចូរលើកតម្កើងព្រះគ្រីស្ទក្នុងភាពនៅលីវ

តើព្រះជាម្ចាស់បានត្រាស់ហៅលោកអ្នកឲ្យមានជីវិតនៅលីវមែនឬ? ប្រសិនបើដូច្នោះមែន  នោះមានរបៀបជាច្រើនក្នុងការបង្ហាញអំពីសិរីល្អរបស់ព្រះជាម្ចាស់ ដែលអ្នករៀបការហើយមិនអាចធ្វើបាន។ ប៉ុន្តែ លោកអ្នកក៏ត្រូវមានអ្នកដទៃមកចូលរួមជាមួយផងដែរ។ ព្រះជាម្ចាស់បានបង្កើតយើងមកជាមួយនឹងអ្នកដទៃ និងសម្រាប់អ្នកដទៃ។ អ្នកដទៃផ្សេងទៀតគឺមិនមែនគ្រាន់តែជាប្រពន្ធ ឬក៏ប្ដីនោះទេ។ ពួកគាត់ក៏ជាមនុស្សដែរ។ ហើយព្រះជាម្ចាស់ក៏បានត្រាស់ហៅឲ្យអ្នកនៅលីវមកធ្វើជាគ្រីស្ទបរិស័ទដែរ។ ព្រះ



50 QnA John Piper Final 1.5.indd 119 25/01/2024 09:22:50 AM

ជាម្ចាស់មានព្រះបន្ទូលថា «ចូរទទួលគ្នាទៅវិញទៅមក ដូចជាព្រះគ្រីស្ទបានទទួលយើងដែរ»។ បន្ទាប់មក «ព្រមព្រៀងមូលមាត់តែមួយនឹងសរសើរតម្កើងដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា» (រ៉ូម ១៥:៥-៦)។ យើងខ្ញុំកំពុងតែនិយាយអំពីគ្រួសារដ៏នៅអស់កល្បជានិច្ចដ៏ពិត។ ចំណុចមួយដែលយើងខ្ញុំចង់សង្កត់ធ្ងន់លើគឺថា៖ ជីវិតអាពាហ៍ពិពាហ៍គឺគ្រាន់តែជាការបណ្តោះអាសន្នតែប៉ុណ្ណោះ។ ប៉ុន្តែ ក្រុមជំនុំស្ថិតនៅអស់កល្បជានិច្ច។

ទំនាក់ទំនងដែលបានសង់ឡើងជាមួយនឹងបងប្អូនប្រុសស្រីនៅក្នុងក្រុមជំនុំគឺស្ថិតនៅអស់កល្បជានិច្ច។ ទំនាក់ទំនងរវាងមនុស្សប្រុស និងមនុស្សស្រីនៅក្នុងជីវិតអាពាហ៍ពិពាហ៍គឺមិនស្ថិតនៅអស់កល្បជានិច្ចនោះទេ។ ព្រះយេស៊ូវបានប្រាប់យើងយ៉ាងច្បាស់លាស់ថា មិនមានជីវិតអាពាហ៍ពិពាហ៍នៅគ្រារស់ឡើងវិញនោះទេ (ម៉ាថាយ ២២:៣០)។ នេះគឺជាមូលហេតុដែលឪពុករបស់យើងខ្ញុំនឹងមិនមានប្រពន្ធពីរនាក់នៅឯស្ថានសួគ៌ទេ ទោះបើថានៅផែនដីនេះគាត់មានប្រពន្ធពីរនាក់ក៏ដោយ។ ឪពុករបស់ខ្ញុំបានចំណាយពេល៣៦ឆ្នាំជាមួយម្តាយរបស់យើងខ្ញុំ ហើយបន្ទាប់មកបានចំណាយពេល២៥ឆ្នាំជាមួយម្តាយចុងរបស់ខ្ញុំ បន្ទាប់ពីអ្នកម្តាយរបស់យើងខ្ញុំបានស្លាប់។ ព្រះយេស៊ូវបានបង្រៀនយើងថា «នោះគេមិនយកគ្នាជាប្តីប្រពន្ធទៀតទេ»។

ដូច្នេះហើយបានជាការនៅលីវមិនមែនមានន័យថា លោកអ្នកទទួលបានជីវិតដែលទាបជាងអ្នកដទៃនោះទេ។ លោកអ្នកក៏អាចបង្ហាញអំពីសិរីល្អនៃសហគមន៍ក្រុមជំនុំនៅក្នុងរបៀបពិសេសៗជាច្រើនបានដែរ។ លោកអ្នកអាចបង្ហាញអំពីសិរីល្អនៃការពឹងផ្អែកលើព្រះជាម្ចាស់បាននៅក្នុងរបៀបពិសេសៗជាច្រើន។ ហើយទាំងនេះគឺជាអំណោយដ៏ពិសេសដែលមិនមានសម្រាប់អ្នកដែលរៀបការហើយនោះទេ។



50 QnA John Piper Final 1.5.indd 120 25/01/2024 09:22:50 AM

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 121 25/01/2024 09:22:50 AM

## សំណួរទី២១៖
# តើឲ្យខ្ញុំប្រាថ្នាទៅស្ថានសួគ៌បានដោយរបៀបណា ខណៈពេលដែលខ្ញុំដឹងថា ខ្ញុំនឹងមិនរៀបការជាមួយនឹងប្ដីរបស់ខ្ញុំនៅទីនោះ?

*មានស្ត្រីម្នាក់បានសួរមកកាន់ខាងយើងថា «តើខ្ញុំនៅអាចប្រាថ្នាចង់ទៅនៅស្ថានសួគ៌យ៉ាងពិតដូចម្ដេច ប្រសិនបើខ្ញុំដឹងថា ខ្ញុំនឹងមិនរៀបការជាមួយនឹងប្ដីរបស់ខ្ញុំនៅទីនោះ?»*

តាមរយៈការដែលបងស្រីថែរក្សាទំនាក់ទំនងនៃអំណរដែលបងស្រីកំពុងតែលូតលាស់នៅក្នុងព្រះគ្រីស្ទ នោះបងស្រីនឹងពិតជានៅបន្តប្រាថ្នាចង់ទៅនៅស្ថានសួគ៌។

យើងខ្ញុំយល់អំពីពេលវេលាដែលយើងស្រឡាញ់កូនៗ ឪពុកម្ដាយ និងជាពិសេសដៃគូរជីវិតរបស់យើងយ៉ាងខ្លាំង។ យើងអាចទទួលបានការអរសប្បាយជាច្រើនតាមរយៈទំនាក់ទំនង ហេតុដូច្នេះយើងមានការឈឺចាប់ពេលដែលបានដឹងថា ទំនាក់ទំនងនោះនឹងបញ្ចប់។

ប៉ុន្តែ នៅឯស្ថានសួគ៌មិនមានការឈឺចាប់នោះទេ។ ដូច្នេះ យើងខ្ញុំក៏យល់អំពីសំណួរមួយដែរ។

ទោះជាយ៉ាងណាក៏ដោយ ក៏បងស្រីនៅអាចលូតលាស់ខាងឯការប្រាថ្នាចង់បានព្រះយេស៊ូវក្នុងរបៀបដ៏ពិសេសបានដែរ ដល់ថ្នាក់ថាបងស្រីហ្នឹងអាចនិយាយដូចតទៅ «ឯនៅស្ថានសួគ៌ តើទូលបង្គំមានអ្នកឯណាក្រៅពីទ្រង់ ហើយនៅផែនដីទូលបង្គំប្រាថ្នាចង់បានតែទ្រង់ទេ ឯសាច់ នឹងចិត្តទូលបង្គំនោះនឹងសាបសូន្យទៅបាន ប៉ុន្តែព្រះទ្រង់ជាទីពឹងនៃចិត្ត ហើយជាចំណែកមរដកនៃទូលបង្គំជាដរាបដែរ» (ទំនុកតម្កើង ៧៣:២៥-២៦)។



50 QnA John Piper Final 1.5.indd 123 25/01/2024 09:22:50 AM

បងស្រីអាចឈានដល់ចំណុចដែលបងស្រីអាចមានអំណរយ៉ាងខ្លាំងក្នុងព្រះយេស៊ូវ ដល់ថ្នាក់ថាដៃគូជីវិតរបស់បងស្រីក៏នឹងក្លាយជាអ្នកជួយបងស្រីក្នុងការមានអំណរក្នុងព្រះយេស៊ូវដែរ។ ដៃគូជីវិតរបស់បងស្រីក្លាយជាទីបង្ហាញនៃអំណររបស់បងស្រីក្នុងព្រះយេស៊ូវ។ ដូច្នេះ សូម្បីតែនៅពេលដែលដៃគូរបស់បងស្រីលែងនៅជាមួយនឹងបងស្រីទៀត នោះក៏បងស្រីនៅអាចមានអំណរក្នុងព្រះយេស៊ូវតទៀតបានដែរ។

ប្រសិនបើបងស្រីមានអារម្មណ៍ថា ការស្លាប់គឺជាការបាត់បង់ នោះយើងខ្ញុំនៅមានចំណុចចុងក្រោយមួយទៀតដែលយើងខ្ញុំចង់ប្រាប់បងស្រី។ យើងខ្ញុំនឹងប្រាប់បងស្រីថា ការស្លាប់គឺជាប្រយោជន៍ ពីព្រោះយើងទទួលបានព្រះគ្រីស្ទ។ ប៉ុន្តែ ខណៈពេលដែលយើងទទួលបានព្រះគ្រីស្ទ នោះយើងក៏ទទួលបាននូវរាល់គ្រប់អ្វីៗទាំងអស់ផ្សេងទៀតជាមួយនឹងទ្រង់ផងដែរ។ រាល់គ្រប់អ្វីៗទាំងអស់ផ្សេងទៀតជាមួយនឹងព្រះគ្រីស្ទក៏នឹងកាន់តែប្រសើរជាងមុនទៅទៀតដែរ។

ដូច្នេះ សេចក្តីស្រឡាញ់ក្នុងជីវិតអាពាហ៍ពិពាហ៍នឹងក្លាយទៅជាអ្វីដែលល្អប្រសើរជាងដែរ។ «ដ្បិតដល់គ្រារស់ឡើងវិញ នោះគេមិនយកគ្នាជាប្តីប្រពន្ធទៀតទេ» (ម៉ាថាយ ២២:៣០)។ ត្រឹមត្រូវហើយ! យើងនឹងមិនមែនជាប្តីប្រពន្ធទៀតទេ ដោយសារមិនមានពិធីរៀបការទៀតទេ។ ព្រះយេស៊ូវបានមានបន្ទូលអំពីស្ត្រីដែលបានមានប្តីប្រាំពីរនាក់។ ព្រះអង្គបានសួរគាត់ថា «ដល់គ្រារស់ឡើងវិញ តើនាងនោះនឹងត្រូវធ្វើជាប្រពន្ធរបស់អ្នកណា» (ម៉ាថាយ ២២:២៨)។ ព្រះអង្គបានឆ្លើយតបថា «ដ្បិតដល់គ្រារស់ឡើងវិញ នោះគេមិនយកគ្នាជាប្តីប្រពន្ធទៀតទេ»។ ដូច្នេះ គាត់នឹងមិនក្លាយជាអ្នកមានប្តីលើសពីមួយឡើយ។

ឪពុករបស់ខ្ញុំមានប្រពន្ធពីរនាក់ក្នុងពេលខុសៗគ្នា ដែលបានស្លាប់ហើយ។ គាត់បានរៀបការជាមួយនឹងប្រពន្ធទី១របស់គាត់អស់រយៈពេល



50 QnA John Piper Final 1.5.indd 124 25/01/2024 09:22:51 AM

២៥ឆ្នាំ ហើយបន្ទាប់មកក៏បានរៀបការជាមួយនឹងប្រពន្ធទី២របស់គាត់អស់រយៈពេល៣៦ឆ្នាំដែរ។ ឪពុករបស់យើងខ្ញុំនឹងមិនមានប្រពន្ធពីរនាក់នៅឯស្ថានសួគ៌នោះទេ។ គាត់នឹងស្គាល់ស្ត្រីទាំងពីរនាក់នោះ ហើយគាត់ក៏នឹងមានសេចក្តីស្រឡាញ់ដ៏ល្អឥតខ្ចោះថ្មីសម្រាប់ពួកគាត់ទាំងពីរនាក់នោះដែរ។ សេចក្តីស្រឡាញ់ថ្មីនេះនឹងមិនមែនក្លាយជារឿងដ៏ចម្លែកសម្រាប់ពួកគាត់ណាម្នាក់នោះទេ។ ហើយវាក៏នឹងក្លាយជាសេចក្តីស្រឡាញ់ដ៏ល្អប្រសើរជាជាងសេចក្តីស្រឡាញ់ដែលពួកគាត់បានមានក្នុងជីវិតនេះផងដែរ។

រាល់គ្រប់ចំណុចដែលបងស្រីស្រឡាញ់អំពីជីវិតអាពាហ៍ពិពាហ៍ក៏នឹងបន្តមានបន្ទាប់ពីបងស្រីបានស្លាប់ដែរ ប៉ុន្តែនឹងមានលើសពីនោះទៅទៀត។ គឺវានឹងល្អប្រសើរជាង។

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 125 25/01/2024 09:22:51 AM

# សំណួរទី២២៖
# របៀបជួយមិត្តភក្តិគេចចេញពីដំណឹងល្អ ដែលសន្យាភាពចម្រុងចម្រើន

*សព្វថ្ងៃយើងកំពុងតែរស់នៅក្នុងយុគសម័យដ៏ទំនើបៗ ហើយក៏ជាយុគសម័យដ៏អាក្រក់ៗផងដែរ។ ភស្តុតាងមួយដែលសបញ្ជាក់ថា យើងកំពុងតែរស់នៅក្នុងយុគសម័យដ៏អាក្រក់ គឺត្រង់ថាឥឡូវនេះមានការបង្រៀនខុសឆ្គងបានជ្រាបចូលមកក្នុងប្រទេសយើង ដែលយើងហៅការបង្រៀននោះថា "ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន"។*

មានបណ្តាក្រុមជំនុំ និងព័ន្ធកិច្ចមួយចំនួនកំពុងតែប្រកាស និងបង្រៀនទៅកាន់ពួកអ្នកក្រីក្រអំពីដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន។ ការបង្រៀនបែបនេះបានបង្ខាំងសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរទាក់ទងទៅនឹងការរងទុក្ខ ហើយក៏បានបន្ទាបសិរីរុងរឿងនៃដំណឹងល្អយ៉ាងទាបរហូតដល់ដីជំនួសយកឥរិយាបថរបស់មនុស្ស ជាជាងយកសិរីរុងរឿងនៃភ្នំកាល់វ៉ារី។

យើងទាំងអស់គ្នាសុទ្ធសឹងតែបានជួបប្រទះគ្រូគង្វាល ក៏ដូចជាមិត្តភក្តិ និងក្រុមគ្រួសារដែលអះអាងថា បើយើងទទួលជឿលើព្រះយេស៊ូវ ហើយប្រកាសក្នុងព្រះនាមព្រះអង្គនៅពេលដែលយើងចង់បានអ្វីមួយ ដោយគ្រាន់តែមានជំនឿឲ្យបានគ្រប់គ្រាន់ល្មម នោះព្រះអង្គនឹងប្រទានឲ្យជាមិនខាន។ យើងហៅសេចក្តីបង្រៀនបែបនេះថា ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន។ ក្នុងកាលៈទេសៈបែបនេះ តើឲ្យយើងគួរនឹងឆ្លើយតបជាមួយនឹងពួកគាត់ដោយរបៀបណាទៅ? តើព្រះគម្ពីរមានចែងយ៉ាងដូចម្តេចខ្លះដែលយើងអាចយកមកប្រើប្រាស់ក្នុងការឆ្លើយតបទៅកាន់ពួកគាត់? ខាងក្រោមនេះគឺជារបៀប៣យ៉ាងដែលយើងអាចយកទៅប្រើប្រាស់ក្នុងការឆ្លើយតប៖



50 QnA John Piper Final 1.5.indd 127 25/01/2024 09:22:51 AM

## បញ្ហាទី១នៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន

វាបន្ទាបទេវវិទ្យាដែលមានចែងនៅក្នុងព្រះគម្ពីរទាក់ទងទៅនឹងការដែលគ្រីស្ទបរិស័ទនីមួយៗគួរតែរំពឹងនឹកចាំអំពីការរងទុក្ខ ពោលគឺការរងទុក្ខដែលគ្រីស្ទបរិស័ទដឹងថា ខ្លួននឹងជួបប្រទះ ហើយព្រះគម្ពីរក៏បានសន្យាថាពួកគាត់ក៏នឹងរងទុក្ខបែបដូច្នោះដែរ។ កណ្ឌគម្ពីរ (១ពេត្រុស ៤:១៩) បានចែងថា «ដូច្នេះ ពួកអ្នកដែលរងទុក្ខ តាមព្រះហឫទ័យនៃព្រះ នោះត្រូវផ្ញើព្រលឹងខ្លួន ទុកនឹងព្រះដ៏បង្កបង្កើត ដែលទ្រង់ស្មោះត្រង់ ដោយខ្លួនប្រព្រឹត្តការល្អចុះ»។ ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបន្ទាបការបង្រៀនដែលមានពាសពេញក្នុងព្រះគម្ពីរមួយនេះយ៉ាងខ្លាំងក្លា៖ ព្រះជាម្ចាស់បានត្រាស់ហៅឲ្យយើងរងទុក្ខ។ ហើយនេះមិនគ្រាន់តែទាក់ទងទៅនឹងការរងទុក្ខនៃការបៀតបៀនប៉ុណ្ណោះទេ ប៉ុន្តែក៏ទាក់ទងនឹងការរងទុក្ខខាងឯសាច់ឈាមដែលនឹងរលាយបាត់សូន្យទៅ សាច់ឈាមដែលនឹងមានជំងឺនានា ដូចដែលមានចែងក្នុងកណ្ឌគម្ពីរ (រ៉ូម ៨:២៣) និង(២កូរិនថូស ៤:១៦) ដែរ។

ជាទូទៅ អាស្រ័យដូចនេះហើយបានជាគ្រីស្ទបរិស័ទដែលទៅក្រុមជំនុំដែលបង្រៀនភាពចម្រុងចម្រើនជារឿយៗមិនបានត្រៀមខ្លួនទាល់តែសោះក្នុងការទទួលយកនូវអ្វីៗដែលព្រះជាម្ចាស់បានគ្រោងទុកសម្រាប់ពួកគាត់ ហើយនេះគឺពិតជារឿងមួយដែលគួរឲ្យសោកស្ដាយណាស់។ ហេតុដូច្នេះហើយបានជាយើងមានចិត្តចង់រកបៀបដោះស្រាយសម្រាប់គ្រួសារ មិត្តភក្តិ និងគ្រូនានាទាក់ទងនឹងសេចក្ដីបង្រៀនដែលសន្យាភាពចម្រុងចម្រើនមួយនេះ។

នេះឯងជាមូលហេតុមួយដែលក្រុមជំនុំមួយចំនួនមិនសូវពេញចិត្តឬក៏សប្បាយចិត្តនៅពេលដែលពួកគេឃើញជនពិការមកចូលរួមជាមួយក្រុមជំនុំរបស់ពួកគេ ពីព្រោះពួកគេមិនមានទេវវិទ្យាដែលចេញពីព្រះគម្ពីរដែលទាក់ទងនឹងការរងទុក្ខ ហើយផលផ្លែក៏ពិបាកទទួលស្គាល់ដែរ។



50 QnA John Piper Final 1.5.indd 128 25/01/2024 09:22:51 AM

## បញ្ហាទី២នៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន

ដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនក៏បន្ទាបសិរីរុងរឿងនៃដំណឹងល្អយ៉ាងទាបរហូតដល់ដីមកជំនួសយកភាពរុងរឿងខាងឯសាច់ឈាមវិញ។ អំណោយទានដ៏ជាក់លាក់នៃដំណឹងល្អក្នុងព្រះគម្ពីរសញ្ញាថ្មីគឺមិនទាក់ទងនឹងភាពចម្រុងចម្រើនខាងឯសាច់ឈាមនោះទេ។ អំណោយទានដ៏ជាក់លាក់គឺជាអំណរនៃការមានភាពផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់ និងអំណរដ៏អស់កល្បជានិច្ចដែលមាននៅព្រះហស្តខាងស្តាំរបស់ព្រះអង្គក៏គ្មានទីបញ្ចប់តាមរយៈព្រះយេស៊ូវគ្រីស្ទ (ទំនុកតម្កើង ១៦:១១)។ ទោះបើថាជីវិតយើងសព្វថ្ងៃនេះល្អប្រសើរជាងមុននៅលើផែនដីនេះយ៉ាងណាក៏ដោយ ក៏វាជាចំណាត់ថ្នាក់ទី២ទាក់ទងនឹងរបៀបដែលព្រះគម្ពីរសញ្ញាថ្មីឲ្យតម្លៃ។

ប្រាកដណាស់! នឹងមានថ្ងៃដ៏ល្អប្រសើរនៅឯផែនដីថ្មីដែលពេលនោះគ្រប់អ្វីៗនឹងរុងរឿងជាមិនខាន ប៉ុន្តែនេះមិនមែនជាអ្វីដែលដំណឹងល្អឲ្យមានភ្លាមៗនៅក្នុងព្រះគម្ពីរសញ្ញាថ្មីទាក់ទងនឹងអ្វីផ្សេងៗទៀតនោះឡើយ។ បញ្ហាដ៏ធំបំផុតក្នុងលោកីយ៍នេះគឺថា ព្រះជាម្ចាស់ក្រោធនឹងអ្វីៗដែលទ្រង់បានបង្កើតមក ដោយសារពួកវាបះបោរទាស់ប្រឆាំងនឹងព្រះអង្គ ហើយចំណុចស្នូលនៃដំណឹងល្អគឺថា ក្នុងព្រះគ្រីស្ទ ព្រះជាម្ចាស់បានបង្កើតឲ្យមានការស្កប់ចិត្តជាចម្បងទាក់ទងទៅនឹងកំហឹងមួយនោះ ហើយបានយកព្រះអង្គផ្ទាល់ធ្វើជាទ្រព្យសម្បត្តិរបស់ទ្រង់ មិនមែនការអាក្រក់របស់យើងនោះទេ។ គ្រូៗដែលប្រកាសដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានធ្វើឲ្យមានការភ័ន្តច្រឡំដ៏ខ្លាំងក្រៃលែង ដោយពួកគាត់បានបង្វែរលទ្ធផលចំណាត់ថ្នាក់ទី២នៃដំណឹងល្អឲ្យក្លាយទៅជាចំណាត់ថ្នាក់លេខ១ទៅវិញ ដែលទាក់ទងទៅនឹងចំណុចមួយចំនួនដែលអាចនឹងកើតឡើងបាន តែការពិតវាមិនដូច្នោះឡើយ។



50 QnA John Piper Final 1.5.indd 129 25/01/2024 09:22:52 AM

## បញ្ហាទី៣នៃដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន

គ្រូៗដែលបង្រៀនដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនក៏បង្ខូចមូលដ្ឋានគ្រឹះនៃសេចក្តីសង្គ្រោះរបស់យើងផងដែរ ដោយពួកគាត់ផ្តោតខ្លាំងទៅលើចំណុចថា តើយើងអាចនឹងបង្កើតផលផ្លែនៃជំនឿដែលនាំឲ្យមានទ្រព្យសម្បត្តិយ៉ាងមហិមាជាជាងការផ្តោតទៅលើសិរីរុងរឿងនៃព័ន្ធកិច្ចរបស់ព្រះគ្រីស្ទក្នុងការដែលព្រះអង្គសុគតហើយបានមានព្រះជន្មរស់ឡើងវិញ ដើម្បីនឹងដកពិរុទ្ធភាពនៃអំពើបាបរបស់យើងចេញ និងធ្វើឲ្យព្រះជាម្ចាស់ស្កប់ព្រះទ័យនឹងសេចក្តីក្រោធរបស់ទ្រង់។

## ការស្រឡាញ់អស់អ្នកដែលយើងស្រឡាញ់

ខាងក្រោមនេះគឺជារបៀបមួយចំនួនដែលយើងអាចបង្ហាញសេចក្តីស្រឡាញ់ទៅកាន់អស់អ្នកដែលលង់ក្នុងសេចក្តីបង្រៀនដែលសន្យាភាពចម្រុងចម្រើន៖

*ទី១* ចូរឯកភាព និងអបអរសាទរជាមួយនឹងពួកគាត់ត្រង់ថា ពួកគាត់បានគិតយ៉ាងត្រឹមត្រូវហើយដោយជឿថាព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យបុត្រាបុត្រីរបស់ទ្រង់មានសុខភាពល្អ និងមានទ្រព្យសម្បត្តិ—មិនយូរមិនឆាប់។ ព្រះជាម្ចាស់មិនបានចាត់ព្រះយេស៊ូវឲ្យមកកាន់ផែនដីនេះ ដើម្បីធ្វើឲ្យពួកគាត់មានទុក្ខលំបាកដ៏អស់កល្បជានិច្ចនោះទេ ប៉ុន្តែឲ្យមានភាពអរសប្បាយដ៏អស់កល្បជានិច្ច និងដើម្បីឲ្យដកចេញនូវរាល់ទឹកភ្នែកពីភ្នែករបស់ពួកគាត់ (វិវរណៈ ២១:៤)។

ប៉ុន្តែ សូមលើកសំណួរនេះជាមួយនឹងគ្រួសាររបស់លោកអ្នកទាក់ទងទៅនឹងពេលវេលា។ ទាក់ទងទៅនឹងពេលវេលា គ្រូៗដែលបង្រៀនដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានយល់ដឹងមិនត្រឹមត្រូវសោះ។ តើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងទទួលបាននូវសេចក្តីសន្យាដ៏ល្អៗ



50 QnA John Piper Final 1.5.indd 130 25/01/2024 09:22:52 AM

ទាំងអស់នោះសម្រាប់ឥឡូវនេះក្នុងវេលានេះយ៉ាងពេញទីមែន ឬក៏ថាព្រះគម្ពីរបានបង្រៀនថាព្រះជាម្ចាស់បានសង្គ្រោះយើងពីមួយដំណាក់កាលទៅមួយដំណាក់កាលទៀត ហើយថាដំណើរជីវិតនៅលើផែនដីនេះ រវាងការបំផ្លាស់បំប្រែចិត្តជឿ និងការទទួលបានសិរីល្អគឺទាក់ទងគ្នាយ៉ាងស្អិតល្មួតជាមួយនឹងការរងទុក្ខក្នុងក្ដីសង្ឃឹមនៃសិរីល្អទៅវិញទេឬ? ដូច្នេះ ត្រង់នេះយើងខ្ញុំចង់លើកទឹកចិត្តឲ្យបងប្អូនជជែកគ្នាអំពីប្រធានបទនេះជាមួយនឹងពួកគាត់ដោយផ្ដោតទៅលើពេលវេលា ដោយមិនមែនថាយើងនឹងទទួលបានសុខភាពល្អ ទ្រព្យសម្បត្តិ ឬក៏ភាពអរសប្បាយក្នុងព្រះជាម្ចាស់មិនយូរមិនឆាប់នោះទេ។

*ទី២* ចូលនិយាយទៅកាន់ពួកគេអំពីចំណុចមួយដែលថា ព្រះជាម្ចាស់ផ្ទាល់គឺជាទ្រព្យសម្បត្តិដ៏ល្អអស្ចារ្យសម្រាប់យើង មិនមែនអំណោយទានរបស់ទ្រង់ឡើយ។ ឧទាហរណ៍៖ «ឯនៅស្ថានសួគ៌ តើទូលបង្គំមានអ្នកឯណាក្រៅពីទ្រង់ ហើយនៅផែនដីទូលបង្គំប្រាថ្នាចង់បានតែទ្រង់ទេ ឯសាច់នឹងចិត្តទូលបង្គំ នោះនឹងសាបសូន្យទៅបាន ប៉ុន្តែព្រះទ្រង់ជាទីពឹងនៃចិត្ត ហើយជាចំណែកមរដកនៃទូលបង្គំជាដរាបដែរ» (ទំនុកតម្កើង ៧៣:២៥-២៦)។ ហើយកណ្ឌគម្ពីរ (ហាបាគុក ៣:១៧-១៨) ក៏បានចែងផងដែរថា «ទោះបើដើមល្វាមិនមានផ្កា ក៏ឥតមានផ្លែទំពាំងបាយជូរ ហើយផលនៃដើមអូលីវក៏ខានមាន ស្រែចំការឥតបង្កើតបានអាហារ ហ្វូងចៀមត្រូវបាត់ចេញពីក្រោល ហើយគ្មានគោនៅក្នុងឃ្នងក៏ដោយ គង់តែខ្ញុំនឹងរីករាយ ដោយសារព្រះយេហូវ៉ា ខ្ញុំនឹងអរសប្បាយក្នុងព្រះដ៏ជួយសង្គ្រោះខ្ញុំដែរ»។ ចំពោះគ្រូៗដែលអធិប្បាយដំណឹងល្អដែលសន្យាភាពចម្រុងចម្រើន ពួកគាត់មិនស្គាល់ខគម្ពីរទាំងនេះទេ ដោយសារក្នុងខទាំងនេះបានដកចេញនូវចំណុចមួយចំនួន និងដោយសាររបៀបដែលយើងអាចទទួលបានអំណរដូចដែលមានចែងក្នុងគម្ពីរនេះ។



50 QnA John Piper Final 1.5.indd 131 25/01/2024 09:22:52 AM

*ទី៣* ចូរលើកឡើងអំពីចំណុចនៃរបៀបដែលគ្រួសាររបស់លោកអ្នកអាចបង្ហាញសេចក្ដីស្រឡាញ់ទៅកាន់ជនពិការអចិន្ត្រៃយ៍។ តើពួកគាត់រអៀសខ្លួនដោយសារជនពិការក្នុងសង្គមរបស់ពួកគាត់ដែរឬទេ? ឬក៏ថាជនពិការទាំងនោះគឺជាទីសម្គាល់នៃសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទដែលពួកគាត់មានតាមរយៈការដែលពួកគាត់យកចិត្តទុកដាក់ជាមួយនឹងជនពិការទាំងនោះឬ? ហើយវាគឺជាចំណុចសម្គាល់នៃជំនឿដ៏អស្ចារ្យមួយដែលអស់អ្នកនោះមានខណៈពេលដែលពួកគាត់មិនទាន់បានទទួលការព្យាបាល ប៉ុន្តែពួកគាត់នៅមានអំណរក្នុងក្ដីសង្ឃឹមនៃសិរីល្អរបស់ព្រះជាម្ចាស់ ជាជាងពិបាកចិត្ត និងខឹងព្រះអង្គ។ តើនោះមិនមែនជាជំនឿដ៏អស្ចារ្យទេឬអី?

*ទី៤* ចូរសួរគ្រួសារលោកអ្នកថា តើពួកគាត់យល់ឃើញយ៉ាងដូចម្ដេចទាក់ទងនឹងសេចក្ដីសន្យានៃការរងទុក្ខក្នុងព្រះគម្ពីរ? ប្រសិនបើពួកគាត់លើកឡើងថា «អឺ តាមពិតទៅ វាទាក់ទងតែនឹងការបៀតបៀនប៉ុណ្ណោះទេ។ ព្រះអង្គមិនបានសន្យាថា យើងនឹងរងទុក្ខដោយមានជំងឺនោះទេ» នោះលោកអ្នកអាចលើកឡើងនូវខគម្ពីរដែលរៀបរាប់អំពីការដែលរូបរាងកាយយើងនឹងរលួយសូន្យបាត់ទៅ។ ហើយសួរយោបល់ពួកគាត់អំពីខគម្ពីរទាំងនោះ។ តាមការយល់ដឹងរបស់យើងខ្ញុំ យើងខ្ញុំគិតថាការប្រកាសដំណឹងល្អដែលសន្យាភាពចម្រុងចម្រើនបានដកចេញទាំងស្រុងនូវការរងទុក្ខ មិនមែនគ្រាន់តែទាក់ទងនឹងការរងទុក្ខនៃការបៀតបៀនប៉ុណ្ណោះនោះទេ។

*ទី៥* ចូលចែកចាយអំពីដំណើររឿងនៃគ្រីស្ទបរិស័ទពីមុនៗនៅក្នុងប្រវត្តិសាស្ត្រ ដែលព្រះជាម្ចាស់បានប្រើប្រាស់យ៉ាងពេញទី ហើយពួកគាត់ក៏បានរងទុក្ខយ៉ាងឥតល្ហែផងដែរ។

*ទី៦* ទាក់ទងទៅនឹងរបៀបរៀបរយនៃការសន្ទនាបែបនេះ ចូលសូមឪពុកម្ដាយ បងប្រុស បងស្រី ឬក៏អ្នកណាដែលលោកអ្នកត្រូវជជែកគ្នាអំពីចំណុចនេះ ហើយសុំពួកគាត់ឲ្យមានការអនុញ្ញាតនិយាយអំពីចំណុចទាំងអស់នេះ



50 QnA John Piper Final 1.5.indd 132 25/01/2024 09:22:53 AM

ហើយរៀបចំពេលវេលាដែលពួកគាត់រំពឹងថានឹងអាចនិយាយគ្នា ជាជាងនិយាយយកតែម្ដងដោយមានការភ្ញាក់ផ្អើល ហើយលោកអ្នកត្រូវមានការការពារ។ យើងខ្ញុំសង្កេតឃើញថា ជារឿយៗ យើងព្យាយាមព្រោះគ្រាប់នៃគំនិតរបស់យើងនៅក្នុងពេលវេលាដែលមិនបានព្រាងទុកជាមុន ហើយវាក៏មិនមែនជាពេលវេលាដ៏ត្រឹមត្រូវផងដែរ។ ហេតុដូច្នេះហើយបានជាយើងចាំបាច់ត្រូវសុំការអនុញ្ញាតពីពួកគាត់ ដើម្បីរៀបចំពេលវេលាឲ្យបានត្រឹមត្រូវ។

*ទី៧* ចូលអធិស្ឋានទៅកាន់ព្រះជាម្ចាស់ដោយទូលសូមអង្វរឲ្យព្រះអង្គបើកភ្នែកពួកគាត់ឃើញអំពីអំណរដ៏ល្អក្នុងការរងទុក្ខឥឡូវនេះ ហើយនឹងឃើញអំពីអំណរដ៏ល្អក្នុងភាពចម្រុងចម្រើននៅពេលព្រះគ្រីស្ទយាងត្រឡប់មកវិញ។ “ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុងកាលដែលសិរីល្អទ្រង់លេចមក” (១ពេត្រុស ៤:១៣)។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 133 25/01/2024 09:22:53 AM

50 QnA John Piper Final 1.5.indd 134 25/01/2024 09:22:53 AM

## សំណួរទី២៣៖
# តើវាជាអំពើបាបឬទេ ដែលខ្ញុំមានស្នេហា ជាមួយនឹងអ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ?

*បុរសវ័យក្មេងម្នាក់បានសួរដូចតទៅ៖ «លោកគ្រូ តើវាជាអំពើបាបឬទេ ដែលខ្ញុំមានស្នេហាជាមួយនឹងអ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ?»*

មុនយើងខ្ញុំឆ្លើយថា ជាអំពើបាប ឬក៏មិនមែនជាអំពើបាប យើងខ្ញុំចង់សួរបុរសដែលកំពុងសួរទៅវិញថា «តើប្អូនគិតថាអ្វីទៅជាអំពើបាប?»

នៅក្នុងកណ្ឌគម្ពីរ រ៉ូម ៣:២៣ មានចែងថា «គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ»។ ដូច្នេះ អំពើបាបគឺជាការខ្វះមិនដល់សិរីល្អនៃព្រះ។ តើនេះមានន័យយ៉ាងដូចម្តេច? តើ «ការខ្វះមិនដល់សិរីល្អ» មានន័យយ៉ាងដូចម្តេច?

ក្នុងភាសាក្រិកពាក្យ «ខ្វះមិនដល់» មានន័យថា «ការពុំមាន» ឬក៏ «ការខ្វះខាត»។ ដូច្នេះ ការប្រព្រឹត្តអំពើបាបគឺជាការពុំមានសិរីល្អរបស់ព្រះជាម្ចាស់។ តើការខ្វះមិនដល់មានន័យយ៉ាងដូចម្តេច? ព្រះអង្គមិនបានបង្កើតយើងឲ្យមានលក្ខណៈល្អអស្ចារ្យដូចជាទ្រង់នោះទេ។ កណ្ឌគម្ពីរ រ៉ូម ១:២៣ ចែងថាមនុស្សមានបាប «បំផ្លាស់សិរីល្អនៃព្រះដែលមិនចេះខូច»។ នៅពេលដែលពួកគេបំផ្លាស់ នោះមានន័យថា ពួកគេខ្វះខាតហើយ។ នេះមានន័យថា នៅពេលដែលពួកគេសម្លឹងមើលសិរីល្អរបស់ព្រះជាម្ចាស់ ហើយពួកគេសម្លឹងមើលរូបផ្សេងៗ ទំនងមុខរបស់ខ្លួននៅក្នុងកញ្ចក់ ហើយពួកគេក៏មិនបានជ្រើសរើសយកព្រះជាម្ចាស់។ ដូច្នេះ ពួកគាត់ខ្វះព្រះ។

### សូមគិតអំពីចំណង់ចំណូលចិត្តរបស់ខ្លួន

យើងខ្ញុំបានពណ៌នាអំពីអំពើបាបថា ជាការ*ជ្រើសរើស*យកអ្វីមួយផ្សេង



50 QnA John Piper Final 1.5.indd 135 25/01/2024 09:22:53 AM

ទៀតក្រៅពីព្រះជាម្ចាស់។ អំពើបាបគឺជាអាកប្បកិរិយា សេចក្តីប្រាថ្នា ទង្វើ និងពាក្យពេចន៍ដែលចេញពីខ្លួនយើង នៅពេលដែលយើងជ្រើសរើសយកអ្វីមួយផ្សេងទៀតលើព្រះជាម្ចាស់។ ការនេះកើតឡើងនៅពេលដែលយើងមិនយកព្រះជាម្ចាស់ធ្វើជាសេចក្តីប្រាថ្នាដ៏ឧត្តុង្គឧត្តម និងជាទ្រព្យសម្បត្តិដ៏ស្កុកស្តម្ភរបស់យើង។ នេះគឺជាអត្ថន័យនៃពាក្យអំពើបាបដែលមានក្នុងព្រះគម្ពីរ។

ឥឡូវ ចូរយើងនិយាយអំពីការថៃចង់គ្នា។ តើអ្វីទៅជាការថៃចង់ ឬក៏ជាការមានស្នេហា? តើការមានស្នេហារបស់លោកអ្នកមានន័យថា បុគ្គលម្នាក់ទៀតបានក្លាយជាអ្នកដែលមានតម្លៃចំពោះលោកអ្នកខ្លាំងជាងព្រះជាម្ចាស់មែនឬ? មែនឬ? បើមែន នោះខ្ញុំមិនខ្វល់ថា បុគ្គលនោះជាគ្រីស្ទបរិស័ទ ឬក៏មិនមែនជាគ្រីស្ទបរិស័ទនោះទេ។

លោកអ្នកទំនងជាអាចមានស្នេហាជាមួយនឹងគ្រីស្ទបរិស័ទ ហើយនៅពេលនេះក៏កំពុងតែនៅបន្តប្រព្រឹត្តអំពើបាបដែរ។ លោកអ្នកទំនងជាអាចមានស្នេហាជាមួយនឹងបុគ្គលណាម្នាក់ដែលមិនមែនជាគ្រីស្ទបរិស័ទ ហើយនៅពេលនេះក៏កំពុងតែនៅបន្តប្រព្រឹត្តអំពើបាប ពីព្រោះសេចក្តីប្រាថ្នារបស់លោកអ្នក សេចក្តីស្រឡាញ់របស់លោកអ្នក ឬក៏តម្រូវការរបស់លោកអ្នកសម្រាប់បុគ្គលម្នាក់នោះឆ្លុះបញ្ចាំងថា ព្រះជាម្ចាស់មិនមានកន្លែងក្នុងជីវិតរបស់លោកអ្នកដែលធំ ពេញដោយអំណាច ព្រះចេស្តា ភាពស្កប់ស្កល់ និងភាពស្រស់ស្អាតក្នុងលក្ខណៈដែលព្រះអង្គគួរមានក្នុងជីវិតរបស់លោកអ្នក។

ប្រសិនបើលោកអ្នកមានតម្រូវការការសម្រាប់ដៃគូជីវិតខ្លាំងជាងតម្រូវការសម្រាប់ព្រះជាម្ចាស់ នោះមានន័យថាលោកអ្នកកំពុងតែប្រព្រឹត្តអំពើបាបហើយ។ វាមិនពាក់ព័ន្ធនឹងបុគ្គលដែលលោកអ្នកកំពុងតែថៃចង់នោះទេ។ លោកអ្នកត្រូវត្រឡប់ក្រោយ ហើយយកព្រះជាម្ចាស់ធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន។



50 QnA John Piper Final 1.5.indd 136 25/01/2024 09:22:53 AM

## សូមពិចារណាអំពីគោលដៅរបស់ខ្លួន

ចម្លើយនេះទំនងច្រើនជាងអ្វីដែលបុរសវ័យក្មេងម្នាក់នេះកំពុងតែសួរចង់បានទៅទៀតហើយមើលទៅ។ នេះគឺជាអ្វីដែលលោកអ្នកទំនងជាចង់ដឹង។ ឧបមាថា ខ្លួនមិនមានបញ្ហានោះ។ លោកអ្នកមិនមែនកំពុងតែចង់បានបុគ្គលណាម្នាក់ផ្សេងទៀតក្រៅពីចង់បានព្រះជាម្ចាស់នោះទេ។ ដូច្នេះ តើវានៅតែជាអំពើបាបដែរឬទេក្នុងការដែលលោកអ្នកមានស្នេហាជាមួយនឹងអ្នកមិនជឿ?

ចម្លើយរបស់ខ្ញុំលើសំណួរហ្នឹងវាគឺថា «តើអ្វីទៅជាការមានស្នេហា ឬក៏ការចែចង់គ្នា?» តើលោកអ្នកកំពុងតែប្រើប្រាស់ពាក្យស្នេហា ឬក៏ការចែចង់គ្នាក្នុងអត្ថន័យអ្វី? បុរសវ័យក្មេងនោះទំនងជាឆ្លើយថា «ខ្ញុំមិនមានចំណាប់អារម្មណ៍ក្នុងការបង្ហាញនូវសេចក្តីស្នេហានោះទេ។ ខ្ញុំគ្រាន់តែចង់ធ្វើជាស្មរបន្ទាល់នៃព្រះគុណរបស់ព្រះជាម្ចាស់ទៅកាន់នារីម្នាក់នេះ ដែលមិនមែនជាអ្នកជឿប៉ុណ្ណោះ ខណៈពេលដែលយើងទៅញ៉ាំភីហ្សា ដោយសង្ឃឹមថានឹងនាំឲ្យនាងទទួលជឿព្រះគ្រីស្ទដែរ»។ បើនិយាយម្យ៉ាងវិញទៀតទៅ នេះគឺគ្រាន់តែជាការផ្សាយដំណឹងល្អប៉ុណ្ណោះ មិនបានជាស្នេហានោះទេ។ បើដូច្នោះមែន នោះចម្លើយរបស់យើងខ្ញុំគឺថា «បាន! ទៅចុះ»។

ប៉ុន្តែ សូមប្រយ័ត្ន ពីព្រោះនៅពេលណាដែលបុរសម្នាក់ និងនារីម្នាក់ចំណាយពេលជាមួយនឹងគ្នា នោះអាចនឹងមានអ្វីលើសពីនោះផ្សេងទៀតដែលអាចកើតឡើងបាន ក្រៅពីការផ្សាយដំណឹងល្អ។ អាចមានរឿងអ្វីផ្សេងទៀតកើតឡើងបានដែលមានលក្ខណៈផ្ទាល់ខ្លួន និងស្និទ្ធស្នាលជាងនោះ ជាពិសេសនៅពេលដែលពួកគាត់កំពុងនិយាយគ្នាអំពីអ្វីដែលជ្រៅៗ។ យើងខ្ញុំធ្លាប់ឃើញរឿងនេះបានកើតឡើង ដូច្នេះយើងខ្ញុំចង់ហាមលោកអ្នកឲ្យមានការប្រុងប្រយ័ត្ន។

ប៉ុន្តែ ចុះប្រសិនបើបុរសវ័យក្មេងម្នាក់នោះឆ្លើយតបថា «តាមពិតទៅ ខ្ញុំមានចំណាប់អារម្មណ៍ជាមួយនឹងនារីម្នាក់នេះខ្លាំងណាស់។ ហើយចំពោះ



50 QnA John Piper Final 1.5.indd 137 25/01/2024 09:22:54 AM

ខ្ញុំ ការចែចង់គ្នាគឺជាផ្នែកមួយនៃការមានទំនាក់ទំនងនឹងនាំឲ្យមានស្នេហា ដែលអាចនឹងមានជីវិតអាពាហ៍ពិពាហ៍»។ បើដូច្នោះ នោះយើងខ្ញុំនឹងឆ្លើយ ដូចតទៅ៖ «ប្រសិនបើប្អូនកំពុងតែធ្វើបែបនោះ ហើយប្រសិនបើប្អូនកំពុង តែចែចង់អ្នកមិនជឿដោយមានទស្សនៈក្នុងការចាប់ផ្តើម ការលួតលាស់ និងការបង្កើតទំនាក់ទំនងស្នេហាឲ្យកាន់តែមានការស៊ីជម្រៅដែលអាចនាំ ឲ្យមានជីវិតអាពាហ៍ពិពាហ៍បាន នោះប្អូនក៏កំពុងតែធ្វើឲ្យសេចក្តីស្រឡាញ់ របស់ប្អូនសម្រាប់ព្រះគ្រីស្ទផលប៉ះពាល់អវិជ្ជមានដែរហើយ។ ប្អូនកំពុងតែ ប្រព្រឹត្តល្មើសនឹងអ្វីដែលព្រះគម្ពីរបានចែង ហើយក៏កំពុងតែធ្វើនូវអ្វីដែល ខុសឆ្គងទៀតផង»។

នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៧:៣៩ សាវ័ក ប៉ុល បានមានប្រសាសន៍ ថាឲ្យរៀបការតែជាមួយនឹងអ្នក «ក្នុងព្រះអម្ចាស់»។ ប្រសិនបើគោលបំណង របស់ប្អូនគឺលង់ស្នេហ៍ជាមួយ ឬក៏រៀបការជាមួយនឹងនារីដែលមិននៅក្នុងព្រះ អម្ចាស់ នោះមានន័យថា ការមិនស្តាប់បង្គាប់បទគម្ពីរគឺជាគោលដៅរបស់ ប្អូនហើយ។ ប្រសិនបើប្អូនមានគោលដៅមិនស្តាប់បង្គាប់តាមបទគម្ពីរនេះ នោះវាក៏ដូចជាថា ប្អូនក៏កំពុងតែមិនស្តាប់បទគម្ពីរនេះរួចស្រេចទៅហើយ។

ហើយនៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ៦:១៤ ក៏បានចែងថា «កុំឲ្យទឹមនឹម ស្រៀក ជាមួយនឹងមនុស្សមិនជឿឡើយ»។ ខគម្ពីរនេះក៏ទាក់ទងគ្នាជាមួយ នឹងជីវិតអាពាហ៍ពិពាហ៍ដែរ។ មូលហេតុគឺដោយសារជីវិតអាពាហ៍ពិពាហ៍គឺ ជាប្រភេទមួយនៃការរួបរួមគ្នាដ៏ជ្រាលជ្រៅ។ ព្រះអង្គសព្វព្រះហឫទ័យឲ្យវាជា ការរួបរួមគ្នាខាងឯព្រលឹងវិញ្ញាណក៏ដូចជាការរួបរួមគ្នាខាងឯរូបកាយដែរ។

មិនអាចមានការរួបរួមខាងឯព្រលឹងវិញ្ញាណដ៏ជ្រាលជ្រៅនោះទេ ប្រសិន បើបុគ្គលពីរនាក់មានទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភខុសៗគ្នា។ ចំពោះបុគ្គលម្នាក់ គឺព្រះគ្រីស្ទ ហើយចំពោះបុគ្គលម្នាក់ទៀតគឺអ្វីដែលពាក់ព័ន្ធជាមួយនឹង លោកីយ៍។ ចាប់តាំងពីដើមនៃទំនាក់ទំនងនេះគឺថា មានការបែកគ្នាយ៉ាង



50 QnA John Piper Final 1.5.indd 138 25/01/2024 09:22:54 AM

ជ្រាលជ្រៅបាត់រួចទៅហើយ។

ដូច្នេះ យើងខ្ញុំគិតថា មិនគួរឲ្យមានទំនាក់ទំនងស្នេហាដែលលើកទឹកចិត្តឲ្យទំនាក់ទំនងឈានដល់ការមានអាពាហ៍ពិពាហ៍ដែលមិនគួរមាននោះទេ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 139 25/01/2024 09:22:54 AM

# សំណួរទី២៩៖
# ប្រសិនបើលោកគ្រូមានពេលពីរនាទីនិយាយជាមួយនឹងសម្តេច ប៉ាប តើលោកគ្រូនឹងនិយាយអ្វីទៅកាន់គាត់?

តាមពិតទៅ យើងខ្ញុំមិនដែលសួរខ្លួនឯងអំពីសំណួរនេះពីមុនទេ។

យើងខ្ញុំនឹងទំនងជាសួរគាត់ថា «ក្នុងពេលវេលាមួយនាទី សូមពន្យល់អំពីទស្សនៈរបស់លោកទាក់ទងទៅនឹងការរាប់ជាសុចរិត»។ ហើយបន្ទាប់មក ដោយពឹងលើការពន្យល់របស់គាត់ នោះយើងខ្ញុំនឹងផ្តល់ជូននូវទស្សនៈនៃការរាប់ជាសុចរិតរបស់យើងខ្ញុំវិញ។

យើងខ្ញុំគិតថា ការរួបរួមគ្នារវាងក្រុមជំនុំរ៉ូម៉ាំងកាតូលិក និងប្រូតេស្តង់មិនទាន់អាចទៅមុខបាននៅឡើយទេ។ យើងខ្ញុំគិតថា សម័យកំណែទម្រង់មិនទាន់ឈានដល់ទីបញ្ចប់នៅឡើយ។ នៅមិនទាន់មានការផ្លាស់ប្រែគ្រប់គ្រាន់នៅក្នុងក្រុមជំនុំរ៉ូម៉ាំងកាតូលិកទាក់ទងនឹងទស្សនៈនៃការរាប់ជាសុចរិតនៅឡើយទេ ក៏ដូចជាប្រធានបទជាច្រើនផ្សេងៗទៀតផងដែរ។

យើងខ្ញុំកំពុងតែនិយាយអំពីការរាប់ជាសុចរិត ពីព្រោះនេះគឺជាប្រធានបទដ៏សំខាន់បំផុត។ តាមពិតទៅ យើងខ្ញុំអាចនិយាយអំពីអំណាចរបស់សម្តេច ប៉ាប អំពីអត្ថន័យនៃពិធីអភិបូជានៅក្នុងក្រុមជំនុំកាតូលិក ឬក៏អំពីតួនាទីនៃពិធីលាងព្រះអម្ចាស់ ឬក៏អំពីតំណែងរបស់នាងម៉ារា។

ប៉ុន្តែប្រធានបទទាំងនោះមិនសូវសំខាន់ជាងប្រធានបទដែលនៅកណ្តាលនោះទេ៖ «តើក្រុមជំនុំរ៉ូម៉ាំងកាតូលិកបង្រៀនថាយើងពឹងផ្អែកលើតែសេចក្តីសុចរិតរបស់ព្រះគ្រីស្ទដែលផ្ទេរមកយើងតាមរយៈជំនឿតែមួយគត់ដែរឬទេ? តើនេះជាមូលហេតុដែលថាព្រះជាម្ចាស់នៅខាងយើង ១០០% មែនឬ ហើយបន្ទាប់មកការញែកជាបរិសុទ្ធត្រូវតែកើតឡើង? តើសម្តេច ប៉ាប បង្រៀន



50 QnA John Piper Final 1.5.indd 141 25/01/2024 09:22:54 AM

ចំណុចនេះដែរឬទេ?»

ហើយប្រសិនបើសម្តេច ប៉ាប លើកឡើងថា «ទេ យើងមិនធ្វើដូច្នោះទេ» នោះយើងខ្ញុំនឹងឆ្លើយតបទៅគាត់វិញថា «អញ្ចឹង យើងខ្ញុំគិតថា នៅក្នុងចំណុចស្នូលនៃទេវវិទ្យារបស់ក្រុមជំនុំរ៉ូម៉ាំងកាតូលិកមានការបង្រៀនខុសឆ្គងហើយ»។

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 142 25/01/2024 09:22:55 AM

## សំណួរទី២៥៖
# តើទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះជាម្ចាស់ល្អដែរឬទេ?

*នេះគឺជាសារមួយដែលយើងបានទទួល៖ «ជម្រាបសួរលោកគ្រូ! នាងខ្ញុំឈ្មោះ ម៉ារា ហើយខ្ញុំនៅក្មេងទេ ប៉ុន្តែខ្ញុំដឹងថា ជំនឿរបស់ខ្ញុំក៏នៅតែសំខាន់ ទោះបីខ្ញុំនៅក្មេងក៏ដោយ។ ខ្ញុំដឹងថា ខ្ញុំមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ ហើយថាខ្ញុំអាចអធិស្ឋានទៅកាន់ព្រះអង្គ និងទុកចិត្តលើព្រះអង្គបាន ប៉ុន្តែពេលខ្លះខ្ញុំពិបាកក្នុងការស្វែងស្គាល់ទំនាក់ទំនងនេះណាស់។ អ្វីដែលខ្ញុំចង់សួរគឺថា តើមានរបៀបណាដែលខ្ញុំអាចដឹងថា ទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះជាម្ចាស់ល្អដែរឬទេ? ខ្ញុំមិនទាន់បានប្រឈមមុខជាមួយនឹងការលំបាក ដែលនាំឲ្យខ្ញុំមានមន្ទិលសង្ស័យលើជំនឿរបស់ខ្លួននៅឡើយទេ។ ខ្ញុំដឹងថា ខ្ញុំក៏នឹងត្រូវឆ្លងកាត់ពេលលំបាកនោះដែរ ប៉ុន្តែតើមានរបៀបណាដែលអាចជួយឲ្យខ្ញុំដឹងថាខ្ញុំកំពុងតែដើរនៅក្នុងកន្លងដ៏ត្រឹមត្រូវដែរឬទេ? សូមអរគុណ»។*

ក្មួយ ម៉ារា ក្មួយមានសំណួរល្អណាស់។ ហើយវាក៏មិនមានភាពខុសគ្នាសម្រាប់មនុស្សពេញវ័យដែរ។ សំណួររបស់ក្មួយ ក្នុងនាមជាក្មេងម្នាក់ ក៏ជាសំណួរដូចគ្នាដែលមនុស្សវ័យជំទង់ជាច្រើនបានធ្លាប់សួរ ដែលមានរួមទាំងលោកគ្រូផ្ទាល់ផងដែរ ច្រើនសួរម្តងហើយម្តងទៀត។ តើយើងអាចដឹងថាទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ល្អប៉ុណ្ណាបាន ដោយរបៀបណា?

មូលហេតុដែលនេះជាសំណួរដ៏ល្អមួយគឺដោយសារព្រះគម្ពីរផ្ទាល់ក៏បានសួរសំណួរនេះដែរ។ «ចូរអ្នករាល់គ្នាពិចារណាខ្លួនឯងមើល តើស្ថិត



50 QnA John Piper Final 1.5.indd 143 25/01/2024 09:22:55 AM

នៅក្នុងជំនឿឬទេ ចូរល្បងខ្លួនមើលចុះ តើអ្នករាល់គ្នាមិនយល់ឃើញថា ព្រះយេស៊ូវគ្រីស្ទគង់ក្នុងអ្នករាល់គ្នាទេឬអី លើកតែអ្នករាល់គ្នាត្រូវកាត់ចោលចេញប៉ុណ្ណោះ» (២កូរិនថូស ១៣:៥) ។ ដូច្នេះ ក្អួយបានសួរសំណួរនេះបានយ៉ាងត្រឹមត្រូវ៖ តើមានចំណុចដែលយើងពិចារណាខ្លួនឯងមើលដែរឬទេ? តើមានរបៀបណាដែលខ្ញុំអាចគិត ដែលអាចជួយឲ្យយើងដឹងថា យើងមានទំនាក់ទំនងល្អជាមួយនឹងព្រះជាម្ចាស់ដែរឬទេ? ខាងក្រោមនេះគឺជាអ្វីដែលលោកគ្រូចង់លើកឡើងសម្រាប់ក្អួយ៖

### ១. ព្រះគុណរបស់ព្រះអង្គសង្គ្រោះយើង

ក្អួយ ម៉ារា បានទទួលសេចក្តីសង្គ្រោះហើយ ក្អួយបានទទួលការអត់ទោសសម្រាប់រាល់អំពើអាក្រក់ដែលក្អួយបានប្រព្រឹត្ត ហើយនឹងប្រព្រឹត្ត ហើយព្រះជាម្ចាស់ក៏បានយកក្អួយធ្វើជាកូនរបស់ទ្រង់ហើយដែរ។ តាមរយៈជំនឿលើព្រះយេស៊ូវ ក្អួយបានទទួលជីវិតអស់កល្បជានិច្ច មិនមែនដោយសារក្អួយបានធ្វើអ្វីល្អ ឬក៏ជាក្មេងស្រីល្អនោះទេ។ នេះគឺជាចំណុចដ៏សំខាន់ណាស់។ ការធ្វើជាក្មេងល្អគឺប្រៀបដូចជាផ្លែឈើនៅលើដើមឈើមួយ ប៉ុន្តែជំនឿគឺជាដើមឈើលើព្រះគ្រីស្ទ។ ព្រះយេស៊ូវបានមានបន្ទូលថា៖ «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦)។ មានតែតាមរយៈការទុកចិត្តលើព្រះយេស៊ូវ ទទួលជឿលើព្រះអង្គ ទទួលយក និងឱបក្រសោបទ្រង់តែប៉ុណ្ណោះ ដែលអាចនាំឲ្យយើងមានទំនាក់ទំនងត្រឹមត្រូវជាមួយនឹងព្រះជាម្ចាស់បាន។ កណ្ឌគម្ពីរ អេភេសូរ ២:៨ បានចែងថា៖ «ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ»។



50 QnA John Piper Final 1.5.indd 144 25/01/2024 09:22:55 AM

ដូច្នេះ ក្មួយ ម៉ារា សូមកុំរាប់អំពើល្អរបស់ក្មួយ ដើម្បីឲ្យឃើញថា ក្មួយបានប្រព្រឹត្តល្អល្មម ហើយស័ក្តិសមឲ្យព្រះជាម្ចាស់ទទួលយកក្មួយនោះឡើយ។ នោះមិនមែនជារបៀបដែលព្រះអង្គទទួលយកក្មួយទេ។ នោះគឺជាអ្វីដែលអារក្សចង់ឲ្យក្មួយធ្វើ ក្នុងការគិតអំពីព្រះជាម្ចាស់ដោយរបៀបនោះ។ ព្រះយេស៊ូវបានសុគតសម្រាប់មនុស្សមានបាប។ ព្រះជាម្ចាស់បានរាប់មនុស្សទុច្ចរិតថាសុចរិត។ ដូច្នេះ ចូរកុំគិតថា ក្មួយអាចក្លាយជាមនុស្សល្អជាមុនសិនបានឡើយ។ ទេ! យើងទទួលបានសេចក្តីសង្គ្រោះរួចពីអំពើបាបតាមរយៈជំនឿ មិនមែនតាមរយៈការធ្វើល្អនោះទេ។ បន្ទាប់មក ព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យស្រឡាញ់នូវអ្វីដែលល្អ ហើយស្អប់អំពើបាប ដើម្បីឲ្យយើងអាចចាប់ផ្តើមផ្លាស់ប្តូរបាន។ នេះគឺជាចំណុចដំបូង ហើយក៏ជាចំណុចដ៏សំខាន់បំផុតដែលលោកគ្រូចង់បញ្ជាក់ប្រាប់។

## ២. ការតយុទ្ធជាមួយនឹងអំពើបាបរបស់យើង

បន្ទាប់ពីយើងបានទទួលសេចក្តីសង្គ្រោះហើយ នោះយើងក៏នៅបន្តប្រព្រឹត្តអំពើបាបដែរ។ សាវ័ក ប៉ុល បានលើកឡើងអំពីចំណុចនេះនៅក្នុងកណ្ឌគម្ពីររ៉ូមជំពូក៧។ ព្រះយេស៊ូវបានបង្រៀនឲ្យយើងទូលសូមការអត់ទោសជាប្រចាំថ្ងៃ (ម៉ាថាយ ៦:១២)។ សាវ័ក យ៉ូហាន បានមានប្រសាសន៍ថា យើងជាមនុស្សកុហក ប្រសិនបើយើងនិយាយថាយើងគ្មានអំពើបាប (១យ៉ូហាន ១:១០)។ ដូច្នេះ ព្រះអង្គបានសង្គ្រោះយើង ព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងយើង ហើយព្រះអង្គយកឈ្នះលើទម្លាប់ចាស់ៗរបស់យើងបន្តិចម្តងៗ ដើម្បីនាំឲ្យយើងមានការបន្ទាបខ្លួន។ ប្រសិនបើក្មួយសួរខ្ញុំថា “លោកគ្រូ ហេតុអ្វីបានព្រះជាម្ចាស់ចំណាយពេលយូរម្ល៉េះ ក្នុងការធ្វើឲ្យខ្ញុំក្លាយជាមនុស្សល្អ?”។ លោកគ្រូមានអាយុ៦៨ឆ្នាំហើយ ហើយលោកគ្រូក៏នៅបន្តសួរសំណួរដដែលនេះ។ ហេតុអ្វីបានព្រះជាម្ចាស់ចំណាយពេលយូរម្ល៉េះ ក្នុងការធ្វើឲ្យខ្ញុំ

ក្លាយជាមនុស្សល្អ? ចម្លើយរបស់លោកគ្រូគឺ៖ លោកគ្រូគិតថា ព្រះអង្គធ្វើដូច្នោះ ដើម្បីនាំឲ្យយើងបន្ទាបខ្លួន នាំឲ្យយើងមានការខ្មេចខ្ទាំ ហើយព្រះអង្គចង់ឲ្យយើងត្រូវការទ្រង់ខ្លាំង ហើយចង់ឲ្យយើងត្រូវការព្រះគុណ ដើម្បីកុំឲ្យយើងមានអំនួត។

តាមពិតទៅ នេះគឺជាចំណុចដ៏អស្ចារ្យពីកណ្ឌគម្ពីរ ១យ៉ូហាន ១:៦-៧។ ខគម្ពីរនេះបានលើកឡើងថា ប្រសិនបើយើងនិយាយថា យើងគ្មានអំពើបាប នោះយើងមិនដើរក្នុងពន្លឺទេ។ ប៉ុន្តែ ប្រសិនបើយើងកំពុងតែដើរក្នុងពន្លឺ នោះយើងនឹងលន់តួអំពើបាបរបស់ខ្លួនជាមិនខាន។ នេះពិតជាអស្ចារ្យណាស់ ដោយសារខគម្ពីរនោះលើកឡើងថា៖ «តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ»—ដែលនេះមានន័យថា យើងមានទំនាក់ទំនងល្អជាមួយនឹងព្រះជាម្ចាស់—រួមទាំងការលន់តួបាប ដែលនេះមិនអាចមានន័យថា ការដើរក្នុងពន្លឺមានន័យថា យើងគ្មានបាបទាល់តែសោះនោះទេ។ មិនអាចមានន័យដូច្នោះបានទេ។ ដូច្នេះ របៀបមួយដែលក្មួយអាចដឹងថា ក្មួយមានទំនាក់ទំនងល្អជាមួយនឹងព្រះជាម្ចាស់បាន គឺមិនមែនត្រង់ថា ក្មួយមិនប្រព្រឹត្តអំពើបាបឡើយ តែត្រង់ថាក្មួយទទួលស្គាល់អំពើបាបរបស់ខ្លួន ពីព្រោះពន្លឺកំពុងតែចែងចាំងនៅក្នុងដួងចិត្តរបស់ក្មួយ ហើយក្មួយលន់តួបាបនោះ ហើយសូមឲ្យព្រះជាម្ចាស់អត់ទោស ហើយក្មួយទូលសូមឲ្យព្រះយេស៊ូវគ្របបាំងអំពើបាបនោះដោយព្រះលោហិតរបស់ទ្រង់។ នេះគឺជាចំណុចទី២។ យើងដែលជាគ្រីស្ទបរិស័ទត្រូវតែរៀនទទួលស្គាល់សេចក្តីពិតថា យើងក៏នៅបន្តប្រព្រឹត្តអំពើបាបដែរ។

### ៣. ទំនុកចិត្តដែលយើងមាន

ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យក្មួយមានទំនុកចិត្តថា ក្មួយគឺជាកម្មសិទ្ធិរបស់ទ្រង់។ ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យក្មួយបារម្ភអំពីទំនាក់ទំនងរបស់ក្មួយជាមួយនឹងទ្រង់ទេ។ កណ្ឌគម្ពីរ ១យ៉ូហាន ៥:១៣ បានចែងថា៖ «ខ្ញុំ



50 QnA John Piper Final 1.5.indd 146 25/01/2024 09:22:56 AM

បានសរសេរសេចក្តីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ»។ ព្រះអង្គសព្វព្រះហឫទ័យឲ្យក្មួយមានការអរសប្បាយ ក្នុងការមានទំនុកចិត្ត មានអំណរ និងមានការធានា ហើយព្រះអង្គសព្វព្រះហឫទ័យឲ្យក្មួយប្រាកដថាក្មួយមិនអីទេជាមួយនឹងទ្រង់ និងថានៅពេលដែលក្មួយចូលគេងនៅពេលយប់ នោះក្មួយមិនចាំបាច់ខ្លាចអ្វីឡើយ។ ក្មួយអាចគេងយ៉ាងសុខស្រួល ទោះបីថាក្មួយស្លាប់នៅពាក់កណ្តាលអាធ្រាត្រក៏ដោយ ក៏ក្មួយនៅមានសុវត្ថិភាពដែរ។ ក្មួយនឹងមានសុវត្ថិភាពជាមួយនឹងព្រះយេស៊ូវ។

## ៤. របៀបដែលយើងអាចដឹងថា យើងទទួលបានសេចក្តីសង្គ្រោះ

លោកគ្រូគិតថា នេះគឺជាសំណួរដ៏ធំដែលក្មួយបានសួរ។ ព្រះគម្ពីរពិតជាបានជួយយើង ក្នុងរបៀបល្បងលខ្លួនឯង ដើម្បីឲ្យដឹងថាយើងមានទំនាក់ទំនងល្អឬក៏អត់។ នេះគឺគ្រាន់តែជារបៀបមួយចំនួនតែប៉ុណ្ណោះ៖ «មិនដែលមានអ្នកណានិយាយ ដោយនូវព្រះវិញ្ញាណនៃព្រះថា ព្រះយេស៊ូវត្រូវបណ្តាសានោះឡើយ ក៏គ្មានអ្នកណាអាចនឹងថា ព្រះយេស៊ូវទ្រង់ជាព្រះអម្ចាស់ដែរ លើកតែដោយនូវព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ» (១កូរិនថូស ១២:៣)។ ដូច្នេះ ប្រសិនបើដួងចិត្តរបស់ក្មួយថា «ព្រះយេស៊ូវ ទ្រង់គឺជាព្រះអម្ចាស់របស់ទូលបង្គំ។ ព្រះអង្គគឺជាចៅហ្វាយរបស់ទូលបង្គំ។ ព្រះអង្គគឺជាព្រះរបស់ទូលបង្គំ។ ទូលបង្គំចង់ស្គាល់ព្រះហឫទ័យរបស់ទ្រង់» នោះគឺជាព័ន្ធកិច្ចរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់ក្មួយ។

នេះជារបៀបមួយទៀត៖ «អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបម្រើឲ្យត្រូវភ័យខ្លាចទៀតឡើយ គឺបានទទួលនិស្ស័យជាកូនចិញ្ចឹមវិញ ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱអ័ប្បា ព្រះវរបិតាអើយ! ហើយព្រះ



50 QnA John Piper Final 1.5.indd 147 25/01/2024 09:22:56 AM

វិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ បើសិនណាជាកូនព្រះហើយ នោះយើងក៏បានគ្រងមរដកដែរ គឺជាអ្នកគ្រងមរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង ឲ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ ដើម្បីឲ្យបានតម្កើងឡើងជាមួយនឹងទ្រង់ដែរ» (រ៉ូម ៨:១៥-១៦)។ ដែលនេះមានន័យថា នៅពេលដែលក្មួយលើកឡើងចេញពីជម្រៅនៃដួងចិត្តថា «ឱព្រះជាម្ចាស់អើយ ទ្រង់គឺជាព្រះវរបិតារបស់ទូលបង្គំ។ ទូលបង្គំជាកូនរបស់ទ្រង់។ ទូលបង្គំត្រូវការឪពុក។ ទូលបង្គំជាក្មេងតូចម្នាក់ ដែលត្រូវការទ្រង់ក្នុងគ្រប់ចំណុចនៃជីវិត» នៅពេលដែលដួងចិត្តរបស់ក្មួយកំពុងតែលើកឡើងដូចនោះ នោះគឺជាទីបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងក្មួយហើយ។

នេះជារបៀបមួយទៀត៖ « យើងរាល់គ្នាដឹងថា យើងបានកន្លងផុតពីសេចក្តីស្លាប់ ទៅដល់ជីវិតហើយ ពីព្រោះយើងស្រឡាញ់ដល់ពួកបងប្អូន» (១យ៉ូហាន ៣:១៤)។ ការជះឥទ្ធិពលមួយនៃការដែលព្រះយេស៊ូវស្រឡាញ់យើងនៅពេលដែលព្រះអង្គសុគតជំនួសយើង ហើយបានប្រគល់រូបអង្គទ្រង់សម្រាប់យើងគឺថា យើងក៏ចេះចាប់ផ្តើមស្រឡាញ់មនុស្សម្នាដូចទ្រង់ដែរ ជាពិសេសបងប្អូនគ្រីស្ទបរិស័ទ។ ដូច្នេះ ប្រសិនបើក្មួយឃើញថាក្មួយចេះស្រឡាញ់គ្រីស្ទបរិស័ទផ្សេងៗ ហើយមានចិត្តសប្បាយនៅពេលឃើញអ្នកដទៃទទួលបានសេចក្តីសង្គ្រោះ ចង់ស្គាល់ពួកគាត់ និងនៅក្បែរពួកគាត់ នោះគឺជាសេចក្តីសម្គាល់មួយដែលថា ក្មួយក៏បានចូលក្នុងគ្រួសាររបស់ព្រះជាម្ចាស់ហើយដែរ។

នេះជារបៀបមួយទៀត៖ «អស់អ្នកណាដែលកើតពីព្រះ នោះមិនដែលប្រព្រឹត្តអំពើបាបទេ ពីព្រោះពូជព្រះនៅក្នុងអ្នកនោះឯង បានជាពុំអាចនឹងធ្វើបាបបានឡើយ ដ្បិតបានកើតពីព្រះមក» (១យ៉ូហាន ៣:៩)។ យើងបានអានរួចហើយនៅក្នុងកណ្ឌគម្ពីរ ១យ៉ូហាន ១:១០ ត្រង់ថាយើងគឺជាមនុស្សកុហក ប្រសិនបើយើងនិយាយថា យើងគ្មានអំពើបាប។ ប៉ុន្តែ ខគម្ពីរមួយនេះ



50 QnA John Piper Final 1.5.indd 148 25/01/2024 09:22:56 AM

មិនមែនមានន័យថា ក្មួយនឹងលែងប្រព្រឹត្តអំពើបាបទេ។ អ្វីដែលខគម្ពីរនេះមានន័យគឺថា លែងមានលំនាំនៃអាកប្បកិរិយា ដែលក្មួយនៅលើកឡើងថា «ខ្ញុំស្រឡាញ់អំពើបាបខ្ញុំណាស់។ ខ្ញុំនឹងបន្តប្រព្រឹត្តអំពើបាប។ ខ្ញុំមិនខ្វល់អំពីអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលទេ។ ខ្ញុំនឹងបន្តប្រព្រឹត្តអំពើបាបនេះ។ ហើយខ្ញុំក៏មិនខ្វល់ថា វាមានឥទ្ធិពលអ្វីលើខ្ញុំដែរ»។ ប្រសិនបើក្មួយបន្តរស់នៅក្នុងអំពើបាប ប្រសិនបើក្មួយយកអំពើបាបធ្វើជាមិត្តភក្តិ ហើយប្រសិនបើក្មួយនៅបន្តប្រព្រឹត្តអំពើបាបដូចនោះ នោះក្មួយនឹងមិនអាចមានទំនាក់ទំនងព្រះជាម្ចាស់បានទេ ហើយក្មួយក៏មិនអាចដឹងយ៉ាងប្រាកដថាក្មួយពិតជាបានទទួលសេចក្តីសង្គ្រោះហើយដែរ។

## ៥. សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់

នេះជារបៀបពិចារណាខ្លួនឯងមើលចុងក្រោយមួយទៀត៖ «ហើយអ្នកណាដែលស្គាល់ព្រះនោះក៏ស្តាប់យើងខ្ញុំ» (១យ៉ូហាន ៤:៦)។ ពាក្យ «យើងខ្ញុំ» សំដៅទៅលើអ្នកនិពន្ធព្រះគម្ពីរ គឺពួកសាវ័ក។ ព្រះយេស៊ូវបានមានបន្ទូលថា «ចៀមខ្ញុំទាំងប៉ុន្មានវាស្តាប់ខ្ញុំ» (យ៉ូហាន ១០:២៧)។ ដូច្នេះសញ្ញាសម្គាល់មួយដែលបង្ហាញថា ក្មួយមានទំនាក់ទំនងល្អជាមួយនឹងព្រះជាម្ចាស់គឺថា ក្មួយស្រឡាញ់ព្រះគម្ពីររបស់ក្មួយ។ ក្មួយចូលចិត្តរៀនអំពីព្រះជាម្ចាស់។ ក្មួយចង់ដឹងបន្ថែមទៀតអំពីព្រះជាម្ចាស់។

## វិធីនៃការដែលកាន់តែល្អលាស់

ដូច្នេះ ទាំងនោះគឺជាការពិចារណាខ្លួនឯងមើលប្រាំយ៉ាង ដែលបង្ហាញអំពីរបៀបដែលក្មួយអាចមានភាពប្រាកដប្រជាថា ក្មួយមានទំនាក់ទំនងល្អជាមួយនឹងព្រះជាម្ចាស់។ ប៉ុន្តែ លោកគ្រូនៅមានយោបល់ដ៏ល្អមួយទៀត។ សូមកុំចំណាយពេលច្រើនពេកក្នុងការពិចារណាមើលខ្លួនឯង។ សូមកុំធ្វើដូច្នោះឡើយ។ ការធ្វើបែបនោះនឹងបង្កឲ្យមានបញ្ហាពីព្រោះតែក្មួយដឹងថា នៅ

មានអ្វីកើតឡើងដែរឬទេ? គឺថា ក្មួយនឹងចំណាយពេលច្រើនពេកគិតអំពីខ្លួនឯង។ ផ្ទុយទៅវិញ គ្រាន់តែប្រើប្រាស់ការពិនិត្យពិចារណាមើលខ្លួនឯងម្ដងម្កាល ហើយចំណាយពេលច្រើនទៀតក្នុងការគិតអំពីព្រះយេស៊ូវ និងគិតអំពីព្រះបន្ទូលរបស់ទ្រង់ ហើយរកគ្រប់អ្វីៗដែលទ្រង់បានសម្រេច ព្រមទាំងរាល់សេចក្ដីសន្យារបស់ទ្រង់វិញ។ បើនិយាយម្យ៉ាងវិញទៀត ចំណែកដ៏ល្អបំផុតក្នុងការមានការធានា និងមានទំនុកចិត្ត ត្រង់ថាក្មួយមានទំនាក់ទំនងល្អ គឺឲ្យភ្លេចអំពីខ្លួនឯង។ នេះគឺជាចំណុចដ៏ល្អណាស់នៅពេលដែលក្មួយអាចស្គាល់ព្រះយេស៊ូវបានយ៉ាងច្បាស់ ហើយចំណាយពេលជាច្រើនទៀតក្នុងការស្គាល់ទ្រង់ ហើយរីករាយជាមួយនឹងអ្វីដែលព្រះអង្គបានបង្ហាញដល់ក្មួយអំពីទ្រង់ចេញពីព្រះគម្ពីរ ដែលក្មួយផ្ទាល់មិនបានគិតអំពីចំណុចទាំងនោះ។

ហើយនេះគឺជាចំណុចមួយចំនួនទៀត។ ព្រះអង្គរក្សាយើងចេញពីការមិនមានជំនឿ។ ព្រះជាម្ចាស់កាន់យើងនៅក្នុងព្រះហស្ដរបស់ទ្រង់។ «ចៀមខ្ញុំទាំងប៉ុន្មានវាស្ដាប់ខ្ញុំ ហើយមកតាម ខ្ញុំក៏ស្គាល់វាដែរ ខ្ញុំឲ្យជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកណាឆក់យកវាពីដៃខ្ញុំបានទេ» (យ៉ូហាន ១០:២៧-២៨)។ ដូច្នេះ ចូរមានទំនុកចិត្ត។ ព្រះជាម្ចាស់នឹងរក្សាក្មួយ។ ព្រះជាម្ចាស់នឹងធ្វើឲ្យទំនាក់ទំនងរបស់ក្មួយល្អប្រសើរ។

ហើយចំណុចចុងក្រោយ ដែលលោកគ្រូនឹងលើកឡើងគឺថា៖ សម្រាប់ថ្ងៃនេះ កុំបារម្ភថាក្មួយនឹងមានទំនាក់ទំនងល្អនៅថ្ងៃស្អែកឡើយ។ ថ្ងៃនីមួយៗមានការពិចារណាមើលខ្លួនឯងរៀងៗខ្លួន ហើយថ្ងៃនីមួយៗក៏មានសេចក្ដីមេត្តាករុណារបស់វាផ្ទាល់ទាក់ទងទៅនឹងការពិចារណាមើលខ្លួនឯងនោះដែរ។ នេះគឺជាអ្វីដែលកណ្ឌគម្ពីរ បរិទេវៈ ៣:២២ បានលើកឡើង៖ «កុំតែមានសេចក្ដីសប្បុរសរបស់ព្រះយេហូវ៉ា នោះយើងបានសូន្យបាត់អស់រលីងទៅហើយ ឯសេចក្ដីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ»។ សម្រាប់



50 QnA John Piper Final 1.5.indd 150 25/01/2024 09:22:57 AM

ថ្ងៃស្អែក ព្រះជាម្ចាស់នឹងប្រទានអ្វីដែលក្មួយត្រូវការ។ លោកគ្រូក៏ចង់អរគុណដល់ក្មួយដែលបានលើកសួរសំណួរនេះដែរ។ លោកគ្រូអធិស្ឋានទូលសូមឲ្យព្រះជាម្ចាស់ធ្វើឲ្យក្មួយស្រីក្លាយជាមនុស្សពូកែ និងជាស្ត្រីដ៏ស្មោះត្រង់ម្នាក់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 151 25/01/2024 09:22:57 AM

50 QnA John Piper Final 1.5.indd 152 25/01/2024 09:22:57 AM

## សំណួរទី២៦៖
# មិត្តស្រីរបស់ខ្ញុំមានផ្ទៃពោះ តើខ្ញុំគួរធ្វើអ្វីបន្ទាប់?

*ប្អូន សុធា បានសួរដូចតទៅ “សួស្តីលោកគ្រូ! ខ្ញុំបានក្លាយជាគ្រីស្ទបរិស័ទ ប្រហែលជាពីរឆ្នាំមុន ហើយទោះបើខ្ញុំបានធំឡើងក្នុង “គ្រួសារគ្រីស្ទបរិស័ទ” ក៏ដោយ ក៏ឥឡូវនេះខ្ញុំមានរឿងពិបាកមួយដែលខ្ញុំត្រូវទទួលស្គាល់ ខ្ញុំបានជ្រុលជ្រោះជាមួយមិត្តស្រីខ្ញុំ ដែលខ្ញុំបានជួបនៅព្រះវិហារពីរបីខែមុន។ យើងមានការហួសចិត្តយ៉ាងខ្លាំងចំពោះអំពើបាបដែលយើងបានធ្វើជាមួយគ្នា ទោះបើយើងនិយាយថាយើងនឹងមិនធ្វើការនោះក៏ដោយ។ ឥឡូវនេះ មិត្តស្រីរបស់ខ្ញុំមានផ្ទៃពោះហើយ។ ខ្ញុំបានសិក្សាអំពីការរម្លូតកូន។ ខ្ញុំជាមនុស្សពុតត្បុតមែនដែលអនុញ្ញាតឲ្យគំនិតបែបនេះចូលមកក្នុងខ្ញុំ ទោះបើជាជម្រើសនេះខ្ញុំបាននិយាយថា ខ្ញុំមិនចង់ធ្វើវាជាច្រើនឆ្នាំក៏ដោយ។ ប៉ុន្តែ ខ្ញុំខ្លាចណាស់។ ដោយសន្មតថា រឿងនេះវាជាការពិតមែន តើយើងគួរធ្វើអ្វី? តើលោកគ្រូបានផ្តល់ដំបូន្មានអ្វីខ្លះដល់ដៃគូៗដែលបែកបាក់ និងភ័យខ្លាចនៅក្នុងស្ថានភាពរបស់យើង?*

### ចូរស្វែងរកជំនួយ

សុធា! ខ្ញុំមិនដឹងអាយុរបស់ប្អូនទេ។ ខ្ញុំមិនដឹងពីភាពពេញវ័យរបស់ប្អូន ឬស្ថានភាពខាងវិញ្ញាណរបស់ប្អូន ឬឪពុកម្តាយប្អូន ឬក្រុមជំនុំរបស់ប្អូនដែរ។ ដំបូន្មានរបស់ខ្ញុំ ទាក់ទងនឹងកាលៈទេសៈនេះ គឺនឹងត្រូវជាបែបទូទៅ តាមដែលខ្ញុំអាចធ្វើបាន ដោយសារខ្ញុំមិនដឹងពីស្ថានភាពរបស់ប្អូនយ៉ាងលម្អិត។

យើងនឹងនិយាយឲ្យចំចំណុចតែម្តង “សូមកុំពឹងផ្អែកលើតែដំបូន្មានរបស់ខ្ញុំ។ សូមទៅរកគ្រូគង្វាលរបស់ប្អូនដែរ”។ ចំពោះខ្ញុំ មើលទៅប្អូនហាក់ដូចជាខូចចិត្តពិតមែន ហើយដោយសារទំហំនៃអំពើបាប និងការឈឺចាប់



50 QnA John Piper Final 1.5.indd 153 25/01/2024 09:22:57 AM

ដែលប្អូនបានធ្វើគឺធំ ហើយក៏អាចកាន់តែអាក្រក់ទៅៗបាន នោះខ្ញុំចង់ចាប់ផ្ដើមដោយលើកទឹកចិត្តខ្លះៗសិន។

**ការលើកទឹកចិត្តពីរយ៉ាង**

ទីមួយ ក្នុងនាមជាបុរសនៅក្នុងទំនាក់ទំនងមួយនេះ ការដែលប្អូនបានសរសេរមកកាន់ខ្ញុំ ហើយប្អូនមិនបានដាក់ទំនួលខុសត្រូវនោះទៅលើមិត្តស្រីរបស់ប្អូនទេ វាគឺជាសញ្ញាសម្គាល់ល្អ។ ប្អូនបានមានទំនួលខុសត្រូវ ហើយក៏ជាអ្នកផ្ដួចផ្ដើម នេះក៏ជាការល្អដែរ។ ខ្ញុំនឹងត្រឡប់មករឿងនោះវិញបន្តិចទៀតនេះ ពីព្រោះភាពជាបុរសរបស់ប្អូន និងអ្វីដែលប្អូនធ្វើជាមួយវា គឺជាចំណុចដ៏ធំមួយនៅពេលនេះ។

ទីពីរ កុំមានគំនិតថា ប្អូនបានធ្វើបាបដល់ថ្នាក់បែកចេញពីព្រះគ្រីស្ទ ឬពីស្ថានសួគ៌ឲ្យសោះ។ គំនិតទាំងនោះគឺជាគំនិតរបស់អារក្ស និងការចោទប្រកាន់របស់វា។ ប្រសិនបើប្អូនសារភាពអំពើបាបរបស់ប្អូន ហើយបន្ទាបខ្លួននៅចំពោះព្រះនេត្ររបស់ព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ និងជាទ្រព្យសម្បត្តិរបស់ប្អូន នោះប្អូននឹងទទួលបានការអត់ទោស។ ប្អូននឹងទទួលបានកម្លាំង ដើម្បីឲ្យធ្វើនូវអ្វីដែលត្រឹមត្រូវក្នុងស្ថានភាពនេះ។

ជីវិតរបស់ប្អូនទំនងនឹងមានបញ្ហាយ៉ាងខ្លាំងក្នុងរយៈពេលខ្លី (ឬក៏រយៈពេលវែង) ដោយសារតែអំពើបាបនេះ។ ប៉ុន្តែ ព្រះជាម្ចាស់នឹងបង្វែរបញ្ហាទាំងអស់នោះសម្រាប់ការរាប់ជាបរិសុទ្ធរបស់ប្អូន បើប្អូនជឿទុកចិត្តលើទ្រង់ បែរចេញពីអំពើបាប ហើយដាក់ជីវិតខ្លួនទាំងស្រុងលើព្រះយេស៊ូវ។

**ចូរផ្ដួចផ្ដើមគំនិតដោយក្លាហាន**

នេះគឺជាអ្វីដែលខ្ញុំចង់ណែនាំ។ ពិតណាស់! ខ្ញុំបាននិយាយជាមួយអ្នកដទៃដែលមានស្ថានភាពដូចប្អូន ហើយបានប្រាប់ពួកគេដូចនេះដែរ។

ជាដំបូង ប្អូនសុធាគឺជាបុរស។ នោះមានន័យថា ប្អូនមានទំនួលខុសត្រូវ



50 QnA John Piper Final 1.5.indd 154 25/01/2024 09:22:58 AM

យ៉ាងចាំបាច់ និងការទទួលខុសត្រូវយ៉ាងចម្បងក្នុងនាមជាអ្នកដឹកនាំនៅក្នុងទំនាក់ទំនងនេះ។ នោះមានន័យថា អំពើបាបផ្លូវភេទរបស់ប្អូនបានកើតឡើងដោយសារប្អូនបានបរាជ័យក្នុងនាមជាអ្នកដឹកនាំ។

ខ្ញុំមិនបដិសេធទេត្រង់ថា មិត្តស្រីរបស់ប្អូនក៏មានទំនួលខុសត្រូវ និងការចូលដៃក្នុងអំពើបាបនេះដែរ។ នាងគួរតែប្រាប់ប្អូនថា «ទេ! ហើយបណ្ដេញប្អូនចេញ។» ប៉ុន្តែ ខ្ញុំកំពុងតែនិយាយត្រង់ថា ក្នុងនាមជាបុរស—ប្អូន—មានទំនួលខុសត្រូវខ្ពស់ជាងនាង ហើយព្រះជាម្ចាស់បានដាក់តួនាទីឲ្យប្អូនការពារ ថែរក្សា និងដឹកនាំនាង។ ទោះបើនាងបាននាំអាតប្អូនឲ្យធ្លាក់ក្នុងអំពើបាបនេះក៏ដោយ ក៏វាមិនមែនសារៈសំខាន់ដែរ នៅពេលដែលយើងនិយាយអំពីទំនួលខុសត្រូវ និងការទទួលខុសត្រូវដ៏ខុសពីនាងដែលព្រះជាម្ចាស់បានផ្ដល់ឲ្យប្អូនក្នុងនាមជាបុរសក្នុងទំនាក់ទំនងនេះ។

ឥឡូវនេះ ដោយសារប្អូនបានប្រើប្រាស់ការត្រាស់ហៅនេះក្នុងរបៀបដ៏ខុសក្នុងនាមជាបុរស នោះប្អូនបានបរាជ័យក្នុងទំនួលខុសត្រូវដ៏ពិសេសនេះហើយ។ ប៉ុន្តែ ប្អូននៅមានឱកាសក្នុងស្ថានភាពដ៏អាក្រក់នេះ ដើម្បីស្ដារតួនាទីនេះ យ៉ាងហោចណាស់ក្នុងនាមជាអ្នកដឹកនាំប្រកបដោយភាពក្លាហាន មានគំនិតផ្ដួចផ្ដើម និងមានការបន្ទាបខ្លួនក្នុងការធ្វើនូវអ្វីដែលត្រឹមត្រូវ ដែលវាក៏ពិតជាការដ៏ពិបាកណាស់ដែរ។

ជឿខ្ញុំចុះ ការល្បួងនឹងនាំប្អូនឲ្យធ្វើផ្ទុយពីនេះ។ ប្អូននឹងចង់ស្ដីបន្ទោសអ្នកផ្សេង មានការអាណិតខ្លួនឯង ភ័យខ្លាច មានការភិតភ័យ និងចង់ដកខ្លួនចេញ។ នោះហើយជាអ្វីដែលបុរសមួយចំនួនបានធ្វើ។ ពួកគេបោះបង់ភាពជាបុរសរបស់ខ្លួនចោល ហើយពួកគេក៏បោះបង់មាគ៌ារបស់ព្រះយេស៊ូវចោលដែរ នៅពេលពួកគេធ្វើដូច្នោះ។

ទាំងនេះគឺជាការបរាជ័យនៃភាពជាបុរសសម្រាប់គ្រីស្ទបរិស័ទមួយចំនួន។ កុំធ្វើបែបនោះ។ ចូរផ្ដួចផ្ដើមគំនិតដោយធ្វើនូវអ្វីដែលត្រឹមត្រូវវិញ។

## សង្គ្រោះទារកនោះ

ជាដំបូង នោះមានន័យថា ប្អូនគឺជាអ្នកដែលនឹងនិយាយដូចតទៅ «យើងនឹងមិនសម្លាប់ទារកនេះទេ។ យើងបាននាំទារកនេះចូលក្នុងពិភពលោកដោយខុសច្បាប់ ហើយយើងនឹងមិនបន្ថែមភាពមិនស្របច្បាប់នៃការបង្កើតរបស់យើងនូវភាពខុសច្បាប់នៃការបំផ្លាញទារកនេះឡើយ។ ទេ! យើងនឹងមិនធ្វើបែបនោះទេ។»

ចូរនាំមុខ ហើយក្លាហានឡើងសម្រាប់បុព្វហេតុដ៏យុត្តិធម៌ ដែលមានក្តីមេត្តាករុណា និងសម្រាប់ជីវិត។

## ចូរសារភាពអំពីអំពើបាបរបស់ប្អូន

ជាបន្ទាប់ ភាពជាអ្នកដឹកនាំត្រង់ចំណុចនេះមានន័យថា ប្អូនត្រូវដឹកនាំក្នុងការកែប្រែចិត្ត—ចូរកំណត់ដោយមិនរាប់ថាអំពើបាបនេះតូចតាច និងធ្វើជាអ្នកដឹកនាំដោយទៅរកឪពុកម្តាយទាំងសងខាង។

ចូរទៅរកឪពុកម្តាយទាំងសងខាង ហើយសារភាពអំពីអំពើបាបរបស់ខ្លួន។ បន្ទាប់មក ចូរទៅរកគ្រូគង្វាលរបស់ប្អូន ហើយសារភាពអំពីអំពើបាបរបស់ប្អូន ពីព្រោះភាពជាសមាជិកក្នុងក្រុមជំនុំតាមតំបន់បង្កប់នូវរបៀបនៃការរស់នៅដែលជាគំរូល្អ ហើយអ្វីដែលប្អូនៗបានធ្វើមិនមែនជាគំរូល្អទេ។

ការសារភាពទៅកាន់ឪពុកម្តាយរបស់នាងគឺប្រហែលជារឿងដ៏ពិបាកជាងគេបំផុត។ ក្នុងស្ថានភាពខ្លះ វាអាចទាមទារឲ្យប្អូនបង់ថ្លៃជីវិតរបស់ប្អូន។ ខ្ញុំមិននិយាយលេងទេ។ នៅក្នុងវប្បធម៌ខ្លះ ប្អូនត្រូវបង់ថ្លៃជីវិតរបស់ប្អូនក្នុងការសារភាពបែបនេះ។ តែវាជាអ្វីដែលត្រឹមត្រូវក្នុងការធ្វើ។

នេះជាចំណុចដែលប្អូនត្រូវតែក្លាហាន។ ប្អូនត្រូវទូរស័ព្ទទៅកាន់ឪពុករបស់នាង ហើយប្រាប់គាត់ថាប្អូនត្រូវការនិយាយជាមួយនឹងគាត់ មុខទល់មុខ ហើយប្អូនត្រូវធ្វើការនេះឲ្យឆាប់ៗចុះ។



50 QnA John Piper Final 1.5.indd 156 25/01/2024 09:22:58 AM

ពេលប្អូនជួបជាមួយគាត់ ប្អូនត្រូវមើលមុខគាត់ ហើយសារភាពថា “ខ្ញុំបានបរាជ័យក្នុងការមិនការពារកូនស្រីរបស់លោក។” ខ្ញុំមិនខ្វល់ទេបើនាងបានផ្តួចផ្តើមគំនិតនេះ ឬក៏ថាបានបង្ខំឲ្យប្អូនទៅនិយាយជាមួយឪពុកនាង។ ប្អូនត្រូវប្រាប់គាត់ថា ប្អូនបានបរាជ័យក្នុងការការពារកូនស្រីរបស់គាត់ ហើយប្អូនផ្តល់ដំណឹងដល់គាត់អំពីស្ថានភាព ហើយប្អូនក៏ត្រូវទទួលខុសត្រូវដែរ។ ប្អូនមិនយកនាងធ្វើជាពិរុទ្ធជនទេ។ ហើយប្អូនក៏ត្រូវធ្វើការនេះជាមួយនឹងឪពុកម្តាយរបស់ប្អូនដែរ។ ប្អូនជាម្ចាស់នៃអំពើបាបនេះ។ ប្អូនត្រូវធ្វើនូវអ្វីដែលត្រឹមត្រូវ។ នេះគឺជាបេសកកម្មរបស់ប្អូន។

## ចូរក្លាយជាអ្នកស្តាប់

បន្ទាប់មក ប្អូនត្រូវក្លាយជាអ្នកស្តាប់ ព្រោះនឹងមានគេមកនិយាយដាក់ប្អូនជាច្រើន។ ខ្ញុំទាយថា ប្អូននឹងឮពីឪពុកម្តាយទាំងសងខាង។ ឬក៏ប្រហែលជាមិនមាន។ ខ្ញុំមិនដឹងទេ ហើយខ្ញុំក៏មិនស្គាល់ពួកគេដែរ។ ខ្ញុំមិនទាំងដឹងថា ពួកគេជាអ្នកជឿ ឬក៏មិនជឿផង។

ប្អូនត្រូវក្លាយជាអ្នកស្តាប់ម្នាក់ មិនមែនគ្រាន់តែចំពោះខ្ញុំដែលជាអ្នកប្រឹក្សាយោបល់ពីចម្ងាយ ដែលដឹងតិចតួចណាស់អំពីស្ថានភាព ឬអំពីប្អូន ឬមិត្តស្រីរបស់ប្អូន ប៉ុន្តែប្អូនត្រូវស្តាប់ឪពុកម្តាយនាង និងឪពុកម្តាយប្អូន ព្រមទាំងស្តាប់គ្រូប្អូនដែរ។

ប្រសិនបើឪពុកម្តាយនាងមិនមែនជាអ្នកជឿ ហើយចង់ឲ្យប្អូនរម្លូតកូន ប្អូនត្រូវប្រាប់ពួកគេដោយសុភាពរាបសា និងឲ្យអស់ពីកម្លាំងប្អូនថា ប្អូនមិនគាំទ្រការនោះទេ។ ប្អូនប្រាប់ពួកគេថា ប្អូនមិនយល់ស្របនឹងរឿងនោះទេ ហើយតាមលទ្ធភាពដែលប្អូនអាចនិយាយបាន គឺប្អូននឹងមិនធ្វើបែបនោះឡើយ។

ប្អូនពន្យល់ទៅកាន់ពួកគាត់ដោយដកស្រង់ចេញពីព្រះគម្ពីរតាមដែលប្អូនអាចធ្វើបាន។ ដោយសង្ឃឹមថា បន្ទាប់ពីពេលការតក់ស្លុត និងកំហឹងដំបូង

បានធូរស្បើយខ្លះៗ នោះគ្រប់គ្នានឹងអាចមូលគំនិតជាមួយគ្នា ហើយគិតអំពីអនាគតដ៏ល្អជាងនោះដែលប្រកបដោយយុត្តិធម៌ ក្តីមេត្តា និងសង្ឃឹម។

**ចែករំលែកបន្ទុក**

រឿងមួយទៀត ក្នុងនាមជាអ្នកដឹកនាំដែលប្អូនត្រូវគិតគឺការទទួលស្គាល់ថា មិត្តស្រីប្អូននឹងមានបន្ទុកដ៏ធ្ងន់ដែលនាងត្រូវប្រឈមមុខភ្លាមៗនោះ ទាក់ទងនឹងអំពើបាបនេះ។ ឥឡូវនេះ នាងត្រូវពរពោះទារកនេះ ផ្តល់កំណើត និងទ្រទ្រង់ទារកក្នុងផ្ទៃនៅក្នុងខែដំបូង។ នេះនឹងក្លាយជាការផ្លាស់ប្តូរដ៏ធំមួយនៅក្នុងជីវិតនាង។

នេះហើយជាមូលហេតុដែលមនុស្សជាច្រើនរម្លូតកូន ដោយសារតែម្តាយ និងឪពុកបានដាក់ផែនការផ្ទាល់ខ្លួនមុនជីវិតរបស់កូន។ ក្នុងនាមជាគ្រីស្ទបរិស័ទដែលមានភាពចាស់ទុំ និងជាបុរសម្នាក់ នោះប្អូនត្រូវដឹងអំពីបន្ទុកដ៏ធ្ងន់របស់មិត្តស្រីប្អូន ហើយតាមសមត្ថភាពដែលប្អូនអាចធ្វើបាន ប្អូនត្រូវធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីធ្វើឲ្យបន្ទុករបស់នាងស្រាល។ ហើយការសម្លាប់កុមារមិនធ្វើឲ្យបន្ទុករបស់នាងស្រាលទេ។ វាមិនជួយសម្រាលទេ។

ប្អូនត្រូវជួយនាងក្នុងរឿងនេះ ព្រោះប្អូនជាអ្នកដែលទទួលខុសត្រូវច្រើនជាងគេក្នុងរឿងនេះ ក្នុងនាមជាបុរសដែលមិនមានទំនួលខុសត្រូវលើការទទួលខុសត្រូវរបស់ខ្លួន។

**កុំប្រញាប់រៀបការ**

ទាក់ទងទៅនឹងលទ្ធភាពនៃការរៀបការជាមួយគ្នា ខ្ញុំចង់និយាយថា កុំទាន់រៀបការអី ដើម្បីតែប្រយោជន៍កូន។ ខ្ញុំមិនស្គាល់ប្អូន និងមិត្តស្រីរបស់



50 QnA John Piper Final 1.5.indd 158 25/01/2024 09:22:58 AM

ប្អូនគ្រប់គ្រាន់ ដើម្បីឲ្យដឹងថាខ្ញុំគួរលើកទឹកចិត្តឲ្យរៀបការ ឬក៏អត់ទេ។

អ្នកទាំងពីរបានស្គាល់គ្នាត្រឹមតែពីរខែប៉ុណ្ណោះ—យោងតាមពេលដែលប្អូនសួរសំណួរនេះ។ វាមិនគ្រប់គ្រាន់ទេក្នុងការបន្តទៅមុខទៀត។ អ្នកទាំងពីរត្រូវការពេលវេលា ដើម្បីឲ្យស្គាល់គ្នា ហើយដើម្បីឲ្យថាតើការប្ដេជ្ញាចិត្តពេញមួយជីវិតជាមួយគ្នាគឺជាការល្អ ឬក៏អត់។ ប្រសិនបើថាការរៀបអាពាហ៍ពិពាហ៍គឺជាការល្អ ហើយឪពុកម្ដាយយល់ព្រម នោះប្រហែលជាលទ្ធផលដ៏ល្អបំផុត។ ប៉ុន្តែ មិនថានៅក្នុងករណីណាក៏ដោយ ក៏កុំអស់សង្ឃឹមឡើយ ព្រោះអ្នកទាំងពីរមិនដឹងថា តើអនាគតនឹងទៅជាយ៉ាងណាទេ។

ឥឡូវនេះ ព្រះជាម្ចាស់ត្រាស់ហៅប្អូនឲ្យស្មោះត្រង់ និងមានការសម្រេចចិត្តដែលចេះស្ដាប់បង្គាប់។ ព្រះអង្គមិនសន្មតថា ឥឡូវនេះប្អូនអាចមើលឃើញពីផលវិបាកទាំងអស់នៃជម្រើសទាំងនោះទេ។ នោះគឺជាព័ន្ធកិច្ចដ៏អស្ចារ្យរបស់ទ្រង់។ ព្រះអង្គធ្វើគ្រប់អ្វីៗទាំងអស់រួមគ្នា ដើម្បីសេចក្ដីល្អសម្រាប់អ្នកដែលស្រឡាញ់ទ្រង់ (រ៉ូម ៨:២៨) ទោះបើយើងមិនអាចនឹកស្មានថា វាអាចទៅជាយ៉ាងនោះដោយរបៀបណាបានក៏ដោយ។

អ្វីដែលខ្ញុំកំពុងលើកទឹកចិត្តឲ្យប្អូនធ្វើគឺ ប្អូនត្រូវជីករកធនធានក្នុងព្រះគម្ពីរ ព្រះវិញ្ញាណបរិសុទ្ធ និងជំនឿ ដើម្បីឲ្យធ្វើនូវអ្វីៗដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យមនុស្សប្រុសធ្វើក្នុងស្ថានភាពដ៏ពិបាកដូចនេះ។

មកដល់ពេលនេះ នេះទំនងជារដូវកាលដ៏លំបាកបំផុតក្នុងជីវិតរបស់ប្អូន។ វានឹងក្លាយជាការល្បងលដ៏ធំមួយនៃជំនឿ និងភាពជាបុរសរបស់ប្អូន ហើយប្អូនក៏នឹងដឹងថា ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះដ៏អស្ចារ្យ ជាមិត្តដ៏អស្ចារ្យ និងជាអ្នកប្រឹក្សាដ៏គ្រប់គ្រាន់។

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 160 25/01/2024 09:22:59 AM

## សំណួរទី២៧៖
# តើជីវិតអាពាហ៍ពិពាហ៍នឹងព្យាបាលភាពត្រេកត្រអាលរបស់ខ្ញុំបានដែរឬទេ?

*តើជីវិតអាពាហ៍ពិពាហ៍នឹងព្យាបាលភាពត្រេកត្រអាលរបស់ខ្ញុំបានដែរឬទេ? នេះគឺជាសំណួរសម្រាប់ថ្ងៃនេះពីបុគ្គលម្នាក់ដែលមិនទាន់បានរៀបការ ឈ្មោះ សុខ។ «សូមគោរពលោកគ្រូ ខ្ញុំមានអាយុ ២២ ឆ្នាំហើយខ្ញុំមានបន្ទុកខាងផ្លូវភេទយ៉ាងខ្លាំង។ ពេលខ្លះខ្ញុំចុះចូលនឹងសាច់ឈាម ហើយមើលរូប និងវីដេអូអាសអាភាស។ ខ្ញុំស្អប់ការនេះណាស់ ហើយក៏កំពុងប្រយុទ្ធប្រឆាំងនឹងអំពើបាបនេះដោយមានជំនួយពីមិត្តភក្ដិដែរ។»*

*«នៅពេលនេះខ្ញុំមានមិត្តភក្ដិមួយចំនួនដែលព្យាយាមថែរក្សាព្រលឹងខ្ញុំដោយដកស្រង់សម្ដីរបស់សាវ័ក ប៉ុល—«ដ្បិតដែលរៀបការ នោះប្រសើរជាងទុកឲ្យមានតណ្ហាពុះកញ្ជ្រោល។» (១កូរិនថូស ៧:៩ គកស) ហើយពួកគេប្រាប់ខ្ញុំថាខ្ញុំគួរតែរៀបការឆាប់ៗនេះទៅ។ ប៉ុន្តែ ខ្ញុំក៏មានមិត្តភក្ដិមួយចំនួនទៀតដែលបានរៀបការ ហើយក៏បានធានាប្រាប់ខ្ញុំថា ជីវិតអាពាហ៍ពិពាហ៍នឹងមិនអាចព្យាបាលភាពត្រេកត្រអាលរបស់ខ្ញុំបានទេ ហើយថាវាជាសមរភូមិដែលខ្ញុំនឹងប្រឈមមុខក្រោយពេលរៀបការ! ខ្ញុំមិនដឹងជឿមួយណាទេ។ ប្រសិនបើជីវិតអាពាហ៍ពិពាហ៍អាចព្យាបាលភាពត្រេកត្រអាលបាន នោះខ្ញុំគួរតែរៀបការឆាប់ៗនេះ។ ប្រសិនបើវាមិនព្យាបាលភាពត្រេកត្រអាលបានទេ នោះខ្ញុំត្រូវព្យាយាមរស់នៅដោយមានភាពបរិសុទ្ធផ្ទាល់ខ្លួនឥឡូវនេះ ដោយមិនចាំបាច់រៀបការជាបន្ទាន់ទេ។ តើមួយណាត្រូវ?»*

### ទាំងអស់ ឬគ្មានសោះ?

ឱ! ប្អូន សុខ អើយ! អារម្មណ៍របស់ខ្ញុំនៅពេលដែលខ្ញុំស្ដាប់សំណួររបស់



50 QnA John Piper Final 1.5.indd 161 25/01/2024 09:22:59 AM

ប្អូនគឺថា ប្អូនមានផ្នត់គំនិតទាំងអស់ ឬគ្មានសោះ នៅពេលប្អូននិយាយថា "ប្រសិនបើជីវិតអាពាហ៍ពិពាហ៍អាចព្យាបាលភាពត្រេកត្រអាលបាន នោះខ្ញុំគួរតែរៀបការឆាប់ៗនេះ។ ប្រសិនបើវាមិនព្យាបាលភាពត្រេកត្រអាលបានទេ នោះខ្ញុំត្រូវព្យាយាមរស់នៅដោយមានភាពបរិសុទ្ធផ្ទាល់ខ្លួនឥឡូវនេះ ដោយមិនចាំបាច់រៀបការជាបន្ទាន់ទេ។" ពេលដែលប្អូននិយាយដូចនោះ ខណៈពេលដែលខ្ញុំស្តាប់ទៅខ្ញុំដូចជាមានអារម្មណ៍ថាប្អូនមានគំនិតថា ជីវិតអាពាហ៍ពិពាហ៍អាចព្យាបាលភាពត្រេកត្រអាល ឬក៏ថាវាមិនព្យាបាលទេ៖ ការព្យាបាលទាំងស្រុង ឬមិនជាការព្យាបាលសោះ។ នោះហើយជាអ្វីដែលខ្ញុំចង់មានន័យពេលខ្ញុំលើកឡើងថា ផ្នត់គំនិតទាំងអស់ ឬគ្មានសោះ។

ប៉ុន្តែ នោះមិនមែនជារូបភាពដែលយើងឃើញនៅក្នុងព្រះគម្ពីរទេ។ ដូច្នេះ តោះ! ចូរយើងយកព្រះគម្ពីរមកមើល ដើម្បីឲ្យយើងឃើញអ្វីដែលជាជំនួយដ៏ពិតប្រាកដថា តើបទគម្ពីរផ្ដល់ឲ្យយ៉ាងច្បាស់យ៉ាងដូចម្ដេចនៅក្នុងចំណុចនេះ។ ប្អូនបានផ្ដោតអារម្មណ៍យ៉ាងត្រឹមត្រូវលើបញ្ហានេះ។ "ខ្ញុំសូមនិយាយចំពោះអ្នកនៅលីវ និងស្ត្រីមេម៉ាយថា បើគេនៅដូចជាខ្ញុំបាន នោះជាការប្រសើរ។ ប៉ុន្តែ បើគេអត់ទ្រាំមិនបាន ចូររៀបការចុះ ដ្បិតដែលរៀបការ នោះប្រសើរជាងទុកឲ្យមានតណ្ហាពុះកញ្ជ្រោល។" (១កូរិនថូស ៧:៨–៩ គកស)។

សុខ! ប្អូនបានគិតយ៉ាងត្រឹមត្រូវហើយថា ជីវិតអាពាហ៍ពិពាហ៍គឺជាជំនួយដែលព្រះជាម្ចាស់បានរចនាឡើងក្នុងការដោះស្រាយតណ្ហាដ៏ពុះកញ្ជ្រោលក្នុងចំណង់ផ្លូវភេទ។ នោះហើយជាអ្វីដែលខគម្ពីរបានលើកឡើង។ ប៉ុន្តែ ខ្ញុំមិនឃើញអ្វីទេនៅក្នុងខគម្ពីរនេះដែលលើកឡើងអំពីការព្យាបាលទាំងស្រុង ប៉ុន្តែវាជាការផ្ដល់ជំនួយយ៉ាងច្បាស់លាស់។



50 QnA John Piper Final 1.5.indd 162 25/01/2024 09:22:59 AM

### ព្រះជាម្ចាស់បានរចនាជំនួយ

យើងក៏ឃើញអំពីចំណុចដូចគ្នានេះដែរនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៧:២-៣៖ «ប៉ុន្តែ ដោយព្រោះមានអំពើសហាយស្មន់កើតឡើង បុរសម្នាក់ៗត្រូវមានប្រពន្ធជារបស់ខ្លួន ហើយស្ត្រីម្នាក់ៗ ក៏ត្រូវមានប្ដីជារបស់ខ្លួនដែរ។ ប្ដីត្រូវបំពេញករណីយកិច្ចជាប្ដីចំពោះប្រពន្ធរបស់ខ្លួន ហើយប្រពន្ធក៏ត្រូវធ្វើដូច្នោះចំពោះប្ដីរបស់ខ្លួនដែរ។» នោះជាវិធីដ៏ល្អមួយក្នុងការនិយាយថា «ចូររួមភេទជាមួយនាងនៅពេលដែលវាជាប្រយោជន៍សម្រាប់នាងចុះ»។ «ហើយប្រពន្ធក៏ត្រូវធ្វើដូច្នោះចំពោះប្ដីរបស់ខ្លួនដែរ»។ ដូច្នេះ «ចូររួមភេទជាមួយគាត់នៅពេលដែលវាជាប្រយោជន៍សម្រាប់គាត់ចុះ»។

សាវ័ក ប៉ុល បន្តថា៖ «ប្រពន្ធមិនមែនជាម្ចាស់លើរូបកាយរបស់ខ្លួនទេ គឺជារបស់ប្ដី ឯប្ដីក៏ដូច្នោះដែរ មិនមែនជាម្ចាស់លើរូបកាយរបស់ខ្លួនទេ គឺជារបស់ប្រពន្ធ» (១កូរិនថូស ៧:៤)។ ទាំងសងខាងមានការទាមទារលើគ្នាទៅវិញទៅមកទាក់ទងខាងផ្លូវភេទ។ « មិនត្រូវបង្អត់គ្នាឡើយ លើកលែងតែមានការយល់ព្រមគ្នាទុកពេលមួយឲ្យទំនេរ» ហើយបន្ទាប់មក យើងជួបផ្នែកដ៏គួរឲ្យចាប់អារម្មណ៍មួយនេះ—«សម្រាប់អធិស្ឋាន រួចត្រូវវិលមកនៅជាមួយគ្នាវិញ ក្រែងអារក្សសាតាំងល្បួងអ្នករាល់គ្នា ដោយព្រោះមិនចេះអត់ទ្រាំ» (១កូរិនថូស ៧:៥)។

ច្បាស់ណាស់! សាវ័ក ប៉ុល កំពុងបង្រៀនថា ព្រះជាម្ចាស់បានរចនាទំនាក់ទំនងខាងផ្លូវភេទក្នុងជីវិតអាពាហ៍ពិពាហ៍ទុកជាវិធីមួយ ដើម្បីបំបាក់ការចង់ប្រព្រឹត្តអំពើខុសឆ្គងដែលនាំឲ្យការចង់ផិតក្បត់មានការចុះខ្សោយ។ បើមិនដូច្នោះទេ នោះគាត់នឹងមិនសរសេរថា «រួចត្រូវវិលមកនៅជាមួយគ្នាវិញ ក្រែងអារក្សសាតាំងល្បួងអ្នករាល់គ្នា ដោយព្រោះមិនចេះអត់ទ្រាំ» (១កូរិនថូស ៧:៥)។



50 QnA John Piper Final 1.5.indd 163 25/01/2024 09:23:00 AM

## លើសពីភាពជាក់ស្តែង

ឥឡូវនេះ ប្រសិនបើយើងគិត—ហើយមានមនុស្សមួយចំនួនបានធ្វើដូចនោះមែន ហើយខ្ញុំក៏ពិតជាបានតស៊ូនឹងបញ្ហានេះអស់រយៈពេលជាច្រើនឆ្នាំមកដែរ—ពេលស្តាប់ទៅ នេះដូចជាគ្រាន់តែជាការជាក់ស្តែងប៉ុណ្ណោះ និងការមានគំនិតទាបលើជីវិតអាពាហ៍ពិពាហ៍ «ចូររៀបការ ដើម្បីរួមភេទ! តាមវិធីនេះ នោះអ្នកនឹងមិនប្រព្រឹត្តអំពើផិតក្បត់ ឬសហាយស្មន់ឡើយ»។ ការគិតបែបនេះគឺខុសហើយ! មិនមែនដូច្នោះទេ។ វាជាឥទ្ធិពលជាក់ស្តែងនៃជីវិតអាពាហ៍ពិពាហ៍ដែលជាការពិតដ៏ធំធេងជាងឥទ្ធិពលជាក់ស្តែងផ្នែកខាងឯផ្លូវភេទទៅទៀត។

ឧទាហរណ៍៖ ដើម្បីមើលឲ្យឃើញពីចក្ខុវិស័យនៃជីវិតអាពាហ៍ពិពាហ៍—ចក្ខុវិស័យដ៏ធំ និងរុងរឿង ការផ្តោតរបស់ព្រះជាម្ចាស់លើជីវិតអាពាហ៍ពិពាហ៍—យើងគួរទៅអានកណ្ឌគម្ពីរអេភេសូរជំពូក៥សិន។ ប៉ុន្តែ ដូចដែលការគិតខុសថា ភាពជាក់ស្តែងខាងឯផ្លូវភេទគឺជាអត្ថន័យសរុបនៃជីវិតអាពាហ៍ពិពាហ៍ នោះវាក៏ជាការខុសផងដែរក្នុងការគិតថា ទ្រឹស្តីដ៏អស្ចារ្យផ្នែកចក្ខុវិស័យខាងឯទេវវិទ្យានៃជីវិតអាពាហ៍ពិពាហ៍នៅកណ្ឌគម្ពីរ អេភេសូរជំពូក៥ (ដែលមានព្រះគ្រីស្ទ និងក្រុមជំនុំធ្វើជាគំរូប្តី និងប្រពន្ធ) វាក៏មិនរាប់បញ្ចូលយ៉ាងលម្អិតក្នុងការរួមភេទដែលមានឥទ្ធិពលក្នុងជីវិតអាពាហ៍ពិពាហ៍ដែរ។ សរុបសេចក្តីទៅ វាជាការទាំងពីរ មិនមែនថាមានមួយអត់មួយទេ—ជីវិតអាពាហ៍ពិពាហ៍មានទាំងចក្ខុវិស័យដ៏អស្ចារ្យដែលព្រះជាម្ចាស់ផ្តោតលើ ហើយទាំងឥទ្ធិពលយ៉ាងលម្អិតខាងឯរូបកាយដែរ។

## ជំនួយខាងរូបកាយសម្រាប់ជីវិតខាងឯវិញ្ញាណ

ខណៈពេលដែលខ្ញុំបានគិតអំពីចំណុចនេះ ចំពោះខ្ញុំវាហាក់ដូចជាអាចមានប្រយោជន៍ដល់ សុខ ក្នុងការពិចារណាថាទំនាក់ទំនងខាងឯផ្លូវភេទ



50 QnA John Piper Final 1.5.indd 164 25/01/2024 09:23:00 AM

នៅក្នុងជីវិតអាពាហ៍ពិពាហ៍គឺជាជំនួយដល់រូបកាយក្នុងការប្រយុទ្ធសង្គ្រាមខាងឯវិញ្ញាណទាស់ប្រឆាំងនឹងភាពត្រេកត្រអាល និងការផិតក្បត់ ដែលការនេះក៏ដូចគ្នានឹងសកម្មភាពខាងឯសាច់ឈាមមួយចំនួនទៀត ដែលជាជំនួយដល់ការប្រយុទ្ធសង្គ្រាមខាងឯវិញ្ញាណផ្សេងៗទៀត។ សូមឲ្យខ្ញុំលើកជាឧទាហរណ៍។

សកម្មភាពខាងឯសាច់ឈាមនៃការគេងឲ្យបានគ្រប់គ្រាន់ជួយក្នុងការប្រយុទ្ធសង្គ្រាមខាងឯវិញ្ញាណរបស់យើងប្រឆាំងនឹងអំពើបាបនៃការមិនចេះអត់ធ្មត់។ ការហាត់ប្រាណឲ្យបានទៀងទាត់ជួយក្នុងការប្រយុទ្ធប្រឆាំងនឹងភាពអន្លង់អន្លោចរបស់យើង។ «ការដើរនៅក្នុងខ្យល់អាកាសបរិសុទ្ធ»—លោកគ្រូ ស្ពើជិន បាននិយាយយ៉ាងគួរឲ្យចាប់អារម្មណ៍—«ជួយយើងក្នុងការប្រយុទ្ធប្រឆាំងនឹងការបាក់ទឹកចិត្ត»។ ការពិចារណាលើផ្ការំចង់ និងបក្សាបក្សីនៅលើមេឃជួយយើងក្នុងការប្រយុទ្ធប្រឆាំងនឹងការថប់បារម្ភ។ ព្រះយេស៊ូវបានមានបន្ទូលយ៉ាងដូច្នោះនៅក្នុងកណ្ឌគម្ពីរ(ម៉ាថាយជំពូក៦)។

ដោយក្រោកឈរឡើង—ដោយប្រើជើងរបស់គាត់ ដើម្បីក្រោកឡើង—ហើយទុកអាវធំរបស់គាត់ចោល ហើយរត់ចេញពីផ្ទះបានជួយលោក យ៉ូសែប កម្ចាត់អំពើបាបនៃអំពើផិតក្បត់ជាមួយប្រពន្ធរបស់លោក ប៉ូទីផារ។ នោះហើយជាមូលហេតុដែលសាវ័ក ប៉ុល និយាយថា «ចូររត់ចេញពីអំពើសហាយស្មន់ទៅ!» (១កូរិនថូស ៦:១៨)។ នោះមានន័យថា ចូរប្រើប្រាស់សាច់ដុំរបស់អ្នក ដើម្បីរត់ចេញ។ នេះគឺជាការប្រយុទ្ធខាងសាច់ឈាម ហើយក៏ជាការប្រយុទ្ធខាងឯវិញ្ញាណដែរ។ នេះហើយជាមូលហេតុដែលសាវ័ក ប៉ុល សរសេរនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៣:១៤៖ «កុំបំពេញតាមសេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាមឡើយ»។ មានជំហានជាក់ស្ដែងដែលយើងអាចអនុវត្តបានដែលជួយយើងក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើបាប។



50 QnA John Piper Final 1.5.indd 165 25/01/2024 09:23:00 AM

**គ្មានការព្យាបាលទាំងស្រុងទេ**

បើនិយាយម្យ៉ាងទៀតទៅ ព្រះជាម្ចាស់បានតែងតាំងលំនាំឥរិយាខាងឯរូបកាយមួយចំនួន ដើម្បីជាមធ្យោបាយជួយយើងក្នុងការប្រយុទ្ធសង្គ្រាមខាងឯវិញ្ញាណ ដូចជាការប្រយុទ្ធប្រឆាំងនឹងអំពើបាបជាដើម។ ដូចគ្នានឹងការគេងនិងរបបអាហារ និងការដើរហើយពិចារណាអំពីថ្ងៃរះ ហើយរត់ចេញពីពិធីជប់លៀងដ៏ក្តៅគគុកនៅចំណុចជាក់លាក់ណាមួយ ហើយការលុបកម្មវិធីមួយចំនួនចេញពីទូរស័ព្ទរបស់អ្នក គឺជាជំនួយខាងរូបកាយក្នុងការប្រយុទ្ធសង្គ្រាមខាងឯវិញ្ញាណ—ទោះបើវាមិនមែនជាការព្យាបាលទាំងស្រុងក៏ដោយ—ក្នុងរបៀបដូចគ្នា ទំនាក់ទំនងខាងឯផ្លូវភេទក្នុងជីវិតអាពាហ៍ពិពាហ៍គឺជាជំនួយដ៏អស្ចារ្យក្នុងការប្រយុទ្ធសង្គ្រាមខាងឯវិញ្ញាណដែលទាស់ប្រឆាំងនឹងភាពត្រេកត្រអាល និងការផិតក្បត់ ប៉ុន្តែវាមិនមែនជាការព្យាបាលទាំងស្រុងឡើយ។

មូលហេតុដែលយើងដឹងអំពីចំណុចនេះថាមកពីព្រះគម្ពីរគឺដោយសារព្រះយេស៊ូវបានផ្តល់ការព្រមានយ៉ាងខ្លាំងទាស់នឹងការផិតក្បត់ដូចដែលមានចែងនៅក្នុងកណ្ឌគម្ពីរ លូកា ១៨:២០។ វានឹងគ្មានការចង់ប្រព្រឹត្តអំពើផិតក្បត់ទេក្នុងជីវិតអាពាហ៍ពិពាហ៍បើការរួមភេទជាការព្យាបាលទាំងស្រុងសម្រាប់សេចក្តីប៉ងប្រាថ្នាក្នុងការរួមភេទខុសច្បាប់។ នោះព្រះយេស៊ូវនឹងមិនចាំបាច់មានព្រះបន្ទូលថា «កុំផិតឲ្យសោះ»។

មែនហើយ អំណោយនៃការអរសប្បាយខាងឯផ្លូវភេទក្នុងជីវិតអាពាហ៍ពិពាហ៍គឺជាជំនួយដ៏អស្ចារ្យក្នុងការប្រយុទ្ធប្រឆាំងនឹងភាពត្រេកត្រអាល និងការផិតក្បត់ ប៉ុន្តែវាមិនមែនជាការព្យាបាលទាំងស្រុងទេ។ ផ្ទុយទៅវិញ ផលផ្លែទាំងអស់នៃព្រះវិញ្ញាណ ដែលមានមួយក្នុងចំណោមទាំងនោះគឺអំពីការគ្រប់គ្រងខ្លួនឯង យើងនៅតែត្រូវការផលផ្លែនោះក្នុងជីវិតអាពាហ៍ពិពាហ៍ក៏ដូចជាក្រៅជីវិតអាពាហ៍ពិពាហ៍ដែរ (កាឡាទី ៥:២២-២៣)។



50 QnA John Piper Final 1.5.indd 166 25/01/2024 09:23:00 AM

## ការរួបរួមខាងឯវិញ្ញាណដែលកាន់តែមានភាពស៊ីជម្រៅ

សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងអំពីចំណុចមួយផ្សេងទៀតដែលខ្ញុំគិតថាសំខាន់ណាស់ក្រែងលោខ្ញុំបានបង្កើតទស្សនៈសិប្បនិម្មិតលើជីវិតអាពាហ៍ពិពាហ៍។ ជីវិតអាពាហ៍ពិពាហ៍ និងទំនាក់ទំនងខាងឯផ្លូវភេទក្នុងរបៀបដ៏ល្អបំផុតបង្កើតជាជញ្ជាំងភ្លើងការពារមួយរវាងដៃគូជីវិត និងការផិតក្បត់ និងការមើលរូបអាសអាភាស ឬក៏វីដេអូតាមវិធីផ្សេងៗទៀតក្រៅពីការដែលគ្រាន់តែរូបកាយប៉ះគ្នា។ យើងមិនគួរគិតពីការការពារចេញពីអំពើបាបខាងឯផ្លូវភេទថា វាគ្រាន់តែទាក់ទងនឹងការរួមភេទដូចជាការបន្ទូរខាងឯរូបកាយ ឬក៏ដូចជាការបន្ទូរសម្ពាធ ហាក់បីដូចជាថាយើងកំពុងនិយាយបែបនេះ «ខ្ញុំត្រូវតែរាំងបុរសម្នាក់នេះកុំឲ្យផ្ទុះនៅកន្លែងដែលខុស ដូច្នេះគាត់ត្រូវតែបន្ទូរសម្ពាធនេះចេញ»។

នោះគឺជាការពិតមែន ប៉ុន្តែវាមិនមែនជាចំណុកសរុបនៃអ្វីដែលកំពុងកើតឡើងនៅពេលដែលសាវ័ក ប៉ុល និយាយថា ទំនាក់ទំនងខាងឯផ្លូវភេទគឺជាជញ្ជាំងភ្លើងការពារនោះទេ។ វាមានលើសជាងនេះទៅទៀត។ ខ្ញុំគិតថា នៅក្នុងវប្បធម៌របស់យើង យើងបានធ្វើឲ្យការរួមភេទជាអំពើពេស្យាចារបែបជាការបំពេញកាមតណ្ហា បែបជាកីឡានៅចុងសប្តាហ៍ ដូច្នេះវាពិតជាពិបាកណាស់សម្រាប់ឲ្យពួកគេយល់ពីអ្វីដែលខ្ញុំកំពុងនិយាយ។  ព្រះជាម្ចាស់មានគោលបំណងនៅក្នុងភាពស្និទ្ធស្នាលនៃការរួបរួមខាងរូបកាយក្នុងជីវិតអាពាហ៍ពិពាហ៍ថាជាអ្វីមួយដែលអស្ចារ្យ រុងរឿង ស្រស់ស្អាត និងជាការខាងឯវិញ្ញាណនៅពេលដែលមានការរួមភេទកើតឡើង។

ការរួមភេទបង្កើតឲ្យមានជម្រៅចិត្តនៃការស្រឡាញ់ ពង្រឹងការតាំងសេចក្តីសញ្ញា និងការរួបរួមគ្នាខាងឯវិញ្ញាណ និងជាការផ្សារភ្ជាប់ផ្ទាល់ខ្លួនដែលមិនអាចយល់បាន។ នៅពេលដែលការរីកចម្រើនបែបនេះកាន់តែកើតឡើងយ៉ាងជ្រាលជ្រៅទៅៗ នោះអ្នកនឹងកាន់តែមិនចង់មើលរូប ឬវីដេអូអាសអាភាស



50 QnA John Piper Final 1.5.indd 167 25/01/2024 09:23:01 AM

និងទៅផិតក្បត់ជាមិនខាន។ នោះហើយជាសិរីល្អនៃទំនាក់ទំនងផ្លូវភេទនៅក្នុងជីវិតអាពាហ៍ពិពាហ៍។ សុខ! នៅពេលដែលប្អូនបន្តតយុទ្ធ ដើម្បីភាពបរិសុទ្ធខាងឯផ្លូវភេទនៅក្នុងជីវិតនៃភាពនៅលីវរបស់ប្អូនដោយពឹងលើអំណាចនៃព្រះវិញ្ញាណ ទាំងនោះហើយគឺជាអ្វីដែលប្អូនគួរតែចង់បាន និងអធិស្ឋានឆ្ពោះទៅរកជីវិតអាពាហ៍ពិពាហ៍។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 168 25/01/2024 09:23:01 AM

# សំណួរទី២៨៖
# តើអ្នកនឹងទៅចូលរួមពិធីរៀបការភេទដូចគ្នាដែរឬទេ?

*បុគ្គលម្នាក់បានទូរស័ព្ទមក ហើយសួរថា «លោកគ្រូ ប្រសិនបើមានសមាជិកម្នាក់នៅក្នុងក្រុមគ្រួសាររបស់លោកគ្រូបានអញ្ជើញលោកគ្រូឲ្យទៅចូលរួមកម្មវិធី ដែលគេហៅថាពិធីមង្គលការភេទដូចគ្នា នោះលោកគ្រូនឹងទៅចូលរួមដែរឬទេ?»*

បើគ្រាន់តែគិតលើគំនិតមួយនេះ វាបានធ្វើឲ្យយើងខ្ញុំឈឺចិត្តយ៉ាងខ្លាំងបាត់ទៅហើយ? ចម្លើយរបស់យើងខ្ញុំគឺថា «ទេ!»។ យើងខ្ញុំនឹងមិនទៅទេ។ ហើយការដែលមិនទៅចូលរួមពិធីមួយនេះគឺប្រៀបដូចជាការដែលធ្វើឲ្យបេះដូងរបស់ឪពុកម្នាក់ខ្ទេចខ្ទាំអញ្ចឹង។ ខាងក្រោមនេះគឺជាមូលហេតុដែលយើងខ្ញុំមិនទៅចូលរួម៖

## ការឲ្យអត្ថន័យលើពាក្យ «អាពាហ៍ពិពាហ៍»

*ទី១* វាមិនមែនជាពិធីមង្គលការនោះទេ ពីព្រោះវាមិនមែនជាពិធីអាពាហ៍ពិពាហ៍ការចាប់ផ្ដើមទំនាក់ទំនងប្ដីប្រពន្ធ។ ដូច្នេះ ការទៅចូលរួមដោយរាប់វាថាជាពិធីមង្គលការគឺជាការខុសឆ្គងហើយ ពោលគឺជាការកុហក។ ការដែលមានពិធីអាពាហ៍ពិពាហ៍ភេទដូចគ្នាគឺមិនអាចទៅរួចបានទេ។

ព្រះជាម្ចាស់បានផ្ដល់អត្ថន័យលើពិធីអាពាហ៍ពិពាហ៍ថា ជាសេចក្ដីចំណងជីវិតរវាងបុរស និងស្ត្រីម្នាក់ក្នុងនាមជាប្ដីនិងប្រពន្ធ។ ពិធីអាពាហ៍ពិពាហ៍នៃភេទដូចគ្នាគឺមិនដូច្នោះទេ។ ហេតុដូច្នេះហើយបានជាវាមិនមែនជាពិធីអាពាហ៍ពិពាហ៍ការចាប់ផ្ដើមទំនាក់ទំនងគ្រួសារ និងពិធីមង្គលការឡើយ។ យើងខ្ញុំនឹងមិនកុហកខ្លួនឯងដោយរាប់វាថាជាពិធីមង្គលការដោយទៅចូលរួម។



50 QnA John Piper Final 1.5.indd 169 25/01/2024 09:23:01 AM

## របៀបចងភ្ជាប់នៃស្ថានសួគ៌

*ទី២* ចំណងមួយនេះ—ប្រសិនបើលោកអ្នកហ៊ានហៅវាថាដូច្នោះ—គឺមិនមានការចងភ្ជាប់គ្នានៅឯស្ថានសួគ៌ឡើយ។ ព្រះយេស៊ូវបានមានព្រះបន្ទូលថា "ដូច្នេះ អ្វីដែលព្រះបានផ្សំផ្គុំហើយ មិនត្រូវឲ្យអ្នកណាមកពង្រាត់គេឡើយ" (ម៉ាថាយ ១៩:៦)។ នេះហើយគឺជាអ្វីដែលធ្វើឲ្យពិធីមង្គលការអស្ចារ្យ។ ពិធីមង្គលការគឺមិនមែនជាការសម្រេចរបស់មនុស្សលោកនោះទេ។ ព្រះជាម្ចាស់ជាអង្គផ្សំផ្គុំបុរសម្នាក់ និងស្ត្រីម្នាក់។

នៅក្នុងកណ្ឌគម្ពីរ ម៉ាកុស ១០:៩ ព្រះយេស៊ូវបានលើកឡើងថាពិធីអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើងនៅឯស្ថានសួគ៌—មិនមែនគ្រាន់តែរវាងមនុស្សពីរនាក់ ឬក៏គ្រូគង្វាលម្នាក់ ឬក៏ចៅក្រមនោះឡើយ។ ការផ្សំផ្គុំបុរសពីរនាក់ ឬក៏ស្ត្រីពីរនាក់គឺមិនមានការចងក្រងនៅឯស្ថានសួគ៌ទេ។ ហើយការដែលលើកជាសំណើថាវាគឺជាពិធីអាពាហ៍ពិពាហ៍គឺជាបទល្មើសចំពោះស្ថានសួគ៌។

## កុំអបអរសាទរនឹងអំពើបាបឡើយ

*ទី៣* ការជូនពរលើព្រឹត្តិការណ៍នេះគឺជាសម្អប់។ ចំពោះយើងខ្ញុំ វាគឺជាសម្អប់ក្នុងការជូនពរព្រឹត្តិការណ៍នេះ ពីព្រោះវាគឺជាការអះអាងលើជីវិត និងរបៀបរស់នៅដែលនឹងនាំឲ្យធ្លាក់ស្ថាននរក។ សាវ័ក ប៉ុល បានលើកឡើងថា "សូមកុំច្រឡំឲ្យសោះ! ពួកសហាយស្មន់ ពួកថ្វាយបង្គំរូបព្រះ ពួកផិតក្បត់ ពួកប្រុសពេស្យា ពួករួមសង្វាសនឹងភេទដូចគ្នា ពួកចោរ ពួកលោភលន់ ពួកប្រមឹក ពួកជេរប្រមាថ ពួកបោកប្រាស់ នោះមិនអាចគ្រងព្រះរាជ្យរបស់ព្រះទុកជាមរតកបានឡើយ" (១កូរិនថូស ៦:៩-១០)។ ពួកគេនឹងមិនអាចគ្រងបានទេ។

ការអបអរសាទរជីវិតរស់នៅមួយនេះគឺជាការអបអរសាទរការបំផ្លាញ



50 QnA John Piper Final 1.5.indd 170 25/01/2024 09:23:01 AM

មនុស្សជាតិចោល ហើយនេះគឺជាការដ៏គួរឲ្យស្អប់ខ្ពើមណាស់។ វាដូចជាការជួបជុំគ្នា ដើម្បីអបអរសាទរការធ្វើជាចោរ ការប្រមឹក និងការបោកប្រាស់អ្នកដទៃអញ្ចឹង។ វាប្រៀបដូចជាការលើកឡើងថា «តោះ! ចូរយើងជួបជុំគ្នាដើម្បីអបអរសាទរភាពលោភលន់។ ចូរយើងជួបជុំគ្នា ដើម្បីអបអរសាទរអំពើផិតក្បត់។» បុគ្គលណាដែលចូលរួមការអបអរសាទរអំពើបាបក៏កំពុងតែប្រព្រឹត្តអំពើបាបនោះផងដែរ។ ហើយយើងខ្ញុំក៏មិនគួរប្រព្រឹត្តអំពើបាបទេ។

## ការឲ្យតម្លៃការតាំងសេចក្តីសញ្ញា

*ទី៤* ពិធីមួយនេះនឹងប្រមាថព្រះគ្រីស្ទ និងក្រុមជំនុំ។ ព្រះជាម្ចាស់បានរចនាពិធីអាពាហ៍ពិពាហ៍ ដើម្បីបង្ហាញការតាំងសញ្ញារបស់ព្រះគ្រីស្ទចំពោះកូនក្រមុំរបស់ទ្រង់ ពោលគឺក្រុមជំនុំ។ ការអបអរសាទរការផ្សំផ្គុំដែលគ្មានកូនក្រមុំថាជាពិធីអាពាហ៍ពិពាហ៍គឺជាការបង្ខូច និងបង្ខាតរឿងប្រៀបប្រដូចដែលល្អបំផុតលើលោកនេះ។

## ពេញដោយទុក្ខព្រួយ ប៉ុន្តែនៅតែបើកដៃរង់ចាំទទួល

*ទី៥* យើងខ្ញុំនឹងមិនទៅចូលរួម ពីព្រោះទម្ងន់នៃការឈឺចិត្ត និងការស្រឡាញ់ និងការស្អប់ខ្ពើមនឹងទំនងយកឈ្នះលើអារម្មណ៍រំភើបរបស់យើងខ្ញុំជាមិនខាន។ យើងខ្ញុំគិតថា ខ្លួនមិនអាចទំនងនៅរហូតដល់ចប់កម្មវិធីបានឡើយ។

ហើយចំណុចចុងក្រោយដែលខ្ញុំនឹងលើកឡើងគឺថា៖ ការដែលយើងខ្ញុំមិនទៅចូលរួមគឺមិនមែនជាការដែលយើងខ្ញុំដកខ្លួនចេញពីកូនរបស់ខ្លួនឡើយ—ប៉ុន្តែគឺជាការដែលគាត់ដកខ្លួនចេញពីខ្ញុំវិញទេតើ។ យើងខ្ញុំនៅមានជំហរដដែល៖ បើកដៃរង់ចាំទទួលការដែលកូនវង្វេងត្រឡប់មកផ្ទះវិញដោយត្រៀមចិត្តក្នុងការអត់ទោសផងដែរ។



50 QnA John Piper Final 1.5.indd 171 25/01/2024 09:23:02 AM

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 172 25/01/2024 09:23:02 AM

# ផ្នែកទី៤៖ ការរស់នៅ



50 QnA John Piper Final 1.5.indd 173 25/01/2024 09:23:02 AM

លោកអ្នកអាចស្តាប់សៀវភៅនេះជាសំឡេងបាន
ដោយគ្រាន់តែ

ស្កេននៅទីនេះ

50 QnA John Piper Final 1.5.indd 174 25/01/2024 09:23:02 AM

# សំណួរទី២៩៖
# គ្រីស្ទបរិស័ទ និងកញ្ឆា

*មានបុគ្គលបីបួននាក់បានផ្ញើសារសួរយើងថា «តើការដែលគ្រីស្ទបរិស័ទជក់កញ្ឆាគឺជារឿងខុសមែនឬ?» ដោយសន្មតថាការនេះមិនខុសច្បាប់ ឬក៏គ្រូពេទ្យឲ្យប្រើប្រាស់។*

យើងខ្ញុំមិនសូវដឹងប៉ុន្មានទេអំពីកញ្ឆា។ យើងខ្ញុំមិនមែនជាអ្នកជំនាញទេ។ យើងខ្ញុំគ្រាន់តែបានអានបន្តិចបន្តួច ឬក៏ស្តាប់វាគ្មិនមួយចំនួនតាមប្រព័ន្ធបណ្តាញសារព័ត៌មានតែប៉ុណ្ណោះ។ នេះគឺជាការឆ្លើយតបរបស់យើងខ្ញុំក្នុងនាមជាអ្នកមិនសូវដឹងប៉ុន្មាន ហើយយើងគិតថាយើងក៏នៅមានភស្តុតាយ៉ាងច្បាស់ចេញពីការណែនាំក្នុងព្រះគម្ពីរដែរ។

## កញ្ឆា និងកាហ្វេ

ជាទូទៅ គេប្រើប្រាស់កញ្ឆាជាគ្រឿងញៀន ដើម្បីផ្លាស់ប្តូរអារម្មណ៍ដែលបង្កើតបរិយាកាសដ៏សប្បាយភ្លើតភ្លើនមួយបែប។ ជាទូទៅ គេមិនរាប់ការប្រើប្រាស់កញ្ឆាថាជាអ្វីដែលផ្តល់នូវការប្រុងប្រយ័ត្នក្នុងពេលវេលានោះទេ ប៉ុន្តែបានរាប់ថាជាការដែលនាំឲ្យអ្នកប្រើប្រាស់មិនបានដឹងអំពីពេលវេលាដែលខ្លួនកំពុងតែស្ថិតនៅក្នុង។

ក្នុងករណីនេះ ខ្ញុំជឿថាយើងមិនអាចប្រៀបធៀបវាជាមួយនឹងកាហ្វេបានឡើយ។ ទំនងជាអាចមានបុគ្គលណាម្នាក់លើកឡើងថា «បើអញ្ចឹងមែន តើមានអ្វីខុសឆ្គងជាមួយនិងកញ្ឆា? វាប្រៀបដូចជាកាហ្វេដែរតើ។ ទាំងពីរគឺជាគ្រឿងញៀនដែលនាំឲ្យមានការផ្លាស់ប្តូរអារម្មណ៍។ អ្នកផឹកកាហ្វេពេលព្រឹក ដើម្បីផ្លាស់ប្តូរអារម្មណ៍របស់ខ្លួន ហើយខ្ញុំប្រើប្រាស់កញ្ឆា ដើម្បីផ្លាស់ប្តូរអារម្មណ៍របស់ខ្ញុំ។ ទាំងពីរសម្រេចបានគោលបំណងដូចគ្នា។» តាមពិត



50 QnA John Piper Final 1.5.indd 175 25/01/2024 09:23:02 AM

ទៅ វាមិនដូច្នោះទេ ពីព្រោះលទ្ធផលមួយនៃកាហ្វេគឺថាវាធ្វើឲ្យលោកអ្នកមានភាពរៀសរវៃក្នុងពេលវេលារបស់ខ្លួន។ ប្រសិនបើកាហ្វេមិនធ្វើដូចនោះទេ ខ្ញុំគិតថាយើងគួរតែរត់គេចចេញពីវាទៅ។ តាមពិតទៅ ខ្ញុំក៏គិតថា យើងក៏នៅអាចប្រព្រឹត្តអំពើបាបជាមួយនឹងការប្រើប្រាស់កាហ្វេដែរ។

មានចំណុចខុសគ្នាយ៉ាងខ្លាំងរវាងការដែលធ្វើឲ្យខួរក្បាលរបស់យើងមានភាពរហ័សរហួនជាងធ្វើឲ្យយើងរិចរិល ឬក៏កាន់តែឃ្លាតឆ្ងាយចេញពីពេលវេលាដ៏ពិត។ ជាទូទៅ ខ្ញុំមិនគិតថាកញ្ឆាគឺជាគ្រឿងញៀនដែលផ្តល់ថាមពលដល់លោកអ្នក ដើម្បីធ្វើឲ្យលោកអ្នកក្លាយជាឪពុកដែលមានសមត្ថភាពខ្ពស់ ជាម្តាយដែលចំណាប់ ជាបុគ្គលិកដ៏ឆ្នើម ឬក៏ជាពលរដ្ឋដ៏ពូកែនោះទេ។

ផ្ទុយទៅវិញ វាគឺជាការកំសាន្តដែលគេចចេញពីស្ថានភាពពិត ហើយយោងតាមការដែលខ្ញុំបានអានបន្តិចបន្តួច មិនយូរមិនឆាប់វាក៏បំផ្លាញខួរក្បាលយ៉ាងធ្ងន់ធ្ងរដែរ។ ការប្រើប្រាស់កញ្ឆាបង្កើតឲ្យមានលទ្ធផលអវិជ្ជមានដែលនៅយ៉ាងយូរលើសមត្ថភាពនៃខួរក្បាលរបស់យើងដែលព្រះជាម្ចាស់បានបង្កើតឲ្យវាធ្វើនូវអ្វីដែលវាធ្វើ។

## ព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធ

ប្រសិនបើទាំងនោះគឺជាការពិត នោះគោលការណ៍ចេញពីព្រះគម្ពីរដែលនាំឲ្យយើងខ្ញុំគិតថាគ្រីស្ទបរិស័ទគួរគេចខ្លួនចេញពីការប្រើប្រាស់កញ្ឆាជាការកំសាន្ត គឺពីព្រោះរូបកាយយើងគឺជាព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធ (១កូរិនថូស ៦:១៩)។ ការបង្រៀនដ៏សាមញ្ញនេះបានជះឥទ្ធិពលយ៉ាងខ្លាំងមកលើយើងខ្ញុំ កាលយើងខ្ញុំនៅជាកុមារនៅឡើយ។

ក្នុងនាមជាឪពុក នោះខ្ញុំក៏និយាយដូចនេះទាក់ទងនឹងការជក់បារី ការប្រើប្រាស់គ្រឿងស្រវឹងលើសកំណត់ ការប្រើប្រាស់កញ្ឆា និងចំណុចជាច្រើនផ្សេងទៀតដែរ។ យើងខ្ញុំនឹងបង្រៀនថា “រូបកាយរបស់អ្នកបរិសុទ្ធ។



50 QnA John Piper Final 1.5.indd 176 25/01/2024 09:23:02 AM

ព្រះជាម្ចាស់ចង់ឲ្យតម្លៃលើរូបកាយអ្នក។ រូបកាយរបស់អ្នកគឺសម្រាប់ព្រះអម្ចាស់ (១កូរិនថូស ៦:១៣)។ ចូររក្សាខួរក្បាលរបស់អ្នកឲ្យបាននៅភ្លឺថ្លា ហើយអាចគិតដូចដែលសាវ័ក ប៉ុល បានមានប្រសាសន៍ថា "ខាងឯបំណងអាក្រក់ នោះចូរនៅជាកូនង៉ែតចុះ តែចំណែកខាងឯគំនិត នោះចូរធ្វើជាមនុស្សពេញអាយុវិញ" (១កូរិនថូស ១៤:២០)។ នេះមានន័យថា ឲ្យមានភាពរហ័សរហួន—គ្រប់គ្រងលើវាបាន។»

## មានសេរីភាពក្នុងការស្រឡាញ់ព្រះជាម្ចាស់

ឫសគល់ត្រង់នេះគឺថា ព្រះជាម្ចាស់បានប្រទានខួរក្បាលដល់យើង ដើម្បីឲ្យស្គាល់ព្រះអង្គ ហើយព្រះអង្គក៏បានប្រទានបេះដូងដល់យើង ដើម្បីឲ្យស្រឡាញ់ទ្រង់ដែរ។ នោះគ្រីស្ទបរិស័ទនឹងចង់ធ្វើនូវអ្វីដែលគេចចេញពីអ្វីដែលធ្វើឲ្យខួរក្បាលរបស់យើងស្ពឹក វិល ឬក៏ធ្វើឲ្យយើងបែកអារម្មណ៍ចេញពីការលូតលាស់ក្នុងសមត្ថភាព ដើម្បីស្គាល់ព្រះអង្គល្អជាងមុន ឬក៏ស្រឡាញ់ទ្រង់លើសដើម។

នេះគឺជារបៀបដែលព្រះគម្ពីរបានថែងអំពីការស្រវឹង ហើយយើងខ្ញុំគិតថាកញ្ឆាក៏នៅក្នុងក្រុមដូចគ្នានេះដែរ។ ទាក់ទងនឹងការផឹកស៊ី "ដ្បិតដល់ចុងបំផុតនឹងចឹកដូចជាពស់វិញ ហើយអុចដូចជាពស់ហានុមានផង ភ្នែកឯងនឹងឃើញស្រីដទៃ ហើយចិត្តឯងនឹងពោលសេចក្ដីខូចអាក្រក់ដែរ " (សុភាសិត ២៣:៣២-៣៣)។ មួយវិញសោត វានាំចេញពីភាពម៉ឺងម៉ាត់ ការចេះគ្រប់គ្រងលើខ្លួនឯង ដើម្បីប្រើប្រាស់ខួរក្បាលរបស់ខ្លួន ដើម្បីជាសិរីល្អដល់ព្រះជាម្ចាស់។

## គ្រូពេទ្យឲ្យប្រើ

ដោយបានលើកឡើងដូចនោះ យើងខ្ញុំគិតថាគ្រីស្ទបរិស័ទនឹងបែរចេញពីការបំផ្លាញបែបនោះ ពីគ្រឿងញៀនដែលផ្លាស់ប្ដូរអារម្មណ៍ ហើយឈាន



50 QnA John Piper Final 1.5.indd 177 25/01/2024 09:23:03 AM

ទៅរកការគិតដែលច្បាស់លាស់ ហើយភ្លឺថ្លាដើម្បីជាសិរីល្អដល់ព្រះជាម្ចាស់វិញ។ ហើយយើងខ្ញុំក៏នឹងមិនជំទាស់លើការប្រើប្រាស់កញ្ឆាបែបជាថ្នាំដែលមានការគ្រប់គ្រងយ៉ាងត្រឹមត្រូវពីគ្រូពេទ្យ និងកម្រិតប្រើប្រាស់យ៉ាងត្រឹមត្រូវដែរ។ យើងមានគ្រឿងញៀនជាច្រើនដែលគេលក់ជាថ្នាំពេទ្យ ដែលប្រសិនបើមានការប្រើប្រាស់មិនត្រឹមត្រូវ នោះនឹងនាំឲ្យមានការបំផ្លាញលើសខ្លាំងជាងកញ្ឆាទៅទៀត។

យើងខ្ញុំមានមិត្តភក្តិម្នាក់ដែលបានចែកចាយយ៉ាងល្អិតល្អន់ថា គាត់មានកូនប្រុសម្នាក់ដែលឈឺកែងជើងយ៉ាងឥតឈប់ឈរ ហើយយូរទៀតផង។ គាត់បានលើកឡើងថា “ខ្ញុំដឹងពីបទពិសោធន៍របស់គាត់ថា ភាពធូរស្រាលដែលគាត់អាចទទួលបានគឺនៅពេលដែលគាត់ប្រើប្រាស់កញ្ឆាបន្តិចបន្តួច”។ ដូច្នេះ ប្រសិនបើមានរបៀបដែលយើងអាចប្រើប្រាស់កញ្ឆាដូចដែលយើងប្រើប្រាស់ថ្នាំអាស្ពីរីន ឬក៏របៀបដែលយើងប្រើប្រាស់ថ្នាំផ្សះ—ដោយមានការគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្ន—ក្នុងគោលការណ៍ នោះយើងខ្ញុំក៏នឹងមិនជំទាស់ដែរ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 178 25/01/2024 09:23:03 AM

## សំណួរទី៣០៖
# របៀបជម្នះភាពខ្ជិលច្រអូស

*មិត្តអ្នកអានម្នាក់បានផ្ញើសារមកសួរយើងដូចតទៅ៖ «លោកគ្រូ ខ្ញុំជាគ្រីស្ទបរិស័ទម្នាក់ដែលបានកើតជាថ្មី ដែលពីមុនខ្ញុំធ្លាប់រស់នៅក្នុងជីវិតនៃភេទទីបី។ ព្រះជាម្ចាស់បានប្រើប្រាស់ទេវវិទ្យានៃការរងទុក្ខ និងការបាក់បែករបស់លោកគ្រូ ដើម្បីជួយខ្ញុំក្នុងការយកឈ្នះលើសេចក្ដីប្រាថ្នាបែបនោះខាងឯផ្លូវភេទ ដែលមិនបង្ហាញអំពីការកោតខ្លាចព្រះជាម្ចាស់? ប៉ុន្តែ ឥឡូវនេះយើងខ្ញុំមានការតយុទ្ធថ្មីមួយទៀត—ការតយុទ្ធនឹងភាពខ្ជិលច្រអូស។ តើលោកគ្រូមានការប្រឹក្សាអ្វីខ្លះក្នុងការតយុទ្ធនឹងអំពើបាបមួយនេះចំពោះខ្ញុំ?»។*

### រោគវិនិច្ឆ័យខាងឯសាច់ឈាម

វាទំនងជាចម្លែកបន្តិច ប៉ុន្តែអ្វីដែលយើងខ្ញុំនឹងលើកឡើងមុនគេបង្អស់គឺបើកអ៊ុតមើលគ្រឿងម៉ាស៊ីនបន្តិចសិន។ អ្វីដែលខ្ញុំចង់មានន័យនោះគឺថា តើគាត់មានបញ្ហាខាងឯឈាមដូចជាជំងឺពកកដែរឬទេ? តើគាត់បានសម្រាកគ្រប់គ្រាន់ដែរឬទេ? តើគាត់បរិភោគដោយគិតអំពីសុខភាពដែរឬទេ? មានរឿងជាច្រើននៅក្នុងជីវិតគ្រីស្ទបរិស័ទដែលយើងគិតថា ជាការខ្វះខាតខាងឯព្រលឹងវិញ្ញាណ ដែលតាមពិតទៅវាពាក់ព័ន្ធនឹងសាច់ឈាមសោះ។

ប្រមាណជា១០ឆ្នាំមុន យើងខ្ញុំឧស្សាហ៍អស់កម្លាំងណាស់ ហើយយើងខ្ញុំក៏មិនអាចពន្យល់ពីមូលហេតុបានដែរ។ នៅពេលដែលយើងខ្ញុំបានទៅជួបគ្រូពេទ្យ គាត់បានមានប្រសាសន៍ថា «តាមពិតទៅ លោកដឹងទេ ខ្ញុំគិតថាមិនមានបញ្ហាអ្វីឡើយ ប៉ុន្តែតោះចូរយើងឆែកមើលជំងឺបំពង់ករបស់លោកសិន»។ ដប់ពីរម៉ោងក្រោយមក គាត់ក៏បានទូរស័ព្ទមកយើងខ្ញុំ ហើយនិយាយថា «លោកមានជំងឺពកកយ៉ាងខ្លាំងធ្ងន់ធ្ងរ។ ខ្ញុំមិនដឹងថា លោកនៅមាន



50 QnA John Piper Final 1.5.indd 179 25/01/2024 09:23:03 AM

ដំណើរការរស់នៅបានយ៉ាងដូចម្តេចសោះ»។

គាត់ក៏បានឲ្យយើងខ្ញុំលេបថ្នាំ ហើយរឿងនោះក៏បានផ្លាស់ប្តូរ។ កាលនោះប្រសិនបើយើងខ្ញុំព្យាយាមភ្ជាប់ការអស់កម្លាំងរបស់យើងខ្ញុំជាមួយនឹងរឿងខាងវិញ្ញាណ នោះយើងខ្ញុំនឹងមើលរំលងជំងឺនោះទាំងស្រុង។ យើងខ្ញុំបានជាពីជំងឺពកកហើយ។ មិនថាយើងខ្ញុំខិតខំព្យាយាមអានព្រះគម្ពីររបស់ខ្លួនអស់ប៉ុន្មានជំពូកក៏ដោយ ក៏វានឹងមិននាំឲ្យមានការផ្លាស់ប្រែដែរ។ ដូច្នេះ នោះគឺជាចំណុចដំបូងដែលយើងខ្ញុំនឹងធ្វើ។ ប៉ុន្តែ តាមពិតទៅ គាត់មិនកំពុងតែសួរអំពីចំណុចនេះនោះទេ។ គាត់កំពុងតែលើកឡើងថា «ខ្ញុំគិតថា ខ្ញុំមានបញ្ហាខាងឯអំពើបាប។ ទាក់ទងនឹងបញ្ហានេះ តើលោកគ្រូអាចជួយខ្ញុំបានដែរឬទេ?»

**ទេវវិទ្យានៃការខំធ្វើការ**

ការប្រឹក្សាដំបូងរបស់យើងខ្ញុំគឺលើកទឹកចិត្តឲ្យគាត់ចាប់ផ្តើមសិក្សានៅក្នុងដើមដំបូងនៃព្រះគម្ពីរ ហើយឲ្យគាត់យល់ដោយមានទេវវិទ្យានៃការធ្វើការឲ្យបានល្អសិន។

ការងារមិនមែនជាបណ្តាសានោះទេ ប៉ុន្តែ*ការអាក់អន់ចិត្ត*នឹងការងារគឺជាបណ្តាសា។ «ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកអ័ដាមទៅដាក់នៅក្នុងសួនច្បារអេដែន ឲ្យគាត់ធ្វើការហើយថែរក្សា» (លោកុប្បត្តិ ២:១៥)។ ការនេះមានមុនការធ្លាក់ក្នុងអំពើបាបទៅទៀត។ ដូច្នេះ ចូរមានទេវវិទ្យានៃការធ្វើការដ៏ល្អ មាំមួន និងវិជ្ជមានចុះ។ សូមទទួលស្គាល់ថា ព្រះជាម្ចាស់បានដាក់យើងនៅលើពិភពលោកនេះ ដើម្បីឲ្យមានចំណែកក្នុងការធ្វើការ និងការបង្កើតជាមួយនឹងព្រះអង្គ។

ព្រះគម្ពីរបានចែងថា «ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសម្រាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម» (អេភេសូរ ២:១០)។ ឬក៏ថា «ការអ្វីដែលដៃឯងអាចធ្វើបាន



50 QnA John Piper Final 1.5.indd 180 25/01/2024 09:23:03 AM

នោះចូរធ្វើដោយអស់ពីកម្លាំងចុះ» (សាស្តា ៩:១០)។ ឬក៏ថា «ហើយការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឲ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ» (កូឡុស ៣:២៣)។

គោលបំណងរបស់ខគម្ពីរទាំងនោះ គឺដើម្បីឲ្យយើងមានទេវវិទ្យានៃការធ្វើការយ៉ាងរឹងមាំ ក្នុងការដែលយើងរំពឹងមើលអ្វីដែលយើង*កំពុងធ្វើ*ក្នុងអំឡុងថ្ងៃនោះ៖ ការភ្ញាក់ឡើង ការមានកម្លាំងផលិតកម្ម ការធ្វើឲ្យអ្វីមួយចំនួនដំណើរការបាន ការបង្កើតអ្វីមួយ ការសម្អាតបន្ទប់ ការលាងឡានម៉ូតូ ការជួសជុលហ្វ្រាំង ការសរសេរកូដក្នុងកម្មវិធីកុំព្យូទ័រ ការមើលថែអ្នកឈឺ ឬក៏ការចម្អិនអាហារដ៏ឆ្ងាញ់ពិសា។ល។ ទាំងអស់នេះព្រះជាម្ចាស់បានប្រទានពរថាជាអ្វីដែលទ្រង់សព្វព្រះហរទ័យឲ្យអ្នករួមការងារ និងរួមចំណែករបស់ទ្រង់ធ្វើ។

## ការងារតាមរយៈព្រះគុណ

បន្ទាប់ពីគាត់បានយល់ដោយមានទេវវិទ្យានៃការធ្វើការយ៉ាងរឹងមាំ នោះចំណុចមួយទៀតដែលយើងខ្ញុំនឹងចង្អុលបង្ហាញទៅកាន់គាត់គឺអំពីការព្រមានមួយចំនួនទាក់ទងទៅនឹងភាពខ្ជិល។ ឧទាហរណ៍៖ សាវ័ក ប៉ុលបានមានប្រសាសន៍នៅក្នុងកណ្ឌគម្ពីរ (២ថែស្សាឡូនីច ៣:១០) ថា «បើអ្នកណាមិនចង់ធ្វើការ មិនត្រូវទាំងឲ្យអ្នកនោះបរិភោគផង»។

បន្ទាប់មក ទំនងចំណុចចុងក្រោយដែលយើងខ្ញុំនឹងលើកឡើង ទាក់ទងនឹងការខំធ្វើការមានន័យថា គាត់ត្រូវចាប់យកឱកាសនៅពីមុខខ្លួន តាមរយៈព្រះគុណរបស់ព្រះជាម្ចាស់ដែលមាននៅក្នុងគាត់។ យើងខ្ញុំនឹងចង្អុលបង្ហាញនូវខគម្ពីរដែលយើងខ្ញុំពេញចិត្តមួយគឺកណ្ឌគម្ពីរ (១កូរិនថូស ១៥:១០) «ប៉ុន្តែ ដែលខ្ញុំបានជាយ៉ាងណា នោះគឺបានដោយព្រះគុណនៃព្រះទេ ហើយព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំ នោះមិនមែនជាអសារឥតការឡើយ ដ្បិត



50 QnA John Piper Final 1.5.indd 181 25/01/2024 09:23:04 AM

ខ្ញុំបានខំធ្វើការលើសជាងអ្នកទាំងនោះសន្ធឹកណាស់ ប៉ុន្តែ មិនមែនជាខ្ញុំ គឺជាព្រះគុណនៃព្រះ ដែលសណ្ឋិតនៅនឹងខ្ញុំវិញ»។

យើងខ្ញុំនឹងព្យាយាមជួយគាត់ឲ្យរកឃើញរបៀបនៃការអនុវត្តព្រះហឫទ័យរបស់ព្រះអង្គក្នុងតួនាទីនៃការធ្វើការយ៉ាងនឿយហត់ ក្នុងរបៀបដែលថា ក្នុងពេលដែលគាត់កំពុងតែធ្វើនោះ និងបន្ទាប់ពីគាត់បានធ្វើវាហើយ នោះគាត់ក៏នឹងមានអារម្មណ៍ដោយដឹងថា ព្រះជាម្ចាស់កំពុងតែធ្វើការនៅក្នុងយើងខ្ញុំ។ ដូចដែលសាវ័ក ប៉ុល បានមានប្រសាសន៍ថា «នោះក៏ចូរខំប្រឹងឲ្យលើសទៅទៀតផង ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា» (ភីលីព ២:១២-១៣)។ នេះគឺជាអ្វីដែលយើងខ្ញុំគិតថា ផ្តល់ជូននូវអត្ថន័យនៃការធ្វើការក្នុងជីវិតនេះដ៏ខ្ពស់បំផុត។

ដូច្នេះ នេះគឺជាការប្រឹក្សារបស់យើងខ្ញុំ។ យើងខ្ញុំនឹងមើលម្តងមួយៗ ហើយព្យាយាមវែកញែកអំពីតម្រូវការដ៏ពិតនៃបុគ្គលនោះ។ ប៉ុន្តែ នោះគឺជាគោលការណ៍ពីព្រះគម្ពីរដែលយើងខ្ញុំនឹងជីកមើលជាមួយនឹងគាត់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 182 25/01/2024 09:23:04 AM

# សំណួរទី៣១៖
# តើខ្ញុំដឹងថាព្រះជាម្ចាស់បានត្រាស់ហៅឲ្យខ្ញុំធ្វើជាគ្រូគង្វាលដោយរបៀបណា?

មានបុគ្គលម្នាក់បានផ្ញើសារមកកាន់ខាងយើងថា “ខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំឲ្យធ្វើជាគ្រូគង្វាល។ តើខ្ញុំគួរស្វែងរកចំណុចអ្វី ដើម្បីជាអំណះអំណាងពីហេតុផលនៃការត្រាស់ហៅមួយនេះ?”

នេះគឺជាសំណួរដ៏ល្អមួយ។ ខាងក្រោមនេះគឺជាចម្លើយត្រួសៗ៖

## ១) បន្តសង្កេតមើលការប្រាថ្នាដ៏ខ្លាំងមួយនេះដែលបន្តកើតឡើងម្តងហើយម្តងទៀត

និយាយជាទូទៅ នេះមិនមែនជាការឆេះឆួលដែលជាការប្រាថ្នាដែលបានកើតឡើងបន្ទាប់ពីបានឮនរណាម្នាក់បានមានប្រសាសន៍ដែលបានលើកទឹកចិត្តនោះទេ។ ការត្រាស់ហៅមួយនេះបន្តវិលត្រឡប់មកវិញម្តងហើយម្តងទៀតឥតឈប់ឈរ—ជាការប្រាថ្នាដែលលោកអ្នកមិនអាចបោះបង់ចោលបាន។ វាជាការត្រឹមត្រូវទេក្នុងការប្រាថ្នាចង់ធ្វើជាអ្នកត្រួតត្រាយោងតាមកណ្ឌគម្ពីរ (១ធីម៉ូថេ ៣:១)។

## ២) បន្តសង្កេតរកអំណោយទានមួយចំនួនទៀតដែលជាតម្រូវការក្នុងព័ន្ធកិច្ចនៃគ្រូគង្វាល

ឧទាហរណ៍៖ អំណោយទានដែលតម្រូវឲ្យមានការបង្រៀន។ និងការមានប្រាជ្ញាមួយប្រភេទក្នុងការទំនាក់ទំនងជាមួយនឹងមនុស្សម្នា។ ចូរបណ្តុះបណ្តាលអំណោយទានទាំងនោះចុះ។ សូមធ្វើនូវអ្វីដែលលោកអ្នកអាចធ្វើបានក្នុងការបង្ហាត់បង្រៀនអំណោយទានទាំងនោះ។



50 QnA John Piper Final 1.5.indd 183 25/01/2024 09:23:04 AM

### ៣) ស្វែងរកអំណោះអំណាងពីអ្នកដទៃ

នៅពេលដែលបុគ្គលណាម្នាក់លើកខ្លួនជាគ្រូគង្វាលក្នុងក្រុមជំនុំ ខណៈពេលដែលក្រុមជំនុំមិនបានគាំទ្រ នោះមានន័យថាគាត់ទំនងជាកំពុងតែគិតខុសហើយ។ គាត់ទំនងជាមិនសមជាធ្វើជាអ្នកត្រួតត្រាទេ។ អាចមានករណីលើកលែងខ្លះៗត្រង់ថាអាចមានជាអំណោះអំណាង ប៉ុន្តែអំណោះអំណាងនោះមិនទទួលបានការគាំទ្រពីនរណាម្នាក់ឡើយនៅក្នុងក្រុមជំនុំ។ ប៉ុន្តែ ជាទូទៅក្រុមជំនុំគឺជាទីកន្លែងដែលបង្ហាញអំពីអំណោះអំណាងទាំងនោះដែលត្រូវបានប្រទានទៅកាន់អ្នកត្រួតត្រា និងគ្រូគង្វាល។

ដែលនេះមានន័យថា លោកអ្នកដឹកនាំក្រុមតូច ព្យាយាមលើកទឹកចិត្តអ្នកដទៃ មនុស្សម្នាទទួលបានជំនួយ («លោកពិតជាបានលើកទឹកចិត្តខ្ញុំមែន!») ហើយពួកគេក៏បន្តមករកលោកវិញដែរ។ ពួកគេអាចទទួលបានទៀត។ ពួកគេបានសង្កេតឃើញថា វត្តមានរបស់លោកអ្នកបានផ្តល់ជាជីវិតមិនមែនដកយកជីវិតទេ។

ប្រសិនបើមនុស្សម្នាចាប់ផ្តើមដើរចេញពីលោកអ្នកជាជាងចូលមកជិតលោកអ្នក ដើម្បីស្តាប់លោកអ្នក ឬក៏និយាយ ឬក៏សន្ទនាជាមួយនឹងលោកអ្នក នោះទំនងជាមានន័យថាលោកអ្នកគួរគិត «អើ... តើខ្ញុំអាចផ្តល់ជំនួយដល់សមាជិកក្រុមជំនុំដោយរបៀបណាប្រសិនបើពួកគាត់មិនចង់ទទួលជំនួយពីខ្ញុំផង?»។ ដូច្នេះ ចំណុចទី៣គឺថាអំណោះអំណាង។

### ៤) បន្ទាប់មក ខ្ញុំនឹងស្វែងរកកាលៈទេសៈ និងពេលវេលា ដើម្បីបង្ហាញជាអំណោះអំណាងនៃការត្រាស់ហៅនោះ នៅពេលដែលឱកាសផ្តល់ឲ្យមាន

សូមបញ្ជ្រាបជីវិតលោកអ្នកដោយសេចក្តីអធិស្ឋាន ស្រោចស្រង់ជីវិតលោកអ្នកដោយព្រះបន្ទូល ហើយនាំឲ្យមានចលនា។ ហើយនៅពេលដែលក្លិនដែលនឹងផុសចេញពីឆ្នាំងសម្លនោះក្នុងផ្លូវណាមួយ នោះចូរលតាមចុះ។



50 QnA John Piper Final 1.5.indd 184 25/01/2024 09:23:04 AM

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 185 25/01/2024 09:23:05 AM

50 QnA John Piper Final 1.5.indd 186 25/01/2024 09:23:05 AM

## សំណួរទី៣២៖
# តើខ្ញុំរង់ចាំព្រះជាម្ចាស់បានដោយរបៀបណា?

*ព្រះជាម្ចាស់សព្វព្រះទ័យធ្វើការសម្រាប់អស់អ្នកដែលរង់ចាំព្រះអង្គ។ ដូច្នេះ តើយើងរង់ចាំព្រះជាម្ចាស់បានដោយរបៀបណា? តើការរង់ចាំព្រះជាម្ចាស់មានន័យថាយើងមិនធ្វើអ្វីសោះមែនឬ? តើពេលណាយើងឈប់រង់ចាំ ហើយចាប់ផ្តើមមានសកម្មភាព? ទាំងនោះគឺជាសំណួរដ៏សំខាន់ៗដែលលោកគ្រូចន ផាយភ័រ បានអធិប្បាយលើកណ្ឌគម្ពីរ អេសាយ ៦៤:១-៤ ជាសេចក្តីអធិប្បាយដែលគាត់បានអធិប្បាយតាំងពីឆ្នាំ១៩៨២។ ខាងក្រោមនេះជាអ្វីដែលគាត់បានមានប្រសាសន៍។*

នៅក្នុងអត្ថន័យមួយ ព្រះជាម្ចាស់ធ្វើការសម្រាប់មនុស្សគ្រប់គ្នា។ ព្រះជាម្ចាស់ទ្រង់ធ្វើឲ្យថ្ងៃរបស់ទ្រង់រះឡើង បំភ្លឺទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិត ហើយទ្រង់បង្អុរឲ្យភ្លៀងធ្លាក់មក លើទាំងមនុស្សល្អ និងមនុស្សអាក្រក់ផង។ ព្រះអង្គធ្វើឲ្យមានរដូវសាបព្រោះ និងរដូវចម្រូត សូម្បីតែសម្រាប់អស់អ្នកដែលបះបោរប្រឆាំងព្រះអង្គក៏ដោយ (ម៉ាថាយ ៥:៤៥)។ ព្រះជាម្ចាស់ធ្វើការសម្រាប់របស់សព្វសារពើទាំងអស់ដែលទ្រង់បានបង្កើតមក ហើយគ្រប់ទាំងអស់គួរនាំយើងឲ្យមានការប្រែចិត្ត។ ប៉ុន្តែ នៅក្នុងបរិបទរបស់យើង កិច្ចការដែលយើងសំដៅទៅលើគឺមិនមែនជាព្រះគុណទូទៅដែលបានផ្តល់មកសម្រាប់គ្រប់គ្នានោះទេ ប៉ុន្តែជាព្រះគុណពិសេសដែលព្រះអង្គបានប្រទានមកសម្រាប់អស់អ្នកដែលទទួលបានការរៀបចំយ៉ាងជាក់លាក់តែប៉ុណ្ណោះ។

> «ហើយភ្នែកមិនដែលឃើញព្រះឯណាក្រៅពីទ្រង់
> ដែលធ្វើការជំនួសអ្នកដែលសង្ឃឹមដល់ទ្រង់ឡើយ» (អេសាយ ៦៤:៤)។



50 QnA John Piper Final 1.5.indd 187 25/01/2024 09:23:05 AM

កិច្ចការដែលបានលើកឡើងនៅទីនេះបញ្ជាក់យ៉ាងច្បាស់ថា មិនមែនគ្រាន់តែជាកិច្ចការនៃការបង្កើត និងការថែរក្សាទុកនោះទេ។ វាមិនមែនគ្រាន់តែជាការផ្គត់ផ្គង់ដល់តម្រូវការរបស់ធម្មជាតិមួយចំនួនដែលព្រះអង្គធ្វើសម្រាប់គ្រប់គ្នានោះទេ។ ផ្ទុយទៅវិញ វាជាការវិនិយោគរបស់ព្រះជាម្ចាស់ដ៏គ្មានដែនកំណត់ អំណាចនៃអធិបតេយ្យភាពក្នុងការធ្វើគ្រប់អ្វីៗដែលរាស្ត្ររបស់ព្រះអង្គត្រូវការ ដើម្បីជាប្រយោជន៍ដល់ពួកគេ។ ហើយតើព្រះអង្គធ្វើសម្រាប់អ្នកណា? គឺព្រះអង្គធ្វើ*សម្រាប់អស់អ្នកដែលរង់ចាំទ្រង់*។

ដូច្នេះ សំណួរដ៏ធំបំផុតឥឡូវនេះគឺថា តើនោះជាអ្វី? តើលោកអ្នកធ្វើការនោះបានដោយរបៀបណា? ហើយខ្ញុំចង់ព្យាយាមបង្ហាញលោកអ្នកពីក្នុងកណ្ឌគម្ពីរអេសាយអំពីរបៀបដែលលោកអ្នកអាចចេះរង់ចាំព្រះអម្ចាស់បាន។

## សូមរង់ចាំ ហើយអធិស្ឋាន

បណ្ដាជនដែលហោរា អេសាយ កំពុងតែមានប្រសាសន៍ទៅកាន់គឺកំពុងមានបញ្ហា៖ ពួកគាត់ស្ថិតក្នុងគ្រោះថ្នាក់ពីសត្រូវរបស់ខ្លួន គឺសាសន៍អាសស៊ើរ ហើយក្រោយមកទៀតគឺពួកសាសន៍បាប៊ីឡូន។ ហើយឥឡូវនេះ គ្រោះថ្នាក់ដែលព្រះអង្គទតឃើញគឺមិនសូវពាក់ព័ន្ធខ្លាំងជាមួយពួកអាសស៊ើរ និងពួកក្រុងបាប៊ីឡូននោះទេ ប៉ុន្តែគឺជាសេចក្តីល្បួងក្នុងការរត់ទៅស្រុកអេស៊ីព្ទ ដើម្បីរកគេជួយជាជាងស្វែងរកជំនួយពីព្រះជាម្ចាស់ទៅវិញ។ ជាជាងរង់ចាំជំនួយរបស់ព្រះជាម្ចាស់ ទ្រង់ទតឃើញសេចក្តីល្បួងដែលបានលេចឡើងយ៉ាងធំ ដែលពួកគាត់ព្យាយាមរក គឺជំនួយពីមនុស្ស។ ហេតុដូច្នេះហើយបានជាព្រះអង្គមានបន្ទូលនៅក្នុងកណ្ឌគម្ពីរ អេសាយ ៣១:១ ថា៖

> វេទនាដល់ពួកអ្នកដែលចុះទៅឯស្រុកអេស៊ីព្ទដើម្បីរកគេជួយ
> ព្រមទាំងពឹងដល់សេះ
> ហើយទុកចិត្តនិងរទេះចម្បាំង ដោយព្រោះគេមានជាច្រើន



50 QnA John Piper Final 1.5.indd 188 25/01/2024 09:23:05 AM

ហើយនិងពលសេះផង ដោយព្រោះគេមានកម្លាំងណាស់
ឥតសង្ឃឹមដល់ព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល
ឬស្វែងរកព្រះយេហូវ៉ាសោះ!

ដូច្នេះ ចំណុចដំបូងគេបង្អស់ក្នុងការរង់ចាំព្រះជាម្ចាស់គឺមានន័យដូចនេះថា៖ មុនពេលលោកអ្នកខិតខំប្រឹងប្រែងដោះស្រាយបញ្ហារបស់លោកអ្នកផ្ទាល់ ឬក៏ជួលនរណាម្នាក់ឲ្យមកជួយ *សូមអធិស្ឋានជាមុនសិន*។ ចូរស្វែងរកការប្រឹក្សាមកពីព្រះជាម្ចាស់។ តើអ្វីជារបៀបរបស់ព្រះអង្គក្នុងការដោះស្រាយបញ្ហា ហើយនាំលោកអ្នកចេញពីបញ្ហានេះ? នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង ១០៦:១៣ បានចែងថា៖ «តែមិនយូរប៉ុន្មាន ក៏ភ្លេចកិច្ចការរបស់ទ្រង់ទៅ ហើយមិនបានរង់ចាំស្តាប់សេចក្តីដំបូន្មានរបស់ទ្រង់ទេ»។

កិច្ចការដំបូងគេក្នុងការរង់ចាំគឺជាការអធិស្ឋាន—មុនពេលយើងធ្វើអ្វីមួយក្នុងការដោះស្រាយបញ្ហារបស់យើង។ ហើយខ្ញុំដឹងថា ប្រសិនបើលោកអ្នកដូចជាខ្ញុំដែរ នោះលោកអ្នកក៏ធ្លាប់ឆ្លងកាត់ការខិតខំប្រឹងប្រែងជាច្រើន ហើយក្នុងរយៈពេលមួយម៉ោងលោកអ្នកនិយាយថា «ខ្ញុំភ្លេចអធិស្ឋាន»។ ហើយយើងគួរតែខិតខំធ្វើការក្នុងការផ្លាស់ប្រែទម្លាប់នៃការឈប់ម្តងហើយម្តងទៀតៗនេះ ដើម្បីអធិស្ឋានសិន។ ខ្ញុំគិតថា នេះគឺជាអ្វីដែលសាវ័ក ប៉ុល ចង់សំដៅទៅលើនៅពេលដែលគាត់បានលើកឡើងថា «ចូរអធិស្ឋានឥតឈប់ឈរ» (១ថែស្សាឡូនិច ៥:១៧)។ មុនពេលលោកអ្នកធ្វើអ្វីមួយ ក្នុងគ្រប់ការតូចៗទាំងអស់នៅក្នុងជីវិតរបស់លោកអ្នក—គ្រប់ទាំងការសម្ភាសន៍ រាល់គ្រប់ទាំងការជួបជុំ—ចូរអធិស្ឋានទៅកាន់ព្រះអង្គសិន។ «តើការនេះនឹងកើតឡើងយ៉ាងដូចម្តេច ប្រសិនបើទូលបង្គំពឹងលើព្រះអង្គ? តើព្រះអង្គចង់ឲ្យទូលបង្គំធ្វើអ្វី?» បន្ទាប់មក សូមធ្វើតាមអ្វីដែលព្រះអង្គមានព្រះបន្ទូលចុះ។

យើងទាំងអស់គ្នាប្រៀបដូចជាអ្នកជម្ងឺ។ សេចក្តីអធិស្ឋានប្រៀបដូចជាការយកទូរស័ព្ទតេទៅគ្រូពេទ្យ ហើយប្រាប់ថា «ខ្ញុំមានបញ្ហាហើយ ខ្ញុំកំពុង



50 QnA John Piper Final 1.5.indd 189 25/01/2024 09:23:05 AM

ឈឺ។ តើខ្ញុំគួរធ្វើដូចម្ដេច?»។ មុនពេលលោកអ្នកលេបថ្នាំណាមួយ ឬហាត់ប្រាណ សូមលើកទូរស័ព្ទតេទៅកាន់គ្រូពេទ្យសិនចុះ។

បន្ទាប់មក គ្រូពេទ្យទំនងជាប្រាប់លោកអ្នកថា «ចូរសម្រាកសិន កុំធ្វើអ្វីឡើយ»។ ឬគាត់ទំនងជាប្រាប់ថា «ចូរលេបថ្នាំ ហើយហាត់ប្រាណចុះ»។ ដូច្នេះ ការណែនាំទាំងពីរនេះពីព្រះអម្ចាស់នាំយើងចូលនៅក្នុងរបៀបពីរខុសគ្នានៃការរង់ចាំ។ យើងមិនឈប់រង់ចាំបន្ទាប់ពីយើងទទួលបានការត្រាស់ហៅនោះទេ៖ យើងនៅបន្តរង់ចាំ។ មានការរង់ចាំពីរប្រភេទខុសគ្នា។ ចូរយើងមើលភាពខុសគ្នាទាំងពីរនេះម្ដងមួយៗចុះ។

## សូមរង់ចាំ ហើយសម្រាក

ចំណុចទី១នេះ គឺប្រសិនបើគ្រូពេទ្យប្រាប់ថា «ចូរសម្រាកសិនចុះ»។ នៅក្នុងកណ្ឌគម្ពីរ អេសាយ ៣០:១៥-១៦ មានចែងយ៉ាងដូចនេះ៖

ព្រះជាម្ចាស់មានបន្ទូលទៅបណ្ដាជនថា៖

«ឯងរាល់គ្នានឹងបានសង្គ្រោះដោយវិលមកវិញ

ហើយផ្អាកសម្រាក ឯងរាល់គ្នានឹងមានកម្លាំងដោយនៅតែស្ងៀម ហើយមានសេចក្ដីទុកចិត្ត”

តែឯងរាល់គ្នាមិនចូលចិត្តទេ គឺបានសបឆ្លើយថា៖

“ទេ យើងនឹងជិះសេះរត់ទៅ

ដូច្នេះ ឯងរាល់គ្នានឹងត្រូវរត់ទៅមែន ហើយឯងថា យើងនឹងជិះសត្វលឿនដែរ ដូច្នេះគេដែលដេញតាមឯងនឹងបានលឿនដូចគ្នា»។

និយាយម៉្យាងទៀត ព្រះជាម្ចាស់កំពុងនិយាយទូរស័ព្ទថា «ចូរគ្រាន់តែអង្គុយចុះសិន យើងនឹងធ្វើការនោះសម្រាប់ឯង។ កុំខំពេក ហើយសម្រាកចុះ យើងនឹងធ្វើជាកម្លាំងដល់ឯង»។ ប៉ុន្តែ ពួកគាត់មិនធ្វើតាមនោះទេ។ ពួកគាត់ចង់ធ្វើសមយុទ្ធ ដើម្បីទទួលបានជ័យជម្នះលើពួកគេផ្ទាល់សម្រាប់ភាពរុង



50 QnA John Piper Final 1.5.indd 190 25/01/2024 09:23:06 AM

រឿងដល់ទ័ពសេះ និងទ័ពរទេះចម្បាំងរបស់ពួកគាត់វិញ។ ពេលខ្លះ យើងត្រូវតែស្ម័គ្រចិត្តលើកទូរស័ព្ទក្នុងការទទួលយកដំណឹងខកចិត្តៈ «នៅស្ងៀម»។ យើងត្រូវតែស្ដាប់អ្វីដែលលោកម៉ូសេបានលើកឡើងទៅកាន់បណ្ដាជនខណៈពេលដែលពួកគេហៀបនឹងឆ្លងសមុទ្រក្រហមៈ

«កុំខ្លាចអី ឈប់សិន ចាំមើលសេចក្ដីសង្គ្រោះរបស់ព្រះយេហូវ៉ា ដែលទ្រង់នឹងប្រោសដល់អ្នករាល់គ្នា នៅថ្ងៃនេះ ព្រះយេហូវ៉ាទ្រង់នឹងច្បាំងជំនួសអ្នករាល់គ្នា ឯអ្នករាល់គ្នានឹងនៅតែស្ងៀមវិញ» (និក្ខមនំ ១៤:១៣-១៤)។

ដូច្នេះ ចំណុចទី២ក្នុងការរង់ចាំព្រះអម្ចាស់គឺមានន័យដូចនេះៈ បន្ទាប់ពីលោកអ្នកបានអធិស្ឋានទៅកាន់ព្រះដ៏ជាគ្រូពេទ្យរួចហើយ ហើយព្រះអង្គមានបន្ទូលថា «ឲ្យនៅស្ងៀម» នោះចូរនៅស្ងៀម ហើយសម្រាកចុះ។

## សូមរង់ចាំ ហើយធ្វើចុះ

ប៉ុន្តែ នៅមានចំណុចទី៣នៃការរង់ចាំព្រះអម្ចាស់។ ព្រះអង្គទំនងជាមានបន្ទូលថា «ចូរក្រោកឡើង ហើយហាត់ប្រាណ និងលេបថ្នាំចុះ»។ ឬក៏ដើម្បីត្រឡប់ទៅឯបរិបទនៅក្នុងព្រះគម្ពីរសញ្ញាចាស់វិញ ព្រះអង្គទំនងជាមានបន្ទូលថា «ចូរទៅឯសមរភូមិ ហើយច្បាំងចុះ»។

គ្រួសាររបស់ខ្ញុំបានអានកណ្ឌគម្ពីរ ២សាំយ៉ូអែល សម្រាប់ជាការរៀនជាមួយគ្នានៅពេលព្រឹក ហើយកាលពីរ-បីថ្ងៃកន្លងទៅនេះ យើងបានអានកណ្ឌគម្ពីរ ២សាំយ៉ូអែល ៥:១៩។ នៅត្រង់នេះ ស្ថានភាពគឺថា ស្ដេច ដាវីឌទើបតែបានសោយរាជ្យក្រោយពីស្ដេច សូល បានសោយទិវង្គត ហើយពួកសាសន៍ភីលីស្ទីនកំពុងឡោមព័ទ្ធ។ នេះគឺជាអ្វីដែលទ្រង់បានធ្វើ «ដាវីឌទូលសួរដល់ព្រះយេហូវ៉ា»។ ទ្រង់បានរង់ចាំ។ «តើត្រូវឲ្យទូលបង្គំឡើងទៅច្បាំងនឹងពួកភីលីស្ទីនឬទេ? តើទ្រង់នឹងប្រគល់គេមកក្នុងកណ្ដាប់ដៃរបស់ទូលបង្គំឬអី?» *រង់ចាំសិន*។ ហើយចម្លើយគឺថា «ព្រះយេហូវ៉ាទ្រង់មានបន្ទូល



50 QnA John Piper Final 1.5.indd 191 25/01/2024 09:23:06 AM

តបថា ចូរឡើងទៅចុះ ដ្បិតអញនឹងប្រគល់ពួកភីលីស្ទីនមកក្នុងដៃឯងជាពិតប្រាកដ»។ ដូច្នេះ ព្រះបន្ទូលមកកាន់ស្តេច ដាវីឌ មិនមែនឲ្យ «នៅស្ងៀម» ទៀតទេ។ ប៉ុន្តែ ព្រះបន្ទូលមកកាន់ស្តេច ដាវីឌ គឺឲ្យទៅ «ច្បាំង»។ ស្តេច ដាវីឌ មិនបានដោះស្រាយបញ្ហាដោយដៃផ្ទាល់របស់ទ្រង់ឡើយ។ ទ្រង់បានរង់ចាំ។

ប៉ុន្តែ នេះជាខ្លឹមសារសំខាន់។ ឥឡូវ សូមព្យាយាមយល់ឲ្យបានច្បាស់ ដោយសារយើងងាយនឹងគិតថា ការរង់ចាំគឺមានន័យថាជាការនៅស្ងៀម ប៉ុន្តែនៅពេលយើងចាប់ផ្តើមមានសកម្មភាព—រៀបចំសេចក្តីអធិប្បាយ ឬ រៀបចំមេរៀន ទៅធ្វើការ រៀបចំរបាយការណ៍ នៅដល់យប់ជ្រៅ ដើម្បីធ្វើការ ហើយធ្វើការទៀត—នោះយើងមិនត្រូវរង់ចាំទៀតនោះទេ។ នេះមិនមាននៅក្នុងករណីលើកលែងនេះឡើយ—ការនេះផ្លាស់ប្រែជីវិតទាំងអស់—ដោយសារក្នុងអត្ថន័យមួយនៃការរង់ចាំគឺជាការធ្វើការ។ កណ្ឌគម្ពីរ សុភាសិត ២១:៣១ បានចែងដូចនេះថា៖

«គេត្រៀមសេះទុកសម្រាប់ថ្ងៃសឹកសង្គ្រាម តែការដែលមានជ័យជម្នះនោះស្រេចនៅព្រះយេហូវ៉ាទេ»។

តើលោកអ្នកឃើញពីការទាក់ទងគ្នានៃការនោះសម្រាប់អ្នកចម្បាំងដែរឬទេ? វាមានន័យថានៅពេលដែលព្រះអម្ចាស់មានបន្ទូលថា «ចូរទៅ» ស្តេច ដាវីឌ មិនបានលែងរង់ចាំទៀតទេ។ ទ្រង់បានចេញទៅច្បាំងដោយមានចិត្តរំពឹងទុក ដោយដឹងថា «បាទ ខ្ញុំនឹងប្រយុទ្ធឲ្យអស់ពីកម្លាំងរបស់ខ្ញុំ ប៉ុន្តែខ្ញុំត្រូវតែរង់ចាំលើព្រះមួយអង្គដែលព្រះហស្តរបស់ទ្រង់តែមួយប៉ុណ្ណោះដែលអាចប្រទានជ័យជម្នះដល់ខ្ញុំបាន»។ មិនថាលោកអ្នកខិតខំធ្វើការខ្លាំងប៉ុណ្ណាក៏ដោយ ក៏លោកអ្នកគួរតែមានចិត្តនៃការរង់ចាំ ចិត្តនៃការរំពឹង ចិត្តដែលថាតាមរយៈសកម្មភាពទាំងនេះ នោះនឹងមានពន្លឺមកពីស្ថានសួគ៌ក្នុងការធ្វើកិច្ចការដ៏អស្ចារ្យមួយ។ នេះគឺជារបៀបដែលអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើង



50 QnA John Piper Final 1.5.indd 192 25/01/2024 09:23:06 AM

បានរៀបរាប់ថា៖

“គ្មានស្តេចណាបានសង្គ្រោះ ដោយមានពលទ័ពច្រើនឡើយ

មនុស្សខ្លាំងពូកែក៏មិនបានរួច ដោយមានកម្លាំងយ៉ាងខ្លាំងនោះដែរ

ឯសេះ នោះឥតប្រយោជន៍នឹងពឹងឲ្យបានសាន្តត្រាណ ក៏មិនអាចនឹងជួយឲ្យអ្នកណារួចដោយសារកម្លាំងដ៏ខ្លាំងរបស់វាដែរ....

ព្រលឹងនៃយើងខ្ញុំសង្ឃឹមដល់ព្រះយេហូវ៉ា

ទ្រង់ជាជំនួយ ហើយជាខែលរបស់យើងខ្ញុំ

ដ្បិតចិត្តយើងខ្ញុំរីករាយឡើងក្នុងទ្រង់

ពីព្រោះយើងខ្ញុំបានទុកចិត្តដល់ព្រះនាមបរិសុទ្ធរបស់ទ្រង់ហើយ

ឱព្រះយេហូវ៉ាអើយ សូមឲ្យសេចក្តីសប្បុរសរបស់ទ្រង់សណ្ឋិតនៅលើយើងខ្ញុំ

តាមដែលយើងខ្ញុំបានសង្ឃឹមដល់ទ្រង់” (ទំនុកតម្កើង ៣៣:១៦-១៧, ២០-២២)។

ប្រសិនបើព្រះអម្ចាស់ណែនាំយើងក្នុងការចាត់វិធានការប្រុងប្រយ័ត្នដែលជាក់លាក់ជាងមុន ដូចជាការចាក់សោទ្វារនៅពេលយប់ សូមកុំគិតថា លោកអ្នកអាចឈប់រង់ចាំព្រះអម្ចាស់ទៀតឡើយ។ ដ្បិតកណ្ឌគម្ពីរ ទំនុកតម្កើង ១២៧:១ បានចែងថា៖

“បើគ្មានព្រះយេហូវ៉ាថែរក្សាទីក្រុង នោះពួកយាមល្បាតគេចាំយាមជាឥតប្រយោជន៍ដែរ”។

សូម្បីតែយើងដែលជាអ្នកយាម កំពុងតែបំពេញកាតព្វកិច្ចរបស់យើងក៏ដោយ ក៏យើងត្រូវរង់ចាំព្រះអម្ចាស់ដែរ ដ្បិតព្រះអង្គតែមួយអង្គប៉ុណ្ណោះដែលនាំមកនូវសុវត្ថិភាព។ ដូច្នេះ ចំណុចទី៣នៃរបៀបនៃការរង់ចាំព្រះអម្ចាស់គឺដូចនេះ៖ សូម្បីតែនៅពេលព្រះអម្ចាស់មានបន្ទូលថា “ធ្វើចុះ” ក៏យើងនៅតែប្រព្រឹត្តដោយទុកចិត្តលើកិច្ចការរបស់ព្រះអង្គ ហើយយើងរង់ចាំព្រះអម្ចាស់



50 QnA John Piper Final 1.5.indd 193 25/01/2024 09:23:06 AM

ដោយមានចិត្តរំពឹងទុក ទោះបីជាការងាររបស់យើងងាយរងគ្រោះ និងខ្សោយក្តី ក៏លទ្ធផលចុងក្រោយនៃការទាំងអស់ដែលយើងធ្វើគឺស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ដែរ។ ហើយត្រង់ចំណុចនេះ យើងរង់ចាំនៅក្នុងគ្រប់ទាំងកិច្ចការរបស់យើង។

## សូមមើលព្រះជាម្ចាស់ធ្វើការ

សរុបសេចក្តីមក សូមអនុញ្ញាតឲ្យខ្ញុំសង្ខេបនូវចំណុចទាំងបីនេះ៖

១. នៅពេលដែលលោកអ្នកស្ថិតក្រោមកាលៈទេសៈដែលមានសម្ពាធ ដែលកាលៈទេសៈនោះនាំឲ្យលោកអ្នកមានអារម្មណ៍ថា មានអ្វីមួយត្រូវធ្វើឲ្យហើយ—មានអ្វីមួយដែលត្រូវធ្វើ ដើម្បីឲ្យមានសុវត្ថិភាព ឬក៏មានអ្វីមួយដែលមានអ្នកផ្សេងមកជួយ—*ចូររង់ចាំព្រះអម្ចាស់សិន* ដែលនេះមានន័យថា *លោកអ្នកត្រូវតែអធិស្ឋាន*។ មុនពេលលោកអ្នកធ្វើអ្វីមួយ សូមស្វែងរកព្រះអម្ចាស់ សូមស្វែងរកការប្រឹក្សាពីព្រះអង្គសិន។ តើព្រះអង្គនឹងឲ្យលោកអ្នកធ្វើអ្វី ប្រសិនបើមាន?

២. ប្រសិនបើព្រះអម្ចាស់មានបន្ទូលថា «ចូរអង្គុយចុះ ហើយសម្រាកសិន» ប្រសិនបើព្រះអម្ចាស់មានបន្ទូលថា «យប់នេះ កុំទៅព្រះវិហារ ដើម្បីប្រជុំពិភាក្សាគ្នាឡើយ៖ ចូរនៅផ្ទះ ហើយអធិស្ឋានចុះ។ យើងនឹងធ្វើការដែលល្អប្រសើរជាងការជជែករបស់ឯងផង»។ សូមកុំទៅឡើយ។

៣. ហើយប្រសិនបើព្រះអម្ចាស់មានបន្ទូលថា «ចូរទៅ ហើយជជែកឲ្យអស់ពីកម្លាំងរបស់អ្នកចុះ» ចូរកុំពឹងលើខ្លួនឯង តែចូរទៅចូលរួមចុះ។

ខ្ញុំសូមផ្តោតអត្ថន័យលើចំណុចទី២នេះ ខ្ញុំមិនមែនមានន័យថា វាជាការខ្ជិលច្រអូស ឬគេចពីកាតព្វកិច្ចនោះទេ។ ខ្ញុំមានន័យថា ពេលខ្លះ បទពិសោធន៍នៃការខកចិត្ត នៅពេលលោកអ្នកត្រៀមខ្លួនជាស្រេច នៅពេលលោកអ្នកគិតថាវាពឹងផ្អែកលើលោកអ្នកយ៉ាងខ្លាំង ហើយលោកអ្នកមាន



50 QnA John Piper Final 1.5.indd 194 25/01/2024 09:23:06 AM

ភាពឆេះឆួលយ៉ាងខ្លាំង នោះព្រះអម្ចាស់ទំនងជាមានបន្ទូលទៅលោកអ្នកថា «យប់នេះ ឯងគ្រាន់តែនៅផ្ទះ ហើយចាំមើលយើងធ្វើការជំនួសវិញ»។ ហើយលោកអ្នកមានការខកចិត្តបន្តិចបន្តួចដែរដោយសារលោកអ្នកបានរៀបចំផែនការទាំងស្រុងរួចហើយ។ ប៉ុន្តែ ព្រះអង្គសព្វព្រះហឫទ័យក្នុងការធ្វើ*ជំនួសលោកអ្នក* ដើម្បីឲ្យព្រះអង្គទទួលបានសិរីល្អ មិនមែនយើងនោះទេ។

ដូច្នេះ មិនថាយើងនៅស្ងៀម ហើយអង្គុយ ឬមិនថាយើងធ្វើការប៉ុណ្ណានោះទេ សូមឲ្យយើងមានគំនិតបែបនេះ៖ យើងរង់ចាំព្រះអម្ចាស់ ហើយយើងមានចិត្តរំពឹងថា បើទោះជាការងាររបស់យើងលំបាកប៉ុណ្ណាក៏ដោយ ក៏ការសម្រេចចុងក្រោយគឺស្ថិតនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ដែរ។ ហើយព្រះអង្គក៏សព្វព្រះទ័យធ្វើការសម្រាប់អស់អ្នកដែលរង់ចាំទ្រង់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 195 25/01/2024 09:23:07 AM

## សំណួរទី៣៣៖
# ខ្ញុំនឹងមិនបោះបង់ព្រះយេស៊ូវនោះទេ—ប៉ុន្តែ ខ្ញុំក៏ឆ្អែតឆ្អន់នឹងក្រុមជំនុំហើយ

*យើងទើបតែបាននិយាយអំពីក្រុមជំនុំនៅតាមតំបន់ ហើយអ្នកដឹកនាំនៅក្រុមជំនុំទាំងនោះដែលបានបរាជ័យ។ ដូច្នេះ តើលោកគ្រូមានគំនិតយ៉ាងដូចម្តេចចំពោះអស់អ្នកដែលលើកឡើងថា «ខ្ញុំនឹងមិនបោះបង់ព្រះយេស៊ូវនោះទេ ប៉ុន្តែខ្ញុំបានឃើញការបរាជ័យរបស់គ្រូគង្វាល ហើយខ្ញុំក៏ឆ្អែតឆ្អន់នឹងក្រុមជំនុំហើយ»? ខាងក្រោមនេះគឺជាការសន្ទនាវែកញែករកចម្លើយដ៏ខ្លីមួយ។*

*សួស្តីលោកគ្រូ! តើលោកគ្រូមានយោបល់ដូចម្តេចដែរចំពោះការលើកឡើងនេះ? «ខ្ញុំនឹងមិនបោះបង់ព្រះយេស៊ូវទេ ប៉ុន្តែ ខ្ញុំឆ្អែតនឹងក្រុមជំនុំហើយ។ ខ្ញុំមិនអាចទុកចិត្តលើការដឹកនាំបានទៀតទេ។ ខ្ញុំបានគោរពអ្នកដឹកនាំមួយចំនួនយ៉ាងខ្លាំង។ ហេតុដូច្នេះហើយបានជាខ្ញុំនឹងមិនដើរចេញពីព្រះយេស៊ូវនោះទេ ប៉ុន្តែខ្ញុំបានឆ្អែតហើយជាមួយនឹងចំណុចមួយចំនួននៃរចនាសម្ព័ន្ធនៅក្នុងជីវិតក្រុមជំនុំហើយ។*

### ការបោះបង់ព្រះយេស៊ូវ

ប្រសិនបើលោកអ្នកធ្វើដូចនោះ នោះមានន័យថា លោកអ្នកកំពុងតែដើរចេញពីព្រះយេស៊ូវហើយ។ហើយនេះគឺជាមូលហេតុដែលខ្ញុំលើកឡើងបែបនេះ៖ ការដែលលើកឡើងថា «ខ្ញុំស្រឡាញ់ព្រះយេស៊ូវ តែខ្ញុំមិនបានចុះចូលទៅនឹងព្រះបន្ទូលរបស់ទ្រង់ទេ» គឺជាការកុហក។ «បើអ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងកាន់តាមពាក្យខ្ញុំ» (យ៉ូហាន ១៤:២៣)។ ព្រះយេស៊ូវបានបង្កើតក្រុមជំនុំ។ ខ្ញុំមិនបានបង្កើតទេ ហើយសាវ័ក ប៉ុល ក៏មិនបានបង្កើតវាដែរ។ ព្រះយេស៊ូវជាអង្គដែលបានបង្កើតក្រុមជំនុំ។ ស្របតាមកណ្ឌគម្ពីរ



50 QnA John Piper Final 1.5.indd 197 25/01/2024 09:23:07 AM

អេភេសូរ ២:២០—ព្រះអង្គបានតាំងពួកសាវ័កជាគ្រឹះនៃក្រុមជំនុំ។ ហើយបន្ទាប់មក ទ្រង់បានសង់ក្រុមជំនុំជាមួយពួកហោរា គ្រូៗ គ្រូគង្វាល និងបានតែងតាំងឲ្យមានរចនាសម្ព័ន្ធនៃក្រុមជំនុំតាមតំបន់នៅក្នុងរូបកាយរបស់ព្រះគ្រីស្ទដែលយើងហៅថា ក្រុមជំនុំ។

## ព្រះគ្រីស្ទជាអង្គដែលបានបង្កើតក្រុមជំនុំ

នេះមិនមែនជាគំនិតរបស់មនុស្សនោះទេ។ មានអ្នកផ្សាយដំណឹងល្អជាច្រើនដែលជាអ្នកឡូយឆាយ ស្វាវ និងមានទំនោរឆ្វេងនិយម ដែលជាពួកអ្នកគិតថា ពួកគេអាចជំនួសអ្វីមួយក្នុងការរៀបចំក្រុមជំនុំ។ ជាការពិតណាស់ ខ្ញុំត្រូវតែមើលថា តើពួកគេកំពុងតែជំនួសឲ្យអ្វី ហើយសួរថា តើអ្នកពិតជាគ្រាន់តែកំពុងបង្កើតក្រុមជំនុំ ឬក៏កំពុងព្យាយាមបង្កើតក្រុមជំនុំមែន? ប្រសិនបើអ្នកកំពុងតែព្យាយាមបង្កើតក្រុមជំនុំ សូមគ្រាន់តែបង្កើតតាមរបៀបព្រះគម្ពីរបានហើយ។ សូមចាប់ផ្ដើមបង្កើតក្រុមជំនុំតាមរបៀបព្រះគម្ពីរ។ ហើយនោះមានន័យថា សូមស្ដាប់តាមចៅហ្វាយ ព្រះបន្ទូលរបស់ទ្រង់ និងពួកសាវ័ករបស់ទ្រង់តែប៉ុណ្ណោះ។

ដូច្នេះ ក្នុងការជ្រើសរើសយកព្រះយេស៊ូវជាជាងក្រុមជំនុំ នោះមានន័យថា លោកអ្នកកំពុងតែឲ្យតម្លៃលើគំនិតរបស់ខ្លួនលើសជាងព្រះគម្ពីរ ពីព្រោះព្រះគម្ពីរជាកន្លែងដែលយើងជួបព្រះយេស៊ូវ។ លោកអ្នកមិនអាចប្រឌិតរឿងអំពីព្រះយេស៊ូវបានទេ! លោកអ្នកមិនអាចប្រឌិតរឿងពីទ្រង់បានឡើយ។ ទ្រង់គឺជាព្រះយេស៊ូវនៃព្រះគម្ពីរ ឬក៏ជាព្រះយេស៊ូវនៃក្ដីស្រមៃរបស់លោកអ្នកដែរ។ ប្រសិនបើព្រះអង្គជាព្រះនៃព្រះគម្ពីរ សូមលោកអ្នកបានទទួលយកទ្រង់ទាំងស្រុងចុះ។ លោកអ្នកមិនអាចកាត់ព្រះយេស៊ូវជាបំណែកតូចៗបានទេ។ ហើយព្រះយេស៊ូវទាំងមូលនេះឯងដែលជាអង្គដែលស្រឡាញ់ក្រុមជំនុំ។ ព្រះអង្គបានសុគតសម្រាប់ក្រុមជំនុំ។



50 QnA John Piper Final 1.5.indd 198 25/01/2024 09:23:07 AM

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ

50 QnA John Piper Final 1.5.indd 200 25/01/2024 09:23:07 AM

## សំណួរទី៣៩៖

# ខ្ញុំអស់កម្លាំង ហើយរវល់—តើខ្ញុំរកពេល អានព្រះគម្ពីរបានដោយរបៀបណា?

មានពេលវេលាដែលធ្វើឲ្យជីវិតយើងធុញថប់ នៅពេលដែលវាហាក់បីដូចជាអស់កម្លាំង និងរវល់ខ្លាំងពេកដែលការនោះធ្វើឲ្យយើងមិនចំណាយពេលអានព្រះគម្ពីរដែលប៉ះពាល់ចិត្តយើង។ នេះជាអ្វីដែលកញ្ញា អេលីណា (Elaina) បានសួរមកកាន់យើង៖

“ជម្រាបសួរលោកគ្រូ! ខ្ញុំរស់នៅម្នាក់ឯង។ ខ្ញុំធ្វើការជាច្រើនម៉ោង។ ខ្ញុំស្ទើរតែមិនមានពេលអានព្រះគម្ពីរសោះ។ ខ្ញុំធ្វើម្ហូប សម្អាតផ្ទះ ហាត់ប្រាណ ទៅនេះទៅនោះ ទិញម្ហូប ដើរផ្សារ ។ល។ ហើយពេលខ្ញុំមកដល់ផ្ទះវិញ ខ្ញុំអស់កម្លាំងរលីង។ ខ្ញុំរៀបចំកាលវិភាគជាច្រើនដងក្នុងការអានព្រះគម្ពីរ អធិស្ឋាន និងចំណាយពេលម្នាក់ឯងជាមួយព្រះជាម្ចាស់ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ខ្ញុំបានថ្វាយតែ១៥នាទីក្នុងមួយថ្ងៃទៅកាន់ព្រះអង្គតែប៉ុណ្ណោះ តែខ្ញុំមិនចង់ថ្វាយតែប៉ុណ្ណឹងនោះទេ។ ប៉ុន្តែ ខ្ញុំត្រូវរ៉ាប់រងលើការចំណាយជាប្រចាំថ្ងៃ។ ខ្ញុំមានអារម្មណ៍ថាជាប់គាំង។ នៅពេលខ្ញុំអានព្រះគម្ពីរ ខ្ញុំតែងតែងោកងុយ។ ពេលវេលាដែលខ្ញុំមានពិតប្រាកដឥឡូវនេះគឺមានតែចុងសប្តាហ៍។ ប៉ុន្តែ វាមិនគ្រប់គ្រាន់នោះទេ។ តើខ្ញុំអាចយកឈ្នះលើភាពមមាញឹកនៅក្នុងជីវិតរបស់ខ្ញុំ ដើម្បីធានាបានថា ខ្ញុំមានពេលសម្រាប់ព្រះអង្គបានដោយរបៀបណា?”។

យើងអាចបែងចែកអ្វីដែលកញ្ញា អេលីណា បានលើកឡើងទៅជាបីចំណុច ទាក់ទងទៅនឹងការខកចិត្តរបស់គាត់ក្នុងការចំណាយពេលជាមួយព្រះជាម្ចាស់ក្នុងព្រះបន្ទូល។ ទី១ គាត់មានអារម្មណ៍ថាជាប់គាំង។ ទី២ គាត់



50 QnA John Piper Final 1.5.indd 201 25/01/2024 09:23:08 AM

មានអារម្មណ៍ថាអស់កម្លាំង ហាក់បីដូចជាថាគាត់គេងលក់ពេលគាត់អានព្រះគម្ពីរ។ ហើយ*ទី៣* គាត់មានភាពមមាញឹកយ៉ាងខ្លាំងជាមួយនឹងសម្ពាធជាច្រើន ដោយបានដាក់ព្រះគម្ពីរចោលក្នុងជីវិតរបស់គាត់។ សូមអនុញ្ញាតឲ្យខ្ញុំបានលើកឡើងជាមតិយោបល់ខ្លះៗអំពីការទាំងនោះ។

**ចេញពីភាពជាប់គាំង**

ខ្ញុំមើលមនុស្សបើកឡានជាប់គាំងនៅក្នុងព្រិលនៅមុខផ្ទះរបស់ខ្ញុំ។ ផ្ទះរបស់ខ្ញុំនៅកាច់ជ្រុងផ្លូវ ដូច្នេះពួកគេត្រូវឈប់ ហើយរុញឡានចេញពីផ្លូវវិញ។ មនុស្សមួយចំនួនអង្គុយនៅទីនោះនៅកន្លែងដដែលប្រហែល១០នាទី។ ខ្ញុំក្រឡេកមើលទៅទីនោះ ដោយនិយាយថា «អូខេ ខ្ញុំត្រូវទៅទីនោះ ដើម្បីជួយរុញពួកគេហើយ»។ ពួកគេគ្រាន់តែជាន់ឲ្យកង់ឡានវិលទួងម្តងហើយម្តងទៀតៗ ហើយធ្វើដដែលៗម្តងហើយម្តងទៀតៗ នោះគឺជារបៀបដែលនាំឲ្យគាត់លែងជាប់គាំងទៀត។ ព្រិលគឺជាផ្នែកមួយនៃបញ្ហា ប៉ុន្តែការគ្រាន់តែធ្វើរឿងដដែលៗម្តងហើយម្តងទៀតក៏ជាផ្នែកមួយនៃបញ្ហាដែរ។

ដូច្នេះ ដើម្បីឲ្យអាចចេញពីភាពជាប់គាំងបាន នោះយើងទំនងជាតម្រូវឲ្យយើងដាក់លេខថយក្រោយ។ ចំណុចនេះហាក់បីដូចជាផ្ទុត់គំនិតបញ្ច្រាសគ្នា—បើកទៅមុខ ថយទៅក្រោយ ដើម្បីឲ្យលែងជាប់គាំង។ ឬលោកអ្នកត្រូវតែប្រើប៉ែលចូក។ លោកអ្នកចុះពីឡាន ចូកព្រិលចេញពីកង់ឡានខាងមុខរបស់លោកអ្នក។ ឬក៏លោកអ្នកទំនងជាចុចកណ្តឹងនៅផ្ទះខ្ញុំ ហើយសួរថា «តើមានប្រុសៗនៅទីនេះដែរទេ?» ដែលរឿងនេះធ្លាប់បានកើតឡើងមែន។ ខ្ញុំនិងកូនប្រុសរបស់ខ្ញុំបានជួយរុញឡានរបស់មនុស្សជាច្រើនចេញពីការជាប់គាំងក្នុងព្រិលនោះ។ ចំណុចសួលគឺថាៈ ការចេញពីភាពជាប់គាំង ពេលខ្លះតម្រូវឲ្យមានគំនិតបញ្ច្រាសគ្នា ការប្រឹងប្រែងជាថ្មី។



50 QnA John Piper Final 1.5.indd 202 25/01/2024 09:23:08 AM

## ចំណុចចាំបាច់មួយ

តើវាអាចទាក់ទងជាមួយនឹងភាពមមាញឹក និងភាពអស់កម្លាំងក្នុងចំណុចណាខ្លះ? កញ្ញា អេលីណា បានរាយចុះដូចជា ធ្វើម្ហូប សម្អាតផ្ទះ ហាត់ប្រាណ ទៅនេះទៅនោះ ទិញម្ហូប ដើរផ្សារ។ ចំពោះខ្ញុំទាំងនោះហាក់បីដូចជាទូទៅ ល្អ ហើយជាការមានតម្លៃក្នុងការរស់នៅជាប្រចាំថ្ងៃ។ ប៉ុន្តែព្រះយេស៊ូវគង់នៅក្នុងផ្ទះជាមួយស្ត្រីពីរនាក់ដែលពួកគាត់មានការឆ្លើយតបខុសៗគ្នា។ លោកអ្នកប្រហែលជាចាំបានថាខ្ញុំនិយាយអំពីនរណាហើយ—គឺនាងម៉ាថា និងម៉ារា។

នាង ម៉ាថា មានការខ្វល់ខ្វាយជាមួយនឹងការបម្រើជាច្រើន។ ហើយនាងបានចូលទៅឯព្រះអង្គហើយ និយាយថា «ព្រះអម្ចាស់អើយ តើទ្រង់មិនគិតឃើញថា ប្អូនខ្ញុំម្ចាស់ វាទុកខ្ញុំម្ចាស់ ឲ្យខ្វល់ខ្វាយបម្រើតែ ម្នាក់ឯងទេឬអី សូមទ្រង់ប្រាប់ឲ្យវាមកជួយខ្ញុំម្ចាស់ផង ប៉ុន្តែព្រះយេស៊ូវមានបន្ទូលឆ្លើយថា ម៉ាថាៗ អើយ នាងព្រួយចិត្តខំប្រឹងរៀបចំធ្វើអីច្រើនម្ល៉េះ មានសេចក្តីតែ១ទេ ដែលសម្រាប់ត្រូវការ ឯម៉ារា នាងបានរើសចំណែកយ៉ាងល្អ ដែលមិនត្រូវយកចេញពីនាងឡើយ» (លូកា ១០:៤០-៤២)។

ខ្ញុំដឹងថា កញ្ញា អេលីណា បានលើកឡើងថា «មើល! ខ្ញុំត្រូវរ៉ាប់រងលើការចំណាយជាប្រចាំថ្ងៃ»។ នេះជាអ្វីដែលគាត់និយាយ។ ប៉ុន្តែ ខ្ញុំគិតថា ប្រសិនបើព្រះយេស៊ូវទៅលេងផ្ទះរបស់គាត់ ហើយមើលកាលវិភាគរបស់គាត់ នោះព្រះអង្គទំនងជាចង្អុលលើចំណុចមួយចំនួន ហើយមានបន្ទូលថា «ទេ! ការនោះមិនចាំបាច់ប្រើប្រាស់ពេលវេលាច្រើនដូចនេះទេ។ ទេ! អ្នកមិនចាំបាច់លះបង់ពេលវេលា និងកម្លាំងច្រើនដល់ម្លឹងលើការនោះឡើយ។ ការមួយគឺចាំបាច់ហើយ—គឺចាំបាច់ជាងការចម្អិនម្ហូប ចាំបាច់ជាងការសម្អាត ចាំបាច់ជាងការហាត់ប្រាណ ចាំបាច់ជាងការចេញទៅក្រៅទិញអ្វីមួយ និងការដើរផ្សារផង—គឺវាជាតម្រូវការចាំបាច់ច្បាស់ជាង។



50 QnA John Piper Final 1.5.indd 203 25/01/2024 09:23:08 AM

នៅក្នុងកណ្ឌគម្ពីរ លូកា ៨:១៤ ព្រះយេស៊ូវបានព្រមានពីរបៀបមួយដែលព្រះបន្ទូលត្រូវបានឆក់យក គឺដោយសារភាពមមាញឹកជម្មតាដែរ ត្រូវទេ? ព្រះអង្គបានមានបន្ទូលថា «ឯពូជដែលធ្លាក់ទៅក្នុងបន្លា គឺអស់អ្នកដែលបានឮ រួចចេញទៅ នោះសេចក្ដីខ្វល់ខ្វាយ និងទ្រព្យសម្បត្តិ ហើយនិងសេចក្ដីស្រើបស្រាលនៅជីវិតនេះ ក៏ចូលមកខ្ទប់ជិត មិនឲ្យបង្កើតផលផ្លែដ៏ពេញលេញបានឡើយ»។

ទាក់ទងនឹងឃ្លា «ការខ្វល់ខ្វាយនៃជីវិត» តើយើងទាំងអស់គ្នាមិនមានការខ្វល់ខ្វាយទាំងនោះទេឬអី? ប៉ុន្តែ ព្រះយេស៊ូវបានរម្លឹកយើងថា «មនុស្សមិនមែនរស់ ដោយសារតែនំប៉័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះមកដែរ» (ម៉ាថាយ ៤:៤)។

## ទម្លាប់ជាប្រចាំថ្ងៃ

ការលើកទឹកចិត្តរបស់ខ្ញុំចំពោះ កញ្ញា អេលីណា (ក៏ដូចជាមិត្តអ្នកអានទាំងអស់) គឺចង់ឲ្យគាត់អង្គុយចុះ ហើយកត់ក្នុងបញ្ជីពីអ្វីដែលគាត់កំពុងផ្ដោតលើនៅក្នុងជីវិត។ ខ្ញុំចង់និយាយថា គាត់បានដាក់វាចូលក្នុងសំណួរដែលគាត់បានសួរយើងរួចទៅហើយ។ ខ្ញុំកំពុងនិយាយពីផ្នែកលម្អិតនៃជីវិតរបស់គាត់ដែលហាក់បីដូចជាកំពុងប្លន់យកនូវអ្វីដែលគាត់កំពុងតែពិតជាចង់ធ្វើយ៉ាងខ្លាំង។ គាត់គួរតែសួរខ្លួនឯងអំពីចំណុចនីមួយៗ។ តើរបៀបដែលខ្ញុំធ្វើនេះជារបៀបដ៏ល្អបំផុត ហើយតើវាសំខាន់ជាងការដែលខ្ញុំចំណាយពេលជាមួយព្រះជាម្ចាស់នៅក្នុងព្រះបន្ទូលរបស់ព្រះអង្គមែនឬ? តើមានរបៀបណាមួយក្នុងការផ្លាស់ប្ដូរពេលវេលាដែលខ្ញុំបានចំណាយលើការទាំងនោះ ដើម្បីឲ្យខ្ញុំមានពេលវេលាជាមួយព្រះបន្ទូលព្រះអង្គដែរឬទេ?

អ្វីដែលសំខាន់ជាងនេះទៅទៀត ខ្ញុំអាចនិយាយថា សូមដាក់ម៉ោងរោទ៍៤៥នាទី មុនពេលក្រោកនៅពេលព្រឹក។ ហើយឡើងងូតទឹក ស្លៀក



50 QnA John Piper Final 1.5.indd 204 25/01/2024 09:23:08 AM

ពាក់ និងអានព្រះបន្ទូលរបស់ព្រះជាម្ចាស់មុនពេលមានភាពមមាញឹកផ្សេងៗទៀតបានមកដល់។ សូមកុំអានព្រះបន្ទូលនៅពេលសល់ពេលតែតិចតួចឡើយ។ ប៉ុន្តែ សូមញែកពេលវេលាឲ្យបានច្រើន ដើម្បីអានព្រះបន្ទូលវិញ។ ការងារផ្សេងៗទៀតនឹងបានសម្រេចជាមិនខាន។ លោកអ្នកនឹងអាចនៅតែមានលុយសម្រាប់រ៉ាប់រងលើការចំណាយជាប្រចាំថ្ងៃ ប្រសិនបើលោកអ្នកអានព្រះគម្ពីរ។ ខ្ញុំសន្យាថា លោកអ្នកនឹងអាចធ្វើបានមែន ។

**កុំងោកងុយ**

ខ្ញុំបានណែនាំឲ្យក្រោកពីគេង៤៥នាទីមុនម៉ោង។ គាត់ប្រហែលជាកំពុងគ្រវីក្បាល ហើយនិយាយថា “លោកគ្រូនិយាយលេងទេអី? ខ្ញុំអស់កម្លាំងចង់ស្លាប់ហើយ”។ គាត់បាននិយាយថា គាត់បានងោកងុយនៅពេលគាត់កំពុងអានព្រះគម្ពីរ។ តើអ្នកណាមិនធ្លាប់មានរឿងបែបនោះកើតឡើង? ខាងក្រោមនេះជាការអនុវត្ត៣យ៉ាង៖

១. សូមចូលគេងឲ្យបានលឿនជាងធម្មតា ដើម្បីឲ្យបានសម្រាកច្រើនជាងមុន ជាពិសេសសម្រាប់ព្រះ បន្ទូល។ លោកអ្នកអាចបង្ខំខ្លួនឯងឲ្យទៅដើរផ្សារនៅពេលលោកអ្នកអស់កម្លាំង។ ប៉ុន្តែ លោកអ្នក ប្រហែលជាមិនអាចបង្ខំខ្លួនមិនឲ្យងោកងុយនៅពេលកំពុងអស់កម្លាំងនោះទេ។ លោកអ្នកអាចទៅផ្សារ បាននៅពេលលោកអ្នកអស់កម្លាំង។

២. ប្រសិនបើចាំបាច់ នៅពេលព្រឹក ចូរទៅឆុងកាហ្វេ ហើយឲ្យកាហ្វេនោះជួយឲ្យលោកអ្នកស្វាងវិញ ចុះ។ ខ្ញុំមិនមែនជាអ្នកផឹកកាហ្វេទេ ប៉ុន្តែខ្ញុំយល់ថាកាហ្វេមានតួនាទីធ្វើបែបនោះ។ ខ្ញុំផឹកតែកូកាអត់ មានជាតិស្ករ និងតែ តែប៉ុណ្ណោះ។

៣. ប្រសិនបើរាងកាយរបស់អ្នកចាប់ផ្ដើមងងុយដេក ចូរយកព្រះគម្ពីរដែលនៅក្នុងដៃ ហើយក្រោក ឡើងចេញពីកៅអី ឬពូក ហើយដើរជុំ



50 QnA John Piper Final 1.5.indd 205 25/01/2024 09:23:09 AM

វិញបន្ទាប់ដោយអានព្រះគម្ពីរចុះ។ មិនមានអ្វីពិសេសក្នុងការ  អង្គុយអាននោះទេ ហើយវាកាន់តែធ្វើឲ្យលោកអ្នកមិនងាយគេងលក់នៅពេលលោកអ្នកកំពុងដើរ។ ខ្ញុំទើបតែបានធ្វើការនេះកាលពីថ្ងៃមុន។

**កំណប់ទ្រព្យដ៏មានតម្លៃ**

ប្រហែលអ្វីដែលសំខាន់ជាងទិដ្ឋភាពនៃការណែនាំដ៏លម្អិតនេះ នោះគឺជាបទពិសោធន៍គ្រឹះដែលថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានតម្លៃលើសជាងអ្វីៗទាំងអស់។

ចូររម្លឹកខ្លួនឯងអំពីការនេះដោយអានកណ្ឌគម្ពីរ ទំនុកតម្កើង ១៩:៩-១០ មកកាន់ខ្លួនអ្នកផ្ទាល់។ ចូរអានឲ្យឮៗមកកាន់ខ្លួនឯងផ្ទាល់។ «អស់ទាំងខច្បាប់របស់ព្រះយេហូវ៉ាសុទ្ធតែពិតត្រង់ ហើយសុចរិតគ្រប់ជំពូក សេចក្តីទាំងនោះគួរចង់បានលើសជាងមាស អើ ជាជាងមាសសុទ្ធជាច្រើនផង ក៏ផ្អែមជាងទឹកឃ្មុំ ហើយជាងដំណក់ស្រក់ពីសំណុះផង»។ សូមកុំអនុញ្ញាតឲ្យមាស ហើយក៏កុំអនុញ្ញាតឲ្យចំណីអាហារសំខាន់ ឬមានរសជាតិផ្អែមជាងព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។ ការទាំងនោះមិនសំខាន់ ឬមានរសជាតិផ្អែមជាងព្រះបន្ទូលនោះទេ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 206 25/01/2024 09:23:09 AM

## សំណួរទី៣៥៖
# តើជាការខុសឆ្គងឬទេដែលមនុស្សប្រុសស្តាប់ការអធិប្បាយរបស់មនុស្សស្រី?

“ខ្ញុំជាមនុស្សប្រុស។ តើជាការខុសឆ្គងឬទេដែលខ្ញុំស្តាប់ការអធិប្បាយរបស់មនុស្សស្រីដែលជាគ្រីស្ទបរិស័ទ?

ទេ! វាមិនខុសឆ្គងទេ លុះត្រាតែលោកអ្នកចាប់ផ្តើមរំពឹងលើគាត់ថាជាគ្រូគង្វាលរបស់ខ្លួន។

នេះគឺជាអារម្មណ៍របស់យើងខ្ញុំ នៅពេលដែលមានមនុស្សស្រីមួយចំនួនឡើងនិយាយពេលខ្លះនៅសាលាថ្ងៃអាទិត្យ។ យើងមិនចាំបាច់រើសអើងពេកទេ។ ព្រះគម្ពីរបានលើកឡើងយ៉ាងច្បាស់លាស់ហើយថា “មិនបើកឲ្យស្ត្រីណាបង្រៀន ឬឲ្យមានអំណាចលើបុរសទេ” (១ធីម៉ូថេ ២:១២)។ ក្នុងបរិបទនេះ នេះមានន័យថា ស្ត្រីមិនគួរមានអំណាចបែបជាគ្រូបង្រៀនក្នុងក្រុមជំនុំនោះទេ។ ហើយពួកគាត់ក៏មិនគួរធ្វើជាអ្នកចាស់ទុំនៅក្នុងក្រុមជំនុំដែរ។ គ្រូគង្វាលជាច្រើនយល់ស្របអំពីចំណុចនេះក្នុងរបៀបនេះ។

តើនេះមិនមែនមានន័យថា លោកអ្នកមិនអាចរៀនសូត្រពីមនុស្សស្រីនោះទេ។ នេះមិនមែនមានន័យថា មនុស្សស្រីល្ងង់ ឬក៏មិនមានសមត្ថភាពក្នុងការគិតគូរនោះទេ។ នេះគ្រាន់តែមានន័យថា មានទំនាក់ទំនងពិសេសរវាងមនុស្សប្រុស និងមនុស្សស្រី។ ប្រសិនបើស្ត្រីណាម្នាក់ចាប់ផ្តើមមានអំណាចក្នុងឋានៈនៃការបង្រៀនក្នុងជីវិតរបស់លោកអ្នក នោះមានន័យថា ភាពជាបុរសនៃមនុស្សប្រុស និងភាពជាស្ត្រីនៃមនុស្សស្រីបានទទួលការខូចខាតហើយ។

នេះគឺជាចំណុចខ្វែងគំនិតគ្នាយ៉ាងខ្លាំង។ មានមនុស្សរាប់ពាន់នាក់ ឬក៏



50 QnA John Piper Final 1.5.indd 207 25/01/2024 09:23:09 AM

ប្រហែលរាប់លាននាក់ ដែលគិតថាគំនិតនេះគឺឆ្កួត ១០០% ហើយ។ នៅពេលដែលយើងខ្ញុំកំពុងតែប្រយុទ្ធក្នុងសង្គ្រាមនៃឋានៈសម្រាប់មនុស្សប្រុស និងមនុស្សស្រីមានគេបានលើកឡើងជាច្រើនឆ្នាំមុនថា យើងខ្ញុំឆ្កួត។ យើងខ្ញុំមិនឆ្កួតទេ។ នៅសព្វថ្ងៃនេះ មានទាំងមនុស្សវ័យចំណាស់ និងវ័យក្មេងជាច្រើននាក់បានឯកភាព ១០០% ជាមួយនឹងយើងខ្ញុំ។

តើមនុស្សប្រុសគួរស្តាប់ស្ត្រីដូចជាលោកស្រី អេលីសាបិត អេលោត (Elisabeth Elliot) ដែរឬទេ? គាត់មានភាពល្បីល្បាញក្នុងជំនាន់យើងខ្ញុំ។ លោកស្រី អេលីសាបិត អេលោត ជំរុញឲ្យមនុស្សវ័យក្មេងធ្វើជាបេសកជនដែលស្ម័គ្រចិត្តស្លាប់សម្រាប់ព្រះគ្រីស្ទ។ យើងខ្ញុំពិតជាស្រឡាញ់ចំណុចនេះណាស់! សូមលោកស្រី អេលីសាបិត បន្តប្រាប់គេចុះ! គាត់មានភាពក្លាហានយ៉ាងខ្លាំងអំពីការលះបង់ជីវិតរបស់ខ្លួន ហើយពិតជាស្តាប់បង្គាប់ ហើយមានការប្រាជ្ញាចិត្ត ១០០% ក្នុងការបម្រើព្រះ។ គាត់មិនមែនជាគ្រូគង្វាល ហើយគាត់ក៏មិនបានអធិប្បាយនៅព្រឹកថ្ងៃអាទិត្យដែរ។ គាត់គឺជាប្រភេទនៃស្ត្រីដែលយើងខ្ញុំពេញចិត្តយ៉ាងខ្លាំង។ យើងខ្ញុំអាចរៀនបានចំណុចជាច្រើនពីគាត់។

យើងខ្ញុំក៏ចង់រៀនសូត្រពីប្រពន្ធរបស់យើងខ្ញុំដែរ។ ហើយយើងខ្ញុំក៏សប្បាយចិត្តណាស់ក្នុងការរៀនសូត្រពីការនិយាយស្តីរបស់មនុស្សស្រីដែរ។ ប៉ុន្តែយើងខ្ញុំមិនចង់មានទំនាក់ទំនងនៃការស្តាប់ ឬក៏ការទៅចូលរួមនៅក្រុមជំនុំណាមួយ ដែលមានមនុស្សស្រីជាគ្រូគង្វាល ឬក៏អ្នកមានអំណាចលើយើងខ្ញុំនោះទេ។ នេះគឺជាចំណុចគ្រោះថ្នាក់សម្រាប់មនុស្សប្រុស។ យើងខ្ញុំអាចពន្យល់អំពីមូលហេតុនេះចេញពីព្រះគម្ពីរ ចេញពីបទពិសោធន៍ និងចេញពីផ្លូវចិត្តបាន ប៉ុន្តែយើងខ្ញុំទើបតែបានលើកឡើងនូវការសង្ខេបត្រួសៗសម្រាប់លោកអ្នក។

យើងខ្ញុំគិតថា មានមនុស្សស្រីជាច្រើននាក់ដែលជាគ្រូអធិប្បាយនឹងមាន



50 QnA John Piper Final 1.5.indd 208 25/01/2024 09:23:09 AM

ចិត្តរីករាយជាមួយនឹងចម្លើយរបស់យើងខ្ញុំ។ ប៉ុន្តែ វាអាចក្លាយជាការខុសឆ្គងបាន ដូច្នេះលោកអ្នកត្រូវតែមានការប្រុងប្រយ័ត្ន។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**

50 QnA John Piper Final 1.5.indd 210 25/01/2024 09:23:10 AM

# សំណួរទី៣៦៖
# តើការផឹកស្រាមិនអីមែនឬទេ?

តើយើងគួរនិយាយតបយ៉ាងដូចម្តេចចំពោះអស់អ្នកដែលអះអាងថា ការបរិភោគគ្រឿងស្រវឹងគឺមិនអីទេ ពីព្រោះព្រះយេស៊ូវក៏បានផឹកស្រាផងដែរ?

លោកអ្នកគួរឆ្លើយថា «ខ្ញុំគិតថា បងគួរបន្ថែមពីរបីពាក្យទៀតក្នុងឃ្លានោះដែលមានដូចជា "ការផឹកទំនងជាមិនអីទេ"» ឃ្លាដែលថា "តើការផឹកស្រាមិនអីទេឬ" គឺមិនមែនជាឃ្លាច្បាស់លាស់គ្រប់គ្រាន់ចំពោះយើងក្នុងការដឹងថា តើបុគ្គលនោះកំពុងតែលើកឡើងអំពីជីវិតបែបណាក្នុងការរស់នៅរបស់គាត់នោះទេ ហើយក៏ថា តើនោះជាគំរូ ឬក៏លំនាំនៃការរស់នៅដ៏ល្អ ឬក៏មិនល្អនោះផងដែរ។

ចម្លើយរបស់ខ្ញុំគឺដូចតទៅ៖ យើងមិនអាចនិយាយថារបៀបផឹកមួចំនួនគឺមិនអីបាននោះទេ។ ឧទាហរណ៍៖ ដូចជាការផឹករហូតទាល់តែស្រវឹងជោកខ្លួន។ ចំណុចនេះមានយ៉ាងច្បាស់លាស់ក្នុងព្រះគម្ពីរ។ ឧទាហរណ៍មួយទៀតដែលថាការផឹកវាមិនអីទេគឺ៖ ការផឹកជាមួយនឹងបុគ្គលណាម្នាក់ដែលសតិសម្បជញ្ញៈរបស់គាត់កំពុងតែថ្កោលទោសគាត់ និងការផឹកនោះកំពុងតែល្បួងឲ្យគាត់ចង់ផឹករហូតដល់ស្រវឹង ឬក៏បណ្តាលឲ្យគាត់ធ្លាក់ក្នុងការញៀនស្រាដោយផឹកម្តងទៀង បន្ទាប់ពីពួកគាត់បានព្យាយាមដកខ្លួនចេញពីការញៀនជាយូរឆ្នាំហើយ។ ហើយឥឡូវនេះលោកអ្នកកំពុងតែទាក់ទាញពួកគាត់ឲ្យធ្លាក់ក្នុងអ្វីដែលបានបំផ្លាញពួកគាត់។ ហើយវាក៏បានបំផ្លាញមនុស្សរាប់លាននាក់នៅក្នុងសង្គមនេះផងដែរ! វាបានបំផ្លាញជីវិតអាពាហ៍ពិពាហ៍ជាច្រើន។ វាបានបំផ្លាញការងារ។ ក្នុងសង្គមយើង គ្រឿងស្រវឹងគឺពិតជាសាហាវព្រៃផ្សៃខ្លាំងណាស់ជាពិសេសក្នុងរដូវបុណ្យទានម្តងៗ។



50 QnA John Piper Final 1.5.indd 211 25/01/2024 09:23:10 AM

យើងខ្ញុំមិនដឹងថា កាលនៅសម័យព្រះយេស៊ូវ វាសាហាវព្រៃផ្សៃប៉ុណ្ណានោះទេ។ ការស្រវឹងពិតជារឿងដ៏ជាក់ស្ដែងមែននៅសម័យនោះ។ ពិតណាស់! ព្រះគម្ពីរបានថ្កោលទោសការនោះ។ តែថាវាសាហាវព្រៃផ្សៃប៉ុណ្ណានោះយើងខ្ញុំមិនដឹងទេ។ អ្វីដែលយើងខ្ញុំដឹងគឺត្រង់ថា ពេលដែលយើងខ្ញុំនិយាយជាមួយអស់អ្នកដែលកំពុងព្យាយាមផ្ដាច់ចេញពីស្រា ឬក៏ពេលដែលយើងខ្ញុំអធិស្ឋានជាមួយនរណាម្នាក់ ដូចដែលយើងខ្ញុំទើបតែបានធ្វើនាសប្ដាហ៍មុននេះក្រោយពេលថ្វាយបង្គំរួច គាត់បាននិយាយមកយើងខ្ញុំថា «ពេលដែលខ្ញុំចប់នៅទីនេះ នោះខ្ញុំនឹងចេញទៅផឹកស្រារហូតដល់ស្រវឹង ព្រោះខ្ញុំចប់ហើយ។ ខ្ញុំគិតថាខ្ញុំបានបែកឆ្ងាយពីព្រះអង្គហើយ ហើយក៏គ្មានអ្នកណាម្នាក់អាចមកជួយខ្ញុំបានទៀតទេ ហើយព្រះអង្គក៏នឹងមិនអត់ទោសខ្ញុំទៀតដែរ។ ហើយខ្ញុំក៏បានព្យាយាមឲ្យមនុស្សជាច្រើនជួយខ្ញុំជាច្រើនដងដែរ ប៉ុន្តែខ្ញុំគ្មានសង្ឃឹមសោះ!»។ យើងខ្ញុំមិនយល់សោះចំពោះមនុស្សមិនមានការប្រុងប្រយ័ត្នទាក់ទងនឹងគ្រឿងស្រវឹង។

ដូច្នេះហើយបានជាយើងខ្ញុំលើកឡើងថា «បងគួរបន្ថែមពីរបីពាក្យទៀតក្នុងឃ្លានោះ»។

ពិតណាស់! លោកអ្នកមិនអាចអះអាងដោយប្រើប្រាស់ព្រះគម្ពីរថា យើងមិនគួរផឹកស្រានោះទេ ដ្បិតយើងឃើញយ៉ាងច្បាស់ថា ស្រាគឺជាព្រះពរនៅក្នុងព្រះគម្ពីរ។

ប្រសិនបើលោកអ្នកជ្រើសរើសមិនផឹកស្រាដូចជាយើងខ្ញុំ នោះលោកអ្នកមិនអាចអះអាងថា ស្រាអាក្រក់បាននោះទេ។ ថាអញ្ចឹងមិនអាចទៅរួចបានឡើយ។ តាមពិតទៅ ចំពោះយើងខ្ញុំវិញ វាពាក់ព័ន្ធនឹងសង្គមដែលយើងខ្ញុំកំពុងរស់នៅក្នុង។ ពាក់ព័ន្ធនឹងកូនៗ និងចៅៗរបស់យើងខ្ញុំ។ ពាក់ព័ន្ធនឹងលក្ខណៈបុគ្គលិកភាពនៃការរៀនរបស់យើងខ្ញុំផ្ទាល់។ យើងខ្ញុំស្ទើរតែមិនអាចទិញស្ករកៅស៊ូមួយដុំដោយមិនញ៉ាំវាទាំងអស់ក្នុងរយៈពេលមួយម៉ោង



50 QnA John Piper Final 1.5.indd 212 25/01/2024 09:23:10 AM

បានផង។

យើងខ្ញុំដឹងហើយថា មានមនុស្សវ័យក្មេងជាច្រើនមិនចង់ប្រកាន់ភ្ជាប់តាមក្រឹត្យវិន័យនិយម ហើយក៏ចង់សាកល្បងសេរីភាពរបស់ដំណឹងល្អ ប៉ុន្តែយើងខ្ញុំគិតថា ពួកគេមិនស្គាល់ធាតុពិតនៃលោកីយ៍ដែលយើងកំពុងរស់នៅក្នុងនោះឡើយ។

នេះឯងគឺជាការព្រមានដ៏តូចតាចមួយពីយើងខ្ញុំ។ ហើយយើងខ្ញុំក៏ដឹងផងដែរថា នឹងមានមនុស្សជាច្រើនដែលនឹងជំទាស់ប្រឆាំងនឹងយើងខ្ញុំ (ដែលតាមពិតទៅពួកគាត់គឺសុទ្ធតែជាអស់អ្នកដែលយើងខ្ញុំគោរពយ៉ាងខ្លាំង) ត្រង់ចំណុចថា យើងខ្ញុំកំពុងតែបដិសេធនូវអំណោយទានដ៏វិសេសវិសាលពីព្រះជាម្ចាស់សម្រាប់មនុស្សគ្រប់ៗរូបហើយ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 213 25/01/2024 09:23:10 AM

## សំណួរទី៣៧៖
# ប្រសិនបើមនុស្សណាម្នាក់ផឹកស្រា ឬជក់បារី តើការនោះបង្ហាញថាគាត់មិនមែនជាគ្រីស្ទបរិស័ទឬយ៉ាងណា?

ខ្ញុំមិនលើកទឹកចិត្តឲ្យមានការជក់បារី ឬផឹកស្រានោះទេ ប៉ុន្តែមិត្តភក្តិមួយចំនួនជាទូទៅគិតថា ការប្រព្រឹត្តទង្វើទាំងនោះមានន័យថាអ្នកដែលប្រព្រឹត្តនោះមិនមែនជាគ្រីស្ទបរិស័ទ។ តើយើងគួរគិតដូចម្តេចដែរ?

ជាការពិតណាស់ លោកអ្នកមិនអាចវិនិច្ឆ័យ បុគ្គលដែលជក់បារី និងផឹកស្រាថាមិនមែនជាគ្រីស្ទបរិស័ទនោះទេ ដោយសារយើងមិនទទួលបានសេចក្តីសង្គ្រោះតាមរយៈការមិនជក់បារី ឬតាមរយៈការមិនផឹកស្រាឡើយ។ យើងទទួលបានសេចក្តីសង្គ្រោះតាមរយៈការជឿទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ។

នោះមិនមែនមានន័យថា យើងមិនគួរខ្វល់ខ្វាយចំពោះជីវិតអ្នកដទៃនោះទេ។ មានផលប៉ះពាល់ខ្លាំងចំពោះការជក់បារី ហើយក៏មានផលប៉ះពាល់ខ្លាំងចំពោះការផឹកស្រាដែរ។ ផលប៉ះពាល់ទាំងនោះមិនដូចគ្នាទាំងស្រុងទេ ប៉ុន្តែក៏មានមួយចំនួនដែលដូចគ្នាដែរ។ ហើយប្រសិនបើលោកអ្នកពិតជាស្រឡាញ់អស់អ្នកដែលលោកអ្នកស្រឡាញ់មែន នោះមិនថាពួកគាត់ងាយ ឬក៏មិនងាយរងគ្រោះនោះទេ នោះលោកអ្នកនឹងប្រាកដជានិយាយជាមួយពួកគាត់អំពីគ្រោះថ្នាក់ទាំងនោះជាមិនខាន។

ដូច្នេះ វាមិនមែនសាមញ្ញដោយគ្រាន់តែលើកឡើងថា “ចូរឲ្យពួកគាត់ធ្វើអ្វីដែលពួកគាត់ចង់ធ្វើចុះ ព្រោះនោះមិនមែនជារបៀបដែលពួកគាត់ទទួលបានសង្គ្រោះនោះទេ” ជាគោលគំនិតដែលថា យើងទាំងអស់គ្នាទទួលបានសេរីភាពចេញពីព្រះគុណ ដូច្នេះយើងអាចបន្តធ្វើអ្វីក៏បាន។ ផ្ទុយទៅវិញ ផល

ផ្លែនៃដំណឹងល្អអាចផ្លាស់ប្តូរមនុស្សបាន។ វាបានផ្លាស់ប្តូររបៀបដែលពួកគាត់គ្រប់គ្រងគ្រឿងស្រវឹង ហើយវាក៏ផ្លាស់ប្តូររបៀបដែលពួកគាត់គ្រប់គ្រងសារធាតុញៀនរបស់គាត់ផងដែរ។ វាពិតជាចម្លែកមែនដែលមនុស្សម្នាក់រាប់សារធាតុញៀនថាជាផលផ្លែមួយនៃព្រះវិញ្ញាណបរិសុទ្ធ។

ប៉ុន្តែ ខ្ញុំចង់ឲ្យពួកគាត់មានពេលវេលា ក្នុងការយកជ័យជម្នះលើទម្លាប់មួយ ជាពិសេសនៅក្នុងការចាប់ផ្តើមបន្ទាប់ពីបានទទួលជឿ ប្រសិនបើគាត់ត្រូវការពេល ដើម្បីផ្លាស់ប្រែ និងទទួលស្គាល់ថា អ្វីធ្វើឲ្យពួកគាត់ឈឺចាប់។

«ខ្ញុំមានច្បាប់នឹងធ្វើគ្រប់ការទាំងអស់បាន ប៉ុន្តែមិនមែនការទាំងនោះមានប្រយោជន៍ទាំងអស់ទេ» (១កូរិនថូស ៦:១២)។ ហើយគ្រីស្ទបរិស័ទដែលមិនទាន់មានភាពចាស់ទុំមិនតែងតែដឹងអំពីអ្វីដែលមានប្រយោជន៍ និងអ្វីដែលបង្កឲ្យមានគ្រោះថ្នាក់ ព្រមទាំងអំពីអ្វីដែលមានផលប៉ះពាល់ក្នុងរយៈពេលយូរនោះទេ។

ប៉ុន្តែ ចម្លើយដ៏ខ្លី និងចម្លើយដ៏សំខាន់គឺថា លោកអ្នកមិនគួរវិនិច្ឆ័យ ឬសន្និដ្ឋានភ្លាមៗថា ប្រសិនបើបុគ្គលណាម្នាក់ផឹកស្រា ឬជក់បារី នោះបុគ្គលម្នាក់នោះមិនមែនជាគ្រីស្ទបរិស័ទនោះទេ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 216 25/01/2024 09:23:11 AM

## សំណួរទី៣៨៖
# តើព្រះគម្ពីរបានបញ្ជាឲ្យគ្រីស្ទបរិស័ទថ្វាយតង្វាយដែរឬទេ?

*មិត្តអ្នកអានម្នាក់បានសួរថា «លោកគ្រូ តើការដាក់តង្វាយគឺជាអ្វីដែលគ្រីស្ទបរិស័ទត្រូវធ្វើសព្វថ្ងៃនេះដែរមែនឬ? ជាពិសេសតង្វាយ១ភាគ១០?»*

នេះគឺជាសំណួរអំពីទំនាក់ទំនងរវាងក្រឹត្យវិន័យក្នុងព្រះគម្ពីរសញ្ញាចាស់ជាមួយនឹងគ្រីស្ទបរិស័ទសព្វថ្ងៃនេះ ពីព្រោះយើងដឹងហើយថាក្នុងកណ្ឌគម្ពីរលេវីវិន័យ ចោទិយកថា និងជនគណនាសុទ្ធតែបានបង្រៀនថាការដាក់តង្វាយគឺជាតួនាទីសម្រាប់រាស្ត្រដែលបានតាំងសេចក្ដីសញ្ញាជាមួយនឹងព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ដូច្នេះ សំណួរក៏បានក្លាយទៅជា៖ «តើការរៀបរៀងនៃសេចក្ដីតាំងសញ្ញាជាមួយលោក ម៉ូសេ មានការទាក់ទងយ៉ាងដូចម្ដេចជាមួយយើងក្នុងការតាំងសេចក្ដីសញ្ញាថ្មីសព្វថ្ងៃនេះ?» ហើយនេះគឺជាសំណួរដ៏ធំមួយ។ មានគេនិពន្ធសៀវភៅជាច្រើនក្បាលក្នុងការព្យាយាមឆ្លើយតបទៅសំណួរមួយនេះ។ ប៉ុន្តែ យើងខ្ញុំនឹងគ្រាន់តែលើកឡើងនូវខគម្ពីរ ហើយនឹងព្យាយាមឆ្លើយក្នុងលក្ខណៈយ៉ាងសាមញ្ញ តាមដែលយើងខ្ញុំអាចធ្វើបាន។

### ការតាំងសេចក្ដីសញ្ញាថ្មី និងក្រឹត្យវិន័យចាស់?

កណ្ឌគម្ពីរ រ៉ូម ៧:៤, ៦៖ «យ៉ាងដូច្នោះ បងប្អូនអើយ អ្នករាល់គ្នាក៏បានស្លាប់ពីខាងឯក្រិត្យវិន័យដែរ ដោយសាររូបអង្គនៃព្រះគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាបានទៅជារបស់ផងអ្នកម្នាក់ទៀត ដែលបានរស់ពីស្លាប់ឡើងវិញ ប្រយោជន៍ឲ្យយើងបានបង្កើតផលថ្វាយព្រះ...តែឥឡូវនេះ យើងបានរួចពីក្រិត្យវិន័យហើយ ដោយបានស្លាប់ក្នុងសេចក្ដីដែលឃុំឃាំងយើងទុក ប្រយោជន៍ឲ្យយើងបានគោរពប្រតិបត្តិ ដោយវិញ្ញាណដែលបានកែជាថ្មីវិញ



50 QnA John Piper Final 1.5.indd 217 25/01/2024 09:23:11 AM

មិនមែនតាមតែន័យពាក្យពីបុរាណនោះទៀតឡើយ»។

ឬកណ្ឌគម្ពីរ កាឡាទី ២:១៩៖ «ពីព្រោះខ្ញុំបានស្លាប់ខាងឯក្រិត្យវិន័យ ដោយសារក្រិត្យវិន័យនោះឯង ដើម្បីឲ្យខ្ញុំបានរស់ខាងឯព្រះវិញ»។ ឬក៏កណ្ឌគម្ពីរ អេភេសូរ ២:១៥៖ «(លើឈើឆ្កាងរបស់ព្រះគ្រីស្ទ ព្រះជាម្ចាស់បាន) បំបាត់ក្រិត្យវិន័យដែលមានបញ្ញត្តិ នឹងសេចក្ដីហាមប្រាមទាំងប៉ុន្មានចេញ»។ ឬកណ្ឌគម្ពីរ រ៉ូម ៦:១៥៖ «ដូច្នេះ ធ្វើដូចម្ដេច តើគួរឲ្យយើងប្រព្រឹត្តអំពើបាប ដោយព្រោះនៅក្រោមព្រះគុណ»។

ដូច្នេះ ចម្លើយរបស់យើងខ្ញុំគឺថា ក្នុងការតាំងសេចក្ដីសញ្ញាថ្មី ក្នុងទំនាក់ទំនងថ្មីជាមួយនឹងព្រះជាម្ចាស់តាមរយៈព្រះមេស្ស៊ីដែលបានបំពេញនូវរាល់គ្រប់ក្រឹត្យវិន័យទាំងអស់ជំនួសយើង នោះយើងមិនត្រូវស្ថិតក្រោមក្រឹត្យវិន័យទៀតទេ។ វាមិនមែនជារបៀបដ៏ចម្បងដែលនាំឲ្យយើងមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់នោះទេ ឬក៏ជារបៀបដែលយើងរែកញែក និងស្វែងរកកម្លាំង ដើម្បីធ្វើនូវអ្វីដែលជាការគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ដែរ។ ហើយនៅក្នុងកន្លែងរបស់វា យើងក៏ឃើញនូវអ្វីដែលសាវ័ក ប៉ុល បានហៅថាជាក្រឹត្យវិន័យនៃព្រះគ្រីស្ទពីរដង៖ «ចូរយកអាសាគ្នាទៅវិញទៅមក យ៉ាងនោះ ទើបបានសម្រេចតាមក្រឹត្យវិន័យនៃព្រះគ្រីស្ទ» (កាឡាទី ៦:២)។

ឬកណ្ឌគម្ពីរ (១កូរិនថូស ៩:២១) «ហើយដូចជាឥតក្រឹត្យវិន័យដល់ពួកអ្នកដែលគ្មានក្រឹត្យវិន័យ (មិនមែនថាខ្ញុំឥតក្រឹត្យវិន័យរបស់ព្រះទេ គឺខ្ញុំនៅក្នុងក្រឹត្យវិន័យព្រះគ្រីស្ទវិញ) ដើម្បីឲ្យបានពួកអ្នកដែលគ្មានក្រឹត្យវិន័យដែរ»។ ដូច្នេះ វាមិនមែនហាក់បីដូចជាថា យើងកំពុងតែអណ្ដែតដោយគ្មានការគាំទ្រនោះទេ។ ព្រះគ្រីស្ទគឺជាអ្នកគាំទ្រយើង លក្ខណសម្បត្តិរបស់ទ្រង់ អ្វីដែលទ្រង់បានបង្រៀន អ្វីដែលទ្រង់បានលើកឡើង និង «ក្រឹត្យវិន័យនៃព្រះគ្រីស្ទ»។ ហើយតាមពិតទៅ ក្រឹត្យវិន័យនៃព្រះគ្រីស្ទគឺជាក្រឹត្យវិន័យនៃការស្រឡាញ់ដែលបំពេញបទបញ្ញត្តិនៅក្នុងព្រះគម្ពីរសញ្ញាចាស់។



50 QnA John Piper Final 1.5.indd 218 25/01/2024 09:23:11 AM

កណ្ឌគម្ពីរ (រ៉ូម ១៣:៨)៖ «ដ្បិតអ្នកដែលស្រឡាញ់ដល់គេ នោះបានធ្វើសម្រេចតាមក្រិត្យវិន័យហើយ “កុំឲ្យផិតឲ្យសោះ កុំឲ្យសម្លាប់មនុស្សឲ្យសោះ កុំឲ្យលួចឲ្យសោះ កុំឲ្យលោភឲ្យសោះ” ហើយបើមានបញ្ញត្តណាទៀត នោះក៏រួមគ្នាមកក្នុងពាក្យ១ម៉ាត់នេះឯង ដែលថា “ចូរស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង”»។

ដូច្នេះ យើងខ្ញុំគិតថា យើងបែរចេញពីការរក្សាក្រឹត្យវិន័យថាសំខាន់ ថាច្បាស់លាស់ និងថាជារបៀបចម្បងដែលយើងមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ ព្រះគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ—របៀបថ្មីរបស់ព្រះវិញ្ញាណ។ ហើយបន្ទាប់មក សំណួរក៏ក្លាយជា៖ «អញ្ចឹង តើការដាក់តង្វាយមានភាពស៊ីគ្នានៅក្នុងចំណុចណា? បើគ្រាន់តែយកការដាក់តង្វាយជាឧទាហរណ៍ជាក់លាក់នៃក្រឹត្យវិន័យមួយ តើការដាក់តង្វាយមានភាពស៊ីគ្នានៅក្នុងចំណុចណាទៅ?»។

## គ្រូគង្វាល ពួកលេវី និង១០%

យើងដឹងថា នោះគឺជារបៀបនៃការផ្គត់ផ្គង់ដល់ពួកលេវី។ ពួកលេវីមិនមានដីធ្លី។ ពួកគាត់មិនមានមរតក ហើយការយកពន្ធពីកុលសម្ព័ន្ធផ្សេងៗគឺជារបៀបនៃការផ្គត់ផ្គង់ដល់ពួកគាត់។ និយាយឲ្យចំៗទៅ កុលសម្ព័ន្ធផ្សេងៗត្រូវថ្វាយមួយភាគដប់ ហើយយកមកឲ្យពួកលេវី ហើយពួកលេវីរស់នៅដោយពឹងលើតង្វាយពីពួករាស្ត្រដែលបានចែកចាយជាមួយនឹងពួកគាត់។ ដូច្នេះ លោកអ្នកអាចនិយាយជាទូទៅថា នោះគឺជារបៀបនៃការផ្គត់ផ្គង់រចនាសម្ព័ន្ធសាសនា បែបជាការតាំងសញ្ញា នៅជំនាន់នោះ។

ដូច្នេះ សំណួរដែលយើងគួរសួរគឺថា៖ «បើអញ្ចឹងមែន តើនេះគួរជារបៀបដែលយើងផ្គត់ផ្គង់រចនាសម្ព័ន្ធនៃការតាំងសញ្ញាក្នុងក្រុមជំនុំនៅសព្វថ្ងៃនេះដែរឬទេ?» ដោយសារយើងដឹងថា ព្រះគម្ពីរសញ្ញាថ្មីបានលើកឡើងថាគ្រូ



50 QnA John Piper Final 1.5.indd 219 25/01/2024 09:23:12 AM

គង្វាលគួរទទួលការផ្គត់ផ្គង់។ «“មិនត្រូវឃ្លុំមាត់គោដែលបញ្ជាន់ស្រូវឡើយ” ហើយថា “ជើងឈ្នួល គួរឲ្យបានប្រាក់ឈ្នួលខ្លួន”» (១ធីម៉ូថេ ៥:១៨)។ «អ្នកចាស់ទុំណា ដែលជាអ្នកនាំមុខយ៉ាងល្អ នោះត្រូវរាប់ជាគួរនឹងគោរព ប្រតិបត្តិជាទ្វេគុណឡើង» (១ធីម៉ូថេ ៥:១៧)។

ដូច្នេះ យើងដឹងថាសាវ័ក ប៉ុល បានគិតថា គ្រូគង្វាលគួរទទួលប្រាក់ខែ ប្រសិនបើពួកគាត់ចំណាយជីវិតរបស់ខ្លួនដើម្បីដំណឹងល្អ។ តើនោះជាការ អនុវត្តដែលយើងគួរយកមកប្រើប្រាស់ជាមួយនឹងការដាក់តង្វាយដែរមែន ឬ? ហើយដំណោះស្រាយរបស់សាវ័ក ប៉ុល ទាក់ទងនឹងការផ្គត់ផ្គង់គឺថា៖ «ចូរឲ្យគ្រប់គ្នាធ្វើតាមដែលសម្រេចក្នុងចិត្តចុះ មិនមែនដោយស្តាយ ឬដោយ បង្ខំឡើយ ដ្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ» (២កូរិនថូស ៩:៧) នេះហាក់បីដូចជាថាសាវ័ក ប៉ុល មានការច្រណែនក្នុង ការរៃអង្គាសថវិកាដែលមនុស្សម្នាគួរឲ្យ មិនមែនដោយបង្ខំ ឬក៏ស្ទាក់ស្ទើរ ប៉ុន្តែគួរឲ្យដោយអំណរ។

## ការតាំងសេចក្តីសញ្ញាដ៏ល្អប្រសើរជាង និងការថ្វាយដ៏ល្អប្រសើរជាង

នៅចុងបញ្ចប់ ដូចដែលលោកគ្រូ ដុន ខាសុន (Don Carson) ចូលចិត្ត លើកឡើង «ខ្ញុំគិតថា យើងគួរឲ្យតម្លៃលើទ្រព្យសម្បត្តិរបស់យើងក្នុងព្រះ គ្រីស្ទក្នុងទំនាក់ទំនងនៃការតាំងសេចក្តីសញ្ញាថ្មីដ៏ខ្ពង់ខ្ពស់នេះ និងសេរីភាព របស់យើងចេញពីអំពើបាបដ៏ធ្ងន់ធ្ងរ និងដំណឹងល្អដ៏ឧត្តុង្គឧត្តមរបស់យើង ដល់ថ្នាក់ថាយើងនឹងចូលចិត្តថ្វាយ»។ ព្រះយេស៊ូវបានមានព្រះបន្ទូលថា ការ ឲ្យគឺជាព្រះពរខ្លាំងជាងការទទួល (កិច្ចការ ២០:៣៥)។ នោះយើងនឹងទទួល ការរំដោះចេញពីការស្រឡាញ់របស់របរ ការពឹងផ្អែកលើរបស់របរ ហើយយើង នឹងថ្វាយលើសជាងអស់អ្នកដែលបានរស់នៅក្រោមក្រឹត្យវិន័យទៅទៀត ពីព្រោះយើងមានសេចក្តីតាំងសញ្ញាដែលល្អប្រសើរជាង និងសេចក្តីសន្យា



50 QnA John Piper Final 1.5.indd 220 25/01/2024 09:23:12 AM

ដែលល្អប្រសើរជាងដែរ។ គ្រប់អ្វីៗទាំងអស់គឺល្អប្រសើរជាងជាមួយនឹងព្រះគ្រីស្ទ។ ចុះហេតុអ្វីបានជាការថ្វាយមិនគួរល្អប្រសើរជាងដែរទៅ?

ដូច្នេះយើងខ្ញុំគិតថាយើងខ្ញុំអធិប្បាយលើការថ្វាយតង្វាយពីរទៅបីដងក្នុងអំឡុងពេល៣៣ឆ្នាំនៅឯព្រះវិហាររបស់យើងខ្ញុំ។ អ្វីដែលយើងខ្ញុំចង់មានន័យគឺថា យើងខ្ញុំបាននិយាយស្ទើរតែគ្រប់ពេលវេលាអំពីការផ្គត់ផ្គង់ និងការលះបង់ ប៉ុន្តែទាក់ទងទៅនឹងការថ្វាយតង្វាយ...ជាទូទៅ យើងខ្ញុំបានលើកឡើងដូចនេះ៖ “ឱបងប្អូនអើយ! ហេតុអ្វីបានជាយើងចង់ថ្វាយតិចជាង? បុគ្គលដែលលើកឡើងថា៖ “តើខ្ញុំត្រូវថ្វាយមែនឬ?” គឺគាត់កំពុងតែឈរលើជំហរមិនត្រឹមត្រូវរួចស្រេចបាត់ទៅហើយ។ រាល់គ្រប់អ្វីៗទាំងអស់គឺល្អប្រសើរជាងក្នុងការតាំងសេចក្ដីសញ្ញាថ្មី។ យើងមានសេចក្ដីសន្យាល្អប្រសើរជាងសេចក្ដីតាំងសញ្ញាល្អប្រសើរជាង—កណ្ឌគម្ពីរហេព្រើរបានលើកឡើង—ចុះហេតុអ្វីបានជាមិនមានការលះបង់ និងការថ្វាយល្អប្រសើរខ្លាំងជាងដែរទៅ?

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 221 25/01/2024 09:23:12 AM

50 QnA John Piper Final 1.5.indd 222 25/01/2024 09:23:12 AM

## សំណួរទី៣៩៖
# តើខ្ញុំអាចបែងចែកប្រាក់តង្វាយរបស់ខ្ញុំរវាងក្រុមជំនុំ និងព័ន្ធកិច្ចមួយផ្សេងទៀតបានដែរឬទេ?

*លោកគ្រូ ទាក់ទងនឹងតង្វាយ១/១០របស់យើងខ្ញុំចំពោះក្រុមជំនុំ តើយើងខ្ញុំអាចបែងចែកតង្វាយនោះបានដែរឬទេ? ដូចជា៖ —៥% ជូនទៅក្រុមជំនុំ ហើយ៥% ទៀតជូនទៅព័ន្ធកិច្ចគ្រីស្ទបរិស័ទផ្សេងៗទៀត—តើលោកគ្រូមានយោបល់អ្វីដែលទាក់ទងនឹងការបែងចែកប្រាក់តង្វាយ?*

**តើគ្រីស្ទបរិស័ទដាច់ខាតត្រូវតែថ្វាយតង្វាយមែនឬ?**

ទេ! ចំពោះតង្វាយ១/១០នៃប្រាក់ខែរបស់លោកអ្នកព្រះគម្ពីរសញ្ញាថ្មីមិនបានបង្គាប់ថាលោកអ្នក «ត្រូវតែថ្វាយ» នោះទេ។ ទាក់ទងនឹងជីវិតរស់នៅរបស់គ្រីស្ទបរិស័ទ ព្រះគម្ពីរសញ្ញាថ្មីបានរៀបរាប់ខុសគ្នាពីក្រឹត្យវិន័យនៃព្រះគម្ពីរសញ្ញាចាស់។ សាវ័ក ប៉ុល បានលើកឡើងក្នុងកណ្ឌគម្ពីរ (រ៉ូម ៧:៦) ថា៖ « តែឥឡូវនេះ យើងបានរួចពីក្រិត្យវិន័យហើយ ដោយបានស្លាប់ក្នុងសេចក្តីដែលឃុំឃាំងយើងទុក ប្រយោជន៍ឲ្យយើងបានគោរពប្រតិបត្តិ ដោយវិញ្ញាណដែលបានកែជាថ្មីវិញ មិនមែនតាមតែន័យពាក្យពីបុរាណនោះទៀតឡើយ»។

- ឧទាហរណ៍៖ នៅពេលដែលលោកសាវ័ក ប៉ុល ផ្តល់ការណែនាំអំពីរបៀបដែលយើងគួរថ្វាយតង្វាយ គាត់មិនដែលបង្គាប់យើងញែកតង្វាយយើងទុកដោយឡែកឡើយ។ តែគាត់បែរជាលើកឡើងដូចជា «ត្រូវឲ្យអ្នករាល់គ្នាប្រមូលដាក់ទុកនូវអ្វីៗដោយឡែក តាមដែលព្រះបានចម្រើនឲ្យ» (១កូរិនថូស ១៦:២)។



50 QnA John Piper Final 1.5.indd 223 25/01/2024 09:23:13 AM

- ហើយបន្ទាប់មកគាត់បានលើកឡើងក្នុងកណ្ឌគម្ពីរ (២កូរិនថូស ៨:៣) ថា៖ យើងគួរតែថ្វាយតាមសមត្ថភាពរបស់យើង “ដ្បិតយើងខ្ញុំធ្វើបន្ទាល់ថា គេស្ម័គ្រចិត្តតាមកម្លាំងគេ ហើយហួសកម្លាំងគេផង”។
- ហើយក្នុងកណ្ឌគម្ពីរ (២កូរិនថូស ៩:៦-៧) គាត់ក៏បានពណ៌នាពីការថ្វាយដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ។ “យើងខ្ញុំចង់និយាយដូច្នេះគឺថា អ្នកណាដែលព្រោះដោយកំណាញ់ នោះនឹងច្រូតបានតិច ហើយអ្នកណាដែលព្រោះដោយសទ្ធា នោះនឹងច្រូតបានច្រើនវិញ។ ចូរឲ្យគ្រប់គ្នាធ្វើតាមដែលសម្រេចក្នុងចិត្តចុះ មិនមែនដោយស្ដាយ ឬដោយបង្ខំឡើយ ដ្បិតព្រះទ្រង់ស្រឡាញ់ដល់អ្នកណាដែលថ្វាយដោយអំណរ”។

ការបង្រៀននៅក្នុងចំណុចនេះគឺមានន័យថា យើងមិនស្ថិតទៅលើការថ្វាយតង្វាយដែលមានភាគរយទាប ឬភាគរយខ្ពស់នោះទេ។ ព្រះគម្ពីរមិនបានបង្គាប់យើងទេ។ ប៉ុន្តែ យើងគួរតែថ្វាយដោយចិត្តសទ្ធាដែលមានការលះបង់ ចេញពីចិត្ត និងពេញដោយអំណរ។

### អ្នកប្អូនអ្នកមានគួរសម

យើងខ្ញុំធ្លាប់និយាយប្រាប់ក្រុមជំនុំរបស់យើងខ្ញុំថា អ្នកមានគួរសម ហើយធូរធារទៀត (នៅប្រទេសអាមេរិក) ដែលគ្រាន់តែថ្វាយ១០% គឺទំនងជាកំពុងលួចពីព្រះជាម្ចាស់ហើយមើលទៅ។ និយាយម្យ៉ាងទៀត យើងបានធ្លាក់ក្នុងផ្នត់គំនិត (ខាងលិច) ទាក់ទងនឹងទ្រព្យសម្បត្តិ និងរបៀបនៃការរស់នៅថា ការថ្វាយ៥% ឬក៏១០% គឺជាការឲ្យដោយដៃទូលាយហើយ។

យើងខ្ញុំសង្ឃឹមយ៉ាងច្បាស់ថា នៅពេលដែលយើងខ្ញុំលើកឡើងមកថា ការថ្វាយតង្វាយគឺមិនមែនជាការដែលយើងដាច់ខាតឬ “ត្រូវតែថ្វាយ” នោះទេ យោងតាមច្បាប់ព្រះគម្ពីរសញ្ញាថ្មី។ យើងខ្ញុំកំពុងព្យាយាមនិយាយដូចនេះ៖ ឧទាហរណ៍ ថាគ្រូបង្វឹកបាល់ម្នាក់បាននិយាយទៅកាន់ក្រុមរបស់គាត់



50 QnA John Piper Final 1.5.indd 224 25/01/2024 09:23:13 AM

នៅសាលាថា «ដាច់ខាត គ្រប់គ្នាត្រូវតែងើបម៉ោង៥:០០ព្រឹករាល់ព្រលឹម ហើយត្រូវរត់ ៥គ.ម. ដើម្បីហ្វឹកហាត់ខ្លួនឲ្យខ្លាំងបំផុត ដើម្បីធ្វើឲ្យក្នុងក្រុមខ្លាំងពូកែ។» ប៉ុន្តែ ផ្ទុយពីនោះ គ្រូបង្វឹកបែរជាលើកឡើងថា «យើងខ្ញុំចង់ឲ្យគ្រប់គ្នាស្រឡាញ់កីឡានេះឲ្យអស់ពីចិត្ត ហើយយើងខ្ញុំចង់ឲ្យគ្រប់គ្នាខំឲ្យអស់ពីសមត្ថភាព ដើម្បីការប្រកួតនេះ។ យើងខ្ញុំចង់ឲ្យគ្រប់គ្នាខិតខំឲ្យបានពូកែតាមដែលខ្លួនអាចធ្វើទៅបាន ហើយបម្រើក្រុមនេះ ដើម្បីឲ្យយើងបានប្រកួតយ៉ាងល្អបំផុតតាមដែលយើងអាចធ្វើទៅបាន។

តើរបៀបមួយណាល្អជាងគេ? ក្នុងរបៀបទាំងពីរនៃការនិយាយទៅកាន់ក្រុម ហើយរបៀបទីពីរមិនមានច្បាប់ទេ ប៉ុន្តែ ទីមួយមានច្បាប់។ របៀបទីមួយ ត្រូវតែងើបឡើងរាល់ថ្ងៃ នៅម៉ោង៥:០០ព្រឹក វាស្តាប់ទៅពិបាកណាស់។ ប៉ុន្តែ យើងខ្ញុំគិតថារបៀបទីពីរដែលគ្រូបង្វឹកនិយាយគឺល្អបំផុត។ គាត់បានប៉ះពាល់ចិត្តគំនិតរបស់សមាជិកក្រុមជំនុំ។ ហើយប្រសិនបើនរណាម្នាក់មិនគោរពច្បាប់ក្នុងការមិនខំប្រឹងដោយអស់ពីចិត្តសម្រាប់ក្រុម នោះមានន័យថា គាត់មិនបានស្តាប់តាមបំណងចិត្តរបស់គ្រូបង្វឹកឡើយ។ ដូចគ្នានោះដែរ នេះក៏ជាការដូចនឹងការថ្វាយតង្វាយក្នុងក្រុមជំនុំផងដែរ។

## ការឲ្យដោយបរិបូរ

ដោយសារយើងខ្ញុំបានលើកឡើងពីចំណុចទាំងនោះរួចហើយ ឥឡូវយើងខ្ញុំគិតថា យើងខ្ញុំអាចឆ្លើយសំណួរនោះ។ ពេលដែលយើងថ្វាយធនធានរបស់យើងក្នុងការគាំទ្រព័ន្ធកិច្ចដំណឹងល្អ តើព្រះជាម្ចាស់បានតម្រូវឲ្យយើងថ្វាយដល់ភាគរយប៉ុន្មានដល់ក្រុមជំនុំ? ពិតណាស់! យោងតាមការពិភាក្សារបស់យើង ចម្លើយគឺថា៖ ព្រះអង្គមិនបានកំណត់ចំនួនភាគរយទេ។ ចម្លើយលើសំណួរគឺមិនពឹងលើច្បាប់ ឬក៏ចំនួនភាគរយទេ។ ចម្លើយគឺពឹងលើទំហំនៃដួងចិត្តរបស់លោកអ្នក លើទស្សនៈព្រះគម្ពីរទាក់ទងនឹងក្រុមជំនុំតាមតំបន់

និងលើការឲ្យតម្លៃដ៏ល្អនៃព័ន្ធកិច្ច។

យើងខ្ញុំគិតថា ព្រះជាម្ចាស់មានផែនការដ៏ពិសេសសម្រាប់ក្រុមជំនុំតាមតំបន់ ដូច្នេះយើងដែលជាសមាជិកក៏ត្រូវថ្វាយដល់ក្រុមជំនុំដែរ។ ព័ន្ធកិច្ចផ្សេងៗសំខាន់ណាស់ ហើយយើងខ្ញុំចង់ឃើញព័ន្ធកិច្ចនោះលូតលាស់។ ហើយយើងខ្ញុំក៏មានចំណែកក្នុងការធ្វើព័ន្ធកិច្ចមួយចំនួនដែរ។ ប៉ុន្តែ ស្ថាប័នមួយក្នុងផែនដីនេះមានការលើកឡើងយ៉ាងច្បាស់លាស់ក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយច្បាស់ក្នុងដំណឹងល្អគឺត្រង់ក្រុមជំនុំតាមតំបន់។ ប្រសិនបើស្ថាប័ននេះបរាជ័យ នោះមានន័យថា ព័ន្ធកិច្ចផ្សេងៗនឹងគ្មានប្រយោជន៍ទៀតទេ។ ប្រាកដណាស់ ប្រសិនបើក្រុមជំនុំបរាជ័យ នោះមានន័យថា ព័ន្ធកិច្ចផ្សេងៗគ្មានជំហរលើព្រះគម្ពីរទៀតទេ។ ក្រុមជំនុំគឺជារោងសម្រាប់ព័ន្ធកិច្ចផ្សេងៗទៀត។ ក្រុមជំនុំជាកន្លែងដែលអ្នកប្រួបប្រួមក្នុងព័ន្ធកិច្ចនោះទទួលបានការថែបំប៉ន ហើយក៏ជាកន្លែងនៃការថ្វាយបង្គំរួមគ្នាយោងតាមព្រះគម្ពីរផងដែរ។

យើងខ្ញុំគិតថា នេះជា «ច្បាប់» ដ៏ត្រឹមត្រូវមួយ។ សូមទទួលយកការបង្រៀននេះចុះ។ យើងខ្ញុំគិតថា យើងគួរតែថ្វាយតង្វាយជាចម្បងដល់ក្រុមជំនុំ ហើយបន្ទាប់មក យើងគួរថ្វាយលើសពីនោះដល់ព័ន្ធកិច្ចផ្សេងៗ។ ប៉ុន្តែ នេះមិនមែនជាច្បាប់ ឬក៏ជាការទាមទារឲ្យធ្វើនោះទេ។ យើងខ្ញុំមិនអាចអះអាងថា៖ «ព្រះយេហូវ៉ាទ្រង់មានបន្ទូលដូច្នេះ» ទេ។ នេះមិនមែនជាការទាមទារទេ។ នេះគ្រាន់តែជាការណែនាំដែលអាចជាជំនួយមួយប៉ុណ្ណោះ។

ហើយប្រាកដណាស់ យើងខ្ញុំក៏ស្គាល់អ្នកមនុស្សមួយចំនួនដែលមិនអាចចាប់ផ្ដើមថ្វាយដល់ក្រុមជំនុំតាមតំបន់របស់ខ្លួនឡើយ ព្រោះតង្វាយរបស់ពួកគេទំនងច្រើនជាងលុយដែលក្រុមជំនុំមានទៅទៀត។ ប្រាកដណាស់ មានករណីលើកលែងបែបនេះ។ ប៉ុន្តែ យើងខ្ញុំចង់ផ្ដោតលើចំណុចនេះ៖ យើងគួរតែថ្វាយដោយចិត្តសទ្ធា។ ចូរថ្វាយដោយមានការលះបង់។ ចូរយើងមានភាពស្មោះត្រង់ចំពោះក្រុមជំនុំតាមតំបន់របស់យើង។ ហើយចូរឲ្យយើងគិត



50 QnA John Piper Final 1.5.indd 226 25/01/2024 09:23:13 AM

ពីអនាគតទាក់ទងនឹងការគាំទ្រព័ន្ធកិច្ចជាច្រើនផ្សេងៗទៀត។ យើងខ្ញុំគិតថា ព្រះជាម្ចាស់នឹងប្រាប់យើងពីភាគរយនៃការថ្វាយ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 227 25/01/2024 09:23:14 AM

## សំណួរទី៤០៖
# ជីវិតពិបាកណាស់ តែ «ព្រះអង្គល្អ»

ជីវិតពិបាកណាស់ ហើយព្រះជាម្ចាស់ទ្រង់ល្អ។ នេះគឺជាចំណុចស្នូលដែលលោកគ្រូ ចន ផាយភ័រ បានបង្ហាញនៅក្នុងសេចក្តីអធិប្បាយរបស់គាត់ដែលមានចំណងជើងថា "អរព្រះគុណដល់ព្រះជាម្ចាស់សម្រាប់សេចក្តីមេត្តាករុណារបស់ព្រះគ្រីស្ទ" ដែលគាត់បានអធិប្បាយនៅថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលបានដកស្រង់ចេញពីកណ្ឌគម្ពីរបរិទេវជំពូកទី៣។ នេះគឺជាអ្វីដែលគាត់បានមានប្រសាសន៍។

កណ្ឌគម្ពីរបរិទេវគឺជាកណ្ឌគម្ពីរតូចមួយដែលស្ថិតនៅកណ្តាលរវាងកណ្ឌគម្ពីរយេរេមាដែលជាកណ្ឌហោរាធំ និងកណ្ឌគម្ពីរអេសេគាល។ ហើយវាគឺជាកណ្ឌគម្ពីរមួយដែលខ្ញុំគិតថា មិនមានមនុស្សជាច្រើនដឹងអំពីវានោះទេ ពីព្រោះវាខ្លីពេក ហើយក៏កប់ជ្រៅនៅចន្លោះកណ្ឌគម្ពីរទាំងពីរនោះដែរ។ កណ្ឌគម្ពីរនេះមិនមានគេអានច្រើននោះទេ។ ហើយមូលហេតុមួយទៀតក្នុងចំណោមមូលហេតុជាច្រើនដែលគេមិនសូវអានកណ្ឌគម្ពីរនេះគឺដោយសារកណ្ឌគម្ពីរនេះគឺជាកណ្ឌគម្ពីរដ៏រន្ធត់មួយ—ពីព្រោះកណ្ឌគម្ពីរនេះបានបង្ហាញតាមរយៈរូបភាពដ៏គួរឲ្យរន្ធត់នៃការជំនុំជម្រះរបស់ព្រះជាម្ចាស់លើក្រុងយេរូសាឡិម។ ហោរា យេរេមា បានសរសេរកណ្ឌគម្ពីរដ៏ខ្លីនេះនៅពេលដែលទីក្រុងយេរូសាឡិមត្រូវបានបំផ្លាញនៅក្នុងឆ្នាំ៥៨៧ មុនគ.ស. ហើយរូបភាពនៃការបំផ្លាញនេះគឺអាក្រក់មែនទែន៖ ការបាត់បង់ជីវិត ការអត់ឃ្លានដោយសារការឡោមព័ទ្ធ។

### សេចក្តីមេត្តាករុណាមិនដែលបរាជ័យឡើយ

ប៉ុន្តែ—នេះគឺមានចំណុចដ៏អស្ចារ្យមួយ—នៅចំណុចកណ្តាលនៃកណ្ឌគម្ពីរ

ដែលមាន៥ជំពូកនេះ នៅក្នុងជំពូកកណ្ដាល មានចែងនូវពាក្យពេចន៍ដ៏មានតម្លៃ និងផ្អែមល្ហែមបំផុតដែលព្រះជាម្ចាស់ធ្លាប់មានបន្ទូលតាមរយៈហោរាម្នាក់នេះទៅកាន់ប្រជារាស្ត្ររបស់ទ្រង់ឡើយ។ ហើយពាក្យពេចន៍ទាំងនោះគឺជាអ្វីដែលខ្ញុំចង់អាន ពីព្រោះកណ្ឌគម្ពីរនេះមានការប៉ះពាល់ចិត្តពិសេសមួយ នៅពេលដែលលោកអ្នកយល់ពាក្យនោះ៖ កណ្ឌគម្ពីរ បរិទេវ ៣:២១-២៥ មានចែងដូចនេះ៖

តែខ្ញុំនឹកឡើងវិញពីសេចក្ដីនេះ

បានជាខ្ញុំមានសេចក្ដីសង្ឃឹមឡើង

គឺនឹកពីសេចក្ដីនេះថា កុំតែមានសេចក្ដីសប្បុរសរបស់ព្រះយេហូវ៉ា នោះយើងបានសូន្យបាត់អស់រលីងទៅហើយ ឯសេចក្ដីមេត្តាករុណារបស់ទ្រង់នោះមិនចេះផុតឡើយ សេចក្ដីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្ដីស្មោះត្រង់របស់ទ្រង់ធំណាស់

ព្រលឹងខ្ញុំបានពោលថា “ព្រះយេហូវ៉ាជាចំណែកនៃខ្ញុំ ហេតុនោះខ្ញុំនឹងសង្ឃឹមដល់ទ្រង់”

ព្រះយេហូវ៉ាទ្រង់ល្អដល់អស់អ្នកដែលរង់ចាំទ្រង់

គឺដល់ព្រលឹងនៃអ្នកណាដែលស្វែងរកទ្រង់»។

ខគម្ពីរនេះគួរតែប៉ះពាល់គំនិតរបស់លោកអ្នក ដោយសារពាក្យពេចន៍ដ៏មានតម្លៃទាំងនោះ ជាពិសេសនៅឃ្លាដែលថា «សេចក្ដីមេត្តាករុណារបស់ទ្រង់…ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច» ព្រះអង្គបានមានបន្ទូលនៅក្នុងស្ថានភាពដែលគួរឲ្យរន្ធត់នៅក្នុងការរងទុក្ខផ្ទាល់តែម្ដង។ ការរងទុក្ខ ការបំផ្លិចបំផ្លាញ—ឪពុកម្ដាយស៊ីសាច់កូនៗរបស់ខ្លួន ព្រោះពួកគេឃ្លានខ្លាំងពេក (បរិទេវ ៤:១០)។ ហើយការឡោមព័ន្ធនោះគឺអាក្រក់មែនទែន។



50 QnA John Piper Final 1.5.indd 230 25/01/2024 09:23:14 AM

## រៀបចំឡើងសម្រាប់សេចក្ដីមេត្តាករុណា

តើពាក្យពេចន៍ទាំងនេះបានសរសេរចូលសៀវភៅនោះបានដោយរបៀបណា? ហើយជាការពន្យល់មួយផ្នែក ខ្ញុំចង់អានពីរខទៀត។ សូមផ្ទៀងជាមួយខ្ញុំនៅក្នុងកណ្ឌគម្ពីរ បរិទេវ ៣:៣២-៣៣។

តែទោះបើទ្រង់ធ្វើទុក្ខក៏ដោយ គង់តែទ្រង់នឹងអាណិតមេត្តា
ដោយសេចក្ដីសប្បុរសដ៏បរិបូររបស់ទ្រង់ដែរ
ពីព្រោះទ្រង់មិនធ្វើទុក្ខ
ឬឲ្យមនុស្សជាតិត្រូវវេទនា ដោយស្ម័គ្រពីព្រះហឫទ័យទេ។

ឥឡូវនេះ តិចបំផុតក៏យើងអាចរៀនបានចេញពីខគម្ពីរទាំងនោះដែរថា៖ ពេលខ្លះ សេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់គឺត្រូវបានលាក់បាំង និងពិបាកក្នុងការមើលឃើញ ខណៈពេលដែលសេចក្ដីមេត្តាករុណាទាំងនោះកំពុងកើតឡើង ពីព្រោះមានចែងថា ព្រះអង្គទ្រង់ធ្វើទុក្ខ ហើយក៏ធ្វើឲ្យវេទនាផងដែរ។ ហើយវានៅតែមានលើកឡើងថា ក្នុងគ្រប់ទាំងអស់មានគោលបំណងនៃសេចក្ដីមេត្តាករុណា។ ហើយវាមិនមែនចេញមកពីជម្រៅនៃព្រះទ័យទ្រង់ទេ។ ព្រះអង្គមិនសព្វព្រះទ័យធ្វើទុក្ខដល់មនុស្សជាតិនោះទេ។ មានគោលបំណងជាច្រើនសម្រាប់ការរងទុក្ខរបស់ទ្រង់។ វាមិនមែនជាអ្វីដែលព្រះអង្គសព្វព្រះទ័យបំផុតក្នុងការធ្វើនោះឡើយ ប៉ុន្តែព្រះអង្គក៏នៅបានធ្វើការនោះឡើងដែរ។ ហើយប្រសិនបើយើងនឹងទុកចិត្តព្រះអង្គ នោះមានសេចក្ដីមេត្តាករុណារបស់ទ្រង់ដែលបានទុកនៅទីនោះសម្រាប់យើង។

ដូចនឹងកណ្ឌគម្ពីរយ៉ូប លោកអ្នកក៏បានដឹងពីដំណើររឿងរបស់លោកយ៉ូប។ គាត់បានបាត់បង់អ្វីៗគ្រប់យ៉ាងដែលគាត់មាន។ គាត់បានបាត់បង់កូនៗរបស់គាត់ទាំង១០នាក់—កូនៗទាំងអស់។ គាត់បាត់បង់ទ្រព្យសម្បត្តិរបស់គាត់ទាំងអស់។ សុខភាពរបស់គាត់ក៏បានទ្រុឌទ្រោម។ ហើយរាប់ពាន់ឆ្នាំក្រោយមក លោក យ៉ាកុប ដែលជាប្អូនប្រុសរបស់ព្រះយេស៊ូវបានសរសេរ



50 QnA John Piper Final 1.5.indd 231 25/01/2024 09:23:14 AM

នៅក្នុងជំពូក ៥:១១ ដោយបកស្រាយនៅក្នុងកណ្ឌគម្ពីរនោះ។ គាត់បានលើកឡើងថា៖

*ចុះអ្នករាល់គ្នាបានឮនិយាយពីសេចក្តីអត់ធន់របស់លោកយ៉ូបទៅហើយ ក៏បានឃើញថាដល់ចុង បំផុត នោះព្រះអម្ចាស់ទ្រង់មានព្រះហឫទ័យមេត្តាករុណា នឹងសេចក្តីអាណិតអាសូរពោរពេញ ដែរ។*

ដូច្នេះ យោងតាមលោក យ៉ាកុប កណ្ឌគម្ពីរយ៉ូបក៏ពិតជាបានលើកឡើងអំពីទុក្ខលំបាកបែបនេះមែន។ គាត់បានបាត់បង់កូនៗរបស់គាត់ទាំងអស់។ ចំពោះលោក យ៉ូប សុខភាពគាត់ក៏បានធ្លាក់ចុះទាំងស្រុង។ គាត់បានបាត់បង់ទ្រព្យសម្បត្តិរបស់គាត់ទាំងអស់ ហើយខគម្ពីរនោះបានចែងថា បំណងព្រះហឫទ័យរបស់ព្រះអម្ចាស់គឺសេចក្តីមេត្តាករុណា និងសេចក្តីអាណិតអាសូរ។ ដូច្នេះ ប្រសិនបើយើងនឹងទុកចិត្តព្រះអង្គ នោះគឺជាអត្ថន័យនៃការបំផ្លាញនៃទីក្រុងយេរូសាឡិមហើយ។ នោះគឺជាអត្ថន័យនៃការបាត់បង់សុខភាពរបស់គាត់។ ហើយឥឡូវនេះ ខ្ញុំមិនដឹងថាលោកអ្នកកំពុងនៅក្នុងស្ថានភាពបែបណានោះទេ ប៉ុន្តែប្រសិនបើលោកអ្នកទុកចិត្តលើព្រះជាម្ចាស់ នោះសេចក្តីមេត្តាករុណារបស់ព្រះអង្គមាននៅក្នុងជីវិតរបស់លោកអ្នកហើយ។ គឺនៅក្នុងគ្រប់ចំណុចនៃជីវិតរបស់លោកអ្នក—សេចក្តីមេត្តាករុណា និងការរៀបចំឡើង ជាការរៀបចំឡើងដោយសេចក្តីមេត្តាករុណា។ ប្រសិនបើលោកអ្នកនឹងទុកចិត្តលើព្រះជាម្ចាស់ ហើយដើរតាមព្រះអង្គ ដើម្បីទទួលបានសេចក្តីមេត្តាករុណានោះ នោះមិនយូរមិនឆាប់លោកអ្នកនឹងឃើញសេចក្តីមេត្តាករុណានោះជាមិនខាន។

### «ព្រះអង្គល្អ»

យើងអាចនិយាយតាមពាក្យសម្តីរបស់អ្នកស្រី ស៊ូសាន ស៊្យែលលី (Susan Shelley) ដែលជាភរិយារបស់លោក ម៉ាស្សែល ស៊្យែលលី



50 QnA John Piper Final 1.5.indd 232 25/01/2024 09:23:15 AM

(Marshall Shelley)។ លោក ម៉ាស្សែល ស៊្សែលលី គឺជាអ្នកកែសម្រួលអត្ថបទម្នាក់សម្រាប់ទស្សនាវដ្ដី «ជំនឿគ្រីស្ទបរិស័ទសព្វថ្ងៃនេះ»។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩១ ពីរទៅបីថ្ងៃមុនថ្ងៃបុណ្យអរព្រះគុណ នៅម៉ោង ៨:២០នាទីល្ងាច កូនប្រុសរបស់គាត់បានកើតមក។ នៅម៉ោង ៨:២២នាទីល្ងាច ពីរនាទីក្រោយមក កូននោះក៏បានស្លាប់ទៅ។ បួនឆ្នាំក្រោយមក លោក ម៉ាស្សែល បានសរសេរអត្ថបទមួយនៅក្នុងទស្សនាវដ្ដី «ជំនឿគ្រីស្ទបរិស័ទសព្វថ្ងៃនេះ» អំពីការនេះដែលមានចំណងជើងថា «ពីរនាទីទៅកាន់ភាពអស់កល្បជានិច្ច» ដែលនោះគឺជាអត្ថបទដ៏គួរឲ្យកត់សម្គាល់មួយ។ អ្នកគ្រូពេទ្យបានបីកូនដែលស្លាប់នោះមកហើយសួរលោកស្រីថា «តើកូននេះមានឈ្មោះដែរឬទេ?» ហើយគាត់បានឆ្លើយថា "“ថូប៊ី” (Toby) នេះគឺជាឈ្មោះកាត់សម្រាប់ឈ្មោះនៅក្នុងព្រះគម្ពីរដែលហៅថា ថូប៊ីយ៉ា មានន័យថា “ព្រះអង្គល្អ”»។

ហើយនៅពេលលោក ម៉ាស្សែល បានទៅសំណេះសំណាលជាមួយអតីតនិស្សិតនៃសកលវិទ្យាល័យ វីតតុន (Wheaton) ប៉ុន្មានឆ្នាំក្រោយមកនៅសកលវិទ្យាល័យ វីតតុន គាត់បានប្រាប់ដំណើររឿងនេះ ហើយនៅចុងបញ្ចប់នៃការអធិប្បាយរបស់គាត់ដោយសង្ខេបថា «ជីវិតពិបាកណាស់ តែ “ព្រះអង្គល្អ”»។ ជីវិតពិបាកណាស់តែព្រះអង្គល្អ។ នោះគឺជាអត្ថន័យនៃកណ្ឌគម្ពីរបរិទេវ។ នោះគឺជាអត្ថន័យរបស់លោកយ៉ូប។ លោកអ្នកប្រហែលជានិយាយថា នោះគឺជាអត្ថន័យនៃព្រះគម្ពីរ៖ «*ជីវិតពិបាកណាស់ តែ “ព្រះអង្គល្អ”*»។

ហើយមានមនុស្សជាច្រើនក្នុងចំណោមលោកអ្នកក៏កំពុងស្ថិតនៅចំណុចនៃការបញ្ជាក់ថា វាក៏ដូច្នេះមែន។ យ៉ាងហោចណាស់ប្រសិនបើលោកអ្នកទុកចិត្តលើព្រះអង្គ ប្រសិនបើខ្ញុំពិតជាអាចនាំឲ្យលោកអ្នកជឿមែនលើចំណុចនេះថា នោះយើងអាចទុកចិត្តលើព្រះជាម្ចាស់បាន ហើយប្រសិនបើលោកអ្នកទទួលយកមែន នោះលោកអ្នកនឹងដឹងថា ជីវិតពិបាកណាស់ តែ “ព្រះ



50 QnA John Piper Final 1.5.indd 233 25/01/2024 09:23:15 AM

អង្គល្អ”។

ខ្ញុំអធិស្ឋានសូមឲ្យព្រះជាម្ចាស់ប្រទានឲ្យយើងមានភ្នែកឲ្យអាចមើល
ឃើញពីសេចក្ដីមេត្តាករុណារបស់ទ្រង់នៅក្នុងជីវិតរបស់ខ្លួន ហើយឲ្យយើង
អាចឃើញសេចក្ដីមេត្តាករុណាទាំងនោះកាន់តែច្បាស់ និងដឹងថាទាំងនោះ
គឺជាសេចក្ដីមេត្តាករុណា ប្រសិនបើយើងដឹងពីតម្លៃដែលបានបង់សម្រាប់
យើង។ ព្រះអង្គបានចាត់ព្រះរាជបុត្រារបស់ទ្រង់ដែលជាព្រះយេស៊ូវគ្រីស្ទ
ឲ្យមកក្នុងលោកីយ៍ ដើម្បីសុគត ដើម្បីឲ្យកំហុសរបស់ខ្ញុំត្រូវបានដកចេញ
ហើយសេចក្ដីក្រោធរបស់ទ្រង់លុបចេញពីខ្ញុំ  ហើយខ្ញុំនឹងមានសេរីភាព
ដោយសេចក្ដីមេត្តាករុណារបស់ទ្រង់បើកបង្ហូរមកលើខ្ញុំ ខណៈពេលដែល
ព្រះអង្គនៅយុត្តិធម៌ផងដែរ។ ទោះបីខ្ញុំជាមនុស្សមានបាបក៏ដោយ ក៏ព្រះអង្គ
អាចប្រព្រឹត្តនឹងខ្ញុំដោយសេចក្ដីមេត្តាករុណាដែរ។ នោះគឺជារឿងដ៏ អស្ចារ្យ
ដែលព្រះអង្គបានធ្វើតាមរយៈព្រះយេស៊ូវគ្រីស្ទ។ ហើយយើងអាចភ្លក់នូវ
សេចក្ដីមេត្តាករុណានោះកាន់តែផ្អែមថែមទៀតបាន ប្រសិនបើយើងស្គាល់
ពីតម្លៃនោះ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 234 25/01/2024 09:23:15 AM

# សំណួរទី៤១៖
# ជំហានបីយ៉ាងក្នុងការឈប់ចំណាយជីវិតដោយឥតប្រយោជន៍

*លោកគ្រូ ចន បានលើកឡើងអំពី «ជំហានបីយ៉ាងក្នុងការឈប់ចំណាយជីវិតដោយឥតប្រយោជន៍»។ នេះជាអ្វីដែលគាត់បានលើកឡើង។*

## ចូរពឹងផ្អែកលើព្រះអម្ចាស់

កណ្ឌគម្ពីរ សុភាសិត ៣:៥-៦ បានលើកឡើងថា «ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងតម្រង់អស់ទាំងផ្លូវច្រករបស់ឯង»។

នៅពេលអ្នកម្ដាយរបស់ខ្ញុំបានសរសេរសំបុត្រមកកាន់ខ្ញុំ ខណៈពេលខ្ញុំរៀននៅសាកលវិទ្យាល័យ និងនៅរៀនអនុបណ្ឌិត នេះប្រហែលជាខគម្ពីរមួយដែលគាត់ចែកចាយច្រើនបំផុត។ គោលបំណងចម្បងនៃខគម្ពីរនេះគឺថា ឲ្យដើរក្នុងផ្លូវត្រង់។ នេះគឺជាមូលហេតុដែលគាត់បានលើកវាឡើងយ៉ាងញឹកញាប់។

គាត់មិនចង់ឲ្យខ្ញុំវង្វេងចេញពីផ្លូវ ហើយមិនស្ដាប់បង្គាប់ព្រះជាម្ចាស់នោះទេ។ គាត់មិនចង់ឲ្យខ្ញុំចំណាយជីវិតរបស់ខ្ញុំដោយឥតប្រយោជន៍ ឬក៏ធ្វើអ្វីមួយដែលមិនផ្ដល់កិត្តិយសដល់ព្រះជាម្ចាស់ឡើយ។ ខ្ញុំមិនចង់ឲ្យលោកអ្នកវង្វេងចេញទេ។ ហើយព្រះជាម្ចាស់ក៏មិនសព្វព្រះទ័យឲ្យយើងវង្វេងចេញដែរ។ នេះគឺជាគោលបំណងព្រះជាម្ចាស់នឹងតម្រង់អស់ទាំងផ្លូវរបស់យើង ឲ្យត្រង់ឆ្ពោះទៅកាន់ការស្ដាប់បង្គាប់ ត្រង់ឆ្ពោះទៅកាន់អំណរដ៏នៅអស់កល្បជានិច្ច ហើយត្រង់ឆ្ពោះទៅកាន់ជីវិតដែលថ្វាយព្រះកិត្តិយស



50 QnA John Piper Final 1.5.indd 235 25/01/2024 09:23:16 AM

ដល់ព្រះជាម្ចាស់។ ហើយលោកគ្រូមានប្រសាសន៍ថា មានបីជំហាន ដើម្បីទៅដល់ចំណុចនោះ។

**១. ទុកចិត្តព្រះជាម្ចាស់**

ជំហានដំបូង ព្រះជាម្ចាស់មានបន្ទូលប្រាប់យើង ឲ្យទុកចិត្តព្រះអម្ចាស់ដោយអស់អំពីចិត្ត។

ចូរទុកចិត្តសេចក្ដីសន្យានានារបស់ព្រះជាម្ចាស់សម្រាប់គ្រប់ជំហាននៅក្នុងជីវិតរបស់លោកអ្នក។ ចូរទុកចិត្តនៅលើសេចក្ដីសប្បុរស ភាពបរិសុទ្ធ សេចក្ដីមេត្តា សេចក្ដីស្រឡាញ់ ការផ្គត់ផ្គង់ ការស្កប់ចិត្តជាមួយព្រះជាម្ចាស់យ៉ាងពេញទី សម្រាប់គ្រប់ពេលវេលាទាំងអស់នៅក្នុងជីវិតរបស់លោកអ្នក។

**២. ចូរបដិសេធលើការមានភាពឯករាជលើខ្លួនឯង**

ជំហានទី២ ព្រះជាម្ចាស់មានបន្ទូលថា «កុំឲ្យពឹងផ្អែកលើការយល់ដឹងរបស់ខ្លួនឯងឡើយ» ដែលនេះមានន័យថា លោកអ្នកត្រូវតែជ្រើសរើសមិនពឹងផ្អែកលើខ្លួនឯង។

សូមនិយាយមកកាន់ខ្លួនឯងថា «ខ្ញុំសូមសារភាពថា ខ្ញុំខ្លួនឯងទេដែលមិនគ្រប់គ្រាន់នោះ។ ខួរក្បាលរបស់ទូលបង្គំតែឯងមិនមានប្រាជ្ញាគ្រប់គ្រាន់ឡើយ»។ សូមបែរចេញពីការពឹងផ្អែកលើខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយក៏នេះមិនមែនមានន័យថា លោកអ្នកមិនគួរគិត ឬរៀបចំផែនការនោះទេ។ វាគ្រាន់តែមានន័យថា លោកអ្នកមិនចាំបាច់ត្រូវពឹងផ្អែកលើខ្លួនឯងទាំងស្រុងនោះទេ។

គេត្រៀមសេះទុកសម្រាប់ថ្ងៃសឹកសង្គ្រាម តែការដែលមានជ័យជំនះ នោះស្រេចនៅព្រះយេហូវ៉ាទេ (សុភាសិត ២១:៣១)។ ដូច្នេះ សូម្បីតែនៅចំណុចកណ្ដាលនៃការមានគម្រោងការ និងការគិតជាមួយនឹងគំនិតរបស់យើង នោះយើងក៏កំពុងពឹងផ្អែកលើព្រះអម្ចាស់ដែរ។ យើងមិនត្រូវពឹងផ្អែកលើធនធាន



50 QnA John Piper Final 1.5.indd 236 25/01/2024 09:23:16 AM

របស់យើងនោះទេ។

## ៣. ចូរទទួលស្គាល់ព្រះជាម្ចាស់

ជំហានទី៣គឺថា «នៅក្នុងគ្រប់ទាំងផ្លូវរបស់ឯង ចូរទទួលស្គាល់ទ្រង់»។ នៅក្នុងភាសាហេប្រឺ យើងអាចបកប្រែថា «ចូរស្គាល់ព្រះជាម្ចាស់នៅក្នុងគ្រប់ទាំងផ្លូវរបស់ឯង»។

ដូច្នេះ នៅក្នុងគ្រប់ពេលណាក៏ដោយ នៅគ្រប់ជម្រើសថ្មីៗ និងគ្រប់ការសន្ទនាថ្មីៗ នោះលោកអ្នកកំពុងផ្ញើរសារទៅកាន់ព្រះជាម្ចាស់ ដោយទូលថា «ឱព្រះជាម្ចាស់អើយ! នៅក្នុងកាលៈទេសៈនេះ ទូលបង្គំទទួលស្គាល់ព្រះអង្គ។ នៅក្នុងកាលៈទេសៈនេះ ទូលបង្គំស្គាល់ទ្រង់។ នៅក្នុងកាលៈទេសៈនេះ ទូលបង្គំត្រូវការព្រះអង្គក្នុងការចូលរួមជាមួយយើងខ្ញុំ។ នៅក្នុងកាលៈទេសៈនេះ ព្រះអង្គជាអង្គដែលសម្រេចនូវអ្វីៗទាំងអស់។ នៅក្នុងកាលៈទេសៈនេះ ទូលបង្គំពឹងផ្អែកលើព្រះអង្គ។

ប្រសិនបើយើងធ្វើតាមជំហានទាំងបីនេះ នោះព្រះជាម្ចាស់នឹងតម្រង់គ្រប់ទាំងផ្លូវរបស់យើងជាមិនខាន។ ចូរទុកចិត្តលើព្រះជាម្ចាស់។ ចូរបដិសេធលើការមានភាពឯករាជលើខ្លួនឯង។ ចូរយកព្រះជាម្ចាស់ដាក់ក្នុងគ្រប់ទាំងចំណុចទាំងអស់នៅក្នុងជីវិតរបស់លោកអ្នក។ ព្រះជាម្ចាស់នឹងរក្សាយើងចេញពីការចំណាយពេលដោយឥតប្រយោជន៍នៅក្នុងជីវិតរបស់យើង ឬការបំផ្លាញខ្លួនឯង និងអ្នកដទៃដោយសារអំពើបាបដែរ។ ព្រះជាម្ចាស់នឹងនាំយើងទៅកាន់អំណរដែលនៅអស់កល្បជានិច្ច។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 237 25/01/2024 09:23:16 AM

# សំណួរទី៤២៖
# ហេតុអ្វីបានជាគ្រីស្ទបរិស័ទថ្វាយបង្គំនៅថ្ងៃអាទិត្យ?

ហេតុអ្វីបានជាធ្វើការថ្វាយបង្គំនៅថ្ងៃអាទិត្យ? តើមានមូលហេតុអ្វីបានជាគ្រីស្ទបរិស័ទទៅព្រះវិហារនៅថ្ងៃអាទិត្យ? ចម្លើយគឺ៖ ឫសគល់នៃការដែលគ្រីស្ទបរិស័ទថ្វាយបង្គំគឺចេញមកពីសាសនាយូដា។ ការនេះបានកើតឡើងក្នុងចំណោមសាសន៍យូដា។ ហើយព្រះគម្ពីររបស់សាសន៍យូដាគឺជាភាគទី១នៃព្រះគម្ពីររបស់គ្រីស្ទបរិស័ទ។ ហើយសាសន៍យូដាមានក្រឹត្យវិន័យមួយក្នុងចំណោមក្រឹត្យវិន័យទាំងដប់ប្រការ «ចូរឲ្យនឹកចាំពីថ្ងៃឈប់សម្រាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ» (និក្ខមនំ ២០:៨)។ ថ្ងៃ «ឈប់សម្រាក» ជាថ្ងៃទីប្រាំពីរ គឺថ្ងៃសៅរ៍ មិនមែនថ្ងៃអាទិត្យនោះទេ។ ដូច្នេះ មានថ្ងៃមួយក្នុងចំណោមថ្ងៃទាំងប្រាំពីរដែលសាសន៍យូដាបានជួបជុំគ្នា។

ហើយមូលហេតុដែលគ្រីស្ទបរិស័ទបានប្ដូរថ្ងៃ ហើយចាប់ផ្ដើមជុំគ្នាថ្វាយបង្គំនៅថ្ងៃដំបូងក្នុងអាទិត្យគឺ ព្រោះព្រះយេស៊ូវបានមានព្រះជន្មរស់ពីសុគតវិញនៅថ្ងៃដំបូងក្នុងអាទិត្យ។

នៅសតវត្សទី១ ពេលដែលក្រុមជំនុំគ្រីស្ទបរិស័ទបានកើតមានឡើងតាមរយៈការយាងមករបស់ព្រះយេស៊ូវ នោះឯងគឺជាទម្លាប់ ពីព្រោះយើងឃើញក្នុងកណ្ឌគម្ពីរកិច្ចការថាសាវ័ក ប៉ុល បានចូលទៅក្នុងសាលាប្រជុំនៃថ្ងៃឈប់សម្រាក ហើយបានចូលរួមជាមួយនឹងសាសន៍យូដាក្នុងការប្រកាសអំពីព្រះគ្រីស្ទ។ ហើយមូលហេតុដែលគ្រីស្ទបរិស័ទបានប្ដូរថ្ងៃ ហើយចាប់ផ្ដើមជុំគ្នាថ្វាយបង្គំនៅថ្ងៃដំបូងក្នុងអាទិត្យគឺ ព្រោះព្រះយេស៊ូវបានមានព្រះជន្មរស់ពីសុគតវិញនៅថ្ងៃដំបូងក្នុងអាទិត្យ។ ហើយក្រុមជំនុំក៏ហៅថ្ងៃនោះថាជា «ថ្ងៃនៃព្រះអម្ចាស់» (វិវរណៈ ១:១០)។ ហើយយើងក៏អានថែមទៀតអំពីគំរូនានា

នៃការជុំគ្នានៅថ្ងៃនៃព្រះអម្ចាស់ ឬក៏ថ្ងៃដំបូងក្នុងកណ្ឌគម្ពីរ កិច្ចការ ២០:៧ ផងដែរ។ នោះពួកគាត់ក៏បានជុំគ្នានៅ «ថ្ងៃដំបូងក្នុងអាទិត្យ»។ ហើយនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៦:២ ក៏បានលើកឡើងថា ពួកគាត់ត្រូវជុំគ្នា ហើយប្រមូលដាក់ទុកនូវតង្វាយនៅថ្ងៃដំបូងក្នុងអាទិត្យ។ នេះហើយគឺជាមូលហេតុដែលយើងធ្វើកម្មវិធីនៅថ្ងៃអាទិត្យ។ ព្រះយេស៊ូវបានមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយបានបង្កើតរាស្ត្រថ្មីសម្រាប់ទ្រង់ផ្ទាល់ ក៏ដូចជាសម្ពោធក្រុមមនុស្សថ្មី ជាការបង្កើតថ្មីដោយមានថ្ងៃថ្វាយបង្គំថ្មី។

ដូច្នេះ សូមអនុញ្ញាតឲ្យខ្ញុំសង្ខេបដូចតទៅ៖ មូលហេតុដែលគ្រីស្ទបរិស័ទទៅព្រះវិហារនៅថ្ងៃអាទិត្យគឺព្រោះព្រះអង្គបានសង្គ្រោះយើងចេញពីអំពើបាបរបស់យើង បាននាំឲ្យយើងមានការរួបរួមគ្នាជាមួយនឹងព្រះគ្រីស្ទដ៏មានព្រះជន្មរស់នៅ ហើយនិងជាមួយគ្នានឹងគ្នាតាមរយៈជំនឿក្នុងព្រះយេស៊ូវ។ ហើយដោយសារការរួបរួមគ្នាជាមួយនឹងព្រះយេស៊ូវ និងគ្នាជាមួយនឹងគ្នានោះឯង បានជាព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបង្គាប់ឲ្យយើងជួបជុំគ្នាឲ្យបានជាប់លាប់ជារៀងរាល់អាទិត្យក្នុងការថ្វាយបង្គំព្រះជាម្ចាស់ដោយបង្ហាញអំពីអំណររបស់យើង និងការអរព្រះគុណដល់ព្រះអង្គ។ គឺមិនមែនឲ្យយើងធ្វើការនេះតែម្នាក់ឯងនៅកន្លែងនេះកន្លែងនោះនោះទេ ប៉ុន្តែឲ្យជុំគ្នាក្នុងការអធិស្ឋាន ច្រៀង និងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏ដូចជាប្រារព្ធពិធីបុណ្យផ្សេងៗ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 240 25/01/2024 09:23:17 AM

## សំណួរទី៤៣៖
# របៀប៦យ៉ាងសម្រាប់ឪពុកម្តាយ ដើម្បីចិញ្ចឹមកូនរឹងចចេស

*សូមលោកគ្រូចែកចាយលើប្រធានបទទាក់ទងទៅនឹងការដែលមានកូនរឹងចចេសបានដែរឬទេ? តើយើងអាចបន្តទុកចិត្តលើព្រះជាម្ចាស់បានដោយរបៀបណា នៅពេលដែលយើងឃើញថាមិនមានភស្តុតាងនៃការដែលព្រះអង្គកំពុងតែធ្វើការនៅក្នុងជីវិតកូនយើង?*

នេះគឺជាសំណួរដ៏ត្រឹមត្រូវក្នុងការសួរថា៖ តើយើងអាចបន្តទុកចិត្តលើព្រះជាម្ចាស់បានដោយរបៀបណា?

### អ្វីដែលឪពុកម្តាយ និងកូនៗត្រូវការខ្លាំងជាងគេបំផុត

តម្រូវការដ៏សំខាន់បំផុតសម្រាប់ឪពុកម្តាយគ្រប់ៗរូបគឺទុកចិត្តលើព្រះជាម្ចាស់៖

- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់បានធ្វើការសម្រាប់យើងក្នុងព្រះយេស៊ូវ ដើម្បីសង្គ្រោះយើងចេញពីអំពើបាបរបស់យើង
- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងបំពេញរាល់គ្រប់សេចក្តីសន្យារបស់ទ្រង់ទៅកាន់កូនៗរបស់ទ្រង់
- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងទ្រទ្រង់យើង—“កុំឲ្យភ័យខ្លាចឡើយ ដ្បិតអញនៅជាមួយនឹងឯង កុំឲ្យស្រយុតចិត្តឲ្យសោះ ពីព្រោះអញជាព្រះនៃឯង អញនឹងចម្រើនកម្លាំងដល់ឯង អើ អញនឹងជួយឯង អើ អញនឹងទ្រឯង ដោយដៃស្តាំដ៏សុចរិតរបស់អញ” (អេសាយ ៤១:១០)—ព្រះអង្គនឹងរក្សាសេចក្តីសន្យានោះ
- ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងមិនបដិសេធមិនប្រទាននូវអ្វីដែល



50 QnA John Piper Final 1.5.indd 241 25/01/2024 09:23:17 AM

ល្អសម្រាប់អស់អ្នកដែលដើរនៅក្នុងផ្លូវត្រឹមត្រូវ (ទំនុកតម្កើង ៨៤:១១)

• ចូរទុកចិត្តលើព្រះជាម្ចាស់ថា ទ្រង់នឹងគ្រាន់តែប្រទានមកកាន់យើង នូវអ្វីដែលល្អសម្រាប់យើង ហើយថារាល់ផ្លូវរបស់ទ្រង់យុត្តិធម៌ និងពេញដោយប្រាជ្ញា

អ្វីដែលកូនៗយើងត្រូវការពីយើងខ្លាំងជាងគេនោះគឺឃើញយើងមានអំណរ មានសេចក្ដីសង្ឃឹម មានសន្តិភាព មានការស្ដាប់បង្គាប់ ការទុកចិត្តព្រះជាម្ចាស់ និងការសម្រាកក្នុងទ្រង់។ ហើយចម្លើយដែលដកស្រង់ចេញពីព្រះគម្ពីរលើសំណួរនេះ—តើយើងអាចបន្តទុកចិត្តលើព្រះជាម្ចាស់ក្នុងចំណុចនេះ និងក្នុងរាល់កាលៈទេសៈបានដោយរបៀបណា—គឺថាយើងឃើញយ៉ាងច្បាស់នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១០:១៧ «ដូច្នេះ សេចក្ដីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ»។

ហើយខ្ញុំគិតថា នេះមិនមែនមានន័យថា វាគ្រាន់តែពាក់ព័ន្ធទៅនឹងការដែលលោកអ្នកបានកែប្រែចិត្ត ហើយទទួលបានជំនឿនៅលើកដំបូង តាមរយៈការឮអំពីព្រះគ្រីស្ទនោះទេ ប៉ុន្តែក៏អំពីការដែលលោកអ្នកទទួលបានជំនឿដែលទទួលបានកម្លាំងជាថ្មីជារៀងរាល់ថ្ងៃ តាមរយៈការឮផងដែរ។ ជំនឿកើតឡើងជាប្រចាំថ្ងៃតាមរយៈការឮ។ ជំនឿមិនកើតឡើងតាមរយៈបុគ្គលណាម្នាក់នោះទេ លើកលែងតែតាមរយៈព្រះយេស៊ូវ។ ជំនឿកើតឡើងតាមរយៈការដែលគ្រូណាម្នាក់អានព្រះគម្ពីរ និងអនុវត្តតាម—បើមិនដូច្នោះ នោះវានឹងមិនបានកើតឡើងឡើយ។

## ការរម្លឹកដ៏មានតម្លៃ៦យ៉ាងសម្រាប់ឪពុកម្ដាយ

សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវខគម្ពីរមួយចំនួនដែលខ្ញុំសង្ឃឹមថានឹងចម្រើនកម្លាំងដល់ជំនឿរបស់យើង ទាក់ទងទៅនឹងកូនៗរបស់យើង។



50 QnA John Piper Final 1.5.indd 242 25/01/2024 09:23:17 AM

**១. ឪពុកម្តាយដ៏ល្អបំផុតនៅក្នុងចក្រវាលនេះមានកូនដែលរឹងចចេស**

ជាដំបូង ខ្ញុំគិតថា វាជាជំនួយដល់ឪពុកម្តាយក្នុងការដឹងថា ទោះបើថាវាចម្លែកប៉ុណ្ណាក៏ដោយ ក៏កូនៗរបស់ព្រះជាម្ចាស់ផ្ទាល់ក៏បានបះបោរទាស់ប្រឆាំងនឹងទ្រង់ផងដែរ។

“ឱស្ថានសួគ៌អើយ ចូរស្តាប់ ហើយផែនដីអើយ ចូរផ្ទៀងត្រចៀកចុះ
ដ្បិតព្រះយេហូវ៉ាទ្រង់បានមានព្រះបន្ទូលហើយថា
អញបានចិញ្ចឹមបីបាច់រក្សាកូន
តែវារាល់គ្នាបានបះបោរនឹងអញវិញ
ឯគោវាស្គាល់ម្ចាស់
ហើយលាក៏ស្គាល់ស្នូករបស់ម្ចាស់វាដែរ
ប៉ុន្តែអ៊ីស្រាអែលមិនស្គាល់សោះ
រាស្ត្រអញមិនពិចារណាទេ” (អេសាយ ១:២-៣)។

មិនមានឪពុកម្តាយណានៅលើផែនដីនេះដែលជាមនុស្សមិនមានបាប តែពេញទៅដោយប្រាជ្ញា ពេញទៅដោយការស្រឡាញ់ ឬក៏ពេញទៅដោយការអត់ធ្មត់នោះទេ។ ក្នុងនាមជាឪពុកម្តាយ អំពើបាបដែលយើងបានប្រព្រឹត្តនៅក្នុងវត្តមានរបស់កូនៗយើង និងអំពើបាបដែលយើងបានប្រព្រឹត្តទៅលើកូនៗរបស់យើងគឺរាប់មិនអស់ទេ ហើយយើងត្រូវតែកែប្រែចិត្តជាប្រចាំ ហើយសូមការអត់ទោស—ទាំងពីព្រះជាម្ចាស់ និងកូនៗរបស់យើង។ ប៉ុន្តែ សូម្បីតែឪពុកដែលល្អបំផុតនៅលើចក្រវាលនេះ—ព្រះជាម្ចាស់ផ្ទាល់—ក៏មានកូនៗដែលទាស់ប្រឆាំងនឹងទ្រង់ផងដែរ។ ដូច្នេះ កុំអនុញ្ញាតឲ្យសាតាំងទាញទម្លាក់លោកអ្នកឡើយ ដោយមានពិរុទ្ធភាពដែលបំផ្លាញជំនឿរបស់ខ្លួនខ្លាំងជាងលោកអ្នកអាចទ្រទ្រង់បាន។



50 QnA John Piper Final 1.5.indd 243 25/01/2024 09:23:17 AM

## ២. ព្រះគុណរបស់ព្រះជាម្ចាស់ក៏អាចឈោងចាប់មនុស្សមានបាបដ៏ខ្លាំងបំផុតបានដែរ

សាវ័ក ប៉ុល បានលើកឡើងខ្លួនគាត់ជាឧទាហរណ៍ថាជាមនុស្សមានបាបដ៏ខ្លាំងជាងគេបំផុត ដែលនេះមិនគ្រាន់តែមានន័យថា គាត់បានប្រព្រឹត្តនូវអ្វីដែលអាក្រក់ៗខ្លាំងជាងគេនោះទេ ប៉ុន្តែមានន័យថាគាត់បានប្រព្រឹត្តទាស់នឹងពន្លឺដ៏ខ្លាំងបំផុត គឺព្រះជាម្ចាស់ផ្ទាល់។ គាត់បានធំធាត់ឡើងក្រោមការដឹកនាំរបស់លោក កាម៉ាលាល ដែលជាគ្រូបង្រៀនព្រះគម្ពីរសញ្ញាចាស់ដ៏ល្អបំផុតដែលមាននៅក្នុងសម័យកាលនោះ។ គាត់បានលើកឧទាហរណ៍នេះ ដើម្បីលើកទឹកចិត្តយើងថា គ្មានអ្នកណាក្នុងចំណោមយើង ឬក៏ក្នុងចំណោមកូនៗរបស់យើង ដែលព្រះមិនអាចកែបាននោះឡើយ។ ហេតុដូច្នេះហើយបានជាគាត់សរសេរនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ១:១២-១៥៖

“ខ្ញុំមិនបើកឲ្យស្ត្រីណាបង្រៀន ឬឲ្យមានអំណាចលើបុរសទេ ត្រូវឲ្យគេនៅដោយស្រគត់ស្រគំចុះ ពីព្រោះព្រះបានបង្កើតលោកអ័ដាមមកជាមុន រួចមកនាងអេវ៉ា ហើយមិនមែនលោកអ័ដាម ដែលចាញ់បញ្ឆោតទេ គឺជាស្ត្រីវិញទេតើ ដែលចាញ់បញ្ឆោតនោះព្រមទាំងរំលងច្បាប់ផង តែបើសិនជានាងនៅជាប់ក្នុងសេចក្តីជំនឿ សេចក្តីស្រឡាញ់ នឹងសេចក្តីបរិសុទ្ធ ទាំងមានគំនិតមារយាទ នោះនាងនឹងបានសង្គ្រោះក្នុងកាលដែលបង្កើតកូន”។

នេះមានន័យថា មិត្តអ្នកអានសុទ្ធតែស្គាល់នរណាម្នាក់ ឬក៏ខ្លួនធ្លាប់ជាបុគ្គលដែលបានប្រព្រឹត្តអំពើបាបយ៉ាងសាហាវ ដែលពីមុនធ្លាប់បានធំធាត់ឡើងក្នុងផ្ទះ ដែលមានឪពុកម្តាយល្អ ប៉ុន្តែបានបោះបង់ឱកាសនោះចោលជាច្រើនដង គឺជាបុគ្គលដែលមិនមែននៅឆ្ងាយពេក ដល់ថ្នាក់ថាការអត់ធ្មត់របស់ព្រះយេស៊ូវមិនអាចឈោងចាប់គាត់បានឡើយ។ ដូច្នេះ យើងរម្លឹកចំណុចនេះមកកាន់ខ្លួនឯង ហើយយើងចម្រើនកម្លាំងដល់ជំនឿរបស់យើងតាមរយៈប្រយោគដ៏អស្ចារ្យនោះរបស់សាវ័ក ប៉ុល។

## ៣. ព្រះជាម្ចាស់មានពេញទៅដោយអធិបតេយ្យភាពលើដួងចិត្តរបស់មនុស្ស

សូមសញ្ជឹងគិតឲ្យបានច្រើនដងលើសេចក្តីពិតត្រង់ថា ព្រះជាម្ចាស់មានពេញទៅដោយអធិបតេយ្យភាពលើដួងចិត្តរបស់មនុស្ស ហើយជាលទ្ធផលអាចនាំឲ្យសត្វអូដ្ឋចូលតាមរយៈរន្ធម្ជុលបាន ដែលនោះគឺជាការមិនអាចទៅរួចបាន។

ខ្ញុំលើកឡើងដូច្នេះគឺដោយសារនៅពេលដែលបុរសដែលជាអ្នកមានបានដើរចេញពីព្រះយេស៊ូវ គឺគាត់បានធ្វើដូច្នោះ ពីព្រោះគាត់ស្រឡាញ់លោកីយ៍—ហើយលោកអ្នកទំនងជាគិតថា នោះគឺជាអ្វីដែលកូនៗរបស់ខ្ញុំកំពុងតែធ្វើ ហើយក៏ធ្លាប់បានធ្វើ៖ ពួកគាត់បានដើរចេញ ហើយឥឡូវនេះពួកគាត់កំពុងតែស្រឡាញ់លោកីយ៍។ នេះគឺជាអ្វីដែលព្រះយេស៊ូវបានលើកឡើងអំពីបុរសម្នាក់នោះ «"កូនអើយ ពួកអ្នកដែលជាប់ចិត្តនឹងទ្រព្យសម្បត្តិ នោះនឹងចូលទៅក្នុងនគរព្រះពិបាកណាស់"...គេ [ពួកសិស្ស] ក៏មានសេចក្តីប្លែកក្នុងចិត្តជាខ្លាំង ទាំងនិយាយគ្នាទៅវិញទៅមកថា "ចុះបើដូច្នេះ តើអ្នកណាអាចនឹងបានសង្គ្រោះ"» (ម៉ាកុស ១០:២៤, ២៦)។ ពួកសិស្សមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។

ហើយព្រះយេស៊ូវក៏បានឆ្លើយតបនៅក្នុងកណ្ឌគម្ពីរ ម៉ាកុស ១០:២៧ «ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត ដ្បិតព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់បាន...»។ នេះគឺជាអ្វីដែលឪពុកម្តាយជាច្រើនមានអារម្មណ៍។ ពួកគាត់មិនគួរផ្តោតលើចំណុចនេះឡើយ។ ពួកគាត់គួរផ្តោតលើផ្នែកទី២នៃខគម្ពីរនេះ៖ «*ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត ដ្បិតព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់បាន*»។

ឱឪពុកម្តាយទាំងឡាយអើយ យើងត្រូវតែរម្លឹកខ្លួនឯងម្តងហើយម្តងទៀតថា៖ «ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត តែព្រះទ្រង់ធ្វើ



50 QnA John Piper Final 1.5.indd 245 25/01/2024 09:23:18 AM

កើត គ្រប់ទាំងអស់ព្រះទ្រង់ធ្វើកើត» ។ ព្រះអង្គកំពុងតែមានបន្ទូលអំពីការនាំបុគ្គល ដែលស្រឡាញ់ទ្រព្យសម្បត្តិរបស់ខ្លួន និងលោកីយ៍ ចូលក្នុងនគររបស់ព្រះ។ ហើយព្រះអង្គបានមានបន្ទូលថា «យើងអាចធ្វើបាន។ យើងអាចធ្វើបាន។ ឯងមិនអាចធ្វើបានទេ។ ប៉ុន្តែ យើងអាចធ្វើបាន។ ដូច្នេះ ចូរទុកចិត្តយើងចុះ»។

## ៤. ចូរយកព្រះយេហូវ៉ាជាសេចក្តីអំណររបស់អ្នក

សូមផ្តោតចំណាប់អារម្មណ៍របស់លោកអ្នកក្នុងការយកព្រះជាម្ចាស់ជាសេចក្តីអំណររបស់ខ្លួន មិនមែនលើការដែលកូនៗរបស់លោកអ្នកនឹងកែប្រែចិត្តឡើយ។ សូមកុំយល់ច្រឡំថា លោកអ្នកបានគួរសប្បាយចិត្តនៅពេលដែលកូនៗកែប្រែចិត្តឡើយ។ វាគឺជារឿងត្រឹមត្រូវក្នុងការដែលលោកអ្នកសប្បាយចិត្តនៅពេលដែលកូនៗរបស់ខ្លួនកែប្រែចិត្ត។ ប្រសិនបើលោកអ្នកមិនសប្បាយចិត្ត នោះមានន័យថា លោកអ្នកមិនប្រក្រតីទេ។ អ្វីដែលខ្ញុំកំពុងតែលើកឡើងនោះគឺថា តើលោកអ្នកផ្តោតលើអ្វីក្នុងជីវិតខ្លួន។

ខ្ញុំកំពុងតែគិតអំពីកណ្ឌគម្ពីរ ទំនុកតម្កើង ៣៧:៤ «ចូរយកព្រះយេហូវ៉ាជាសេចក្តីអំណររបស់អ្នក នោះទ្រង់នឹងប្រទានឲ្យអ្នកបានដូចបំណងចិត្ត»។ សូមផ្តោតកម្លាំងខាងឯវិញ្ញាណរបស់លោកអ្នកលើការបង្កើតសេចក្តីអំណរក្នុងព្រះជាម្ចាស់ថាទ្រង់ជាព្រះ ក្នុងរបៀបដែលរឹងមាំ ជ្រាលជ្រៅ ឥតរង្អើ និងពេញទៅដោយការស្កប់ចិត្ត។ គឺនៅក្នុងតែរបៀបនេះទេ នោះទើបយើងអាចស្ថិតក្នុងកាលៈទេសៈដែលអាចទទួលបាននូវអ្វីដែលមានសល់នៅក្នុងខគម្ពីរនេះ៖ «នោះទ្រង់នឹងប្រទានឲ្យអ្នកបានដូចបំណងចិត្ត»។

## ៥. ចូរមានបំណងចិត្តចង់ឃើញមនុស្សបាត់បង់ទទួលជឿ

សូមបណ្តាលឲ្យការមានបំណងចិត្ត ការឈឺចាប់ ការអធិស្ឋាន និងសម្រែកយំរបស់លោកអ្នកមានសម្រាប់កូនៗខ្លួន—សូមអនុញ្ញាតឲ្យការ



50 QnA John Piper Final 1.5.indd 246 25/01/2024 09:23:18 AM

ដែលលោកអ្នកចង់ឃើញកូនៗរបស់ខ្លួនកែប្រែចិត្ត និងស្តាប់បង្គាប់—ក្លាយជារង្វាស់នៃការដែលលោកអ្នកចង់ឃើញអ្នកដទៃ ដែលបានបាត់បង់ទទួលជឿផងដែរ។ ចំពោះខ្ញុំ ចំណុចនេះបានក្លាយជាមេរៀនដ៏ធំបំផុត ខណៈពេលដែលខ្ញុំចិញ្ចឹមបីបាច់កូនៗ និងអំពីរបៀបដែលខ្ញុំពិតជាចង់ឃើញពួកគាត់ដើរតាមព្រះគ្រីស្ទ។ ហើយបន្ទាប់មក ខ្ញុំក៏បានយល់ឃើញថា៖ ខ្ញុំមិនបានមានបំណងចិត្តក្នុងការឃើញអ្នកដទៃទទួលជឿដែរ ដូចជាខ្ញុំមានសម្រាប់កូនៗខ្ញុំទេ។ នេះគឺជាចំណុចដែលបានប៉ះពាល់ចិត្តខ្ញុំយ៉ាងខ្លាំងមែនទែន។

សូមអនុញ្ញាតឲ្យកិច្ចការរបស់ព្រះជាម្ចាស់នៃការបង្កើតសេចក្តីប្រាថ្នានៅក្នុងចិត្តរបស់លោកអ្នកសម្រាប់ឲ្យកូនៗរបស់លោកអ្នកកែប្រែចិត្តបង្កើតសេចក្តីប្រាថ្នាសម្រាប់ឲ្យមនុស្សបាត់បង់កែប្រែចិត្តនៅក្នុងជីវិតរបស់លោកអ្នកផងដែរ។

## ៦. សូមបន្តអធិស្ឋាន

អធិស្ឋាន អធិស្ឋាន អធិស្ឋាន អធិស្ឋាន ហើយអធិស្ឋានទៀត។ ព្រះយេស៊ូវបានមានបន្ទូលថាឲ្យបន្តគោះ (លូកា ១១:៩)។ ព្រះអង្គសព្វព្រះហឫទ័យនៅពេលដែលលោកអ្នកគោះ។ ព្រះអង្គនឹងមិនដែលធុញទ្រាន់ជាមួយនឹងសេចក្តីអធិស្ឋានដែលលោកអ្នកលើកឡើងទៅកាន់ព្រះអង្គសម្រាប់កូនៗរបស់លោកអ្នកឡើយ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 247 25/01/2024 09:23:18 AM

50 QnA John Piper Final 1.5.indd 248 25/01/2024 09:23:18 AM

# សំណួរទី៤៩៖
# លោកអ្នកមិនត្រូវការកាន់តែស្រឡាញ់ខ្លួនឯងនោះទេ

*បន្ទាប់ពីចំណាយពេលអស់មួយភាគបួននៃសតវត្សរ៍នៅព្រះវិហារ បេថ្លេហិមបាទីស្ទ លោកគ្រូ ចន ផាបភ័រ បានក្រឡេកមើលក្រោយ និងបានឆ្លុះបញ្ចាំងលើការពេញនិយមដ៏គួរឲ្យព្រួយបារម្ភបំផុតមួយដែលគាត់បានដើរតាមនៅក្នុងគ្រីស្ទបរិស័ទ។ ហើយការពេញនិយមនេះគឺជាការលើកខ្លួនឯង និងការស្រឡាញ់ខ្លួនឯង ហើយវាជាការដែលបានកើតឡើងខ្លាំងមែនទែននៅក្នុងអំឡុងឆ្នាំ ១៩៧០ ដល់ ១៩៨០។ គេបានលើកឡើងថា ការឲ្យតម្លៃលើខ្លួនឯងគឺជាគន្លឹះនៃសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទ៖ ចូរស្រឡាញ់ខ្លួនឯងឲ្យបានច្រើន ហើយបន្ទាប់មកទើបលោកអ្នកអាចស្រឡាញ់អ្នកដទៃទៀតបានយ៉ាងមានប្រសិទ្ធភាព។ ប៉ុន្តែ គំរូបែបនេះគឺជាការបង្ខូចទ្រង់ទ្រាយទៅវិញទេ។ ជាការពិតណាស់ អ្វីដែលព្រះគម្ពីរទាមទារឲ្យគ្រីស្ទបរិស័ទធ្វើគឺលើសឆ្ងាយជាងការលើកខ្លួនឯងទៅទៀត។ វាលើសខ្លាំងជាងនេះ ពីព្រោះព្រះគម្ពីរមិនបានត្រាស់ហៅយើងឲ្យស្រឡាញ់ខ្លួនឯងច្រើនថែមទៀតនោះទេ ប៉ុន្តែឲ្យយើងស្រឡាញ់អ្នកដទៃដោយមានចិត្តស្មោះត្រង់ និងព្យាយាមខ្នះខ្នែងដូចដែលយើងបានស្រឡាញ់ខ្លួនឯងដែរ។ ការត្រាស់ហៅឲ្យស្រឡាញ់ដែលលើសបែបនេះគឺជាការត្រាស់ហៅដែលមានការទាមទារខ្ពស់ណាស់។ លោកគ្រូ ចន ផាបភ័រ ហៅការបើកសម្តែងបែបនេះថាជា “ការហិនវិនាស”—ហិនវិនាសដោយសារវាបានធ្វើឲ្យគ្រីស្ទបរិស័ទក្លាយជា “សាសនាដែលមិនអាចទៅរួចបាន”។ នេះជាអ្វីដែលលោកគ្រូ ចន ផាបភ័រ បានពន្យល់នៅក្នុងសេចក្តីអធិប្បាយរបស់គាត់មួយក្នុងចំណោមសេចក្តីអធិប្បាយទាំង ២០០៥ ចំណងជើងរបស់គាត់។*



50 QnA John Piper Final 1.5.indd 249 25/01/2024 09:23:19 AM

តើបំណុលនៃសេចក្ដីស្រឡាញ់ដែលយើងជំពាក់អ្នកដទៃមានទំនាក់ទំនងជាមួយនឹងការស្រឡាញ់ខ្លួនឯងដោយរបៀបណា? កណ្ឌគម្ពីរ រ៉ូម ១៣:៩ គឺជាការដកស្រង់ចេញពីកណ្ឌគម្ពីរ លេវីវិន័យ ១៩:១៨។ ទាំងព្រះយេស៊ូវ លោក យ៉ាកុប និងសាវ័ក ប៉ុល ក៏បានលើកសម្រង់សម្ដីនេះឡើងដែរ។ នេះគឺជាបញ្ញត្តិនៃសេចក្ដីស្រឡាញ់ដ៏សំខាន់បំផុត «ចូរស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង»។ សំណួររបស់ខ្ញុំគឺថា តើឃ្លាដែលថា «ស្រឡាញ់ដូចខ្លួនឯង» មានន័យយ៉ាងដូចម្ដេច—«ដូចខ្លួនឯង»?

មកដល់ពេលនេះ ខ្ញុំបានបម្រើនៅទីនេះអស់រយៈពេល២៥ឆ្នាំហើយ។ យើងទើបតែបានធ្វើពិធីគម្រប់ខួបកាលពីយប់ថ្ងៃពុធនេះ។ ខ្ញុំអាចចាំបានកាលពី៦ឆ្នាំមុនពេលដែលខ្ញុំបានមកដល់ក្រុមជំនុំ បេថ្លេហិម ដំបូង ហើយខ្ញុំអាចនិយាយបានថា ក្នុងចំណោមការខ្វល់ខ្វាយជាច្រើនក្នុងជីវិតរបស់ខ្ញុំចាប់ពីឆ្នាំ ១៩៧៤ ដល់ ១៩៨៩ គឺជាបញ្ហាមួយនេះហើយ។ តើឃ្លាដែលថា «ដូចខ្លួនឯង» មានន័យយ៉ាងដូចម្ដេច? ខ្ញុំចង្អុលបង្ហាញពីការពិតនៃប្រវត្តិសាស្ត្របន្តិចបន្តួចដោយសារតែខ្ញុំមិនបានទទួលស្គាល់ពីបញ្ហា ឬក៏មានការមួយចំនួនបានផ្លាស់ប្ដូរបន្តិចបន្តួច។ ខ្ញុំមិនបានស្ដាប់លឺដូចកាលពី២០ទៅ៣០ឆ្នាំមុននោះទេ គម្រោងផែនការទាក់ទងទៅនឹងផ្លូវចិត្តដែលបានសង់នៅក្នុងខគម្ពីរនេះមានការខុសខ្លាំងមែនទែន។ ប៉ុន្តែ ខ្ញុំនឹងប្រាប់លោកអ្នកអំពីចំណុចនោះក្រែងលោខ្ញុំនៅមិនទទួលស្គាល់ពីបញ្ហា និងក្រែងលោលោកអ្នកក៏ទទួលស្គាល់បែបដូចនោះដែរ។ ឥលូវនេះ ខ្ញុំនឹងព្យាយាមរំដោះលោកអ្នកចេញពីការលង់បែបនេះ។

### ដំណឹងល្អនៃការលើកខ្លួនឯង

អស់រយៈពេលជាច្រើនឆ្នាំកន្លងផុតទៅ គ្រីស្ទបរិស័ទបានសរសេរអត្ថបទ និងសៀវភៅដែលពួកគេបានលើកឡើងថា បញ្ញត្តិមួយនេះមានន័យថា មូល



50 QnA John Piper Final 1.5.indd 250 25/01/2024 09:23:19 AM

ហេតុដែលមនុស្សមិនអាចស្រឡាញ់អ្នកដទៃទៀតបានគឺក៏ព្រោះតែពួកគេមិនបានរៀនពីរបៀបក្នុងការស្រឡាញ់ខ្លួនឯងឲ្យបានគ្រប់គ្រាន់សិន ហេតុដូច្នេះហើយបានជាកិច្ចការក្នុងការផ្ដល់ការសិក្សា និងកិច្ចការអប់រំ ការចិញ្ចឹមបីបាច់ថែរក្សា និងការអធិប្បាយ គឺដើម្បីជួយមនុស្សឲ្យចេះស្រឡាញ់ខ្លួនឯងខ្លាំងជាងមុន ដើម្បីឲ្យពួកគេមានធនធានក្នុងការស្រឡាញ់អ្នកដទៃទៀតបាន។ ហើយនៅក្នុងគម្រោងផែនការដ៏តូចមួយនោះ ការស្រឡាញ់ខ្លួនឯងគឺតែងតែមានន័យថា ការលើកខ្លួនឡើងឯង។

ដូច្នេះហើយបានជាដំណឹងល្អសកលដែលបានដោះស្រាយបញ្ហាទាំងអស់របស់កុមារ អាពាហ៍ពិពាហ៍ និងជម្លោះអាជីវកម្មគឺជាការខ្វះនូវការលើកខ្លួនឯង ហេតុដូច្នេះហើយ កិច្ចការរបស់អ្នកប្រឹក្សាទាំងអស់ គ្រូអធិប្បាយទាំងអស់ ឪពុកម្ដាយទាំងអស់ អ្នកអប់រំទាំងអស់ គឺជាការនាំកូនតូចៗទាំងនោះឲ្យចេះលើកខ្លួនឯងជីវិតរស់នៅរបស់ពួកគាត់ ហើយឲ្យបុគ្គលិកទាំងអស់ចេះលើកខ្លួនឯងនៅក្នុងជីវិត ហើយបន្ទាប់មក ការទាំងអស់នឹងចាប់ផ្ដើមមានភាពល្អប្រសើរឡើងជាងនេះ ពីព្រោះនៅពេលដែលពួកគេស្រឡាញ់ខ្លួនឯង នោះពួកគេនឹងឲ្យសេចក្ដីស្រឡាញ់នោះហូរហៀរទៅកាន់អ្នកដទៃទៀតដែរ។ នោះគឺជាគម្រោងផែនការបោកប្រាស់ ហើយវាក៏បានបាត់បង់នូវចំណុចសំខាន់ៗក្នុងរបៀបជាច្រើនដែរ។

ទីមួយ សេចក្ដីបង្គាប់បញ្ញាតាមបទគម្ពីរមួយនេះសន្មតថា យើងទាំងអស់គ្នាចេះស្រឡាញ់ខ្លួនឯងហើយ ហើយមិនចាំបាច់ត្រូវការឲ្យគេមកបង្រៀនទាល់តែសោះក្នុងការស្រឡាញ់ខ្លួនឯង។ វាជាការសន្មត។ មនុស្សគ្រប់ៗគ្នាដោយមិនមានករណីលើកលែង មានទំនាក់ទំនងយ៉ាងងប់ងុលជាមួយនឹងការស្រឡាញ់ខ្លួនឯង។ លោកអ្នកមិនត្រូវការរៀនពីការនោះទាល់តែសោះ។

ហើយចំណុចទី២ វាគ្មានអ្វីទាក់ទងជាមួយនឹងការលើកខ្លួនឯងនោះទេ។ សេចក្ដីស្រឡាញ់ដែលលោកអ្នកមានសម្រាប់ខ្លួនឯងមានភាពសាមញ្ញ



50 QnA John Piper Final 1.5.indd 251 25/01/2024 09:23:19 AM

ណាស់ បំណងប្រាថ្នារបស់លោកអ្នកក្នុងការមានភាពសប្បាយរីករាយ និងការធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីឲ្យជីវិតរបស់លោកអ្នកដើរនៅក្នុងផ្លូវដែលលោកអ្នកចង់បាន។ ព្រះអង្គមិនបានមានបន្ទូលថា ដំបូងលោកអ្នកត្រូវរៀនលើកខ្លួនឯងទេ ហើយបន្ទាប់មក ចេញពីការឲ្យតម្លៃយ៉ាងខ្ពស់ដល់គុណសម្បត្តិរបស់លោកអ្នក នោះឥឡូវនេះលោកអ្នកមានសេរីភាពក្នុងការស្រឡាញ់អ្នកដទៃទៀតបាន—បន្ទាប់មកជួយពួកគេឲ្យសន្មតថា ពួកគេចេះឲ្យតម្លៃខ្លួនឯងថាពួកគេអស្ចារ្យប៉ុណ្ណា។

## គ្រប់គ្នាចង់បានភាពសប្បាយរីករាយ

នោះមិនមែនជារបៀបដែលសាវ័ក ប៉ុល កំពុងតែគិតនោះទេ។ ព្រះបន្ទូលមិនបានបង្គាប់ឲ្យយើងស្រឡាញ់ខ្លួនឯងនោះទេ ទាំងនោះគឺគ្រាន់តែជាការសន្មតតែប៉ុណ្ណោះ៖ ចូរស្រឡាញ់អ្នកជិតខាងដូចខ្លួនបានស្រឡាញ់ខ្លួនឯង—ប៉ុណ្ណឹងវាច្បាស់ល្មមដែលមិនគួរមានសំណួរអំពីវាទៀតនោះទេ។

នេះគឺជាឧទាហរណ៍នៅក្នុងកណ្ឌគម្ពីរ អេភេសូរជំពូក ៥។ សាវ័ក ប៉ុល កំពុងនិយាយអំពីប្ដីប្រពន្ធនៅក្នុងកណ្ឌគម្ពីរអេភេសូរនៅក្នុងជំពូកទី៥។ គាត់កំពុងតែប្រើប្រាស់បញ្ញត្តិនៃការស្រឡាញ់អ្នកជិតខាងមកអនុវត្តចំពោះប្ដីប្រពន្ធផងដែរ។ ដូច្នេះ ក្នុងអត្ថន័យនេះ តើឲ្យប្ដីអាចស្រឡាញ់ប្រពន្ធបានដោយរបៀបណា? វាមានដំណើរការដូចនេះ៖ «ត្រូវឲ្យប្ដីស្រឡាញ់ប្រពន្ធបែបយ៉ាងនោះឯង គឺដូចជាស្រឡាញ់រូបកាយរបស់ខ្លួនដែរ អ្នកណាដែលស្រឡាញ់ប្រពន្ធខ្លួន នោះក៏ឈ្មោះថាស្រឡាញ់ដល់ខ្លួនឯងហើយ»។ ហើយបន្ទាប់មក គាត់ក៏បានបន្ថែមឃ្លាដ៏សំខាន់គួរឲ្យភ្ញាក់ផ្អើលនៅក្នុងខ២៩ទៀតថា «ដ្បិតមិនដែលមានអ្នកណាស្អប់រូបសាច់ខ្លួនឯងឡើយ គឺគេតែងចិញ្ចឹម ហើយថ្នាក់ថ្នមវិញ ដូចជាព្រះអម្ចាស់ដល់ពួកជំនុំដែរ» (អេភេសូរ ៥:២៨-២៩)។ គ្មាននរណាម្នាក់ស្អប់ខ្លួនឯងនោះទេ ប៉ុន្តែតែងតែចិញ្ចឹម និងថ្នាក់



50 QnA John Piper Final 1.5.indd 252 25/01/2024 09:23:20 AM

ថ្នមខ្លួនគាត់វិញ។ គ្រប់គ្នាទាំងអស់ដោយមិនមានការលើកលែង សុទ្ធតែស្រឡាញ់ខ្លួនឯង—មិនថាការលើកខ្លួនរបស់គាត់មានលក្ខណៈទាប ឬខ្ពស់នោះទេ។

- គ្រប់គ្នាចង់មានអាហារបរិភោគ ហើយនិងធ្វើស្ទើរតែគ្រប់យ៉ាង ដើម្បីឲ្យបានវាមកបរិភោគ ប្រសិនបើយើងឃ្លានខ្លាំង។
- គ្រប់គ្នាចង់មានទឹកផឹក ហើយមិនឲ្យខ្លួនស្លាប់ដោយសារការស្រេកឃ្លាននោះទេ ហើយយើងនឹងធ្វើស្ទើរតែគ្រប់យ៉ាង ដើម្បីឲ្យខ្លួនយើងទទួលបានទឹកផឹក ប្រសិនបើយើងស្រេកមែន។
- គ្រប់គ្នាចង់គេចឲ្យផុតពីការមានរបួស និងការស្លាប់ ហើយយើងនិងធ្វើគ្រប់យ៉ាង ដើម្បីគេចចេញពីការដើរកាត់មុខរទេះភ្លើង ឬមុខឡាន ឬពីការផឹកថ្នាំពុល ឬក៏ការដែលនាំឲ្យខ្លួនយើងស្លាប់ក្នុងរបៀបផ្សេងៗទៀតដែរ។

យើងស្រឡាញ់ជីវិត និងសុខភាពរបស់យើងខ្លាំងណាស់។ ហើយប្រសិនបើមាននរណាម្នាក់លើកឡើងដោយបដិសេធថា “ចុះសម្រាប់ពួកអ្នកដែលទទួលបានការរីករាយពីការឈឺចាប់ និងពួកអ្នកធ្វើអត្តឃាតខ្លួនឯងវិញ? តើពួកគេជាករណីលើកលែង ឬយ៉ាងណា? ខ្ញុំចង់មានន័យថា ពួកគេមិនបានមើលថែខ្លួនឲ្យបានល្អទេ មែនអត់?”។ ចម្លើយគឺថា ពួកអ្នកដែលទទួលបានការរីករាយពីការឈឺចាប់ និងពួកអ្នកដែលធ្វើអត្តឃាតខ្លួនឯងមិនមែនជាករណីលើកលែងនោះទេ ក្នុងច្បាប់នេះ។

អ្នកដែលទទួលបានការរីករាយចេញពីការឈឺចាប់គឺជាម្នាក់ដែលមានមូលហេតុក្រៀមក្រំ និងគួរឲ្យញញើត ហើយស្វែងរកការរីករាយបានដោយធ្វើឲ្យខ្លួនឯងមានការឈឺចាប់ ឬការទទួលបានភាពអរសប្បាយនឹងការយកចិត្តទុកដាក់របស់គ្រូពេទ្យ។ ខ្ញុំធ្លាប់បាននិយាយជាមួយអ្នកដែលធ្លាប់បានអារដៃខ្លួនឯង។ ខ្ញុំបានសួរស្ត្រីវ័យក្មេងម្នាក់ដែលយើងធ្លាប់បានធ្វើការជា



50 QnA John Piper Final 1.5.indd 253 25/01/2024 09:23:20 AM

មួយ «ហេតុអ្វីបានជាអ្នកអារខ្លួនឯងបែបនេះ?» គាត់មានស្នាមរបួសដាច យ៉ាងធំនៅលើក្បាលពោះរបស់គាត់។ គាត់បានឆ្លើយថា «ដោយសារនោះវា ជាពេលតែមួយគត់ដែលមាននរណាម្នាក់បានប៉ះខ្ញុំ» គាត់ចង់ឲ្យមាននរណា ម្នាក់មកប៉ះគាត់។ គាត់ស្រឡាញ់ខ្លួនគាត់ខ្លាំងណាស់។ «សូមប៉ះខ្ញុំមក! លោកគ្រូពេទ្យ! សូមប៉ះខ្ញុំមក!»។

ជាការពិត វាក៏ដូចគ្នាជាមួយនឹងការធ្វើអត្តឃាតដែរ។ មានហេតុផលតែ មួយគត់ដែលនាំឲ្យមនុស្សសម្លាប់ខ្លួន គឺដោយសារជីវិតរបស់គេមានការ ឈឺចាប់ខ្លាំងពេក ពួកគេមិនអាចប្រឈមនឹងវាបានទៀតនោះទេ ហើយពួក គេចង់គេចឲ្យផុតពីវា។ ពួកគេគ្រាន់តែចង់ចេញឲ្យផុតពីការឈឺចាប់ ដែល នោះក៏ជាការស្រឡាញ់ខ្លួនឯងដែរ។ «ខ្ញុំមិនចង់មានការឈឺចាប់ទៀតទេ»។

គ្រប់គ្នាចូលចិត្តឲ្យគេសរសើរ ហើយដាច់ចេញពីព្រះគុណ នោះពួកយើង ទាំងអស់គ្នាប្រសប់ក្នុងការនិយាយ និងធ្វើការអ្វីមួយ ដើម្បីឲ្យគេចូលចិត្ត និង លើកមុខមាត់យើង។ យើងត្រូវការកិច្ចការដ៏ធំនៃព្រះគុណដ៏ក្រៃលែងក្នុង ការរំដោះលោកអ្នកចេញពីរូបព្រះទាំងនោះ។ យើងស្រឡាញ់ការសរសើរពី មនុស្ស។ មនុស្សគ្រប់គ្នាមានសេចក្ដីស្រឡាញ់សម្រាប់ខ្លួនឯង។ ព្រះយេស៊ូវ មិនបានបង្គាប់វានោះទេ ព្រះអង្គជ្រាបពីវាហើយ។

## ចូរស្វែងរកប្រយោជន៍សម្រាប់អ្នកដទៃ

ឥឡូវនេះ មានមនុស្សជាច្រើនគិតថា វានឹងលើសពេកហើយ ប្រសិនបើ ព្រះយេស៊ូវបានមានបន្ទូលថា «ដូច្នេះ ចូរឈប់ស្រឡាញ់ខ្លួនឯងដូចនោះ ហើយចូរចាប់ផ្ដើមបំពេញកាតព្វកិច្ចនៃក្ដីស្រឡាញ់ទៅកាន់អ្នកដទៃចុះ។ ចូរឈប់មានចំណង់ខ្លាំងក្នុងការស្វែងរកសុភមង្គលដល់ខ្លួនឯង និងដល់ សុខុមាលភាពខ្លួនឯងចុះ។ ចូរបញ្ឈប់ការនោះ សម្លាប់ការនោះ ឆ្កាងការ នោះ ស្លាប់នៅក្នុងការនោះ និងចាប់ផ្ដើមធ្វើអ្វីដែលមិនហូរចេញពីសេចក្ដីប៉ង



50 QnA John Piper Final 1.5.indd 254 25/01/2024 09:23:20 AM

ប្រាថ្នា ដើម្បីភាពអរសប្បាយរបស់លោកអ្នក ហើយចូរគ្រាន់តែធ្វើវាទៅតាមកាតព្វកិច្ច ហើយក្នុងសេចក្តីស្រឡាញ់ផង»។ មានមនុស្សមួយចំនួនអាចនឹងនិយាយថា នោះវាលើសច្រើនណាស់ ហើយខ្ញុំគិតថា វាក៏អាចដូចនោះដែរ។

ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយក៏វាមិនច្រើនដូចអ្វីដែលព្រះយេស៊ូវបានមានបន្ទូល និងដូចអ្វីដែលសាវ័ក ប៉ុល បានមានប្រសាសន៍ និងលោក យ៉ាកុប បានលើកឡើង និងកណ្ឌគម្ពីរលេវីវិន័យបានថែងនោះទេ។ ផ្ទុយទៅវិញ ពួកគាត់បានលើកឡើងថា «ចូរស្រឡាញ់អ្នកជិតខាងក្នុងរបៀបដូចនោះ៖ ដូចដែលលោកអ្នកស្រឡាញ់ខ្លួនឯងយ៉ាងសម្បើមនោះដែរ។ ចូរធ្វើឲ្យបំណងប្រាថ្នារបស់លោកអ្នកបានកើតឡើង ចូរធ្វើឲ្យបំណងប្រាថ្នារបស់លោកអ្នកក្នុងការមានភាពអរសប្បាយក្លាយជារង្វាស់នៃសេចក្តីប៉ងប្រាថ្នារបស់ខ្លួនក្លាយជាភាពអរសប្បាយដល់អ្នកដទៃចុះ»។ លោកអ្នកនិយាយពីភាពច្រើនលើសលប់ លោកអ្នកនិយាយអំពីការផ្លាស់ប្តូរនៃជីវិត អំពីការដែលបេះដូងលោតស្ទើរតែផ្ទុះ និងអំពីសេចក្តីបង្គាប់បញ្ជាដែលមិនអាចទៅរួចបាន។ *ចូរស្រឡាញ់អ្នកជិតខាងរបស់ខ្លួនដូចដែលលោកអ្នកស្រឡាញ់ខ្លួនឯងចុះ។*

- ប្រសិនបើលោកអ្នកមានភាពស្វាហាប់ក្នុងការស្វែងរកសុភមង្គលសម្រាប់ខ្លួនឯង ចូរមានភាពស្វាហាប់ក្នុងការស្វែងរកសុភមង្គលដល់អ្នកជិតខាងរបស់ខ្លួនផងចុះ។
- ប្រសិនបើលោកអ្នកមានគំនិតឆ្នៃប្រឌិតក្នុងការស្វែងរកសុភមង្គលសម្រាប់ខ្លួនឯង ចូរមានគំនិតឆ្នៃប្រឌិតក្នុងការស្វែងរកសុភមង្គលដល់អ្នកជិតខាងរបស់លោកអ្នកដែរ។
- ប្រសិនបើលោកអ្នកមានការតស៊ូ និងទ្រាំទ្រក្នុងការស្វែងរកសុភមង្គលសម្រាប់ខ្លួនឯង ចូរមានការតស៊ូ និងទ្រាំទ្រក្នុងការស្វែងរក



50 QnA John Piper Final 1.5.indd 255 25/01/2024 09:23:20 AM

សុភមង្គលដល់អ្នកជិតខាងរបស់លោកអ្នកដែរ។

សាវ័ក ប៉ុល មិនបានលើកឡើងជាចម្បងថាឲ្យស្វែងរកអ្នកជិតខាងរបស់លោកអ្នកដូចអ្វីដែលលោកអ្នកចង់បាននោះទេ៖ គាត់កំពុងលើកឡើងថា "ចូរស្វែងរកប្រយោជន៍សម្រាប់ពួកគេនៅក្នុងរបៀបដូចគ្នាទៅនឹងការដែលលោកអ្នកស្វែងរកសម្រាប់ខ្លួនឯងវិញ។ ចូរកំណត់កម្រិតសម្រាប់ស្វែងរកខ្លួនរបស់លោកអ្នកផ្ទាល់ ដែលវាខ្ពស់ ជារង្វាស់ក្នុងការស្វែងរកប្រយោជន៍សម្រាប់ពួកគេដែរ"។

**ការច្រើនហួសហេតុ សេចក្តីបង្គាប់ដែលមិនអាចទៅរួច**

នេះគឺជាការហិនវិនាសមួយ។ លោកអ្នកកំពុងអង្គុយនៅផ្ទះ។ លោកអ្នកមានចិត្តរីករាយជាមួយអារម្មណ៍ពេលល្ងាច។ វាមានអារម្មណ៍ល្អ—ការមើលទូរទស្សន៍ មើលវីដេអូ បរិភោគអាហារឆ្ងាញ់ៗ ហើយជជែកគ្នាលេង។ ហើយស្រាប់តែលោកអ្នកឮសេចក្តីបង្គាប់របស់ព្រះយេស៊ូវថា "ចូរស្រឡាញ់អ្នកជិតខាងដូចដែលលោកអ្នកចង់បានពេលវេលាល្ងាចនេះដែរចុះ"។ នេះគឺជាការហិនវិនាសមួយ។ ចូរវាស់ស្ទង់ការស្វែងរកសុភមង្គលរបស់អ្នកដទៃដោយស្វែងរកសុភមង្គលរបស់ខ្លួនឯង។

- តើលោកអ្នកស្វែងរកសុខុមាលភាពដោយរបៀបណា? ចូរស្វែងរកសុខុមាលភាពរបស់ពួកគេក្នុងរបៀបនោះដែរ។
- តើលោកអ្នកឃ្លានទេ? ចូរស្វែងរកអ្នកជិតខាងណាដែលឃ្លាន ហើយផ្គត់ផ្គង់ដល់គាត់ផង។
- តើលោកអ្នកស្រេកទឹកដែរឬទេ? ចូរចម្អែតភាពស្រេកដល់អ្នកជិតខាងរបស់ខ្លួនឯងដែរ។
- តើលោកអ្នកមានអារម្មណ៍ឯកាដែរឬទេ? ចូរស្វែងរកម្នាក់ដែលកំពុងឯកា ហើយធ្វើជាមិត្តនឹងគេចុះ។



50 QnA John Piper Final 1.5.indd 256 25/01/2024 09:23:20 AM

- តើលោកអ្នកកំពុងភ័យខ្លាចមែនទេ? ចូរស្វែងរកនរណាម្នាក់ ដើម្បីកម្សាន្តចិត្តគាត់ចុះ។
- លោកអ្នកចង់ទទួលបានពិន្ទុល្អសម្រាប់ការប្រឡងខាងមុខនេះ។ អ្នកដទៃក៏ដូចគ្នាដែរ ចូរជួយពួកគេ។

នេះគឺជាការជ្រុលពេក។ វាជ្រុលហួសហេតុជាងការនិយាយថា “ចូរឈប់ប្រាថ្នា ហើយចាប់ផ្ដើមបំពេញកាតព្វកិច្ចចុះ”។ វាជារឿងជ្រុលជាងនេះទៅទៀត ពីព្រោះវាបានលើកឡើងថា “ឥឡូវនេះ ការប៉ងប្រាថ្នាដ៏សម្បើមទាំងនេះដែលខ្ញុំមានសម្រាប់សុភមង្គលមិនបានយកចេញឆ្ងាយពីខ្ញុំនោះទេ៖ ពួកគេបានផ្លាស់ប្ដូរទៅជាប្រភេទផ្សេងនៃតន្ត្រីវិញ។ កម្លាំងដូចគ្នាទៅនឹងពីមុន ការចង់បានដូចគ្នា សេចក្ដីប៉ងប្រាថ្នាដូចគ្នា ឥឡូវនេះ ក្លាយជាបំណងប្រាថ្នាសម្រាប់លោកអ្នក និងសម្រាប់សេចក្ដីសង្គ្រោះរបស់លោកអ្នក សម្រាប់សុភមង្គល និងការល្អសម្រាប់លោកអ្នក។ ក្រពះរបស់លោកអ្នកនឹងបានឆ្អែត គំនិតរបស់លោកអ្នកនឹងទទួលបានការអប់រំ ហើយជីវិតរបស់លោកអ្នកមានសារៈសំខាន់។ គ្រប់របស់ទាំងអស់ដែលខ្ញុំចង់បាន ឥឡូវនេះខ្ញុំចង់បានដោយកម្លាំងដូចគ្នា ហើយចង់បានសម្រាប់លោកអ្នកដែរ”។

ជំនឿគ្រីស្ទបរិស័ទគឺជាសាសនាដែលមិនអាចទៅរួចបាន។ នេះគឺជាស្តង់ដារដែលលើសលប់ ហើយវាធ្វើឲ្យខ្ញុំរងចាំយ៉ាងយូរ ដើម្បីឲ្យមានការអស្ចារ្យបានកើតឡើងចំពោះខ្ញុំ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 257 25/01/2024 09:23:21 AM

50 QnA John Piper Final 1.5.indd 258 25/01/2024 09:23:21 AM

# ផ្នែកទី៥៖ អំពើបាប



50 QnA John Piper Final 1.5.indd 259 25/01/2024 09:23:21 AM

## លោកអ្នកអាចស្តាប់សៀវភៅនេះជាសំឡេងបាន ដោយគ្រាន់តែ

## ស្កេននៅទីនេះ

50 QnA John Piper Final 1.5.indd 260 25/01/2024 09:23:21 AM

# សំណួរទី៥៥៖
# តើអំពើបាបខាងឯផ្លូវភេទរបស់ខ្ញុំធ្វើឲ្យខ្ញុំមិនអាចទទួលបានសេចក្តីសង្គ្រោះមែនឬ?

*មានបុរសម្នាក់បានសួរថា "ដូចដែលបានពណ៌នានៅក្នុងកណ្ឌគម្ពីរហេព្រើរ ១២:១៥-១៧ តើយើងអាចឈានដល់ដំណាក់កាលដូចជាលោកអេសាវ នៅពេលណា? ពេលគាត់ឈានទៅដល់ចំណុចដែលមិនអាចកែប្រែចិត្តបាន?"។*

*គាត់ក៏បានបន្តពន្យល់ខ្លះៗអំពីខ្លួនគាត់ថា "ខ្ញុំបានក្លាយជាគ្រីស្ទបរិស័ទអស់ជាច្រើនឆ្នាំហើយ ប៉ុន្តែក៏បានធ្លាក់ក្នុងអំពើបាបខាងឯផ្លូវភេទជាច្រើនលើកច្រើនសារអស់ជាច្រើនឆ្នាំដែរ។ រឿងអតីតកាលរបស់ខ្ញុំមានរួមទាំងការមើលរូប និងវីដេអូអាសអាភាស មានរួមផ្សំទាំងទំនាក់ទំនងបែបផិតក្បត់ជាមួយនឹងប្រពន្ធរបស់បុរសម្នាក់ទៀត និងការទៅលេងស្រីពេស្យាថែមទៀតផង។ ខ្ញុំមិនដែលធ្លាប់ឈប់ក្នុងការតយុទ្ធជាមួយនឹងអំពើបាបនោះទេ។ ខ្ញុំពិតជាស្អប់ពួកវាមែន។ ហើយខ្ញុំក៏មានអំណរក្នុងការលើកឡើងថា ថ្មីៗនេះព្រះជាម្ចាស់បានធ្វើការអស្ចារ្យក្នុងការរំដោះខ្ញុំឲ្យចេញពីទំនាក់ទំនងនៃអំពើផិតក្បត់ដោយខ្ញុំទទួលបានជំនួយពីគ្រូគង្វាលរបស់ខ្ញុំ និងគ្រីស្ទបរិស័ទនានាដទៃទៀត។ ហើយទង្វើនេះបានធ្វើឲ្យខ្ញុំនៅបន្តជឿជាក់ថា ព្រះអង្គនៅតែយកព្រះហឫទ័យទុកដាក់ក្នុងការសង្គ្រោះខ្ញុំ!"។*

*"ទោះជាយ៉ាងណាក៏ដោយ ពេលខ្លះខ្ញុំនៅមានអារម្មណ៍ថាខ្ញុំមិនមានអំណាចសោះក្នុងការទាស់ប្រឆាំងនឹងអំពើបាបខាងឯផ្លូវភេទនេះ។ ខ្ញុំមានការភ័យខ្លាចថា បើខ្ញុំនៅបន្តធ្លាក់ក្នុងអំពើបានខាងឯផ្លូវភេទនេះ ដូចដែលមានពណ៌នានៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១២:១៦ ដែលការនេះនឹងបណ្តាល*

*ឲ្យខ្ញុំឈានទៅដល់ចំណុចដែលមិនអាចកែប្រែចិត្តបាន ពោលគឺធ្លាក់ចេញពីព្រះគុណ។ តើខ្ញុំអាចយកឈ្នះលើការធ្លាក់ក្នុងអំពើបាបដែលខ្ញុំមិនអាចទប់ខ្លួនឯងបាននេះដោយរបៀបណា? ហើយគេចចេញពីការមានចិត្តរឹងចចេសដែលមិនអាចកែប្រែបានដោយរបៀបណា?»។*

## មិនមែនថាយើងមិនមានជំនួយនោះទេ

ខ្ញុំចង់ចាប់ផ្តើមដោយបកស្រាយលើប្រយោគ «ការធ្លាក់ក្នុងអំពើបាបដែលខ្ញុំមិនអាចទប់ខ្លួនឯងបាន»។ ខ្ញុំចង់លើកទឹកចិត្ត «ចូរលើកដៃដែលស្រពន់ឡើង ហើយធ្វើឲ្យជង្គង់ដែលខ្សោយមានកម្លាំងឡើងដែរ ចូរធ្វើផ្លូវឲ្យត្រង់សម្រាប់ជើងអ្នករាល់គ្នា» ចុះ (ហេព្រើរ ១២:១២–១៣)។

យើងគួរតែស្រែកដាក់មុខសារតាំងថា «មិនមែនថាខ្ញុំមិនអាចជួយបានទេ! ព្រះជាម្ចាស់មិនមែនជាអង្គដែលធ្វើឲ្យខ្ញុំធ្លាក់ចុះឡើយ។ ខ្ញុំមិនមែនជាខ្សែរសមុទ្រក្នុងរលកនៃភាពត្រេកត្រអាលទេ។ នោះមិនមែនជាអ្វីដែលព្រះជាម្ចាស់បានបង្កើតឲ្យមនុស្សយើងធ្វើនោះឡើយ។ នេះមិនមែនជាមូលហេតុដែលព្រះគ្រីស្ទសុគតសម្រាប់ខ្ញុំទេ។ នេះក៏មិនមែនជាមូលហេតុដែលខ្ញុំមានព្រះវិញ្ញាណបរិសុទ្ធដែរ។ នេះក៏មិនមែនជាមូលហេតុដែលថាខ្ញុំជាមនុស្សថ្មីក្នុងព្រះគ្រីស្ទដែរ។ មិនមែនថាខ្ញុំមិនអាចជួយបានទេ!»

«ខ្ញុំមានព្រះគ្រីស្ទ ហើយខ្ញុំក៏មានព្រះវិញ្ញាណបរិសុទ្ធដែរ។ ខ្ញុំមានឈាមនៃឈើឆ្កាងរបស់ព្រះរាជបុត្រានៃព្រះ។ ខ្ញុំមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ទាំងមូល។ ខ្ញុំក៏មានសេចក្តីសន្យានៃព្រះគុណដែរ។ មិនមែនថាខ្ញុំមិនអាចជួយបានទេ! ឱព្រះជាម្ចាស់អើយ! សូមដកចេញនូវការកុហកនេះចេញពីជីវិតទូលបង្គំចុះ។» ដរាបណាមនុស្សយើងនៅគិតថាយើងជាជនរងគ្រោះ (ហាក់បីដូចជាថា ភាពត្រេកត្រអាលគឺជាខ្មាំងសត្រូវដែលមានពេញទៅដោយអំណាច ហើយថាខ្លួនមិនអាចជួយខ្លួនឯងបាន) នោះពួកគេគឺចប់



50 QnA John Piper Final 1.5.indd 262 25/01/2024 09:23:21 AM

ហើយ។

វាពិតជាគួរឲ្យកត់សម្គាល់មែន—អស្ចារ្យណាស់! ត្រង់ថាបុគ្គលដែលកំពុងសួរសំណួរនេះផ្តោតទៅលើកណ្ឌគម្ពីរហេព្រើរ។ ជាពិសេស ត្រង់ថាគាត់បានផ្តោតលើការព្រមានទាស់ប្រឆាំងនឹងការឈានដល់ចំណុចដែលយើងលក់ខ្លួនឯងក្នុងនាមជាទាសករនៃភាពត្រេកត្រអាលដែលមិនអាចជួយខ្លួនឯងបាន ដែលព្រះជាម្ចាស់លែងប្រទានការមានសមត្ថភាពក្នុងការកែប្រែចិត្ត ហើយទទួលបានការអត់ទោសក្នុងព្រះគ្រីស្ទ។

ពិតណាស់! នេះគឺជាកន្លែងដ៏ល្អណាស់ក្នុងការដែលគាត់ដើរលើ។ កណ្ឌគម្ពីរហេព្រើរ—មួយកណ្ឌទាំងមូល—គឺត្រូវបានសរសេរឡើង ដើម្បីជួយយើងក្នុងការស៊ូទ្រាំរហូតដល់ទីបញ្ចប់ក្នុងជំនឿ និងការស្តាប់បង្គាប់។ កណ្ឌគម្ពីរហេព្រើរនឹងនិយាយមកកាន់មុខយើង នៅពេលដែលយើងរាប់ខ្លួនថាជាជនរងគ្រោះ ហើយធ្វើពុតថាយើងមិនមានធនធាន ដើម្បីទាស់ប្រឆាំងនឹងអំណាចនៃអំពើបាប។

## ភាពល្ងីល្ងើរបស់លោក អេសាវ

តោះ! ចូរមើលបទគម្ពីរ!

“ចូរប្រយ័ត្នប្រយែង ក្រែងមានអ្នកណាខ្វះព្រះគុណរបស់ព្រះ ហើយមានឫសល្វីងជូរចត់ណាពន្លកឡើង ដែលបណ្តាលឲ្យកើតរឿងរ៉ាវ ហើយដោយសារការនោះ មនុស្សជាច្រើនក៏ត្រូវឡប់ជាស្មោកគ្រោក។ ចូរប្រយ័ត្នប្រយែង ក្រែងមានអ្នកណាប្រព្រឹត្តសហាយស្មន់ ឬទមិឡល្មើសដូចអេសាវដែលលក់សិទ្ធិកូនច្បងរបស់ខ្លួនសម្រាប់តែអាហារមួយពេលប៉ុណ្ណោះនោះឡើយ។ ដ្បិតអ្នករាល់គ្នាដឹងហើយថា ក្រោយមក កាលគាត់ប្រាថ្នាចង់ទទួលពរ តែមិនបានទេ ទោះបើគាត់ខំស្វែងរកទាំងស្រក់ទឹកភ្នែកក៏ដោយ ក៏គាត់រកឱកាសប្រែចិត្តមិនឃើញដែរ” (ហេព្រើរ ១២:១៥–១៧)។



50 QnA John Piper Final 1.5.indd 263 25/01/2024 09:23:22 AM

នេះគឺជាកន្លែងដ៏ល្អបំផុតសម្រាប់ឲ្យបុគ្គលណាម្នាក់ទៅពេលដែលគាត់រៀបនឹងលក់ព្រលឹងរបស់ខ្លួនជាថ្មីម្តងទៀតទៅកាន់ភាពត្រេកត្រអាល។ មានពេលដែលព្រះជាម្ចាស់នឹងដកព្រះវត្តមានទ្រង់ចេញពីលោក អេសាវ។ ដួងចិត្តរបស់លោក អេសាវ មានការរឹងរូសយ៉ាងខ្លាំងដល់ថ្នាក់ថា សូម្បីតែក្នុងការយំស្រែករបស់គាត់ពេលស្វែងរកការប្រែចិត្តក៏មានឫសគល់ដែលពេញទៅដោយភាពមិនស្មោះត្រង់ផងដែរ។ «គាត់ខំស្វែងរក [ការកែប្រែចិត្ត] ទាំងស្រក់ទឹកភ្នែក» ប៉ុន្តែវាគ្រាន់តែជាការធ្វើពុតប៉ុណ្ណោះ។ ទាំងនោះមិនមែនជាការស្រក់ទឹកភ្នែកដ៏ពិតនោះទេ។ គាត់មិនអាចយំដោយមានទឹកភ្នែកពិតសម្រាប់ការកែប្រែចិត្តទៀតបានឡើយ។

ទឹកភ្នែករបស់គាត់គឺមិនមែនជាទឹកភ្នែកពិតទេ។ គាត់គ្រាន់តែចង់បានព្រះពរ។ គាត់ចង់បានសុវត្ថិភាព។ គាត់ចង់បានអំណោយទាន។ គាត់ចង់បានមរតក។ គាត់ចង់បានស្ថានសួគ៌។ ប៉ុន្តែ គាត់មិនចង់បានព្រះជាម្ចាស់ទេ។ គាត់ស្រឡាញ់លោកីយ៍នេះ។ គាត់បានប្តូរនូវអ្វីមួយដែលមានតម្លៃឥតព្រំដែនជាមួយនឹងអាហារមួយពេល។

ដូច្នេះ មូលដ្ឋាននៃសង្គ្រាមដែលយើងត្រូវតែប្រយុទ្ធ (ហើយអាចច្បាំងនិងមានជ័យជម្នះបាន) គឺជាសង្គ្រាមក្នុងការមិនមើលផែនដីនេះដោយមានភាពបត់បែនដ៏អាក្រក់ក្នុងរបៀបដូចដែលលោក អេសាវ ឃើញនោះទេ។ គាត់បានមើលទៅកាន់មរតកដែលព្រះដ៏មានពេញទៅដោយព្រះចេស្តាបានសន្យា ហើយបន្ទាប់មកគាត់ក៏បានមើលម្ហូបមួយចាននោះ។ ឧទាហរណ៍៖ គាត់អាចមើលរូប ឬក៏វីដេអូអាសអាភាស ឬក៏ការលេងស្រីមួយភ្លែត ហើយបន្ទាប់មក គាត់ថ្លឹងថ្លែងទាំងពីរក្នុងគំនិតរបស់ខ្លួន។ ម្យ៉ាងគឺថាគាត់អាចមានអំណររបស់ព្រះជាម្ចាស់យ៉ាងអស់កល្បជានិច្ច ហើយម្យ៉ាងទៀតគឺថាគាត់គ្រាន់តែមានអារម្មណ៍មួយភ្លែតចេញពីការមើលរូប ឬក៏វីដេអូអាសអាភាស។

ក្នុងគំនិតរបស់គាត់ គាត់បានប្រព្រឹត្តិអំពើកាចសាហាវយ៉ាងខ្លាំងនៃ



50 QnA John Piper Final 1.5.indd 264 25/01/2024 09:23:22 AM

ចក្រវាលនេះ។ ការមើលរូប ឬក៏វីដេអូអាសអាភាសមានទម្ងន់ធ្ងន់ជាងក្នុងការថ្លឹងថ្លែង គួរឲ្យប្រាថ្នាចង់បានខ្លាំងជាង គួរឲ្យស្រស់ស្អាត ហើយក៏គួរឲ្យស្កប់ស្កល់ចិត្តណាស់។ ហើយទាក់ទងនឹងព្រះជាម្ចាស់ និងសេចក្ដីសន្យាដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ វាហាក់បីដូចជាគ្មានតម្លៃទាល់តែសោះ។

## តើដល់ពេលណាដែលយឺតយ៉ាវពេក?

គ្រប់ៗគ្នាត្រូវតែទទួលស្គាល់ថា ក្នុងពេលដែលយើងប្រព្រឹត្តអំពើដ៏កាចសាហាវណាស់ នោះព្រះជាម្ចាស់ក៏អាចដើរចេញពីយើង ហើយមិនត្រឡប់មកយើងវិញបានដែរ។ ព្រះអង្គមានលិខិតស្នាម និងច្បាប់គ្រប់បែបបទ ពេលណាដែលយើងធ្វើបែបនោះ យើងកំពុងតែនិយាយទៅកាន់ព្រះអង្គថា “ចូរចេញ! ខ្ញុំចង់ជ្រើសយកម្ហូបនេះជាជាងព្រះអង្គ”។

កណ្ឌគម្ពីរហេព្រើរមានការស្មោះត្រង់ចិត្តយ៉ាងល្អឥតខ្ចោះក្នុងការប្រាប់យើងថា (ហើយកណ្ឌនេះក៏ពិតជាបានធ្វើមែនម្ដងហើយម្ដងទៀតមែនក្នុងការព្រមានដ៏ខ្លាំងក្លាក្រៃលែងបំផុត) ពិតជាមានពេលដែល “យឺតយ៉ាវពេក”។ ពេលដែលភាព “យឺតយ៉ាវពេក” មកដល់ នោះគឺជាពេលដែលលោកអ្នកមិនអាចមានការកែប្រែចិត្តដ៏ពិតទៀតបានឡើយ។ ប្រសិនបើលោកអ្នកអាចកែប្រែចិត្តបានមែន នោះព្រះជាម្ចាស់នឹងប្រាកដជាមានសេចក្ដីមេត្តាករុណាចំពោះលោកអ្នកដែរ។

ព្រះអង្គមានពេញទៅដោយការអត់ធ្មត់។ ព្រះអង្គក៏បានមានព្រះហឫទ័យរាប់រយដងក្នុងការត្រឡប់មករកទាំងលោកអ្នក ហើយនិងខ្ញុំវិញដែរ។ យើងមិនស័ក្តិសមក្នុងការទទួលការដែលទ្រង់ត្រឡប់មកវិញនោះទេ—សូម្បីតែម្ដងក៏មិនស័ក្តិសមដែរ។ ប៉ុន្តែ យើងក៏មិនអាចដឹងថា ពេលណាគឺជាពេលដែលយើងនឹងទំនងជាដេញព្រះអង្គចេញដែលជាលើកចុងក្រោយបាននោះទេ។

ខ្ញុំសូមនិយាយឲ្យច្បាស់៖ ប្រសិនបើព្រះអង្គមិនត្រឡប់មកវិញ គឺយើង

នេះហើយដែលបានបណ្ដេញទ្រង់ចេញ។ យើងបានជ្រើសរើសយកភាពត្រេកត្រអាលធ្វើជាម្ហូបមួយចាន។ យើងបានបណ្ដេញទ្រង់ចេញ។ យើងនិយាយថា «ចេញទៅៗ។ ខ្ញុំឆ្អែតជាមួយឯងហើយ។ ខ្ញុំមិនចង់បានឯងទេ។ ខ្ញុំចង់បាននេះវិញ។ ឥឡូវនេះ ខ្ញុំចង់បាននេះ—មិនមែនឯងទេ!»។ យើងបានបណ្ដេញទ្រង់ចេញ។ ការព្យាយាមទម្លាក់កំហុសលើព្រះជាម្ចាស់គឺជាការយកខ្លួនធ្វើជាអ្នករងគ្រោះ ហើយរាប់ថាអ្វីដែលខ្លួនបានប្រព្រឹត្តគឺជារឿងត្រឹមត្រូវ។

## យើងក្លាយដូចជាអ្វីដែលយើងមើល

សំណួរសួរថា៖ «សួរតើខ្ញុំអាចយកឈ្នះលើការធ្លាក់ក្នុងអំពើបាបដែលខ្ញុំមិនអាចទប់ខ្លួនឯងបាននេះដោយរបៀបណា?»។ ចម្លើយគឺ៖ ចូរបើកភ្នែករបស់ខ្លួនចុះ! ចូរបើកភ្នែករបស់ខ្លួន ខណៈពេលដែលលោកអ្នកមើលព្រះបន្ទូលដ៏ច្បាស់លាស់របស់ព្រះជាម្ចាស់ ដំណឹងល្អដ៏ច្បាស់លាស់របស់ព្រះជាម្ចាស់ និងការព្រមានដ៏ច្បាស់លាស់របស់ព្រះជាម្ចាស់។

ចូលមើលឃើញថាសេចក្ដីសន្យាដ៏ច្បាស់លាស់របស់ព្រះជាម្ចាស់មានតម្លៃរាប់ពាន់ដងច្រើនជាងការប្រឡូកប្រឡាក់ក្នុងអំពើបាបខាងឯផ្លូវភេទទៅទៀត។ ចូរបើកភ្នែករបស់ខ្លួន ហើយមើលឃើញឲ្យច្បាស់អំពីលក្ខណៈដ៏ពិតនេះ។ ចូរបញ្ឈប់ការមើលបែបបត់បែន។ ចូរបញ្ឈប់ការមើលទៅលើភាពសប្បាយភ្លើតភ្លើនមួយរយៈពេលខ្លីនៃការចាប់អារម្មណ៍ខាងឯផ្លូវភេទនាំឲ្យមាន ហាក់បីដូចជាថា មានតម្លៃខ្លាំងជាងការទទួលជាមរតកនូវសិរីល្អរបស់ព្រះជាម្ចាស់។ សូមមើលធាតុពិតចុះ។

ទំនងជាមិនមានកណ្ឌគម្ពីរណាផ្សេងទៀតក្នុងព្រះគម្ពីរដូចជាកណ្ឌគម្ពីរហេព្រើរ ដើម្បីជួយលោកអ្នកក្នុងការធ្វើការនេះទេ។ គោលបំណងនៃកណ្ឌគម្ពីរនេះគឺជួយឲ្យលោកអ្នកឃើញអំពីធាតុពិតនៃតម្លៃរបស់ព្រះជាម្ចាស់។



50 QnA John Piper Final 1.5.indd 266 25/01/2024 09:23:22 AM

នេះគឺពិតជាអស្ចារ្យមែន! គោលបំណងនៃកណ្ឌគម្ពីរនេះគឺជួយរក្សាកុំឲ្យគ្រីស្ទបរិស័ទដែលបានអះអាងថាខ្លួនជាអ្នកជឿក្លាយដូចជាលោក អេសាវ។ នេះហើយជាមូលហេតុដែលយើងមានកណ្ឌគម្ពីរនេះ។

ខ្ញុំធ្លាប់មានមិត្តភក្តិម្នាក់ដែលបានចងចាំកណ្ឌគម្ពីរហេព្រើរទាំងមូល។ សូមព្យាយាមចងចាំកណ្ឌគម្ពីរហេព្រើរដែរចុះ ពីព្រោះជីវិតរបស់លោកអ្នកទំនងត្រូវតែពឹងលើកណ្ឌគម្ពីរនេះ។

## សម្លឹងមើលទៅឯព្រះរាជបុត្រា

បញ្ហាចម្បងរបស់លោកអ្នកគឺថាលោកអ្នកចូល និងចេញពីទស្សនៈបត់បែននៃលោកីយ៍នេះ។ កណ្ឌគម្ពីរហេព្រើរគឺជាទស្សនៈដ៏ល្អឥតខ្ចោះនៃលោកីយ៍នេះ ដែលមានរួមទាំងអំពើផិតក្បត់ ការមើលរូប ឬវីដេអូអាសអាភាស និងរាល់បែបបទនៃអំពើត្រេកត្រអាល។ កណ្ឌគម្ពីរនេះត្រូវបានសរសេរឡើង ហាក់បីដូចជាវ៉ែនតាមួយសម្រាប់លោកអ្នក ពេលដែលលោកអ្នកចាប់ផ្តើមមើលលោកីយ៍នេះក្នុងរបៀបបត់បែន។ សូមពាក់វ៉ែនតានេះចុះ។

សំណួររបស់លោកអ្នកកើតចេញពីកណ្ឌគម្ពីរហេព្រើរជំពូក១២។ សូមពាក់វ៉ែនតានៃកណ្ឌគម្ពីរហេព្រើរជំពូក១២នេះចុះ? មានស្មរបន្ទាល់ជាច្រើននាក់ដែលបានបញ្ចប់ការប្រណាំងនេះ (ហេព្រើរ ១២:១)។ ពួកគេក៏បានតម្រង់ជួរលើទីលានប្រណាំងនៃជីវិតរបស់លោកអ្នកដែរ ហើយពួកគេក៏កំពុងតែស្រែកចំពោះលោកអ្នកចេញពីកណ្ឌគម្ពីរហេព្រើរជំពូក១១ថា៖ «មិនមែនថាលោកអ្នកមិនមានជំនួយនោះទេ។ តាមរយៈជំនឿដូចនោះលោកអ្នកអាចធ្វើការនេះបាន។ លោកអ្នកអាចដើរចេញពីភាពត្រេកត្រអាល និងការមើលរូប និងវីដេអូអាសអាភាសបាន។ តាមរយៈជំនឿដូចនោះលោកអ្នកអាចធ្វើការនេះបាន!»។ អ្នកស្មរបន្ទាល់ជាច្រើននាក់នោះមិនបានក្លាយដូចជាលោក អេ

សារ នោះទេ។ អ្នកស្មរបន្ទាល់ជាច្រើននាក់នោះបានទៅដល់ព្រះយេស៊ូវក្នុងកណ្ឌាគម្ពីរ (ហេព្រើរ ១២:២)។

ខ្ញុំសូមបញ្ចប់ត្រឹមនេះ៖ «[សូម] សម្លឹងមើលព្រះយេស៊ូវ ដែលជាអ្នកចាប់ផ្ដើម និងជាអ្នកធ្វើឲ្យជំនឿរបស់យើងបានគ្រប់លក្ខណ៍ ទ្រង់បានស៊ូទ្រាំនៅលើឈើឆ្កាង ដោយមិនគិតពីសេចក្ដីអាម៉ាស់ឡើយ ដោយព្រោះតែអំណរដែលនៅចំពោះព្រះអង្គ ហើយព្រះអង្គក៏គង់ខាងស្ដាំបល្ល័ង្កនៃព្រះ» (ហេព្រើរ ១២:២)។ ព្រះអង្គបានសម្រេចការនោះសម្រាប់លោកអ្នក ហើយព្រះអង្គនឹងធ្វើវាក្នុងលោកអ្នកដែរ។ សូមមើលឃើញសេចក្ដីពិតដូចលក្ខណៈរបស់វាចុះ។ ចូរមានកម្លាំងឡើងតាមរយៈព្រះគុណ។ ចូរដឹងថា មិនបានថាលោកអ្នកមិនមានជំនួយនោះទេ។ ហើយសូមសម្លាប់ការកុហកនោះចុះពេលវាកើតមានឡើង។

ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖



50 QnA John Piper Final 1.5.indd 268 25/01/2024 09:23:23 AM

# សំណួរទី៤៦៖
# តើខ្ញុំតយុទ្ធជាមួយនឹងការស្រឡាញ់ភេទដូចគ្នា បានដោយរបៀបណា?

មានបុរសម្នាក់ឈ្មោះសំណាងបានលើកជាសំណួរសួរថា *«ប្រសិនបើព្រះគម្ពីរបានរាប់ការស្រឡាញ់ភេទដូចគ្នាថាជាការមិនត្រឹមត្រូវ នោះគឺជាសេចក្តីពិតដែលខ្ញុំក៏ទទួលជឿដែរ ទោះបើក្នុងនាមខ្ញុំជាបុរសម្នាក់ដែលកំពុងតែតយុទ្ធក្នុងការស្រឡាញ់ភេទដូចគ្នាក៏ដោយ តើឲ្យខ្ញុំគួរបកស្រាយកណ្ឌគម្ពីរ ១កូរិនថូស ៧:៨-៩ បានយ៉ាងដូចម្តេច ប្រសិនបើខ្ញុំ «អត់ទ្រាំមិនបាន» ក្នុងការស្រឡាញ់ភេទដូចគ្នា? តើខ្ញុំមានការគិតមិនត្រឹមត្រូវលើឃ្លា «អត់ ទ្រាំមិនបាន» មែនឬ? ខ្ញុំសង្កេតឃើញថា ខ្ញុំកាន់តែមានការពិបាកក្នុងការតយុទ្ធ នឹងភាពត្រេកត្រអាលមួយនេះ ដោយផ្អែកទៅលើខគម្ពីរខាងលើ ព្រោះខ្ញុំមិនដឹងថាគួរធ្វើយ៉ាងដូចម្តេចទៀតទេ?»*

យើងខ្ញុំសូមអរគុណចំពោះ សំណាង ដែលហ៊ាននិយាយត្រង់ៗអំពីការស្រឡាញ់ភេទដូចគ្នា ហើយយើងខ្ញុំក៏សូមអរគុណចំពោះគាត់ដែរ ដែលគាត់ទទួលស្គាល់សេចក្តីពិតក្នុងព្រះគម្ពីរត្រង់ថា ការអនុវត្តការស្រឡាញ់ភេទដូចគ្នាគឺជាអំពើបាប? ហេតុដូចនេះហើយ ដូចដែលគាត់បាននិយាយថា គឺគាត់កំពុងតែតយុទ្ធនៅក្នុងសមរភូមិនៃការមានភាពស្មោះត្រង់នូវអ្វីដែលគាត់កំពុងតែមានជំនឿជឿលើទ្រង់។ នេះពិតជាអស្ចារ្យណាស់ ហើយជាអ្វីដែលស័ក្តិសម ហើយក៏នឹងធ្វើឲ្យព្រះជាម្ចាស់សព្វព្រះហឫទ័យ ទាក់ទងនឹងការតយុទ្ធមួយនោះ។

## មិនមែនជាដំណោះស្រាយឡើយ

គាត់បានសួរអំពីកណ្ឌគម្ពីរ ១កូរិនថូស ៧:៩ ដែលសាវ័ក ប៉ុល បាន



50 QnA John Piper Final 1.5.indd 269 25/01/2024 09:23:23 AM

លើកឡើងថា «ប៉ុន្តែ បើអ្នកទាំងនោះអត់ទ្រាំមិនបាន នោះចូរយកប្តីប្រពន្ធចុះ ដ្បិតដែលយកប្តីប្រពន្ធ នោះជាជាងទ្រាំឲ្យមានសេចក្តីឆេវឆាវវិញ»។ ប៉ុន្តែ ប្រាកដណាស់ នេះជាការពិត! ជីវិតអាពាហ៍ពិពាហ៍គឺជាផ្លូវឬវិធីសាស្ត្រដែលអាចដំណោះស្រាយទៅលើការគ្រប់គ្រងនូវភាពត្រេកត្រអាលខាងឯការរួមភេទរបស់យើង។ ប៉ុន្តែ មានចំណុចពីរយ៉ាងដែលយើងគួរចងចាំនៅត្រង់ចំណុចនេះ ដែលទាក់ទងនឹងអស់អ្នកដែលស្រឡាញ់ភេទផ្ទុយគ្នា និងភេទដូចគ្នា។

*ទី១* ជីវិតអាពាហ៍ពិពាហ៍មិនមែនជាផែនការសម្រាប់ដោះស្រាយភាពត្រេកត្រអាលរបស់មនុស្សប្រុសទេ។ យើងដឹងត្រង់ចំណុចនេះថា ព្រោះមានមនុស្សប្រុសដែលបានរៀបការរួចមកហើយជាច្រើននាក់នៅតែផិតក្បត់ហើយនិងនៅតែមើលរូបភាព ឬក៏វីដេអូអាសអាភាសដដែល។ ដូច្នេះ ចំពោះអស់អ្នកដែលស្រឡាញ់ភេទផ្ទុយ ឬក៏ភេទដូចគ្នា ប្រសិនបើជីវិតអាពាហ៍ពិពាហ៍គឺមិនមែនជាជម្រើសសម្រាប់លោកអ្នក នោះមិនមែនមានន័យថាលោកអ្នកមិនមានដំណោះស្រាយលើភាពអត់មិនបានទេ។ វាមិនមែនជាដំណោះស្រាយទេ ព្រោះជីវិតអាពាហ៍ពិពាហ៍មិនមែនជាដំណោះស្រាយឡើយ។

## ព្រះអង្គបានសម្អាតលោកអ្នក

*ទី២* សាវ័ក ប៉ុល បានមានប្រសាសន៍យ៉ាងចំៗទៅកាន់មនុស្សប្រុសដែលស្រឡាញ់ភេទដូចគ្នា និងពីរបៀបដែលពួកគាត់ត្រូវធ្វើ ដើម្បីគ្រប់គ្រងលើភាពអត់មិនបានរបស់ខ្លួន។ ចំណុចដែលគាត់បានលើកឡើងមានចែងនៅក្នុងជំពូកមុន គឺមិនមែនជំពូក៧ទេ។ ហើយជារឿយៗ យើងគ្រាន់តែអានជំពូកនោះ ដើម្បីរកមូលហេតុថា ការស្រឡាញ់ភេទដូចគ្នាគឺជាអំពើបាបតែប៉ុណ្ណោះ តែយើងបានមើលរំលងពីជំនួយដ៏ប្រសើរដែលខគម្ពីរនេះបានលើក

ឡើង។ នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៦:៩-១០ បានចែងថា «តើអ្នករាល់គ្នាមិនដឹងថា ពួកអ្នកប្រព្រឹត្តអំពើទុច្ចរិត មិនអាចគ្រងព្រះរាជ្យរបស់ព្រះទុកជាមរតកបានទេឬ? សូមកុំច្រឡំឲ្យសោះ! ពួកសហាយស្មន់ ពួកថ្វាយបង្គំរូបព្រះ ពួកផិតក្បត់ ពួកប្រុសពេស្យា ពួករួមសង្វាសនឹងភេទដូចគ្នា ពួកចោរ ពួកលោភលន់ ពួកប្រមឹក ពួកជេរប្រមាថ ពួកបោកប្រាស់ នោះមិនអាចគ្រងព្រះរាជ្យរបស់ព្រះទុកជាមរតកបានឡើយ» (គកស)។ មួយវិញទៀត ប្រសិនបើលោកអ្នកនិយាយថា «ខ្ញុំជាមនុស្សលោភ ហើយខ្ញុំបានកើតមកជាមនុស្សបែបនោះ ហើយខ្ញុំនៅតែឱបក្រសោបភាពលោភលន់ថាជាការត្រឹមត្រូវ» នោះលោកអ្នកនឹងប្រាកដជាវិនាសជាមិនខាន។ ដូច្នេះ ចូរកុំគិតថា មានអំពើបាបណាមួយដែលសាវ័ក ប៉ុល កំពុងតែផ្ដោតលើយ៉ាងខ្លាំងទៅលើនោះឲ្យសោះ។ ប្រសិនបើលោកអ្នកស្រឡាញ់ ថ្នាក់ថ្នម បីបាច់ ថែរក្សា សង្វាតដេញតាម ក៏ដូចជារស់នៅក្នុងអំពើបាបទាំងអស់នោះ នោះវានឹងបំផ្លាញលោកអ្នកចោលជាមិនខាន ពោលគឺមិនមែនគ្រាន់តែទាក់ទងទៅនឹងអំពើបាបនៃការស្រឡាញ់ភេទដូចគ្នា ឬក៏ការផិតក្បត់នោះឡើយ។

ចូរសង្កេតមើលលើខគម្ពីរបន្ទាប់ទៀត ដែលនោះគឺជាខដ៏សំខាន់ «ពីដើមអ្នករាល់គ្នាខ្លះក៏ធ្លាប់ជាមនុស្សបែបនោះដែរ តែព្រះបានលាងសម្អាតអ្នករាល់គ្នា បានញែកអ្នករាល់គ្នាជាបរិសុទ្ធ បានរាប់អ្នករាល់គ្នាជាសុចរិតក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងដោយសារព្រះវិញ្ញាណនៃព្រះរបស់យើងរួចហើយ» (១កូរិនថូស ៦:១១ គកស)។ ខគម្ពីរមួយនេះគឺជាខដ៏សំខាន់បំផុតចំពោះអស់អ្នកដែលកំពុងតយុទ្ធនឹងការស្រឡាញ់ភេទដូចគ្នា ហើយក៏កំពុងតែព្យាយាមឲ្យជីវិតរបស់យើងរស់នៅបានបរិសុទ្ធហើយប្រសើរឡើងជាងមុន។ ពីដើមលោកអ្នកជាមនុស្សដែលប្រព្រឹត្តការស្រឡាញ់ភេទដូចគ្នា។ ពីមុនលោកអ្នកជាមនុស្សបែបនោះមែន ប៉ុន្តែពេលនេះលោកអ្នកមិនមែនជាមនុស្សបែបហ្នឹងទៀតទេ។ តើមានអ្វីបានកើតឡើង? ចម្លើយគឺ៖



50 QnA John Piper Final 1.5.indd 271 25/01/2024 09:23:24 AM

លោកអ្នកបាន ឱបក្រសោបយកព្រះនាមរបស់ព្រះយេស៊ូវ ថាទ្រង់ជាម្ចាស់គ្រងលើជីវិតរបស់ខ្លួន។ លោកអ្នកបានចុះចូលនឹងទ្រង់ ហើយបានដាក់ជំនឿលើទ្រង់ទាំងស្រុង ហើយព្រះលោហិតរបស់ទ្រង់បានលាងសម្អាតនូវរាល់អំពើបាបរបស់លោកអ្នកចេញ។ ព្រះអង្គបានលាងសម្អាតលោកអ្នកហើយ ហើយព្រះជាម្ចាស់ក៏បានរាប់យើងថាជាមនុស្សសុចរិត។ លោកអ្នកត្រូវបានញែកចេញជាបរិសុទ្ធ។ ហើយបន្ទាប់មកទៀត សាវ័ក ប៉ុល បានលើកឡើងយ៉ាងចំៗថា ព្រះវិញ្ញាណរបស់ព្រះនៃយើងរាល់គ្នាជាអង្គដែលបានជះឥទ្ធិពលយ៉ាងខ្លាំងបំផុតក្នុងការញែកចេញជាបរិសុទ្ធមួយនេះ។

**អំណាចនៃព្រះវិញ្ញាណបរិសុទ្ធ**

ជាដំបូងបង្អស់ លោកអ្នកត្រូវតែដឹងថា ព្រះជាម្ចាស់ព្រមទទួលយកលោកអ្នក ទ្រង់បានប្រកាសថាលោកអ្នកលែងមានបាបទៀតហើយ ហើយក៏បានសម្អាតលោកអ្នកព្រមទាំងរាប់លោកអ្នកជាមនុស្សសុចរិត។ ហើយពីមួយថ្ងៃទៅមួយថ្ងៃ លោកអ្នកបានទុកចិត្តលើសេចក្តីសន្យារបស់ព្រះជាម្ចាស់ឲ្យជាជំនួយសម្រាប់ខ្លួនតាមរយៈសេចក្តីសន្យារបស់ទ្រង់។ ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកដោយពោរពេញទៅដោយអំណាច ហើយនឹងជួយលោកអ្នកបដិសេធរាល់សេចក្តីល្បួងដែលកើតមានឡើង។ លោកអ្នកសម្លាប់ជីវិតនៃនិស្ស័យសាច់ឈាមចោល ដូចដែលបានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៨:១៣ តាមរយៈព្រះវិញ្ញាណ ដោយពឹងផ្អែកទៅលើព្រះវិញ្ញាណ ដោយស្រែកហៅព្រះវិញ្ញាណ និងដោយរស់នៅក្នុងព្រះវិញ្ញាណ។ មិនមែនក្នុងខ្លួនឯងទេគឺក្នុងព្រះអង្គវិញ។ ក្នុងកណ្ឌគម្ពីរ កាឡាទី ៣:៥ បានលើកឡើងថា ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកយើង ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណឲ្យធ្វើការអស្ចារ្យទាំងនេះតាមរយៈការមានជំនឿ។ ក្នុងនោះមានន័យថា លោកអ្នកបានឮនូវសេចក្តីសន្យា លោកអ្នកឮនូវសេចក្តី



50 QnA John Piper Final 1.5.indd 272 25/01/2024 09:23:24 AM

សន្យាដំណឹងល្អ ហើយលោកអ្នកព្រមទទួលស្គាល់ដោយទុកចិត្តជឿក្នុង និងតាមរយៈការធ្វើឲ្យបុគ្គលភាពរបស់ព្រះជាម្ចាស់ ជំនួយ និងរង្វាន់របស់ទ្រង់មានតម្លៃចំពោះលោកអ្នកលើសជាងអំណាចនៃការល្បួងដែលលោកអ្នកកំពុងតែប្រឈមមុខទៅទៀត ហើយការនោះនឹងធ្វើឲ្យលោកអ្នកអាចសម្លាប់សេចក្ដីល្បួងនោះបាន។

សរុបសេចក្ដីមកផ្ដោតទៅសំណួរខាងលើរបស់សំណាង ចម្លើយរបស់យើងខ្ញុំគឺ៖ លុះត្រាតែព្រះជាម្ចាស់បានត្រាស់ហៅឲ្យលោកអ្នករៀបការ ហើយសូមកុំសន្មតថាការនោះទំនងនឹងមិនអាចកើតឡើងឡើយ។ យើងខ្ញុំកំពុងតែនិយាយទៅកាន់បុគ្គលដែលស្រឡាញ់ភេទដូចគ្នា។ លុះត្រាតែលោកអ្នករៀបការជាមួយនឹងមនុស្សស្រី ដោយសារលោកអ្នកកំពុងតែតយុទ្ធក្នុងការស្រឡាញ់មនុស្សប្រុស ឬក៏ថាលុះត្រាតែអ្នករៀបការជាមួយនឹងមនុស្សប្រុស ដោយសារអ្នកកំពុងតែតយុទ្ធនឹងការស្រឡាញ់មនុស្សស្រី...និយាយឲ្យខ្លីទៅ៖ លុះត្រាតែលោកអ្នករៀបការជាមួយនឹងភេទផ្ទុយពីភេទរបស់ខ្លួន នោះចូរទុកចិត្តលើផែនការដ៏អស្ចារ្យរបស់ព្រះគ្រីស្ទក្នុងការដែលទ្រង់ធានានូវរាល់សេចក្ដីសន្យាសម្រាប់លោកអ្នក ក៏ដូចជានឹងប្រទានព្រះវិញ្ញាណបរិសុទ្ធដ៏ខ្លាំងពូកែ ដើម្បីឲ្យមកជួយលោកអ្នកក្នុងការរស់នៅឲ្យបានបរិសុទ្ធ និងការមានជីវិតដ៏មានតម្លៃហើយមានប្រយោជន៍ដោយមិនតយុទ្ធនឹងអំពើបាបខាងឯផ្លូវភេទ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**

50 QnA John Piper Final 1.5.indd 274 25/01/2024 09:23:25 AM

# សំណួរទី៤៧៖
# តើខ្ញុំយកគំនិតខ្ញុំឲ្យចុះចូលនឹងព្រះដោយរបៀបណា?

*“ព្រោះគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើងខ្ញុំ មិនមែនជារបស់ខាងសាច់ឈាមទេ គឺជាឥទ្ធិឫទ្ធិដែលមកពីព្រះ សម្រាប់នឹងរំលំទីមាំមួនវិញ ដែលអាចនឹងរម្លាយអស់ទាំងគំនិតដែលគេរិះគិត នឹងគ្រប់ទាំងសេចក្ដីយ៉ាងខ្ពង់ខ្ពស់ ដែលលើកខ្លួនឡើងទាស់នឹងចំណេះនៃព្រះ ព្រមទាំងនាំអស់ទាំងគំនិតឲ្យចុះចូលស្ដាប់បង្គាប់ព្រះគ្រីស្ទវិញ” (២កូរិនថូស ១០:៤-៥)។*

**អាវុធខាងឯវិញ្ញាណ**

ជាដំបូង យើងត្រូវតែចងចាំថា អាវុធសង្គ្រាមរបស់យើងគឺជាអាវុធខាងឯវិញ្ញាណ មិនមែនជាអាវុធខាងឯសាច់ឈាមទេ ហើយក៏ជាឥទ្ធិឫទ្ធិដែលមកពីព្រះជាម្ចាស់ដែរ។

**បានលើកឡើង ប៉ុន្តែមិនមែនជាបង្គាប់**

ចំណុចដំបូងដែលយើងខ្ញុំគិតថាយើងត្រូវតែលើកឡើងនៅពេលដែលយើងយកខគម្ពីរមួយនេះមកអនុវត្តន៍ផ្ទាល់ខ្លួន គឺយើងត្រូវតែប្រាកដឲ្យច្បាស់ថា យើងកំពុងតែយល់អត្ថន័យខគម្ពីរនេះយ៉ាងត្រឹមត្រូវជាមុនសិន។ នៅពេលដែលសាវ័ក ប៉ុល លើកឡើងជាដំបូងថា គាត់រម្លាយអស់ទាំងគំនិតដែលគេរិះគិតទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ហើយបន្ទាប់មកថាគាត់នាំអស់ទាំងគំនិតឲ្យចុះចូលស្ដាប់បង្គាប់ព្រះគ្រីស្ទវិញ អ្វីដែលយើងត្រូវចងចាំនោះគឺថាវាសំដៅទៅលើការគិតគូរ និងចិត្តរបស់អ្នកដទៃ។

និយាយម្យ៉ាងវិញទៀត វាហាក់បីដូចជាសាវ័ក ប៉ុល កំពុងតែមានប្រសាសន៍ថា “ខ្ញុំនឹងទៅសួរសុខទុក្ខពួកមានកលល្បិចខ្ពស់ទាំងនោះនៅ



50 QnA John Piper Final 1.5.indd 275 25/01/2024 09:23:25 AM

ក្រុងកូរិនថូស ដែលកំពុងតែមានអំនួតអះអាងអំពីភាពប៉ិនប្រសប់ខាងឯផ្នែកទស្សនវិជ្ជារបស់ខ្លួន ហើយខ្ញុំនឹងបំផ្លាញពួកគេចោល មិនមែនដោយប្រើប្រាស់ចំណុចទស្សនៈវិជ្ជាណាផ្សេងទៀតមកប្រឆាំងនោះទេ ប៉ុន្តែប្រើប្រាស់អំណាចពីព្រះជាម្ចាស់ផ្ទាល់វិញ។ ខ្ញុំនឹងបង្ហាញអំណាចឲ្យពួកគេឃើញ ហើយគំនិតរបស់ពួកគេនឹងត្រូវដួលរលំចុះក្នុងការគិតគូររបស់គេជាមិនខាន។ ហើយបន្ទាប់មកខ្ញុំនឹងនាំអស់ទាំងគំនិតរបស់ពួកគេឲ្យចុះចូលស្តាប់បង្គាប់ព្រះគ្រីស្ទវិញ។»

សរុបសេចក្តីទៅសាវ័ក ប៉ុល គឺជាអ្នកចម្បាំង ហើយខ្មាំងសត្រូវគឺជាអស់អ្នកដែលមានគំនិត និងការរិះគិតដែលពេញទៅដោយអំនួត ហើយលើកខ្លួនឡើងទាស់នឹងព្រះជាម្ចាស់។ នៅពេលដែលសាវ័ក ប៉ុល បានយកឈ្នះលើគំនិត និងការរិះគន់ទាំងនោះដោយអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះការគិតគូរ និងគំនិតរិះគន់របស់គេនឹងត្រូវបាននាំឲ្យមានការចុះចូលស្តាប់បង្គាប់ ហើយពួកគេនឹងក្លាយជាមនុស្សដែលមានការគិតគូរដូចព្រះគ្រីស្ទ ឬក៏ថាជាមនុស្សដែលស្តាប់បង្គាប់ព្រះគ្រីស្ទវិញ។

ខគម្ពីរមួយនេះមិនបានបង្គាប់យើងឲ្យនាំអស់ទាំងគំនិតផ្ទាល់ខ្លួនឲ្យចុះចូលស្តាប់បង្គាប់ព្រះគ្រីស្ទវិញនោះទេ ប៉ុន្តែជាប្រយោគស្របអំពីអ្វីដែលសាវ័ក ប៉ុល កំពុងតែធ្វើទៅកាន់អស់អ្នកដែលទោសប្រឆាំងនឹងគាត់។ គាត់កំពុងតែបំផ្លាញទស្សនវិជ្ជារបស់ពួកគេ ហើយនាំយកការគិតដែលចាញ់របស់ពួកគេឲ្យចុះចូលចំពោះព្រះគ្រីស្ទ ដើម្បីឲ្យពួកគេអាចក្លាយទៅជាអ្នកមានគំនិតត្រឹមត្រូវបាន ពោលគឺមានការស្តាប់បង្គាប់ក្នុងរបៀបដែលគេគួរគិតគូរអំពីព្រះគ្រីស្ទ។

## របៀបនាំអស់ទាំងគំនិតឲ្យចេះចុះចូលស្តាប់បង្គាប់

កណ្ឌគម្ពីរ ២កូរិនថូស ១០:៥ មិនមែនជាការបង្គាប់ឲ្យយើងធ្វើការនេះ



50 QnA John Piper Final 1.5.indd 276 25/01/2024 09:23:25 AM

ដោយខ្លួនឯងនោះទេ ប៉ុន្តែនៅមានរបៀបដែលយើងអាចអនុវត្តខគម្ពីរនេះបាន។ ចូរប្រាកដឲ្យច្បាស់ថា លោកអ្នកកំពុងតែស្ថិតនៅក្នុងភាគីមួយណា—ហើយថា តើភាគីដែលយើងកំពុងស្ថិតនៅនោះត្រូវ ឬក៏មិនត្រូវ?—កន្លែងដែលយើងគួរនឹងនៅគឺក្នុងក្រុមមនុស្សដែលមានការគិតគូរដូចដែលពេលសាវ័ក ប៉ុល កំពុងព្យាយាមបំផ្លាញចោលគំនិត។ នោះឯងគឺជាភាគីដែលយើងត្រូវចូលរួម។ បន្ទាប់មកទើបយើងអាចបំផ្លាញការរឹះគន់ និងការគិតគូដែលលើកខ្លួនទាស់ប្រឆាំងនឹងចំណេះរបស់ព្រះជាម្ចាស់ ហើយទើបយើងអាចនាំអស់ទាំងគំនិតឲ្យចេះចុះចូលស្ដាប់បង្គាប់បាន។

ដូច្នេះ នៅពេលដែលយើងអានខគម្ពីរនេះ យើងគួរតែគិតថា “ខ្ញុំកំពុងនៅកន្លែងនេះ។ សូមបំផ្លាញខ្ញុំចោលចុះ។ សូមនាំអស់ទាំងគំនិតគិតគូររបស់ខ្ញុំឲ្យស្ដាប់បង្គាប់។ សូមបំផ្លាញអស់ទាំងគំនិតមិនត្រឹមត្រូវ ឬក៏អំនួតដែលខ្ញុំមានអំពីព្រះជាម្ចាស់ចោលចុះ។” ការនេះមានអត្ថន័យពីរយ៉ាងដែលយើងជាគ្រីស្ទបរិស័ទគួរធ្វើ៖

## ១) ចូរពិនិត្យពិច័យរាល់គំនិតទាំងអស់ពេលចុះចូល

យើងគួរស្ដាប់សាវ័ក ប៉ុល ហើយចុះចូលនូវរាល់គំនិត ការគិត និងអារម្មណ៍របស់យើងអំពីព្រះជាម្ចាស់ និងអំពីជីវិតចំពោះសេចក្ដីបង្រៀនរបស់សាវ័ក ប៉ុល (ក្នុងនាមជាសាវ័ករបស់ព្រះជាម្ចាស់) ដើម្បីពិនិត្យពិច័យ ហើយប្រសិនបើមានចំណុចណាមួយដែលមិនស៊ីគ្នាជាមួយនឹងសេចក្ដីបង្រៀនរបស់គាត់ នោះយើងត្រូវតែបំផ្លាញវាចោល។

យើងខ្ញុំធ្លាប់មានបទពិសោធន៍ដ៏ឈឺចាប់បែបនេះផ្ទាល់។ ប្រសិនបើលោកអ្នកពិតជាប្រៀបធៀបចិត្តគំនិតរបស់លោកអ្នកទៅកាន់សេចក្ដីបង្រៀនរបស់ពួកសាវ័កដោយល្បងលវាមែន ហើយនិយាយថា “ប្រសិនបើមានការគិតគូរក្នុងជីវិតរបស់ខ្ញុំដែលខ្ញុំត្រូវតែបំផ្លាញចោល សូមបំផ្លាញវាចោលចុះ!” ការនេះ

នឹងបង្វែរជីវិតលោកអ្នកចេញជាមិនខានដោយមានការផ្លាស់ប្រែដ៏អស្ចារ្យកើតឡើង។ ក្នុងឆាកជីវិតនេះ មានពេលដែលយើងខ្ញុំធ្លាប់យំក្រសោបយ៉ាងខ្លាំង នៅពេលដែលព្រះជាម្ចាស់ដកចេញនូវអ្វីៗដែលយើងខ្ញុំគិតថា វាសំខាន់នៅក្នុងជីវិតរបស់យើងខ្ញុំចេញ។

ដូច្នេះ យើងខ្ញុំគិតថា នោះជាចំណុចដំបូងដែលយើងត្រូវធ្វើឡើង។ យើងស្ដាប់សាវ័ក ប៉ុល។ យើងនាំយកនូវរាល់អ្វីៗដែលយើងគិត (រាល់គំនិត រាល់ទស្សនៈ និងទស្សនវិជ្ជា) ឲ្យចុះចូលនឹងព្រះជាម្ចាស់ ហើយយើងប្រកាសថា "ប្រសិនបើចាំបាច់ សូមឲ្យព្រះបន្ទូលរបស់ព្រះអង្គដកវាចេញទៅ"។

## ២) ទូលសូមឲ្យព្រះវិញ្ញាណបរិសុទ្ធធ្វើការ

នេះជាចំណុចទីពីរនៃអត្ថន័យនេះ។ យើងគួរទូលសូមឲ្យព្រះវិញ្ញាណបរិសុទ្ធធ្វើការ ពីព្រោះសាវ័ក ប៉ុល បានលើកឡើងថា យើងមិនមែនច្បាំងជាមួយនឹងមនុស្សខាងឯសាច់ឈាមក្នុងការរិះគន់នោះទេ។ ព័ន្ធកិច្ចរបស់យើងមានអំណាច ដូច្នេះហើយយើងគួរតែប្រើប្រាស់អំណាចដែលយើងមាន។

សាវ័ក ប៉ុល បានមានប្រសាសន៍ថា "ព្រោះគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើងខ្ញុំ មិនមែនជារបស់ខាងសាច់ឈាមទេ គឺជាឥទ្ធិឫទ្ធិដែលមកពីព្រះសម្រាប់នឹងរម្លាយទីមាំមួនវិញ" (២កូរិនថូស ១០:៤)។ យើងអាចនិយាយម្យ៉ាងទៀតថា គាត់កំពុងតែបំផ្លាញចោលការរិះគន់ និងគំនិតដែលបន្ទាបបន្ថោកព្រះជាម្ចាស់ ប៉ុន្តែគាត់មិនបានធ្វើការនោះដោយប្រើប្រាស់ទស្សនវិជ្ជាក្នុងការវែកញែកនោះទេ។

នៅពេលដែលយើងអានព្រះគម្ពីរ យើងក៏ត្រូវតែព្យាយាមសិក្សាឲ្យបានច្រើនដែរ។ យើងខ្ញុំចូលចិត្តសិក្សាខ្លាំងណាស់ យើងខ្ញុំក៏ស្រឡាញ់ការវែកញែកទស្សនវិជ្ជា ដើម្បីឲ្យយល់វាផងដែរ។ ប៉ុន្តែ យើងខ្ញុំក៏គួរតែស្រែកយំបែបនេះ "ឱ! ព្រះអម្ចាស់អើយ! ទូលបង្គំដឹងហើយថា តក្កនៃលក្ខណៈគិតគូរ



50 QnA John Piper Final 1.5.indd 278 25/01/2024 09:23:25 AM

របស់ទូលបង្គំគឺមិនល្មមគ្រប់គ្រាន់ឡើយក្នុងការបំផ្លាញចោលនូវគំនិតគិតគូររបស់ទូលបង្គំដែលបានចាក់ឫសក្នុងសេចក្ដីខុសឆ្គងយ៉ាងជ្រាលជ្រៅ ហេតុដូច្នេះហើយបានជាទូលបង្គំសូមជំនួយពីព្រះអង្គ។ ទូលបង្គំទូលសូមឲ្យព្រះវិញ្ញាណបរិសុទ្ធជួយទូលបង្គំ ហើយទូលបង្គំក៏ចង់ឃើញព្រះភក្ត្រព្រះអង្គផងដែរ។»

សាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៥:១៨ ដូចតទៅ «ខ្ញុំមិនហ៊ាននិយាយពីការអ្វី លើកតែពីការដែលព្រះគ្រីស្ទបានធ្វើដោយសារខ្ញុំប៉ុណ្ណោះទេ គឺជាការនាំសាសន៍ដទៃឲ្យស្ដាប់បង្គាប់»។ ការស្ដាប់បង្គាប់មួយនោះក៏ដូចជាការស្ដាប់បង្គាប់នៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ១០:៤-៥ ផងដែរ នៅពេលដែលយើងនាំចិត្តគំនិតរបស់យើងឲ្យចុះចូលស្ដាប់បង្គាប់ព្រះគ្រីស្ទ។

ក្នុងកណ្ឌគម្ពីរ រ៉ូម ១៥:១៨ សាវ័ក ប៉ុល បានលើកឡើងថា «ខ្ញុំមិនហ៊ាននិយាយពីការអ្វី លើកតែពីការដែលព្រះគ្រីស្ទបានធ្វើ»។ ហើយនេះឯងគឺជាអ្វីដែលយើងខ្ញុំចង់សង្កត់ន័យលើ នៅពេលដែលយើងខ្ញុំលើកឡើងអំពីការសូមជំនួយពីព្រះជាម្ចាស់។ ចូរថ្វាយខ្លួនដល់ព្រះគ្រីស្ទដែលកំពុងមានព្រះជន្មរស់ឡើងវិញ—តាមរយៈអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ដោយប្រសាសន៍របស់សាវ័ក ប៉ុល—ដើម្បីឲ្យព្រះអង្គអាចដកចេញនូវរាល់អ្វីៗទាំងអស់ចោលបាន។ នោះឯងទើបលោកអ្នកអាចនាំការត្រិះរិះពិចារណា ចិត្តគំនិតឲ្យចុះចូលស្ដាប់បង្គាប់ និងរាល់គ្រប់អ្វីៗទាំងអស់អាចក្រាប់តាមព្រះគ្រីស្ទបាន។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 279 25/01/2024 09:23:26 AM

50 QnA John Piper Final 1.5.indd 280 25/01/2024 09:23:26 AM

## សំណួរទី៤៨៖

# ប្រសិនបើខ្ញុំបានស្លាប់ចំពោះអំពើបាបហើយ ហេតុអ្វីបានជាខ្ញុំត្រូវសម្លាប់វាជារៀងរាល់ថ្ងៃ?

*ប្រសិនបើគ្រីស្ទបរិស័ទបានកើតជាថ្មី ហើយបានស្លាប់ចំពោះអំពើបាបហើយ ចុះហេតុអ្វីបានជាអំពើបាបមានឥទ្ធិពលលើការសម្រេចចិត្តក្នុងចិត្តរបស់យើងអញ្ចឹង? ដូចគ្នានឹងសាច់ឈាមដែរ? ហេតុអ្វីបានជាយើងត្រូវសម្លាប់វាជារៀងរាល់ថ្ងៃ? សណ្ឋានរបស់ខ្ញុំក្នុងព្រះគ្រីស្ទ និងការងារប្រចាំថ្ងៃរបស់ខ្ញុំ—ការសម្លាប់មួយនេះ—ហាក់បីដូចជា (ហើយមានអារម្មណ៍ថា) វាជំទាស់នឹងគ្នា!*

ប្រាកដណាស់! ពិតមែនហើយ។ ខ្ញុំក៏យល់ពីអារម្មណ៍នេះដែរ។ តោះ! ចូរយើងព្យាយាមធ្វើនូវចំណុចពីរយ៉ាងក្នុងការឆ្លើយសំណួរនេះ។ ទី១៖ ចូរព្យាយាមបង្ហាញចេញពីព្រះគម្ពីរសញ្ញាថ្មីអំពីអ្វីដែលពិតជាបានកើតឡើងក្នុងការកើតជាថ្មី ជាពិសេសទាក់ទងទៅនឹងការដែលគ្រីស្ទបរិស័ទនៅបន្តប្រព្រឹត្តអំពើបាបទៀត។ ទី២៖ ហើយបន្ទាប់មក ចូរយើងសាកល្បងមើលថា តើយើងអាចឆ្លើយបានយ៉ាងហោចណាស់ផ្នែកខ្លះៗនូវសំណួរ "ហេតុអ្វីបានជាព្រះជាម្ចាស់ធ្វើវាក្នុងរបៀបនោះ?" ពីព្រោះនេះហើយគឺជាចំណុចស្នូលនៃសំណួរមួយនេះ។ ប៉ុន្តែ មុនយើងអាចទៅដល់ចំណុចនោះបាន ខ្ញុំគិតថា ជាដំបូងយើងត្រូវចាប់ផ្ដើមសួរថា "តើមានអ្វីកើតឡើងក្នុងការបង្កើតជាថ្មី ឬក៏ក្នុងការកើតជាថ្មី?"។

### ការកើតជាថ្មី

ចម្លើយរបស់ខ្ញុំលើសំណួរដំបូងគឺថា៖ អ្វីដែលព្រះជាម្ចាស់បង្កើតមកនៅក្នុងការកើតជាថ្មីគឺមិនមែនឲ្យមានគ្រីស្ទបរិស័ទដែលគ្មានអំពើបាបនោះទេ។



50 QnA John Piper Final 1.5.indd 281 25/01/2024 09:23:26 AM

អ្វីដែលព្រះអង្គបង្កើតនៅមានការទាក់ទិនក្នុងសង្គ្រាម មិនមែនល្អឥតខ្ចោះឡើយ មានពេញទៅដោយអំណាចព្រះចេស្ដាពីព្រះវិញ្ញាណបរិសុទ្ធ ការស៊ូទ្រាំ ការយកព្រះគ្រីស្ទធ្វើជាសម្បត្តិ ការស្អប់អំពើបាប ការមានសណ្ដានជាថ្មី—ការកើតជាថ្មីក្នុងព្រះគ្រីស្ទ។ សូមកុំមើលរំលងការ*ទាក់ទិនក្នុងសង្គ្រាម* និងការ*ស្អប់អំពើបាបឡើយ*។

ការបង្កើតជាថ្មីក្នុងព្រះគ្រីស្ទគឺជាអ្នកប្រយុទ្ធ។ សាវ័ក ប៉ុល បានលើកឡើងក្នុងចំណុចចុងបញ្ចប់នៃជីវិតរបស់គាត់ថា៖ «ខ្ញុំបានតយុទ្ធយ៉ាងល្អ» (២ធីម៉ូថេ ៤:៧) ហើយគាត់ក៏បានប្រាប់លោក ធីម៉ូថេ ឲ្យ «តយុទ្ធយ៉ាងល្អ» ដែរ (១ធីម៉ូថេ ៦:១២)។ ហើយអ្វីដែលគាត់ចង់មានន័យថា គឺការតយុទ្ធ ដើម្បីភាពបរិសុទ្ធ និងជំនឿ៖ ការតយុទ្ធយ៉ាងល្អសម្រាប់ជំនឿ។ ដូច្នេះ សូមកត់សម្គាល់អំពីខគម្ពីរជាគូៗទាំង៤នេះដែលមានលក្ខណៈហាក់បីដូចជាមិនសមហេតុសមផល ដើម្បីឃើញអំពីរបៀបនៃព្រឹត្តិការណ៍នៃការកកើតជាថ្មីមានទំនាក់ទំនងជាមួយគ្នាក្នុងការបន្តធ្វើសង្គ្រាម។

## ១. មិនមែនគ្មានអំពើបាបទេ

នេះគឺជាគូដំបូង៖

«អស់អ្នកដែលកើតពីព្រះមិនប្រព្រឹត្តអំពើបាបទេ» (១យ៉ូហាន ៣:៩)។

«ប្រសិនបើយើងពោលថា យើងគ្មានបាបសោះ នោះយើងបញ្ឆោតខ្លួនឯង» (១យ៉ូហាន ១:៨)។

ការកើតជាថ្មីនេះហាក់បីដូចជាការបង្កើតឌីអិនអេ (DNA) ក្នុងបុគ្គលម្នាក់នេះ—ឌីអិនអេដែលមានលក្ខណៈដូចជាព្រះ ដែលមិនមានការស្កប់ចិត្តក្នុងការបន្តប្រព្រឹត្តអំពើបាបឡើយ។ ទោះបើថា ក្នុងជីវិតនេះ បើយើងនិយាយថា យើងគ្មានអំពើបាប នោះយើងក៏មានការយល់ដឹងមិនត្រឹមត្រូវអំពីរបៀបដែលវាមិនដំណើរការហើយ។ ដូច្នេះ នេះគឺជាគូដំបូង។



50 QnA John Piper Final 1.5.indd 282 25/01/2024 09:23:26 AM

## ២. ស្លាប់ចំពោះបាប

នេះគឺជាគូទី២៖

«យើងដឹងថា មនុស្សចាស់របស់យើងបានជាប់ឆ្កាងជាមួយព្រះអង្គហើយ ដើម្បីឲ្យរូបកាយដែលជាប់មានបាបនេះ ត្រូវវិនាសសាបសូន្យ ហើយកុំឲ្យយើងជាប់ជាអ្នកបម្រើរបស់បាបទៀត» (រ៉ូម ៦:៦)។

«ដូច្នេះ អ្នករាល់គ្នាក៏ត្រូវចាត់ទុកខ្លួនដូចជាបានស្លាប់ខាងឯបាប ហើយរស់ខាងឯព្រះវិញ នៅក្នុងព្រះគ្រីស្ទយេស៊ូវដែរ។ ដូច្នេះ កុំឲ្យបាបសោយរាជ្យក្នុងរូបកាយរបស់អ្នករាល់គ្នា ដែលតែងតែស្លាប់ ដើម្បីឲ្យអ្នករាល់គ្នាស្ដាប់តាមសេចក្ដីប៉ងប្រាថ្នារបស់បាបនោះឡើយ» (រ៉ូម ៦:១១-១២)។

នេះគឺជាការបង្គាប់បញ្ជា។ ចូរចាប់ផ្ដើមសម្លាប់អំពើបាប ចាត់ទុកខ្លួនឯងថាស្លាប់ក្នុងអំពើបាប ហើយយកខ្លួនមកដាក់ក្រោមការសោយរាជ្យរបស់ព្រះគ្រីស្ទវិញ មិនមែនក្រោមការសោយរាជ្យនៃសាច់ឈាមដែលទៀងនឹងស្លាប់របស់ខ្លួនឡើយ។ ដូច្នេះ ប្រយោគស្របគឺ៖ «លោកអ្នកបានស្លាប់ហើយ។» (សូមអានបន្ថែមក្នុងកណ្ឌគម្ពីរ រ៉ូម ៧:៤) និងប្រយោគបង្គាប់បញ្ជា «តែចំពោះអ្នករាល់គ្នា យើងនឹងរស់នៅជាមួយព្រះអង្គ ដោយសារព្រះចេស្ដារបស់ព្រះ» (២កូរិនថូស ១៣:៤)—នេះហើយគឺជាគូទី២។

## ៣. អ្នកតយុទ្ធ

នេះគឺជាគូទី៣៖

«អ្នករាល់គ្នាបានស្លាប់ហើយ ឯជីវិតរបស់អ្នករាល់គ្នាក៏បានលាក់ទុកជាមួយព្រះគ្រីស្ទ» (កូឡុស ៣:៣)។

«ដូច្នេះ ចូរសម្លាប់និស្ស័យសាច់ឈាមរបស់អ្នករាល់គ្នា ដែលនៅផែនដីនេះចេញ» (កូឡុស ៣:៥)។

ដូច្នេះ សេចក្ដីស្លាប់ដែលយើងបានស្លាប់ធ្វើឲ្យយើងក្លាយជាអ្នកតយុទ្ធ



50 QnA John Piper Final 1.5.indd 283 25/01/2024 09:23:26 AM

ប្រឆាំងនឹងអ្វីដែលយើងទើបតែបានស្លាប់ចំពោះ។

## ៤. ព្រះបន្ទូលដ៏រស់

នេះគឺជាគូចង់ក្រោយ៖

«ព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយវិញ ជាព្រះបន្ទូលរបស់ព្រះដែលរស់នៅ ហើយស្ថិតស្ថេរ» (១ពេត្រុស ១:២៣)។

«ដូច្នេះ ចូរលះបង់អស់ទាំងការអាក្រក់ កិច្ចកល ពុតត្បុត ចិត្តច្រណែន និងពាក្យនិយាយដើមគេទាំងប៉ុន្មានចេញទៅ។ ត្រូវសង្វាតរកទឹកដោះសុទ្ធខាងវិញ្ញាណវិញ ដូចទារកដែលទើបនឹងកើត ដើម្បីឲ្យអ្នករាល់គ្នាចម្រើនឡើងដល់ការសង្គ្រោះ» (១ពេត្រុស ២:១-២)។

សរុបសេចក្តីទៅ អ្វីដែលខ្ញុំទទួលបានចេញពីខគម្ពីរទាំង៤គូនោះគឺថា អ្វីដែលការកើតជាថ្មី ការបង្កើតជាថ្មីនាំឲ្យមានគឺការទាក់ទិននឹងការធ្វើសង្គ្រាម មិនមែនការល្អឥតខ្ចោះ ការពេញទៅដោយអំណាចព្រះចេស្តាពីព្រះវិញ្ញាណបរិសុទ្ធ ការស៊ូទ្រាំ ការយកព្រះគ្រីស្ទធ្វើជាសម្បត្តិ ការស្អប់អំពើបាប និងការមានសណ្ឋានជាថ្មីក្នុងព្រះគ្រីស្ទ។ យើងមានការធានារួចស្រេចហើយអំពីលទ្ធផល តែការតយុទ្ធគឺពិតណាស់។

## សិរីល្អនៃព្រះគុណរបស់ទ្រង់

សំណួរចុងក្រោយគឺថា «ហេតុអ្វីបានជាព្រះជាម្ចាស់ធ្វើវាក្នុងរបៀបនោះ?»។ ព្រះអង្គមានអំណាចក្នុងការខ្វាស់ព្រះហស្តរបស់ទ្រង់ ហើយធ្វើឲ្យយើងលែងមានអំពើបាបបានទេតើ។ យើងដឹងថាព្រះអង្គអាចធ្វើបាន ពីព្រោះព្រះអង្គនឹងធ្វើវាក្នុងមួយប៉ប្រិចភ្នែក (១កូរិនថូស ១៥:៥១-៥២)—នៅពេលព្រះអង្គប្រោសយើងឲ្យរស់ពីស្លាប់ឡើងវិញ ឬក៏នៅពេលដែលយើងស្លាប់—ហើយព្រះអង្គក៏នឹងមិនធ្វើឲ្យយើងមានលក្ខណៈដូចជាមនុស្ស



50 QnA John Piper Final 1.5.indd 284 25/01/2024 09:23:27 AM

យន្តផងដែរនៅពេលដែលទ្រង់ប្រព្រឹត្តការនោះដែរ។ ព្រះអង្គនឹងធ្វើឲ្យយើងលែងជាមនុស្សមានបាប ដោយមិនដកចេញនូវភាពជាមនុស្សរបស់យើងចោលឡើយ មិនថាតិចជាង ឬក៏ច្រើនជាងដែរ។ នៅស្ថានសួគ៌ យើងនឹងមិនប្រព្រឹត្តអំពើបាបជាថ្មីម្តងទៀតទេ។ ហេតុអ្វីបានជាព្រះអង្គមិនធ្វើការនោះឥឡូវៗនេះ? នេះគឺជាសំណួរ។

ខ្ញុំគិតថា៖ យ៉ាងហោចណាស់ មានចម្លើយបែបទ្រង់ទ្រាយធំលើសំណួរនេះ ហើយក៏នៅមានចម្លើយមិនសូវជាច្បាស់លាស់បែបទ្រង់ទ្រាយតូចលើសំណួរនេះដែលកើតចេញពីចម្លើយទ្រង់ទ្រាយធំ។ ចម្លើយបែបទ្រង់ទ្រាយធំគឺថា៖ ព្រះជាម្ចាស់ធ្វើបែបនេះ ពីព្រោះព្រះអង្គសព្វព្រះហឫទ័យឲ្យដំណើរនៃការញែកជាបរិសុទ្ធអាចថ្វាយការសរសើរតម្កើងយ៉ាងខ្លាំងនៅលើសិរីល្អរបស់ទ្រង់ ជាពិសេសការសរសើរសិរីល្អនៃព្រះគុណរបស់ព្រះអង្គ។

ខ្ញុំលើកឡើងបែបនេះ  ពីព្រោះមានខគម្ពីរជាច្រើនបានលើកឡើងអំពីលទ្ធផលនៃព្រះហឫទ័យទាក់ទងទៅនឹងការញែកជាបរិសុទ្ធ ឧទាហរណ៍៖ ក្នុងកណ្ឌគម្ពីរ ភីលីព ១:១១។ លទ្ធផលគឺត្រង់ថាឲ្យយើង «ព្រមទាំងមានពេញជាផលនៃសេចក្តីសុចរិតដែលមកដោយសារព្រះយេស៊ូវគ្រីស្ទ សម្រាប់ជាសិរីល្អ ហើយជាសេចក្តីសរសើរដល់ព្រះផង»។ ព្រះអង្គនឹងនាំមកនូវផលនៃសេចក្តីសុចរិតយ៉ាងពេញលេញ ពីព្រោះព្រះអង្គសព្វព្រះហឫទ័យចង់ទទួលបានការលើកតម្កើង។ នេះហើយគឺជាការរចនាក្នុងមូលហេតុដែលទ្រង់ធ្វើក្នុងរបៀបដែលទ្រង់ធ្វើនោះ។

កណ្ឌគម្ពីរ ២ថែស្សាឡូនីច ១:១១-១២ ក៏បានលើកឡើងអំពីផលនៃការញែកជាបរិសុទ្ធរបស់យើងថាគឺ៖ «ដើម្បីឲ្យព្រះនាមនៃព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង បានតម្កើងឡើងក្នុងអ្នករាល់គ្នា ហើយអ្នករាល់គ្នាក្នុងទ្រង់ផង តាមព្រះគុណរបស់ព្រះនៃយើង និងព្រះអម្ចាស់យេស៊ូវគ្រីស្ទ»។

ដូច្នេះ មិនថាយើងអាចឃើញចម្លើយក្នុងកម្រិតបែបទ្រង់ទ្រាយតូចអំពី



50 QnA John Piper Final 1.5.indd 285 25/01/2024 09:23:27 AM

មូលហេតុទាក់ទងទៅនឹងចំណុចនេះ ឬក៏ថាវាច្បាស់លាស់យ៉ាងខ្លាំងក្នុងចម្លើយកម្រិតបែបទ្រង់ទ្រាយធំដែលថា ព្រះជាម្ចាស់បានជ្រើសរើសរាប់យើងជាបរិសុទ្ធតាមរយៈរបៀបដ៏ឈឺចាប់ យឺតយ៉ាវ ដែលមានការបន្តទៅមុខ ទាក់ទិនក្នុងរបៀបនៃការធ្វើសង្គ្រោម ពីព្រោះវាថ្វាយសិរីល្អទៅកាន់ព្រះគ្រីស្ទ និងព្រះគុណរបស់ព្រះជាម្ចាស់ខ្លាំងជាងការដែលព្រះអង្គខ្វាស់ព្រះហស្តរបស់ទ្រង់ ហើយធ្វើឲ្យយើងល្អឥតខ្ចោះ និងលែងមានអំពើបាបពេលកើតជាថ្មី។ ឥឡូវ តើមានមូលហេតុបន្ទាប់បន្សំបែបទ្រង់ទ្រាយតូចដែលយើងអាចឃើញដែលទំនងនឹងការពន្យល់អំពីមូលហេតុទាក់ទងទៅនឹងករណីនេះដែរឬទេ? ខ្ញុំនឹងលើកឡើង៣ចំណុចៈ

## ១. មិនអាចជួយបាន

តាមរយៈការយឺតយ៉ាវ ការឈឺចាប់ និងការទាក់ទិនក្នុងដំណើរនៃការធ្វើសង្គ្រាមទាំងនេះ យើងទទួលបានការរម្លឹកថា៖ ជារៀងរាល់ថ្ងៃ ប្រសិនបើព្រះអង្គទុកខ្ញុំចោលនៅតែឯង នោះខ្ញុំគ្មានសង្ឃឹមយ៉ាងពេញទី ពេញទៅដោយអំពើបាប ហើយក៏មិនអាចជួយខ្លួនឯងបានដែរ។

## ២. ការអត់ធ្មត់របស់ព្រះជាម្ចាស់

ចេញពីការរម្លឹកនេះ ព្រះជាម្ចាស់បានធ្វើឲ្យយើងស្គាល់អំពីការអត់ធ្មត់របស់ទ្រង់ និងព្រះគុណរបស់ទ្រង់ក្នុងការកាន់យើង និងការត្រឡប់មកយើងវិញម្តងហើយម្តងទៀត ហើយក៏ប្រឆាំងសម្រាប់យើង និងនាំយើងទៅកាន់សិរីល្អដោយមានសុវត្ថិភាពដែរ។

វាមិនមែនជាការភ្ញាក់ផ្អើលទេដែលកណ្ឌគម្ពីរ យូដាស បានបញ្ចប់យ៉ាងរន្ធត់ ដោយលើកឡើងអំពីការសរសើរព្រះជាម្ចាស់ទាក់ទងនឹងការស៊ូទ្រាំរបស់ទ្រង់ និងការប្រទានអំណាចក្នុងជីវិតគ្រីស្ទបរិស័ទពេលធ្វើសង្គ្រាម៖ “រីឯព្រះអង្គដែលអាចរក្សាអ្នករាល់គ្នាមិនឲ្យជំពប់ដួល ហើយដាក់អ្នករាល់គ្នា



50 QnA John Piper Final 1.5.indd 286 25/01/2024 09:23:27 AM

នៅចំពោះសិរីល្អរបស់ព្រះអង្គ ដោយឥតបន្ទោសបាន ទាំងមានអំណរ គឺព្រះតែមួយព្រះអង្គ ជាព្រះសង្គ្រោះនៃយើង ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង សូមថ្វាយសិរីល្អ ឫទ្ធានុភាព ព្រះចេស្តា និងអំណាច តាំងពីមុនសម័យកាលទាំងអស់ នៅពេលនេះ និងអស់កល្បជានិច្ចតរៀងទៅ។ អាម៉ែន។» (យូដាស ១:២៤-២៥)។

តើនេះមិនមែនជាការដ៏អស្ចារ្យមែនឬ? តើគាត់កំពុងតែថ្វាយសិរីល្អទៅកាន់ព្រះជាម្ចាស់សម្រាប់អ្វី? គាត់កំពុងតែថ្វាយសិរីល្អ ឫទ្ធានុភាព ព្រះចេស្តា និងអំណាចទៅកាន់ព្រះជាម្ចាស់ទាក់ទងទៅនឹងមូលហេតុដ៏សាមញ្ញមួយ៖ ព្រះជាម្ចាស់បន្តព័ន្ធកិច្ចជាមួយនឹងយើងយ៉ាងអត់ធ្មត់រហូតដល់ទីបញ្ចប់។ ចំណុចនេះពិតជាគួរឲ្យភ្ញាក់ផ្អើលមែន ហើយខ្ញុំគិតថា ខ្ញុំមិនអាចយល់ដល់កម្រិត នោះដែលខ្ញុំអាចយល់បានដោយគ្មានព្រះជាម្ចាស់ ដែលកំពុងធ្វើការទាំងនោះក្នុងរបៀបដែលទ្រង់កំពុងតែធ្វើដែរនោះទេ។

## ៣. ការក្រេបជញ្ជក់ភាពស្រស់ស្អាត

ចំណុចចុងក្រោយដែលខ្ញុំនឹងលើកឡើងគឺថា ដោយសារភាពបរិសុទ្ធដ៏ពិតគឺជាការកើតឡើងចេញពីការមើលឃើញភាពស្រស់ស្អាតដ៏ឧត្តុង្គឧត្តមខ្ពស់ជាងគេបំផុត និងតម្លៃរបស់ព្រះគ្រីស្ទ នោះសណ្ឋាននៃការច្បាំងជាប្រចាំថ្ងៃបន្តនាំ ហើយមានធាតុពិតនេះនៅពីមុខខ្ញុំ ដើម្បីឲ្យព្រះគ្រីស្ទ និងភាពស្រស់ស្អាតរបស់ទ្រង់ និងតម្លៃរបស់ទ្រង់បន្តនៅជាចំណុចស្នូលក្នុងជីវិតរបស់ខ្ញុំ។

យើងនឹងឃើញកាន់តែច្បាស់ឡើងៗថា សាតាំងចាញ់មិនមែនតាមរយៈការដែលព្រះជាម្ចាស់ខ្វាស់ព្រះហស្តរបស់ទ្រង់ ឬអំណាចឆៅរបស់ទ្រង់ប៉ុណ្ណោះនោះទេ ប៉ុន្តែតាមរយៈភាពស្រស់ស្អាតដ៏ឧត្តុង្គឧត្តមរបស់ព្រះយេស៊ូវគ្រីស្ទ ដែលខ្ញុំត្រូវមើលឲ្យច្បាស់ជាប្រចាំថ្ងៃចេញពីព្រះបន្ទូល ដើម្បីនាំឲ្យខ្ញុំមានចំណាប់អារម្មណ៍ទៅកាន់ព្រះយេស៊ូវ ជាជាងទៅកាន់អ្វីដែល



50 QnA John Piper Final 1.5.indd 287 25/01/2024 09:23:27 AM

មិនបរិសុទ្ធ។

ខ្ញុំគិតថា ចំណុចស្នូលដែលខ្ញុំនឹងលើកឡើងទាក់ទងនឹងសំណួរនេះគឺ៖ មិនថាព្រះជាម្ចាស់មានមូលហេតុអ្វីក៏ដោយទាក់ទងនឹងការដែលព្រះអង្គញែកយើងជាបរិសុទ្ធក្នុងរបៀបដ៏យឺតយ៉ាវ ឈឺចាប់ ពេញទៅដោយការធ្វើសង្គ្រាមក៏ដោយ ក៏ការជ្រើសរើសរបស់ព្រះអង្គនេះគឺ ពីព្រោះទ្រង់ទទួលបានសិរីល្អខ្លាំងជាង ពេលដែលយើងច្បាំងក្នុងសង្គ្រាមជាប្រចាំថ្ងៃជាមួយនឹងអាវុធដែលព្រះអង្គបានប្រទានដល់យើង និងក្នុងរបៀបដែលព្រះអង្គបានគ្រោងទុកសម្រាប់យើង។ ដូច្នេះ ចូរយើងចាប់ផ្ដើមតយុទ្ធឲ្យបានយ៉ាងល្អចុះ!

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**



50 QnA John Piper Final 1.5.indd 288 25/01/2024 09:23:28 AM

## សំណួរទី៤៩៖
# ការបង្រៀនកូនពេលមានវិបត្តិក្នុងគ្រួសារ «កំហុសរបស់យើង»

*តើយើងអាចបង្រៀនកូនៗយើងនៅពេលកំពុងមានវិបត្តិក្នុងគ្រួសារបាន ដោយរបៀបណា?*

«កុំឲ្យទុកចិត្តអ្នកជិតខាង ក៏កុំឲ្យជឿមិត្រសម្លាញ់ផង សូម្បីតែនាងដែលឯងឱបនៅនាទ្រូង ក៏ចូររក្សាបបូរមាត់ចំពោះនាងដែរ ដ្បិតកូនប្រុសបង្អាប់ឪពុក ហើយកូនស្រីក៏ចចើងទាស់នឹងម្ដាយ ឯកូនប្រសាស្រីទាស់ទទឹងនឹងម្ដាយក្មេក ហើយខ្មាំងសត្រូវរបស់អ្នកណា នោះគឺជាពួកអ្នកនៅផ្ទះរបស់អ្នកនោះឯង» (មីកា ៧:៥-៦)។

ដោយសញ្ជឹងគិតអំពីការឈឺចាប់នៃភាពច្របូកច្របល់ដូចនេះនៅក្នុងសង្គម និងក្នុងគ្រួសារ ហោរា មីកា បានធ្វើជាគំរូសម្រាប់យើងក្នុងពីររបៀប យោងតាមខ៩។ គាត់បានប៉ាន់ស្មានយ៉ាងត្រឹមត្រូវអំពីខ្លួនឯង ហើយក៏បានឱបយកសេចក្ដីសង្ឃឹមនៅក្នុងព្រះជាម្ចាស់។ «ខ្ញុំនឹងរងទ្រាំចំពោះសេចក្ដីគ្នាន់ក្នាញ់របស់ព្រះយេហូវ៉ា ពីព្រោះខ្ញុំបានធ្វើបាបនឹងទ្រង់ហើយ គឺនឹងរងទ្រាំដរាបដល់ទ្រង់កាន់ក្ដីជំនួសខ្ញុំ ហើយបានសម្រេចសេចក្ដីយុត្តិធម៌ដល់ខ្ញុំ នោះទ្រង់នឹងនាំខ្ញុំចេញមកឯពន្លឺ រួចខ្ញុំនឹងរំពឹងមើលសេចក្ដីសុចរិតរបស់ទ្រង់» (មីកា ៧:៩)។

ខាងក្រោមនេះគឺជាសេចក្ដីអធិប្បាយរបស់លោកគ្រូ ចន ផាបភ័រ ពីឆ្នាំ២០១០ ដែលគាត់បានពន្យល់អំពីចំណុចអនុវត្តចេញពីខនេះ សម្រាប់គ្រួសារដែលមានការបាក់បែកនូវសព្វថ្ងៃនេះ។

អ្វីដែលធ្វើឲ្យដើមខ៩មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងគឺ ពីព្រោះគាត់បាន



50 QnA John Piper Final 1.5.indd 289 25/01/2024 09:23:28 AM

លើកសម្តីនេះឡើងក្នុងពេលដែលគេបានប្រព្រឹត្តអំពើបាបទាស់នឹងគាត់។ លោកអ្នកដឹងហើយថា នេះគឺជាអ្វីដែលពិបាកខ្លាំងជាងគេមួយនៅក្នុងលោកនេះ នៅពេលដែលមិត្តភក្តិ គ្រួសារ អ្នករួមការងាររបស់យើងប្រព្រឹត្តអំពើបាបទាស់នឹងយើង។ ប្រសិនបើគ្មានព្រះវិញ្ញាណបរិសុទ្ធ នោះយើងមិនអាចដោះស្រាយបញ្ហានេះបានទេ។

## កំហុសរបស់យើង

ហោរា មីកា ដឹងហើយថាមានគេប្រព្រឹត្តអំពើបាបទាស់ប្រឆាំងនឹងគាត់។ គាត់ដឹងថា ការចោទប្រកាន់មួយចំនួនទាស់នឹងគាត់គឺមិនមែនជាការចោទត្រឹមត្រូវ។ គាត់ដឹងថា ព្រះជាម្ចាស់នឹងរាប់គាត់ថាត្រឹមត្រូវនៅក្នុងរឿងមួយចំនួន ហើយគាត់ក៏ដឹងផងដែរថា ព្រះជាម្ចាស់នៅខាងគាត់ មិនមែនទាស់នឹងគាត់ទេ។ ព្រះជាម្ចាស់នឹងនាំគាត់ចូលពន្លឺ ចេញពីភាពងងឹត។ ព្រះជាម្ចាស់នឹងរាប់ថាគាត់គ្មានទោស។ ដូច្នេះ ហោរា មីកា មានភាពក្លាហានក្នុងទំនុកចិត្តរបស់គាត់ ក្នុងអំណះអំណាងរបស់គាត់—គឺពិតជាក្លាហានមែន។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្វីដែលគាត់ផ្តោតចំណាប់អារម្មណ៍លើក្នុងការពន្យល់អំពីសេចក្តីក្រោធរបស់ព្រះអម្ចាស់ គឺលើអំពើបាបរបស់គាត់ផ្ទាល់៖ «ខ្ញុំនឹងរងទ្រាំចំពោះសេចក្តីគ្នាន់ក្នាញ់របស់ព្រះយេហូវ៉ា ពីព្រោះខ្ញុំបានធ្វើបាបនឹងទ្រង់ហើយ»។

ខ្ញុំចង់លើកទឹកចិត្តឲ្យឪពុកម្តាយមានអាកប្បកិរិយាដែលមានសេចក្តីសង្ឃឹម ខណៈពេលដែលកំពុងតែមានវិបត្តិ ហើយអាកប្បកិរិយានោះគឺមានភាពក្លាហាន ដោយមានការខូចចិត្ត។ សំណួរសួរថា៖ ហេតុអ្វីបានជាហោរា មីកា មានការខូចចិត្ត? ហើយចំណុចស្នូលនៃចម្លើយរបស់គាត់គឺមិនទាក់ទងទៅនឹងអំពើបាបដែលគេបានប្រព្រឹត្តទាស់ប្រឆាំងនឹងគាត់ទេ ប៉ុន្តែគឺអំពើបាបរបស់គាត់ផ្ទាល់បានប្រឆាំងនឹងព្រះជាម្ចាស់វិញ។ នោះគឺជា



50 QnA John Piper Final 1.5.indd 290 25/01/2024 09:23:28 AM

ចំណុចស្នូលនៃចម្លើយរបស់គាត់។ ហើយនេះហើយគឺជាចំណុចស្នូលនៃការចិញ្ចឹមបីបាច់ថែរក្សាកូន។ ប្រសិនបើមិនមានចំណុចនេះទេ នោះនឹងមិនអាចមានចំណុចផ្សេងទៀតឡើយ—គឺគ្មានទេ។ ឱប្ដី និងប្រពន្ធអើយ! នេះគឺជាចំណុចចាប់ផ្ដើម ឬក៏ថាជាចំណុចផ្ដើមជាថ្មី។ អាកប្បកិរិយានៃការចិញ្ចឹមបីបាច់កូន ដោយមានសេចក្ដីសង្ឃឹម ខណៈពេលដែលកំពុងតែមានវិបត្តិ គឺអាកប្បកិរិយានៃការមានភាពក្លាហានដោយខូចចិត្ត។ ហើយការមានការខូចចិត្តជាចម្បង និងជាចំណុចស្នូល គឺដោយសារអំពើបាបរបស់យើងផ្ទាល់។

នេះគឺជាចម្បាំងដ៏ធំដែលយើងកំពុងតែប្រឈមមុខជាមួយ ហើយយើងអាចមានជោគជ័យបានគឺតាមរយៈតែព្រះគុណរបស់ព្រះជាម្ចាស់។ ខ្ញុំកំពុងតែអធិស្ឋានសម្រាប់លោកអ្នក។ សូមព្រះជាម្ចាស់ប្រទានមកកាន់យើងនូវការអស្ចារ្យ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នូវការបន្ទាបខ្លួន ខណៈពេលដែលកំពុងតែមានគេប្រព្រឹត្តអំពើបាបទាស់នឹងយើង គឺឲ្យយើងគិតអំពីអំពើបាបរបស់យើងដែលទាស់នឹងព្រះជាម្ចាស់វិញ។ នេះគឺជាការអស្ចារ្យដែលព្យាបាល គឺជាអ្វីដែលអាចប្រទានសេចក្ដីសង្ឃឹម ខណៈពេលដែលយើងគិតថាមិនមានសង្ឃឹមទាល់តែសោះ។

នៅពេលដែលយើងឈរនៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់នៅថ្ងៃជំនុំជម្រះ ដើម្បីលើកហេតុផលទៅកាន់ព្រះអង្គ គឺព្រះអង្គនឹងមិនអនុញ្ញាតឲ្យយើងលើកឡើងអំពីអំពើបាបដែលគេបានប្រព្រឹត្តទាស់នឹងយើងនោះទេ ដោយទ្រង់មានមូលហេតុមួយចំនួន៖

- ព្រះអង្គមានសៀវភៅកំណត់ត្រាអំពីអំពើបាបរបស់យើងហើយ ទ្រង់មិនត្រូវការឲ្យយើងជួយទេ។
- ព្រះអ្វីដែលយើងនឹងលើកឡើងគឺមិនត្រឹមត្រូវទេ ពីព្រោះការចងចាំរបស់យើងមិនល្អគ្រប់គ្រាន់។
- យើងនឹងប្រើឱកាសនោះ ដើម្បីប្រកែកថាខ្លួនឯងត្រូវ។



50 QnA John Piper Final 1.5.indd 291 25/01/2024 09:23:28 AM

យើងនឹងមិនទទួលបានពេល ដើម្បីរៀបរាប់អំពីអំពើបាបរបស់អ្នកដទៃទេ។ គឺមានតែពេល ដើម្បីរៀបរាប់អំពីអំពើបាបរបស់ខ្លួនប៉ុណ្ណោះ។ ការទទួលស្គាល់កំហុសរបស់យើងគឺជារបៀបមួយដែលយើងអាចប្រើប្រាស់ ដើម្បីបង្រៀនកូនៗយើង ខណៈពេលដែលយើងកំពុងតែប្រឈមមុខនឹងវិបត្តិក្នុងគ្រួសារ។

ប្រសិនបើយើងចង់ធ្វើជាឪពុកម្ដាយល្អ ពេលដែលគ្រួសារមានបញ្ហា ជាដំបូងយើងត្រូវតែទទួលស្គាល់ថា អំពើបាបរបស់យើងគឺជាបញ្ហាដ៏អាក្រក់បំផុត។ ហើយជាបន្ទាប់យើងត្រូវតែទទួលស្គាល់ថា ព្រះលោហិតរបស់ព្រះយេស៊ូវគ្របបាំងលើវាទាំងអស់។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ**



50 QnA John Piper Final 1.5.indd 292 25/01/2024 09:23:29 AM

# សំណួរទី៥០៖
# សេចក្តីប្រាថ្នាដំបូងគេបង្អស់ក្នុងការប្រព្រឹត្តអំពើបាបរបស់សាតាំងមកពីណា?

*ឆន្ទៈជ្រើសរើសសេរីគឺជាការធ្វើនូវអ្វីដែលយើងប្រាថ្នាចង់ធ្វើ ប៉ុន្តែព្រះជាម្ចាស់គឺជាអង្គដែលប្រទានសេចក្តីប្រាថ្នាឲ្យធ្វើការល្អនោះ។ ដោយយោងលើកណ្ឌគម្ពីរ យ៉ាកុប ១:១៣ ខ្ញុំនៅមានការពិបាកយល់អំពីរបៀបដែលសាតាំងទទួលបានសេចក្តីប្រាថ្នាដំបូងរបស់វាក្នុងការប្រព្រឹត្តអំពើបាបមកពីណាណាស់។*

*ផ្ទុត់គំនិតនៃសេចក្តីសន្និដ្ឋានដែលមិនអាចយល់បានដ៏ពិបាកគឺថា ទាំងសាតាំង និងលោក អ័ដាម បានប្រព្រឹត្តអំពើបាប ពីព្រោះព្រះជាម្ចាស់បានប្រទានការប្រាថ្នាដល់ពួកគេ ដើម្បីប្រព្រឹត្តបាប (ដកស្រង់ចេញពីសៀវភៅ "Chosen But Free" ក្នុងទំព័រ៣៦ និពន្ធដោយ៖ លោកគ្រូ Norman Geisler)។ ខ្ញុំគិតថាលោក អ័ដាម ទទួលសេចក្តីប្រាថ្នាក្នុងការប្រព្រឹត្តអំពើបាបពីនាង អេវ៉ា ដែលទទួលសេចក្តីប្រាថ្នានោះពីសាតាំង ប៉ុន្តែព្រះជាម្ចាស់មានអធិបតេយ្យភាពលើរាល់គ្រប់អ្វីៗទាំងអស់—ដែលមានរួមទាំងសេចក្តីប្រាថ្នារបស់យើង—តើការនេះធ្វើឲ្យទ្រង់ក្លាយជាអ្នកនិពន្ធដំបូងនៃការមានសេចក្តីប្រាថ្នាមុនគេបង្អស់ក្នុងការប្រព្រឹត្តអំពើបាបមែនឬ?*

## ការធ្លាក់ក្នុងអំពើបាបដំបូង

តាមដែលខ្ញុំអាចចងចាំបាន ជាច្រើនឆ្នាំមកហើយខ្ញុំធ្លាប់លើកឡើងម្តងហើយម្តងទៀតថា នេះគឺជារឿងអាថ៌កំបាំងដ៏ខ្លាំងបំផុតក្នុងទេវវិទ្យារបស់ខ្ញុំដែលខ្ញុំមិនដែលមានចម្លើយសមល្មមបាន។ សំណួរដ៏ជាក់លាក់ត្រង់នេះគឺថា តើអំពើបាបដំបូងកើតឡើងដោយរបៀបណា—ពាក្យ "ដោយរបៀប

*ណា*» គឺជាពាក្យគន្លឹះ។ លើឃ្លា «អំពើបាបដំបូង» ខ្ញុំមិនសំដៅលើអំពើបាបដំបូងរបស់លោក អ័ដាម ទេ។ ប៉ុន្តែ ខ្ញុំសំដៅលើអំពើបាបដំបូងរបស់សាតាំងដែលនោះគឺជាអំពើបាបដំបូងបង្អស់នៅក្នុងចក្រវាលនេះ។

ការបើកឆាកក្នុងព្រះគម្ពីរមិនបានបើកឡើងដោយពន្យល់អំពីអំពើអាក្រក់ដំបូងនោះទេ ប៉ុន្តែអំពីវត្តមាននៃអំពើអាក្រក់ដែលមិនមានការពន្យល់។ ព្រះជាម្ចាស់បានបង្កើតមនុស្សយើងដោយគ្មានកំហុសខុសឆ្គងទេ ហើយសត្វពស់មានវត្តមាននៅទីនោះរួចស្រេចទៅហើយ។ សត្វពស់នោះមានចិត្តពេញដោយល្បិចកល ហើយក៏បានបង្ហាញអំពីការទាស់ប្រឆាំងនឹងព្រះជាម្ចាស់ទាក់ទងទៅនឹងរបស់សព្វសារពើដែលទ្រង់បានបង្កើតមកដែរ។ នេះឯងគឺជាចំណុចដែលព្រះគម្ពីរបានចាប់ផ្ដើម។

តាមដែលខ្ញុំអាចយល់ឃើញបាន មើលទៅ ព្រះគម្ពីរមិនបានប្រទានការពន្យល់អំពីរបៀបដែលសាតាំងក្លាយជាតួអាក្រក់នោះទេ។ ប៉ុន្តែ ខ្ញុំដឹងថាតាមតម្រុយ សាតាំងគឺជាទេវតាដ៏ល្អម្នាក់ដែលព្រះជាម្ចាស់បានបង្កើតមក។ លោក យូដាស បានលើកឡើងអំពីពួកទេវតាដែលមិនបាននៅក្នុងឋានៈនៃអំណាចរបស់ខ្លួន ប៉ុន្តែបានចាកចេញពីទីកន្លែងដែលពួកគេកំពុងនៅ។ គាត់បានលើកឡើងថា ព្រះជាម្ចាស់បានឃុំទេវតាទាំងនោះក្នុងច្រវាក់ដ៏នៅអស់កល្បជានិច្ចក្រោមភាពងងឹតដ៏ស្រងេះស្រងោចរហូតដល់គ្រានៃថ្ងៃថ្កោលទោសយ៉ាងខ្លាំង (យូដាស ១:៦)។

ខ្ញុំមិនមានមន្ទិលសង្ស័យថា ពេលដែលព្រះជាម្ចាស់បង្កើតសាតាំងមក វាល្អ ហើយបន្ទាប់មកវាក៏បានធ្លាក់ពីកន្លែងដ៏ត្រឹមត្រូវរបស់វា ដូចដែលលោក យូដាស បានលើកឡើងនោះទេ ពីព្រោះខ្ញុំមិនគិតថាអំពើអាក្រក់ និងព្រះជាម្ចាស់មានក្នុងពេលតែមួយតាំងពីអស់កល្បជានិច្ចឡើយ។ ខ្ញុំមិនជឿថាមានកម្លាំងពីរប្រឆាំងគ្នានោះទេ៖ មានតែព្រះជាម្ចាស់ សេចក្ដីសប្បុរសរបស់ទ្រង់ និងព្រះប្រាជ្ញាញាណ និងអំណាចព្រះចេស្ដារបស់ទ្រង់ប៉ុណ្ណោះដែល



50 QnA John Piper Final 1.5.indd 294 25/01/2024 09:23:29 AM

មានតាំងពីអស់កល្បជានិច្ចមក។ ប៉ុន្តែ ក្នុងរបៀបណាមួយ អំពើអាក្រក់ក៏បានកម្លាយចេញមក។ តែវាជាចំណុចទី២ ដោយសារព្រះជាម្ចាស់មិនមែនជាអង្គប្រព្រឹត្តអំពើបាប។ ទាក់ទងនឹងចំណុចនេះ ស្ទើរតែគ្រីស្ទបរិស័ទគ្រប់ៗរូបឯកភាពគ្នា។

## ចម្លើយខ្លី ហើយឥតប្រយោជន៍

តើសាតាំងបានក្លាយជាតួអង្គអាក្រក់ដោយរបៀបណា? ខ្ញុំមិនដឹងទេ។ ហើយវាក៏ច្បាស់លាស់ចំពោះខ្ញុំដែរថា ចំពោះអ្នកដែលជឿជាក់លើរបស់សព្វសារពើរបស់ព្រះជាម្ចាស់ដែលកើតឡើងដោយសិទ្ធិសម្រេចផ្ទាល់ខ្លួន (ដូចជាទេវតា និងមនុស្ស) ក៏មិនដឹងចម្លើយដែរ។ ការលើកឡើងថាសាតាំងមានឆន្ទៈសេរី—ដែលកើតឡើងដោយសិទ្ធិសម្រេចផ្ទាល់ខ្លួន—គឺមិនមែនជាការពន្យល់អំពីមូលហេតុដែលវាបានប្រព្រឹត្តអំពើបាបដំបូងរបស់វាទេ។ វាគ្រាន់តែជាផ្លាកឈ្មោះមួយប៉ុណ្ណោះ។ នេះមិនមែនជាការពន្យល់ទេ។

វាគ្រាន់តែជាការដាក់ផ្លាកឈ្មោះលើរឿងអាថ៌កំបាំងប៉ុណ្ណោះ។ តើឲ្យជីវិតដ៏ល្អឥតខ្ចោះ—ដោយមានឆន្ទៈដ៏ល្អឥតខ្ចោះ និងដួងចិត្តដ៏ល្អឥតខ្ចោះ—អាចមានបទពិសោធន៍នៃសន្ទុះមិនល្អឥតខ្ចោះបណ្ដាលឲ្យឆន្ទៈបង្វែរទៅទិសដៅនៃអំពើបាបដោយរបៀបណាបាន? ចម្លើយគឺ៖ គ្មានអ្នកណាដឹងទេ ដែលមានរួមអស់ទាំងអ្នកដែលលើកឡើងថា «អូ! វាជាឆន្ទៈសេរី!»។ នេះមិនមែនជាការពន្យល់ទេ។ វាគ្រាន់តែជាឈ្មោះមួយសម្រាប់រឿងអាថ៌កំបាំងប៉ុណ្ណោះ។

យើងមិនដឹងទេ។ ព្រះគម្ពីរក៏មិនបានពន្យល់អំពីរបៀបនោះដែរ។ ខ្ញុំគិតថា ខ្ញុំមិនឯកភាពនឹងសម្រង់សម្ដីរបស់លោកគ្រូ Norman Geisler «ផ្ទុត់គំនិតនៃសេចក្ដីសន្និដ្ឋានដែលមិនអាចយល់បានដ៏ពិបាកគឺថា ទាំងសាតាំង និងលោក អ័ដាម បានប្រព្រឹត្តអំពើបាប ពីព្រោះព្រះជាម្ចាស់បានប្រទានការប្រាថ្នាដល់ពួកគេ ដើម្បីប្រព្រឹត្តបាប» ទេ។ ខ្ញុំមិនជឿថា ព្រះជាម្ចាស់បាន



50 QnA John Piper Final 1.5.indd 295 25/01/2024 09:23:29 AM

ប្រទាននូវសេចក្ដីប្រាថ្នាចម្បងក្នុងការប្រព្រឹត្តអំពើបាបដល់សាតាំងនោះទេ។ នេះគឺជាការពន្យល់បែបសង្ខេបដ៏សាមញ្ញបំផុតនូវទស្សនៈរបស់មនុស្សស្ទើរតែទាំងអស់គ្នា។ ខ្ញុំមិនដឹងថា តើសាតាំងចាប់ផ្ដើមមានអារម្មណ៍ក្នុងការមានទំនោរចិត្តដំបូង ដើម្បីបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់ដោយរបៀបណាទេ។

## ជំហរដែលពេញទៅដោយអធិបតេយ្យភាព

នេះគឺជាចំណុចដែលខ្ញុំដឹង៖ ព្រះជាម្ចាស់មានពេញទៅដោយអធិបតេយ្យភាព។ គ្មានអ្វីកើតឡើងលើកលែងតែចេញពីផែនការរបស់ទ្រង់ ដែលមានរួមទាំងអ្វីៗដែលទ្រង់បណ្ដាលឲ្យកើតឡើងផ្ទាល់ មិនថាតិច ឬច្រើន—និងអ្វីៗដែលទ្រង់មិនបណ្ដាលឲ្យកើតឡើងផ្ទាល់ មិនថាតិច ឬច្រើនដែរ។ ខ្ញុំមិនមានមន្ទិលសង្ស័យទេត្រង់ថា ការធ្លាក់ចុះរបស់សាតាំង និងរាល់ចំណុចនៃផែនការប្រោសលោះរបស់ព្រះជាម្ចាស់សម្រាប់សិរីល្អនៃព្រះគុណរបស់ទ្រង់ក្រោយនោះបន្ទាប់ពីផែនការដ៏នៅអស់កល្បជានិច្ចរបស់ព្រះអង្គ។

ប៉ុន្តែ គឺនៅត្រង់ចំណុចនេះហើយដែល*របៀប*នៃបុព្វហេតុ របៀបនៃការដែលសាតាំងបានប្រព្រឹត្តអំពើបាបដំបូងបានកើតឡើង។ ខ្ញុំមានរបៀបនៃការគិតរបស់ខ្ញុំទាក់ទងនឹងចំណុចដែលព្រះជាម្ចាស់ទតឃើញវា ទាក់ទងនឹងអ្វីដែលកើតឡើងដែលទ្រង់ស្អប់។

ឧទាហរណ៍៖ នេះជាអ្វីដែលទ្រង់បានធ្វើពេលព្រះអង្គបានគ្រោងទុកការឆ្កាងរបស់ព្រះយេស៊ូវ យោងតាមកណ្ឌគម្ពីរ កិច្ចការ ៤:២៧-២៨។ ការសម្លាប់ព្រះយេស៊ូវគឺជាអំពើបាប ហើយវាក៏ត្រូវបានគ្រោងទុកយ៉ាងលម្អិតដោយព្រះជាម្ចាស់ដែរ។ លោកអ្នកអាចអានអំពីការនេះក្នុងកណ្ឌគម្ពីរទំនុកតម្កើង ហើយលោកអ្នកក៏អាចអានអំពីការនេះក្នុងព្រះគម្ពីរសញ្ញាថ្មីបានផងដែរ។



50 QnA John Piper Final 1.5.indd 296 25/01/2024 09:23:30 AM

ទាក់ទងនឹងរបៀប ខ្ញុំមិនដឹងទេ—*របៀប*ដ៏ជាក់លាក់ដែលព្រះជាម្ចាស់ធ្វើ ខណៈពេលដែលព្រះអង្គនៅមិនមានអំពើបាប ហើយអំពើបាបនៃរាល់អ្វីៗទាំងអស់នោះដែលបានកើតឡើង និងទំនួលខុសត្រូវខាងឯសីលធម៌របស់អ្នកដែលបានប្រព្រឹត្តអំពើបាបទាំងនោះ។ ប៉ុន្តែ ខ្ញុំគិតថា ព្រះគម្ពីរបង្រៀនឲ្យយើងជឿថា ព្រះអង្គមានអធិបតេយ្យភាពលើរាល់អំពើបាបទាំងអស់ ហើយថាព្រះអង្គក៏មិនដែលប្រព្រឹត្តអំពើបាបដែរ។ នេះគឺជាអ្វីដែលខ្ញុំជឿជាក់ថា ព្រះគម្ពីរបានបង្រៀនយើង។

## តម្រុយក្នុងព្រះគម្ពីរ

ទាក់ទងនឹងរបៀបដែលព្រះអង្គធ្វើការទាំងអស់នោះក៏យើងឃើញថា មានតម្រុយខ្លះៗក្នុងព្រះគម្ពីរដែរ។ ខ្ញុំចង់លើកឡើងនូវចំណុចមួយ។ ខ្ញុំមិនអះអាងថានេះគឺជាការពន្យល់ទេ ប៉ុន្តែគឺជាគំនិតដែលស័ក្តិសមក្នុងការគិតទាក់ទងនឹងការពន្យល់មួយបែប ដែលយើងអាចនឹងចាប់ផ្ដើមយល់នៅថ្ងៃណាមួយបាន។

ក្នុងកណ្ឌគម្ពីរ អេសាយ ៦៣:១៧ ហោរាបានស្រែកទៅកាន់ពួកមនុស្សម្នាថា៖ «ឱព្រះយេហូវ៉ាអើយ! ហេតុអ្វីបានជាព្រះអង្គធ្វើឲ្យយើងខ្ញុំវង្វេងចេញពីផ្លូវរបស់ព្រះអង្គ?» ទាន់ទេបងប្អូន «ឱព្រះយេហូវ៉ាអើយ! ហេតុអ្វីបានជាព្រះអង្គធ្វើឲ្យយើងខ្ញុំវង្វេងចេញពីផ្លូវរបស់ព្រះអង្គ»? «ឱព្រះយេហូវ៉ាអើយ! ហើយឲ្យយើងខ្ញុំមានចិត្តរឹងទទឹងចំពោះសេចក្ដីកោតខ្លាចដល់ព្រះអង្គដូច្នេះ? សូមព្រះអង្គវិលមកវិញដោយយល់ដល់ពួកអ្នកបម្រើរបស់ព្រះអង្គគឺជាកុលសម្ព័ន្ធទាំងប៉ុន្មាននៃមរតករបស់ព្រះអង្គ»។

ដូច្នេះ យើងឃើញថា គាត់បានលើកឡើងថា នៅចុងបញ្ចប់ព្រះជាម្ចាស់គឺជាអង្គដែលជាបុព្វហេតុនៃការវង្វេងរបស់យើង—ការវង្វេងរបស់សាសន៍អ៊ីស្រាអែលក្នុងអំពើបាប។ តើព្រះជាម្ចាស់បានធ្វើការនោះដោយរបៀបណា?



50 QnA John Piper Final 1.5.indd 297 25/01/2024 09:23:30 AM

ផ្នែកទី២នៃខគម្ពីរៈ «សូមព្រះអង្គវិលមកវិញដោយយល់ដល់ពួកអ្នកបម្រើរបស់ព្រះអង្គ» លើកជាសំណើរ ឬក៏ចង្អុលបង្ហាញថា របៀបណាមួយ ក្នុងអវត្តមានរបស់ព្រះជាម្ចាស់ ការនោះបានក៏កើតឡើង។

បន្ទាប់មក គាត់បានលើកឡើងក្នុងកណ្ឌគម្ពីរ អេសាយ ៦៤:៧ ដែលប្រមាណជា៩ខបន្ទាប់ថាៈ «គ្មានអ្នកណាអំពាវនាវដល់ព្រះនាមព្រះអង្គ ឬដាស់តឿនខ្លួនអ្នកឲ្យចាប់តោងព្រះអង្គឡើង ដ្បិតព្រះអង្គបានគេចព្រះភក្ត្រចេញពីយើងខ្ញុំ ហើយក៏បានធ្វើឲ្យយើងខ្ញុំរលាយទៅដោយសារអំពើទុច្ចរិតរបស់យើងខ្ញុំផង»។ ជាថ្មីម្តងទៀត គឺការលាក់ព្រះភ័ក្ត្ររបស់ទ្រង់នោះឯងដែលពន្យល់អំពីអំពើបាប។

**ពន្លឺ និងស្រមោល**

ខ្ញុំមិនមែនកំពុងលើកឡើងថា នេះគឺជាការពន្យល់អំពីអំពើបាបដែលមិនអាចមានការជំទាស់បានទេ ប៉ុន្តែក្នុងរបៀបណាមួយ ពេលដែលព្រះជាម្ចាស់បាំងសិរីល្អរបស់ទ្រង់ពីសាតាំង ហើយក្នុងការបាំងសិរីល្អរបស់ទ្រង់នោះ—ដែលការនេះខ្ញុំនៅមិនអាចយល់ទាំងស្រុងបាននៅឡើយ—នោះសាតាំងក៏មានចិត្តចង់ឡើងខ្ពស់ជាងព្រះជាម្ចាស់ដែលបានបាំងសិរីល្អរបស់ទ្រង់។

ខ្ញុំមិនដឹងថាការនេះកើតឡើងដោយរបៀបណានោះទេ ប៉ុន្តែនេះគឺជាការបង្ហាញមួយថាទំនងជាមានអ្វីមួយកើតឡើងបែបនេះ។ ខ្ញុំគ្រាន់តែលើកឡើងថា នេះទំនងជាចំណុចមួយដែលស័ក្តិសមឲ្យយើងយកមកគិតលើៈ អ្នកដែលថាព្រះជាម្ចាស់ទំនងជាអាចសោយរាជ្យលើវត្តមាន និងអវត្តមាននៃអំពើបាបបាន មិនថាដោយផ្ទាល់ តាមរយៈសកម្មភាពសកម្មនោះឡើយ ប៉ុន្តែស្របពេលនោះក៏តាមរយៈការលាក់រូបអង្គទ្រង់ផ្ទាល់នោះដែរ។

មានលោកគ្រូម្នាក់បានលើកឡើងថាៈ មានចំណុចខុសគ្នារវាងរបៀបដែលពន្លឺភ្លឺឡើងនៅរសៀលម៉ោង ៣:០០ តាមរយៈពន្លឺនៃព្រះអាទិត្យ និង



50 QnA John Piper Final 1.5.indd 298 25/01/2024 09:23:30 AM

របៀបដែលមានស្រមោលតាមរយៈការដែលដើមឈើបាំងពន្លឺនោះ—ទោះជាយ៉ាងណាក៏ដោយ គឺពន្លឺនៃព្រះអាទិត្យនោះហើយដែលមានទំនួលខុសត្រូវសម្រាប់ទាំងពន្លឺនៅពេលថ្ងៃ និងស្រមោលនៅក្រោមដើមឈើនោះ។

ប៉ុន្តែ ខ្ញុំចង់បញ្ចប់នៅកន្លែងដែលខ្ញុំបានចាប់ផ្ដើម៖ ទាក់ទងនឹងរបៀបដែលអំពើបាបដំបូងក្នុងចក្រវាលនេះបានកើតឡើងគឺថា ខ្ញុំមិនដឹងចម្លើយទេ។ វាគឺជារឿងអាថ៌កំបាំងចំពោះខ្ញុំ។ ខ្ញុំមិនដឹងអំពីរបៀបទេ។ អ្វីដែលព្រះគម្ពីរបានបង្រៀនខ្ញុំគឺថា ព្រះជាម្ចាស់មានពេញទៅដោយអធិបតេយ្យភាពលើរាល់គ្រប់អ្វីៗទាំងអស់ ដែលនេះមានរួមទាំងអំពើបាប ហើយថាព្រះអង្គផ្ទាល់មិនមានបាបនោះទេ។

**ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖**

# កំណត់យោង

## សំណួរទី១

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ដេត, លោកស្រី ពុល រដ្ឋា, កញ្ញា សួន សុជាតា, លោក ហុង សម្ភស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/a-theology-of-prayer-in-three-minutes
ដោយមានការអនុញ្ញាត។

## សំណួរទី២

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ភស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/do-all-religions-lead-to-god ដោយមានការអនុញ្ញាត។

## សំណួរទី៣

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ដេត, លោក ហុង សម្ភស និង លោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/do-we-have-free-will-to-choose-christ ដោយមានការអនុញ្ញាត។

## សំណួរទី៤

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ហុង សម្ភស, លោក សឹម រក្សា, និង លោក ឯក សត្យា
ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពីៈ
https://www.desiringgod.org/interviews/how-does-it-glorify-god-to-predestine-people-to-hell



50 QnA John Piper Final 1.5.indd 300 25/01/2024 09:23:31 AM

## សំណួរទី៥

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង ប៉ូវ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស និង លោក ស៊ឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-it-sin-to-dislike-divine-election
ដោយមានការអនុញ្ញាត។

## សំណួរទី៦

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង ប៉ូវ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ឯក សត្យា, លោក ស៊ឹម រក្សា, លោក Jeff Lai និងលោក ហុង សម្ភស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/should-i-pray-to-the-father-the-son-or-the-spirit
ដោយមានការអនុញ្ញាត។

## សំណួរទី៧

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង ប៉ូវ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស និង លោក ស៊ឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/what-are-your-thoughts-on-halloween ដោយមានការអនុញ្ញាត។

## សំណួរទី៨

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង ប៉ូវ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស, លោកស្រី ឡូញ ស្រីរ័ត្ន និងលោក ស៊ឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/what-makes-easter-so-special ដោយមានការអនុញ្ញាត។

## សំណួរទី៩

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្គស និង លោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី https://www.desiringgod.org/interviews/what-does-it-mean-practically-to-keep-the-sabbath-holy ដោយមានការអនុញ្ញាត។

## សំណួរទី១០

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្គស និង លោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី https://www.desiringgod.org/interviews/wimpy-theology-makes-wimpy-women ដោយមានការអនុញ្ញាត។

## សំណួរទី១១

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ដេត, លោកស្រី ពុល រដ្ឋា, កញ្ញា សួន សុជាតា, លោក ហុង សម្គស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី https://www.desiringgod.org/interviews/can-a-born-again-christian-lose-salvation ដោយមានការអនុញ្ញាត។

## សំណួរទី១២

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ដេត, លោក ហុង សម្គស និង លោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី https://www.desiringgod.org/interviews/did-the-death-of-jesus-accomplish-anything-for-the-non-elect#full-video ដោយមានការអនុញ្ញាត។



50 QnA John Piper Final 1.5.indd 302 25/01/2024 09:23:31 AM

## សំណួរទី១៣

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោក ទេព រ៉ូ និងលោក ឈាង ប៉ូវ៉ា
កែសម្រួលដោយៈ លោកស្រី ឡូញ ស្រីរដ្ឋ, លោក ខែម បូឡុង, លោក ឯក សត្យា, លោក ហុង សម្ផស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-know-im-saved **ដោយមានការអនុញ្ញាត។**

## សំណួរទី១៤

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង ប៉ូវ៉ា
កែសម្រួលដោយៈ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ឯក សត្យា, លោក សឹម រក្សា, លោក ហុង សម្ផស និងលោកស្រី ឡូញ ស្រីរ័ត្ន
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-know-if-the-holy-spirit-is-in-me **ដោយមានការអនុញ្ញាត។**

## សំណួរទី១៥

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង ប៉ូវ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស, លោកស្រី ឡូញ ស្រីរ័ត្ន និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/gods-fame-and-global-missions **ដោយមានការអនុញ្ញាត។**

## សំណួរទី១៦

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង ប៉ូវ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស, លោកស្រី កែវ សិរីវុឌ្ឍី និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/suicide-and-salvation **ដោយមានការអនុញ្ញាត។**



50 QnA John Piper Final 1.5.indd 303 25/01/2024 09:23:32 AM

## សំណួរទី១៧

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កស, លោក សឹម រក្សា និងលោកស្រី ឡូញ ស្រីរ័ត្ន
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/who-is-jesus-to-you ដោយមានការអនុញ្ញាត។

## សំណួរទី១៨

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កស, លោកស្រី ឡូញ ស្រីរ័ត្ន និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/why-adam-matters-for-global-missions ដោយមានការអនុញ្ញាត។

## សំណួរទី១៩

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កស, លោក ង៉ែត វិទូ និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/does-the-bible-say-true-christians-never-sin ដោយមានការអនុញ្ញាត។

## សំណួរទី២០

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោក ខែម បូឡុង
កែសម្រួលដោយៈ លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កស, លោក ឈាង បូរ៉ា និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-singleness-is-good ដោយមានការអនុញ្ញាត។

## សំណួរទី២១

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ដេត, លោក ឯក សត្យា, លោក សឹម រក្សា, លោក Jeff Lai និងលោក ហុង សម្គស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-can-i-desire-heaven-when-i-know-i-wont-be-married-to-my-husband-there ដោយមានការអនុញ្ញាត។

## សំណួរទី២២

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, កញ្ញា សួន សុជាតា, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្គស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-to-help-friends-escape-the-prosperity-gospel
ដោយមានការអនុញ្ញាត។

## សំណួរទី២៣

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ឯក សត្យា, លោក សឹម រក្សា, លោក Jeff Lai និងលោក ហុង សម្គស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-it-sinful-to-date-a-non-christian
ដោយមានការអនុញ្ញាត។

## សំណួរទី២៤

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ឯក សត្យា, លោក សឹម រក្សា, លោក Jeff Lai និងលោក ហុង សម្គស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/if-you-had-two-minutes-to-talk-with-the-pope-what-would-you-say-to-him ដោយមានការអនុញ្ញាត។



50 QnA John Piper Final 1.5.indd 305 25/01/2024 09:23:32 AM

## សំណួរទី២៥

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ឯក សត្យា, លោក ហុង សម្ភស, លោក ជួប ប៊ុនហាក់ និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-my-relationship-with-god-healthy
ដោយមានការអនុញ្ញាត។

## សំណួរទី២៦

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស, លោក សឹម រក្សា និងលោក ប៊ុន ដេត
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/my-girlfriend-is-pregnant-what-do-i-do-next ដោយមានការអនុញ្ញាត។

## សំណួរទី២៧

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស, លោក សឹម រក្សា និងលោកស្រី ថាវ ប៊ុនរី
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/will-marriage-cure-my-lust ដោយមានការអនុញ្ញាត។

## សំណួរទី២៨

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/would-you-attend-a-gay-wedding
ដោយមានការអនុញ្ញាត។

## សំណួរទី២៩

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ដេត, លោក ហុង សម្ផស និង លោក ស៊ឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/christians-and-marijuana ដោយមានការអនុញ្ញាត។

## សំណួរទី៣០

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស និង លោក ស៊ឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-to-fight-laziness ដោយមានការអនុញ្ញាត

## សំណួរទី៣១

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស និង លោក ស៊ឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-know-if-god-is-calling-me-to-be-a-pastor ដោយមានការអនុញ្ញាត។

## សំណួរទី៣២

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស, លោក ស្រី ឡុញ ស្រីរ័ត្ន និងលោក ស៊ឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-wait-for-god ដោយមានការអនុញ្ញាត។



50 QnA John Piper Final 1.5.indd 307 25/01/2024 09:23:33 AM

## សំណួរទី៣៣

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ខែម បូឡុង
កែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស, លោក សឹម រក្សា និងលោកស្រី ឡូញ ស្រីរដ្ឋ
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/i-will-not-leave-jesus-but-im-done-with-the-church
ដោយមានការអនុញ្ញាត។

## សំណួរទី៣៤

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស, លោកស្រី ឡូញ ស្រីរ័ត្ន និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/im-tired-and-busy-how-do-i-make-time-for-the-bible ដោយមានការអនុញ្ញាត។

## សំណួរទី៣៥

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ឯក សត្យា, លោក សឹម រក្សា, លោក Jeff Lai និងលោក ហុង សម្ផស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-it-wrong-for-men-to-listen-to-female-speakers
ដោយមានការអនុញ្ញាត។

## សំណួរទី៣៦

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-it-okay-to-drink-alcohol ដោយមានការអនុញ្ញាត។



50 QnA John Piper Final 1.5.indd 308 25/01/2024 09:23:33 AM

## សំណួរទី៣៧

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កុស, លោកស្រី កែវ សិរីវុឌ្ឍី និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/if-a-person-drinks-or-smokes-does-that-mean-theyre-not-a-christian ដោយមានការអនុញ្ញាត។

## សំណួរទី៣៨

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កុស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/is-tithing-commanded-for-christians
ដោយមានការអនុញ្ញាត។

## សំណួរទី៣៩

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កុស, លោកសឹម រក្សា និងកញ្ញា យ៉ុន សាឯម
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/may-i-split-my-giving-between-my-church-and-another-ministry ដោយមានការអនុញ្ញាត។

## សំណួរទី៤០

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយៈ លោកគ្រូ John Piper
បកប្រែដោយៈ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយៈ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្កុស, លោកសឹម រក្សា និងលោកស្រី កែវ សិរីវុឌ្ឍី
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/life-is-hard-god-is-good ដោយមានការអនុញ្ញាត។

## សំណួរទី៤១

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោក ខែម បូឡុង
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ឯក សត្យា, លោក សឹម រក្សា, លោក Jeff Lai, លោក ឈាង បូរ៉ា និងលោក ហុង សម្ផស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/three-steps-to-stop-wasting-your-life
ដោយមានការអនុញ្ញាត។

## សំណួរទី៤២

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ផស និង លោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/why-do-christians-worship-together-on-sundays
ដោយ មានការអនុញ្ញាត។

## សំណួរទី៤៣

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ឯក សត្យា និងលោក ហុង សម្ផស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/six-ways-parents-of-rebellious-children-fight-for-faith#modal-346-fbf1gtoy ដោយមានការអនុញ្ញាត។

## សំណួរទី៤៤

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ខែម បូឡុង
កែសម្រួលដោយ៖ លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក សួន ចាន់រួម, លោក ប៊ុន ដេត, លោក ឯក សត្យា, លោក ហុង សម្ផស និងលោក សឹម រក្សា
ដកស្រង់ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/you-dont-need-more-self-love ដោយមានការអនុញ្ញាត។



50 QnA John Piper Final 1.5.indd 310 25/01/2024 09:23:34 AM

## សំណួរទី៩៥

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ដេត, លោក សឹម រក្សា, លោក ហុង សម្កុស និងលោកស្រី ឡូញ ស្រីរ័ត្ន
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/has-my-sexual-sin-made-me-unsavable **ដោយមានការអនុញ្ញាត។**

## សំណួរទី៩៦

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា និងលោក ទេព រ៉ូ
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក សឹម រក្សា, លោក ហុង សម្កុស និងលោកស្រី ឡូញ ស្រីរ័ត្ន
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-fight-same-sex-desires
ដោយមានការអនុញ្ញាត។

## សំណួរទី៩៧

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោក ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង, កញ្ញា អឿង ដាលីន, លោកគ្រូ លូកា ស្មិត, អ្នកគ្រូ សេង សុខា, លោក សឹម រក្សា, និងលោក ហុង សម្កុស
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/how-do-i-take-my-thoughts-captive
ដោយមានការអនុញ្ញាត។

## សំណួរទី៩៨

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ ក្រុមការងារ ផ្លូវពិត និងលោកស្រី ពុល រដ្ឋា
ដកស្រង់ខ្លះៗ និងកែសម្រួលដោយមានការអនុញ្ញាតចេញពី៖
https://www.desiringgod.org/interviews/if-im-dead-to-sin-why-must-i-kill-it-every-day



50 QnA John Piper Final 1.5.indd 311 25/01/2024 09:23:34 AM

## សំណួរទី៤៩

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស និងលោក សឹម រក្សា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/parenting-through-a-family-crisis
ដោយមានការអនុញ្ញាត។

## សំណួរទី៥០

យើងបានទទួលការអនុញ្ញាតឲ្យកែសម្រួលលើឯកសារដើមរបស់អ្នកនិពន្ធ។
និពន្ធដោយ៖ លោកគ្រូ John Piper
បកប្រែដោយ៖ លោកគ្រូ ឈាង បូរ៉ា
កែសម្រួលដោយ៖ លោក ខែម បូឡុង, លោក ទេព រ៉ូ, លោក ឯក សត្យា, លោក ហុង សម្ភស, លោក សឹម រក្សា និងលោកស្រី ពុល រដ្ឋា
ដកស្រង់ខ្លះៗ និងកែសម្រួលចេញពី
https://www.desiringgod.org/interviews/where-did-satans-first-desire-for-evil-come-from
ដោយមានការអនុញ្ញាត។



50 QnA John Piper Final 1.5.indd 312 25/01/2024 09:23:34 AM

# មានធនធានជាច្រើនទៀតនៅ៖

ផ្លូវពិត
plovpit.com

**For ordering information please visit:**

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ

សូមចូលទៅកាន់គេហទំព័រ៖

**https://plovpitshop.com**

# ហើយទាញយកសៀវភៅ
# ជាច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com

50 QnA John Piper Final 1.5.indd 313 25/01/2024 09:23:34 AM